

# ប្រវត្តិនគរូបនីយកម្ម

## នៅកម្ពុជា

អ្នករៀបរៀង៖ បណ្ឌិត អ៊ុ វំឌី

Editions Angkor
គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ

www.elibraryofcambodia.org

ទទួលអំណោយពីលោក ខ្មៅ ឃុនសំរ៉ែង
កក្កដា 2015

# ប្រវត្តិនគរូបនីយកម្ម

## នៅកម្ពុជា

អ្នករៀបរៀង៖ បណ្ឌិត អ៊ូ វ៉ឌី

រក្សាសិទ្ធិគ្រប់យ៉ាង

គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ

២០១២

www.elibraryofcambodia.org

រក្សាសិទ្ធិគ្រប់យ៉ាង

**គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ**

Editions Angkor

ISBN: 978-99950-2-171-9

www.elibraryofcambodia.org

# មាតិកា

ទំព័រ

អារម្ភកថា ........ vii

សេចក្ដីផ្ដើម ........ ១

## ជំពូក១

## លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ ដែលនាំឱ្យប្រទេសក្លាយជាអាណាចក្រខ្មែរនិង ការចាកចោលក្រុងអង្គរ

១- លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រតាមរយៈភូគព្ភសាស្ត្រ ........ ៣

២- លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រតាមរយៈប្រវត្តិសាស្ត្រ ........ ៥

៣- លក្ខណៈពិសេសនៃការកកើត និងការរីកចម្រើននៃទីក្រុងអង្គរ ........ ៨

៤- ការរៀបចំទីក្រុងរបស់ខ្មែរ និងទំនាក់ទំនងជាមួយនឹងទស្សនៈព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា (នៅសម័យអង្គរ) ........ ១៧

៥- មូលហេតុនៃសង្គ្រាមដែលនាំដល់ការចាកចោលក្រុងអង្គរ ........ ២២

## ជំពូក២

## ទីក្រុងចតុមុខ (រាជធានីភ្នំពេញ)

១- ការរៀបចំទីក្រុងសម័យចតុមុខ រជ្ជកាលព្រះពញាយ៉ាតមកដល់សម័យសង្គមរាស្ត្រនិយម ........ ២៧

១.១- ការពង្រីកទីក្រុងភ្នំពេញ ........ ៣០



www.elibraryofcambodia.org

១.២- នគរូបនីយកម្មនៅក្រុងភ្នំពេញ ..... ៣៤

## ជំពូក៣

## ទំនាក់ទំនងរវាងដំណើរនគរូបនីយកម្មនិងចលនាផ្លាស់ទី តាមព្រឹត្តិការណ៍ធំៗនៅកម្ពុជា

១- ចលនាផ្លាស់ទីមកទីក្រុងភ្នំពេញឬមកតំបន់ចតុមុខ ( សតវត្សទី ១៥ មក សតវត្សទី២០) ..... ៤៧

២- នគរូបនីយកម្មនៅកម្ពុជា និងទីក្រុងភ្នំពេញចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧០ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ..... ៥០

២.១- នគរូបនីយកម្មកើតចេញពីចលនាផ្លាស់ទី ចាប់ពីថ្ងៃទី ១៨ ខែមិនា ឆ្នាំ១៩៧០ ..... ៥០

២.២- ការរលំរលាយនគរូបនីយកម្មនៅកម្ពុជា: ក្រុងភ្នំពេញ ទីក្រុងនានា និងទីប្រជុំជន ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ..... ៥៩

២.៣- ចលនាផ្លាស់ទីចូលក្រុងភ្នំពេញ ទីក្រុង និងទីប្រជុំជននានាក្រោយ ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ..... ៧៣

## ជំពូក៤

## នគរូបនីយកម្មនិងស្ថាបត្យកម្មនៅកម្ពុជាតាមសម័យកាល

១-សម័យមុនអង្គរនិងសម័យអង្គរ ..... ៨៣

២-សម័យអាណានិគមបារាំង(១៨៦៣-១៩៥៣) ..... ៨៨

៣-សម័យឯករាជ្យឬសម័យសង្គមរាស្ត្រនិយម ( ១៩៥៣ - ១៩៧០) ..... ៩៥



www.elibraryofcambodia.org

## ជំពូក៥

## នគរូបនីយកម្មនៅកម្ពុជានាចុងទសវត្សឆ្នាំទី៨០ នៃសតវត្សទី២០ និងទសវត្សឆ្នាំទី១០ នៃសតវត្សទី២១


១- ការសិក្សាពីនិយមន័យ ទីប្រជុំជននិងទីជនបទផ្សារភ្ជាប់នឹងបរិបទនៃបណ្តុំប្រជាជនក្រុង និងដំណើរនគរូបនីយកម្ម ........ ១០០

១.១- ការកំណត់លក្ខណៈវិនិច្ឆ័យទីប្រជុំជនឡើងវិញ ........ ១០៥

១.២- ការកំណត់ចំនួនទីប្រជុំជននៅទូទាំងប្រទេស ........ ១០៥

២- ចំណោត់ថ្នាក់បណ្តុំប្រជាជនក្រុង និងនគរូបនីយកម្ម ........ ១០៦

៣- គោលនយោបាយ និងក្របខណ្ឌគតិយុត្តមួយចំនួននៅកម្ពុជា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ........ ១១១

៤- នគរូបនីយកម្មនៅទសវត្សឆ្នាំទី៨០ ដល់ទសវត្សឆ្នាំទី៩០ នៃសតវត្សទី២០ ........ ១២០

៥- ទីក្រុងនិងបញ្ហាលំនៅឋាននៅទសវត្សឆ្នាំទី១០ នៃសតវត្សទី២១ ........ ១២៥

៦- នគរូបនីយកម្ម និងប្រវត្តិនៃទីតាំងរាជធានី ទីក្រុង និងទីប្រជុំជន ........ ១៣៤

សេចក្តីសន្និដ្ឋាន ........ ១៧២

ប្រភពឯកសារយោង ........ ១៧៥

ឧបសម្ព័ន្ធ ១ ........ ១៨០

ឧបសម្ព័ន្ធ ២ ........ ១៨៧




www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅនេះ មានគោលបំណងផ្តល់នូវចំណេះដឹងដល់និស្សិតមុខវិជ្ជាភូមិវិទ្យា ប្រវត្តិវិទ្យា ស្ថាបត្យកម្ម នគរូបនីយកម្មឬអ្នករៀបចំក្រុង អ្នកស្រាវជ្រាវ និងអ្នកអានទាំងនានា ដែលមានបំណងចង់ស្វែងយល់អំពី **"ប្រវត្តិនគរូបនីយកម្មនៅព្រះរាជាណាចក្រកម្ពុជា"** ដែលបានកើតឡើងនៅទឹកដីកម្ពុជានៃដែនដីសុវណ្ណភូមិ និងការនាំមកនូវការកើតឡើងនៃទីក្រុងទីប្រជុំជន ។

ខ្ញុំសង្ឃឹមថាលោកអ្នកអាននឹងបានយល់ពីការវិវត្តរបស់សង្គមកម្ពុជា ដែលជម្រុញឱ្យកើតមានជានគរូបនីយកម្មនៅសម័យអង្គរ ក្រោយអង្គរ សម័យអាណាព្យាបាលបារាំង សម័យសង្គមរាស្ត្រនិយម សម័យប៉ុលពត សម័យប្រជាជនកម្ពុជាមានជីវិតរស់ឡើងវិញ ជាលើកទី ២ ( ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩) និងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ឋិតក្នុងសន្តិភាព ស្ថិរភាពនយោបាយ ។

សៀវភៅនេះក៏បង្ហាញឱ្យឃើញផងដែរ ពីចលនាផ្លាស់ទីរបស់ប្រជាជនកម្ពុជាតាមរបបនយោបាយ ការនាំទៅរកភាពរលំរលាយនៃទីក្រុង និងការកកើតឡើងវិញនៃទីក្រុង ។

អ្នកនិពន្ធយល់ឃើញថាសៀវភៅនេះ ពិតជាមិនទាន់មានលក្ខណៈស៊ីជម្រៅនៅឡើយ តែដើម្បីរួមចំណែកក្នុងការផ្តល់ចំណេះដឹង និងទុកជាឯកសារសម្រាប់និស្សិតបញ្ញវន្ត អ្នកស្រាវជ្រាវ ក៏ដូចជាជួយរួមចំណែកក្នុងការបណ្តុះពុទ្ធិដល់កុលបុត្រខ្មែរ ខ្ញុំបានខិតខំស្រាវជ្រាវចងក្រងសៀវភៅនេះឡើង ។

សូមអស់លោកមិត្តអ្នកអានមេត្តាអធ្យាស្រ័យនូវរាល់កំហុសឆ្គង និងកង្វះខាតនានា ដែលបានកើតឡើងដោយអចេតនានិងសូមមេត្តាជួយបំពេញកង្វះខាតដោយអនុគ្រោះ ។

ភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១

សូមអរគុណ



www.elibraryofcambodia.org

# សេចក្តីផ្តើម

ទឹកដីកម្ពុជាមានទំនាក់ទំនងយ៉ាងស្អិតល្មួត ជាមួយបណ្តាប្រទេសនៅអាស៊ីអគ្នេយ៍ទាំងលក្ខខណ្ឌធម្មជាតិ និងការឈានឡើងនៃប្រវត្តិសាស្ត្រ។ តំបន់នេះទទួលនូវឥទ្ធិពលខ្យល់មូសុង ដែលជាទូទៅមានរុក្ខជាតិខៀវស្រស់បំព្រងពេញមួយឆ្នាំ។ កម្ពុជាជាដែនដីចំណាស់ ដែលមានមនុស្សខ្មែររស់នៅតាំងពីយូរយារមកហើយ ។

ស្លាកស្នាមនៃមនុស្សបុព្វកាល ត្រូវបានរកឃើញនៅសម័យយុគថ្មបំបែករហូតមកដល់យុគលោហៈ។ ផ្អែកលើឯកសារទាំងឡាយ បូរាណវិទូមួយចំនួនបានធ្វើការស្រាវជ្រាវនៅតំបន់នេះដូចជាៈលោក E. SAURIN, J.P.CARBONEL, CECILE MOURER, ROLAND MOURER, P. LEVY, B.P.GROSLIER HENRY MAMSUY ROQUES[១] បានសន្និដ្ឋានថា ទឹកដីកម្ពុជាសម្បូរទៅដោយកេរ្តិ៍តំណែល បុរាណវត្ថុ ឋិតនៅពាសពេញប្រទេសដូចជា ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ រហូតដល់ខេត្តតាកែវ ខេត្តកំពត...។

អ្នកប្រាជ្ញជាតិពន្ធុវិទ្យាបានសន្និដ្ឋានថា មានមនុស្សពីរក្រុមមករស់នៅលើតំបន់ឥណ្ឌូចិនតាំងពីច្រើនសតវត្សមុនគ្រិស្តសករាជ។ មនុស្សទាំងពីរក្រុមនោះ គឺពួកអូស្ត្រាឡូអ៊ីត និងពួកមេឡានេស៊ីដែលមានសម្បុរខ្មៅ។ ជាបន្តបន្ទាប់នៅសតវត្សទី ១០ មុនគ្រិស្តសករាជ មានពួកឥណ្ឌូនេស៊ីដែលជាជនជាតិស្បែកលឿង បានមករស់នៅលាយឡំនឹងប្រជាជនចាស់លើតំបន់ឥណ្ឌូចិន បង្កើតបានជាតិសាសន៍ខ្មែរ-មន។ ជនជាតិខ្មែររស់នៅតាមដងទន្លេមេគង្គភាគខាងត្បូង ឯជនជាតិមនរស់នៅភាគខាង

---

[១] - Ou Vuddy thèse doctorat 1993: "Quelques Aspects de la Repartition de la Population cambodgienne Actuelle"



www.elibraryofcambodia.org

ជើងតាមដងទន្លេសេមូល ក្នុងដែនដីប្រទេសភូមាឬមីយ៉ាន់ម៉ា ។ សព្វថ្ងៃនេះ នៅក្នុងទឹកដីនៃប្រទេសចិន មានជនជាតិមនរស់នៅក្នុងខេត្តគុនមិញ ដែលជាតំបន់ភាគខាងត្បូងបំផុតនៃប្រទេសចិនជាប់នឹងប្រទេសភូមា និងជាតំបន់ឋិតនៅប៉ែកខាងជើងបំផុតនៃទឹកដីភូមា។



www.elibraryofcambodia.org

# ជំពូក១

## លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រ ដែលនាំឱ្យប្រទេស ក្លាយជាអាណាចក្រខ្មែរ និងការចាកចោលក្រុងអង្គរ

### ១-លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រតាមរយៈភូគព្ភសាស្ត្រ

សណ្ឋានដីនៃអាណាចក្រខ្មែរ កសាងឡើងពីចលនាតិចតូនិច និងតាមរយៈនៃដំណើរសំណឹក និងកំទេចកំណ ដែលបានកើតឡើងនៅគ្រប់សម័យកាលធរណីទាំងអស់។ តំបន់នេះ ទទួលរងនូវចលនាខ្លាំងក្លា នៃពំនើងផ្ទត់ធំៗជាញឹកញាប់ គឺពំនើងផ្ទត់កាលេដូញាង និងអែស៊ីញាងនៅស័កទី១ តែផ្ទៃដីស័កនេះត្រូវមេសំណឹកពង្រិចពង្រីល ក្លាយជាទំនាបសំណឹកទៅវិញនៅចុងស័កទី១។ នៅចុងស័កទី២ មានពំនើងផ្ទត់មួយទៀត គឺអាំងដូស៊ីញាងដែលបង្កឱ្យតំបន់នេះមានដីប្រកបដោយទម្រង់ថ្មក្រែ (ថ្មភក់[២]) សឹងពាសពេញប្រទេសដូចជាតំបន់ជួរភ្នំក្រវាញ ជួរភ្នំដងរែក និងខ្ពង់រាបខាងកើត។ ចលនាតិចតូនិចដែលមានកម្លាំងខ្លាំងក្លានេះ បង្កើតបានជាភ្នំហិមាល័យ និងមានឥទ្ធិពលដល់ជួរភ្នំក្រវាញ បានធ្វើឱ្យផ្ទៃផែនដីតំបន់នេះ ងើបឡើងបន្តិច និងបញ្ចប់ទៅវិញ នៅត្រង់ជួរភ្នំដំរីក្នុងខេត្តកំពតជាប់នឹងសមុទ្រ។ ចលនានេះ បានធ្វើឱ្យភូមិភាគតំបន់បឹងទន្លេសាបសព្វថ្ងៃស្រុតចុះ ហើយត្រូវគ្របដណ្តប់ដោយទឹកសមុទ្រនៅចុងស័កទី៣ ដែលធ្វើឱ្យផ្លូវទឹកនានាទទួលរងនូវការចាក់បង្គរកំទេច កំណរហូរពីតំបន់ខ្ពស់តាមទន្លេមេគង្គ (នៅប្រទេសកម្ពុជា) ទន្លេមេ-

---

[២] - grès : សិលាក្រែ ឬថ្មភក់



www.elibraryofcambodia.org

ណាម (នៅប្រទេសថៃ) ទន្លេសាលូអង់ (នៅប្រទេសមីយ៉ាន់ម៉ា) សុទ្ធតែមានប្រភពមកពីតំបន់ខ្ពស់ភាគខាងជើងនៃខ្ពង់រាបខាងកើតទីបេ ។សណ្ឋានដីបានងើបបន្តិចម្តងៗដោយកម្លាំងចលនាតិចតូនិច គួបផ្សំនឹងចលនាថយចុះទៅនៃទឹកសមុទ្រ (régression de la mer) បានធ្វើឱ្យគេមើលឃើញនូវវិទ្ធភាពទំនាបកណ្តាលធំធេង នោះគឺដីល្បាប់ថ្មីឋិតនៅក្បែរផ្លូវទឹក (បឹងទន្លេសាបនិងទន្លេមេគង្គ) ដីល្បាប់ចាស់ឋិតនៅក្បែរតំបន់ខ្ពស់ (ជួរភ្នំក្រវាញ ជួរភ្នំដងរែក និងខ្ពង់រាបខាងកើត)។ នៅតាមតំបន់ទំនាបកណ្តាល គេសង្កេតឃើញមានកូនភ្នំតូចៗ លេចចេញឡើងដែលជាទួលកសិណ។ នៅស័កទី៣ មានព្រឹត្តិការណ៍បន្ទុះភ្នំភ្លើងបានធ្វើឱ្យទឹកដីនៃអាណាចក្រខ្មែរទទួលរងនូវចលនាបំណាក់ស្រុត និងមានរំហៀវសិលាបាសាល់គ្របដណ្តប់តាមតំបន់ភូមិសាស្ត្របង្កើតបានជាខ្ពង់រាប។ ក្រោមឥទ្ធិពលត្រូពិចម៉ូសុងក្តៅហើយសើម បានបង្កលក្ខណៈឱ្យសិលាបាសាល់ពុកផុយក្លាយជាដីក្រហមមានជីជាតិ និងបម្រើឱ្យដល់ការដាំដុះ និងការលូតលាស់នៃរុក្ខជាតិនានា។ កត្តាអាកាសធាតុ សណ្ឋានដី ភោគទ្រព្យព្រៃឈើ ផ្លូវទឹក ធនធានដី ធនធានសត្វ គួបផ្សំនឹងអាណាចក្រនេះ មានធនធានមនុស្សខ្មែរប្រកបដោយឧត្តមគតិស្នេហាជាតិខ្ពស់ លក្ខណៈសម្បត្តិជាអ្នកអង់អាច ឧស្សាហ៍ព្យាយាម មានទេពកោសល្យ អាចស្ថាបនាប្រទេស បង្កើតក្រុងអង្គរពោរពេញដោយកិត្តិសព្ទល្បីរន្ទឺ និងក្លាយជាប្រទេសថ្កុំថ្កើងរុងរឿង និងសម្បូរណ៍សប្បាយ។

ដែនដីនៃអាណាចក្រខ្មែរជាដែនដី ដែលសម្បូរណ៍ដោយសិលាថ្មភក់ (ថ្មក្រៃ) ថ្មបាសាល់ ថ្មបាយក្រៀម ថ្មក្រានីត ដែលសិលាទាំងនេះជាសារធាតុសំខាន់ ជាពិសេស **សិលាក្រៃ និងថ្មបាយក្រៀម និងថ្មក្រានីត** ដែលបុព្វបុរសខ្មែរបានយកថ្មទាំងនេះមកសាងសង់ប្រាសាទ បន្សល់ទុករហូតដល់សព្វថ្ងៃមានចំនួនជាងមួយពាន់



www.elibraryofcambodia.org

ប្រាសាទ ឋិតនៅរាយបាយពាសពេញលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងនៅលើដែនដីនៃអាណាចក្រខ្មែរសម័យនោះ មានដូចជាប្រាសាទភិមៃ (នៅប្រទេសថៃ) ប្រាសាទវត្តភូ (នៅប្រទេសលាវ) ប្រាសាទអូរកែវ (នៅប្រទេសវៀតណាម) សព្វថ្ងៃ។

## ២-លក្ខណៈពិសេសនៃទីតាំងភូមិសាស្ត្រតាមរយៈប្រវត្តិសាស្ត្រ

ទីតាំងភូមិសាស្ត្រនៅសម័យមហានគរ មានឥទ្ធិពលធំធេងដល់កំណេកំណើតការលូតលាស់ របាយធនធានធម្មជាតិ ប្រជាជន សេដ្ឋកិច្ច វប្បធម៌... ដែលទឹកដីនេះបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយភូមិភាគអាស៊ីអគ្នេយ៍ ទាំងដីគោក និងដីកោះ លើលក្ខខណ្ឌធម្មជាតិ និងប្រវត្តិសាស្ត្រ។ ដែនដីនេះ ឋិតក្នុងតំបន់អាកាសធាតុត្រូពិច នៃអឌ្ឍគោលខាងជើង សម្បូរដោយកំដៅ និងឋិតក្នុងតំបន់អាស៊ីមូសុងសម្បូរដោយភ្លៀង ដែលជាតំបន់មានលក្ខណៈប្រសើរដល់ការដុះលូតលាស់នៃរុក្ខជាតិ មានដំណាំត្រូពិចគ្រប់ប្រភេទ។

នៅដើមសតវត្សទី១ នៃគ្រិស្តសករាជ តំបន់នេះជាដែនដីសុវណ្ណភូមិ មានមនុស្សខ្មែរតាំងទីរស់នៅពីយូរលង់ណាស់មកហើយ ដោយបង្កើតបានជាសង្គមមានរបៀបរៀបចំច្បាប់រដ្ឋច្បាស់លាស់ ដឹកនាំដោយស្ត្រីសោយរាជ្យឈ្មោះព្រះនាងសោមា តាមភាសាចិនហៅថាព្រះនាងលីវយី[៣] នៅនគរកោះគកធ្លក ដែលមាន **អង្គរបុរី** ជារាជធានីទី១ នៃអាណាចក្រភ្នំ ឬនគរភ្នំ (ខេត្តតាកែវសព្វថ្ងៃ)។ ព្រះនាងបានរៀបអភិសេកជាមួយព្រាហ្មណ៍ ដែលមកពីប្រទេសឥណ្ឌា ឈ្មោះព្រះបាទ

---

[៣] - បុព្វបុរសខ្មែរបានបង្កើតរដ្ឋឈ្មោះថា អាណាចក្រភ្នំ ឬនគរភ្នំពីសតវត្សទី ១ ដល់សតវត្សទី ៦ តាមភាសាចិនហៅថា ហ្វូណន។



www.elibraryofcambodia.org

កៅណ្ឌិន្យ តាមភាសាចិនហៅថា ព្រះបាទហ៊ុនទៀន ហើយព្រះអង្គបាននាំមកជាមួយនូវសាសនាព្រាហ្មណ៍។

ឆ្លងកាត់ប្រវត្តិសាស្ត្រសម័យកាលនោះ អាណាចក្រភ្នំមានឈ្មោះបោះសម្លេងលើដែនដីអាស៊ី និងអឺរ៉ុប និងមានទំនាក់ទំនងពាណិជ្ជកម្មរវាងបណ្តាប្រទេសក្នុងតំបន់អាស៊ី មានចិន ចម្ប៉ា ឥណ្ឌា និងអឺរ៉ុប (ដូចជាចក្រភពរ៉ូម៉ាំងនៅសម័យកាលនោះ ចក្រភពរ៉ូមមានអំណាចខ្លាំងពូកែ)[៤] (មើលរូបទី១)។

អាណាចក្រភ្នំ ឬនគរភ្នំ មានអាយុចាប់ពីសតវត្សទី១ ដល់សតវត្សទី៦ តាមភាសាចិនហៅថា ហ្វូណន។ តំណតមកចាប់សតវត្សទី៦ ដល់សតវត្សទី៨ ខ្មែរភាគខាងជើង បានបង្កើតរដ្ឋមួយឈ្មោះអាណាចក្រចេនឡា[៥] ដែលមានក្សត្រគ្រងរាជ្យនៅតាមបុរីតូចៗ និងមានរាជធានីឈ្មោះ**ភវបុរៈ**។

តាមឯកសារចិនបានបញ្ជាក់ថា នៅដើមសតវត្សទី៨ ចេនឡាធំ ត្រូវបែងចែកជាពីរ គឺចេនឡាដីគោកនៅតំបន់ខាងជើង លើទឹកដីចេនឡា មុនមានរាជធានីឈ្មោះ **ភវបុរៈ** និងចេនឡាលិចទឹក នៅខាងត្បូងមាន **រាជធានីសម្ភុបុរៈ** (ស្រុកសំបូរ ខេត្តក្រចេះសព្វថ្ងៃ)[៦]។ នៅសម័យចេនឡាក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ ខ្មែរមានរាជធានីឈ្មោះ**ឥសានបុរៈ** ដែលហៅថា **សំបូរព្រៃគុហ៍** ឋិតនៅភាគខាងជើងនៃទីក្រុងកំពង់ធំសព្វថ្ងៃ។ ឯកសារបង្ហាញថា មានប្រជាជនរស់នៅចំនួន

[៤] - តាមកំណាយនៅស្ថានីយបុរេប្រវត្តិអូរកែវ (បច្ចុប្បន្នឋិតក្នុងទឹកដីវៀតណាម) ក្នុងដីសណ្តទន្លេមេគង្គបានបង្ហាញឱ្យឃើញថាតំបន់នេះជាទីក្រុងកំពង់ផែធំមួយ ដែលមានលក់ដូរលោហធាតុមានតម្លៃ ត្បូង គុជ ឈើគ្រឿងក្រអូប ។ល។ សម្រាប់នាំចេញទៅប្រទេសក្រៅតាមសំពៅ។

[៥] - ជាសាមន្តរដ្ឋ រដ្ឋចំណុះរបស់នគរភ្នំ ហៅតាមភាសាចិនថា ចេនឡា (ឋិតនៅភាគខាងជើង និងជាខាងត្បូងប្រទេសលាវសព្វថ្ងៃ)។

[៦] - ចេនឡាធំជាទឹកដី ដែលរួមមាន ចេនឡា និងនគរភ្នំ។



www.elibraryofcambodia.org

២០០០០គ្រួសារ និងមានទីក្រុងតូចៗចំនួន៣៣។ ក្រុងនីមួយៗមានមនុស្សរស់នៅច្រើនពាន់គ្រួសារ និងមានមន្ត្រីជាអ្នកគ្រប់គ្រង។ រាល់បីថ្ងៃម្តង ព្រះរាជាទ្រង់បើកសវនាការនៅក្នុងបន្ទប់ធំមួយឋិតនៅកណ្តាលទីក្រុង។ បានសេចក្តីថា នៅពេលនោះការចាត់ចែងដឹកនាំប្រទេសមានលក្ខណៈរលូន និងប្រទេសប្រកបដោយសុខសន្តិ-ភាពនិងសុវត្ថិភាព។

**រូបទី ១ :** ដែនដីនៅសម័យកាលអាណាចក្រខ្មែរ




ប្រភព: ដកស្រង់ពី Wikipedia



www.elibraryofcambodia.org

## ៣-លក្ខណៈពិសេសនៃការកកើតនិងការរីកចម្រើននៃទីក្រុងអង្គរ

ឋិតនៅចន្លោះប្រទេសធំពីរ គឺចិន និងឥណ្ឌា ដែលមានខឿនអរិយធម៌រុងរឿងតាំងពីរយូរលង់ អាណាចក្រខ្មែរបានទទួលឥទ្ធិពលផ្នែកវប្បធម៌ នយោបាយ សេដ្ឋកិច្ច តាំងពីកំណាក់កំណើតប្រទេសនាដើមគ្រិស្តសករាជមកម្ល៉េះ។ តាមរយៈប្រវត្តិសាស្ត្របានឆ្លុះបញ្ចាំងឱ្យឃើញថា ទីតាំងភូមិសាស្ត្រនេះ បានផ្តល់នូវលក្ខខណ្ឌធម្មជាតិ លក្ខខណ្ឌសង្គម មានអំណោយផលល្អនាំឱ្យបុព្វបុរសខ្មែរយើង មានលទ្ធភាពកសាងខឿនវប្បធម៌ នយោបាយនិងសេដ្ឋកិច្ចឈានដល់កំពូលនាសម័យអង្គរ ក្លាយជាមហាអំណាចមួយនៅតំបន់អាស៊ី។

អាណាចក្រនេះគ្របដណ្តប់ដោយព្រៃឈើទាំងលើតំបន់ភ្នំ និងខ្ពង់រាប គួបផ្សំនឹងដំណាំស្រូវ និងដំណាំអាហារផ្សេងៗលាតសន្ធឹងលើផ្ទៃដីតំបន់ទំនាបទន្លេមេគង្គ ទំនាបទន្លេមេណាម ដែលនាំមកនូវដីល្បាប់ដ៏មានជីជាតិ និងធនធានធម្មជាតិសម្បូរណ៏បែប។ ខ្យល់មូសុងប្រាំង និងមូសុងវស្សាបក់កាត់ នាំមកនូវរបបទឹកភ្លៀង និងបង្កើតបានជាចរន្តទឹកក្តៅ និងចរន្តទឹកត្រជាក់ ឆ្លាស់ផ្លាស់ប្តូរគ្នាបង្កឱ្យសម្បូរណ៏ដោយមច្ឆាជាតិទឹកសាប និងទឹកប្រៃ និងពពួកសត្វសមុទ្រច្រើនប្រភេទទៀត ដែលកត្តាទាំងអស់នេះ បានបង្កលក្ខណៈឱ្យមនុស្សខ្មែរមានលក្ខណៈសម្បត្តិអំណោយផលដល់ការកសាងប្រទេស។ ទន្ទឹមនេះ ព្រះរាជាមួយចំនួនជាស្តេចខ្លាំងពូកែ ល្បីល្បាញខាងការពារនិងកសាងប្រទេសជាតិ។

សម័យអង្គរបានចាប់ផ្តើមពីគ្រិស្តសករាជ៨០២ គឺជាឆ្នាំដែលព្រះបាទជ័យវរ្ម័នទី២ ធ្វើពិធីទេវរាជនៅលើភ្នំគូលែន ហើយចប់នៅគ្រិស្តសករាជ១៤៣១ ជាឆ្នាំដែលព្រះបាទពញាយ៉ាតចាកចោលក្រុងអង្គរ បានសេចក្តីថា រយៈពេល៦២៩ឆ្នាំ គឺជា



www.elibraryofcambodia.org

សម័យកាលមួយដែលប្រទេសខ្មែរ បានស្គាល់នូវភាពរុងរឿងបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សលោក ។

ព្រះបាទយសោវរ្ម័នទី១ ជាស្ថាបនិកទីដំបូងគេក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលបានកសាងទីក្រុងថ្មី គឺទីក្រុងអង្គរ ឬក្រុងយសោធរបុរៈ ៨៨៩-៩០០[៧] ។ ព្រះអង្គជាបុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ ដែលមានទីក្រុងជារាជធានីនាសម័យអាណាចក្រខ្មែរដ៏ល្អអស្ចារ្យ ។ ពីសតវត្សទី៩ ដល់ពាក់កណ្តាលសតវត្សទី១៥ ប្រទេសកម្ពុជាមានប្រជាជនប្រមាណជា១០លាននាក់ ។ អាស្រ័យដោយសង្គ្រាមកើតមានជាបន្តបន្ទាប់និងជម្ងឺរាតត្បាតពេញទូទាំងប្រទេស ចំនួនប្រជាជនចេះតែថយទៅ ហើយបញ្ហានេះជះឥទ្ធិពលយ៉ាងខ្លាំងដល់របាយប្រជាជនទូទាំងប្រទេសផងដែរ ។

បុព្វបុរសខ្មែរជាមនុស្សមានគំនិតច្នៃប្រឌិត ដោយបានរៀបចំបរិ ព្រមទាំងធ្វើនយោបាយកសិកម្ម ផ្អែកលើរបៀបចាត់ចែងប្រព័ន្ធទឹកជាមូលដ្ឋាន ។ ការរៀបចំប្រទេសដែលបានធ្វើឡើងនៅរាជ្យព្រះបាទឥន្ទ្រវរ្ម័ន អាស្រ័យដោយស្ថានភាពនិងអំណាចរបស់ប្រទេសមានស្ថិរភាព មានកម្លាំងគ្រប់គ្រាន់ រួមនឹងជំនឿសាសនាមានលក្ខណៈមុតមាំ ។ នយោបាយទឹកនៅជំនាន់ព្រះឥន្ទ្រវរ្ម័ន មានលក្ខណៈផុសផុលខ្លាំងក្លា មានព្រែកជីកខ្វាត់ខ្វែងជាប្រព័ន្ធមួយស្មុគស្មាញនិងមានបារាយ ព្រមទាំងត្រួទឹកផ្សេងៗជាគោល ។ នៅពេលដែលព្រះបាទឥន្ទ្រវរ្ម័នបានឡើងសោយរាជ្យភ្លាម ព្រះអង្គបានចាត់ចែងឱ្យមានការសាងសង់បារាយមួយមានទំហំ ៣,៨ គីឡូម៉ែត្រគុណនឹង ៨០០ ម៉ែត្រដោយយកទឹកមកពីស្ទឹងរលួស ។ បារាយនេះមានឈ្មោះ "**ឥន្ទ្រតដាក**" យកព្រះនាមព្រះរាជាដាក់ ។ ទឹកដែលយកមកពីបារាយទាំងនោះ គឺសម្រាប់

---

[៧] - Paul Bruno និងលោក ស៊ុនហេង ម៉េងឈាង : ជនជាតិខ្មែរ ភាគទី ១ ស.វ.ទី ១ - ស.វ.ទី ១៥។



www.elibraryofcambodia.org

បម្រើឱ្យវិស័យកសិកម្មនារដូវប្រាំង។ វិស័យកសិកម្មរីកចម្រើន ជាពិសេសគឺការធ្វើស្រែប្រាំងបានច្រើនឥតមានទំនេរដី[៨]។

អាស្រ័យដោយហេតុផលទាំងនេះ បានធ្វើឱ្យសេដ្ឋកិច្ចប្រទេសមានការរីកចម្រើនឡើង សង្គមមានស្ថិរភាព មានអំណាចរឹងមាំនិងធ្វើឱ្យអាណាចក្រខ្មែរថ្កុំថ្កើងរុងរឿងដោយសារការរៀបចំនគរពេលនោះមានលក្ខណៈពិសេស ដែលប្រទេសផ្តោតការយកចិត្តទុកដាក់លើនយោបាយទឹក។

ក្សត្រគ្រងរាជ្យនៅសម័យអង្គរ ក្នុងរជ្ជកាលនៃអង្គព្រះមហាក្សត្រនីមួយៗ ក៏ដូចជាប្រជារាស្ត្រទូទាំងប្រទេសដែរ គឺមានបំណងចង់ធ្វើឱ្យទីក្រុងកាន់តែមានសោភ័ណភាពលើសដើមជានិច្ច។ តាមរយៈសំណង់ស្ថាបត្យកម្មដែលបានបន្សល់ទុកនិងស្លាកស្នាមដែលនៅសេសសល់មកដល់សព្វថ្ងៃ បូរាណវិទូបានធ្វើការសិក្សាស្រាវជ្រាវឃើញថា ប្រមាណជាពាសតវត្ស ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ អ្នកដំណើរជនជាតិព័រទុយហ្គេ ឈ្មោះ **ឌីយេហ្គោដូភូត** បានសរសេរថា: "**លោកឮគេថាក្រុងអង្គរពីដើមជាក្រុងដ៏មួយល្អ ហើយស្អាតបំផុតនៅលើលោក**"។

ព្រះរាជានៅលើកដំបូង មានគំនិតរៀបចំរាជធានីឱ្យទៅជាទីក្រុងមួយដ៏អស្ចារ្យ អច្ឆរិយៈ នោះគឺព្រះបាទយសោវរ្ម័នទី១ បានសេចក្តីថា ជាក្រុងទីមួយដែលមានប្លង់ម៉ត់ចត់ ហើយមានន័យទូលំទូលាយ ស្របទៅតាមលក្ខណៈលោកធាតុនៃព្រហ្មញ្ញសាសនា។ ព្រះរាជាបន្តមកទៀត បានរៀបចំក្រុងយសោធបុរៈឱ្យកាន់តែប្រសើរឡើងដែរ ដូចជាព្រះបាទរាជេន្ទ្រវរ្ម័ន បានវិលត្រឡប់ពីកោះកេរ្តិ៍ ដោយមកតាំងរាជធានីនៅយសោធបុរៈ ដែលមានសិលាចារិកមួយ បានចែងថាព្រះអង្គបាន

[៨] - លោកអាំងជូលាន និងក្រុមរបស់លោកក្នុងសៀវភៅ "អង្គរអតីត-បច្ចុប្បន្ន-អនាគត" ទំព័រ៤២-៤៣។



www.elibraryofcambodia.org

រៀបចំទីក្រុងនេះឱ្យកាន់តែទំនើបនិងឱ្យកាន់តែល្អឡើង ដោយទ្រង់បានសាងសង់ប្រាសាទមាសមួយដ៏ភ្លឺចិញ្ចាចបីដូចជាប្រាសាទរបស់ព្រះមហិន្ទ្រៈនៅលើផែនដី។

នៅក្នុងរាជព្រះបាទសូរិយាវរ្ម័នទី១ សង្ហារណៈបរិក្ខារក្រុង(អង្គរទី១) ត្រូវរងការខ្វះខាតអស់ជាច្រើនដោយសារសង្គ្រាមស៊ីវិល ម្ល៉ោះហើយព្រះអង្គបានបញ្ជាឱ្យគេរៀបចំស្ថាបនាជួសជុល ប៉ុន្តែលុះក្រោយបន្តិចមក ព្រះអង្គក៏មានព្រះតម្រិះឈ្វេងយល់ថា គោងតែបង្កើតក្រុងថ្មីមួយទៀត ដើម្បីសម្រួលដល់ដំណើរជីវភាពរបស់ប្រជារាស្ត្រផង និងដើម្បីលើកកិត្តិយសព្រះរាជសន្តិវង្សរបស់ព្រះអង្គផង។ ហេតុនេះព្រះអង្គបានចាត់ឱ្យអ្នករៀបចំក្រុង រៀបប្លង់អង្គរទី២ ដែលឋិតនៅចំកណ្ដាលមានប្រាសាទធំមួយ។ គម្រោងប្លង់នេះ ត្រូវបានសំរេចដោយស្នាព្រះហស្តរបស់ក្សត្រព្រះនាមឧទ័យទិត្យវរ្ម័នទី២។ ព្រះរាជាទាំងពីរអង្គនេះ បានចាត់ចែងឱ្យគេស្ថាបនាបារាយណ៍មួយ នៅខាងលិចទីក្រុងថ្មី គឺបារាយណ៍ខាងលិចដែលមានទំហំ (៨០០០ម៉ែត្រគុណនឹង ២២០ម៉ែត្រ) សម្រាប់យកទឹកប្រើប្រាស់និងផ្គត់ផ្គង់កសិកម្ម ក្នុងបំណងចិញ្ចឹមប្រជាជន ដែលរស់នៅក្នុងទីក្រុងថ្មីរបស់ព្រះអង្គនាបច្ចុប្បន្ននិងទៅអនាគត។ ព្រះបាទសូរិយាវរ្ម័នទី២ បានបន្តការរៀបចំក្រុងអង្គរនេះតទៅទៀត ដោយទ្រង់បានកសាងប្រាសាទមួយដ៏ធំអស្ចារ្យ គឺប្រាសាទអង្គរវត្តដែលនាំឱ្យទីក្រុងថ្មីនេះ មានសម្រស់កាន់តែឆើតឆាយថែមទៀត។ ស្នាព្រះហស្តជាចំបងរបស់ព្រះអង្គ (ព្រះបាទជ័យវរ្ម័នទី៧) ក្នុងចំណោមស្នាព្រះហស្តទាំងឡាយ គឺការស្ថាបនានិងការរៀបចំក្រុងអង្គរទី៣ សព្វថ្ងៃយើងហៅថា អង្គរធំ។ ទីក្រុងថ្មីមួយនេះ សាងសង់នៅលើទីទួល ជាទីកន្លែងរបស់ទីក្រុងអង្គរចាស់ (អង្គរទី២) ដែលត្រូវបានទទួលរងនូវការវិនាសអន្តរាយ ដោយកងទ័ពចាមចូលវាយលុកលុយបំផ្លិចបំផ្លាញនៅឆ្នាំ១១៧៧។ ដូចនេះទីក្រុងអង្គរគឺជាទីក្រុងមួយ ដែលស្ថាបនា



www.elibraryofcambodia.org

ឡើងដោយឈរលើទស្សនៈបែបព្រហ្មញ្ញនិយមផង និងបែបព្រះពុទ្ធសាសនាមហាយានផង។ តាមរយៈសំណង់ស្ថាបត្យកម្ម ដែលបានបន្សល់ទុកបានបង្ហាញឱ្យមនុស្សខ្មែរ ក៏ដូចជាមនុស្សជាតិលើពិភពលោកវាយតម្លៃបានថា ព្រះរាជានៃអាណាចក្រខ្មែរ ច្រើនតែជាក្សត្រដែលមានទេពកោសល្យខាងនគរូបនីយកម្ម ហើយព្រះរាជាដែលមានស្នាដៃអស្ចារ្យជាងគេលើវិស័យនេះ គឺព្រះបាទជ័យវរ្ម័ទី ៧ (មើលរូបទី ២-៣-៤-៥)។

**រូបទី២:** ប្លង់ក្រុងរសោធរបុរៈនៅដំណាក់កាលទី១។ សញ្ញាត្រីកោណជាសំណង់ដែលបានសង់នៅសតវត្សទី១០ រជ្ជកាលព្រះបាទយសោវរ្ម័នដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី៥





www.elibraryofcambodia.org

**រូបទី៣**៖ ប្លង់ក្រុងយសោធរបុរៈនៅដំណាក់កាលទី២ ។ សញ្ញាត្រីកោណជាសំណង់ដែលបានសង់នៅសតវត្សទី១១ រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ដល់រជ្ជកាលព្រះបាទជ័យវរ្ម័នទី៦





www.elibraryofcambodia.org

**រូបទី៤**: ប្លង់ក្រុងសោធរបុរៈនៅដំណាក់កាលទី៣ ។ សញ្ញាត្រីកោណជាសំណង់ដែលបានសង់នៅដើមសតវត្សទី១២ រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី១ដល់ពាក់កណ្ដាលសតវត្សទី១៣





www.elibraryofcambodia.org

**រូបទី៥:** ប្លង់ក្រុងរលោធរបុរៈនៅដំណាក់កាលទី៤។ សញ្ញាត្រីកោណជាសំណង់ដែលបានសង់នៅរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧



**ប្រភព:** រូបទី២-៣-៤-៥ អង្គរ: អតីត-បច្ចុប្បន្ន-អនាគតដោយ លោក អាំង ជូលាន...ទំព័រ៤៧- ៥៤-៥៥-៦៧។

រូបទី៦ បានបង្ហាញឱ្យឃើញពីទីតាំងភូមិសាស្ត្រ ដែលមានលក្ខណៈអំណោយផលដល់ការកសាងប្រាង្គប្រាសាទនានា។ ប្រាង្គប្រាសាទនានាបានកសាងឡើងដោយផ្អែកលើលក្ខខណ្ឌធម្មជាតិ ព្រោះតំបន់ខាងលើមានសណ្ឋានដីខ្ពស់ ជាទីដែលបុព្វបុរសខ្មែរយកថ្ម ដោយបណ្តែតតាមផ្លូវទឹក មានស្ទឹងសៀមរាប។ ស្ទឹងទាំងឡាយនៅតំបន់នេះ មានប្រភពពីតំបន់ភ្នំគូលែន ដែលជាតំបន់ខ្ពស់ ហូរពីទិសខាងជើងធ្លាក់ចុះមកបឹងទន្លេសាប។ ដូចនេះបឹងទន្លេសាបក៏ជាប្រភពធនធានដ៏សម្បូរបែបអស្ចារ្យ សម្រាប់ផ្តល់ដល់ការដ្ឋានសមរភូមិមុខ ដើម្បីសាងសង់ប្រាង្គប្រាសាទនានា



www.elibraryofcambodia.org

មានដូចជាអ្វីៗសព្វបែបយ៉ាង ទាំងសាច់ត្រី សាច់សត្វ បន្លែ ផ្លែឈើ សព្វសារពើមិន មានខ្វះ ។

**រូបទី៦:** លក្ខខណ្ឌធម្មជាតិអំណោយផលនៃទីតាំងភូមិសាស្ត្រ






www.elibraryofcambodia.org

## ៤-ការរៀបចំទីក្រុងរបស់ខ្មែរនិងទំនាក់ទំនងជាមួយនឹងទស្សនៈព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា (នៅសម័យអង្គរ)

ផ្ដើមចេញពីទស្សនៈនេះ ខ្មែរយើងបានរកឃើញរូបមន្តមួយ ដែលតម្រូវឱ្យកសាងនិងរៀបចំទីក្រុង តាមរបៀបរៀបចំក្រុងមានរបៀបតែមួយមិនសូវខុសគ្នាប៉ុន្មានទេ ទោះបីមានការរៀបចំក្រុងនៅតាមខេត្តក្ដី ក៏ដូចជានៅតាមយសោធបុរៈដែរ។ តាមធម្មតាប្លង់ទីក្រុងបែកចេញពីប្លង់ប្រាសាទដែលឋិតនៅចំកណ្ដាល ហើយប្រាសាទទាំងនេះត្រូវហ៊ុំព័ទ្ធដោយកំពែងមួយជាន់ ឬពីរជាន់ ឯនៅខាងក្រៅកំពែងមានគូរទឹកហ៊ុំព័ទ្ធមួយជាន់ថែមទៀត។ ប្រាសាទកណ្ដាលតំណាងឱ្យភ្នំព្រះសុមេរុ មានន័យថា នៅសម័យកាលនោះ អ្នករៀបចំស្ថាបនាទីក្រុងបានឈរលើស្មារតីដោយយកទីក្រុងជាតំណាងឱ្យពិភពលោកទាំងមូល ដែលមានកំពែងធ្វើអំពីថ្មបាយក្រៀម និងមានក្លោងទ្វាររៀបលាយជាមួយថ្មភក់ ឬជាការប្រមើលគន់គូរគិត និងសន្និដ្ឋានថា ជាជួរភ្នំចក្រវាឡដែលព័ទ្ធជុំវិញពិភពលោក ឯគូរទឹកតំណាងឱ្យមហាសាគរ។ ប្លង់ទីក្រុងទាំងនោះ តែងរៀបចំឡើងដោយមានគំនិតទាក់ទងទៅនឹងតារាវិទ្យា។ ជាទូទៅ កំពែងមានរាងបួនជ្រុងស្មើ ដោយមានកំពែងក្នុងនិងកំពែងក្រៅ។ កំពែងក្នុងហៅថា **កំពែងប្រាសាទ** ឯកំពែងក្រៅហៅថា **កំពែងវិស័យ**។ នៅចន្លោះកំពែងទាំងពីរគឺជាទីប្រជុំជន។ ទីប្រជុំជនភូមិគឺមានផ្ទះរបស់បណ្ដារាស្ត្រប្រក់ស្លឹក ឬស្បូវ រួមមានវាលស្រែនិងចំការព្រមទាំងផ្លូវទឹកតូចធំ។នៅចំកណ្ដាលនៃជ្រុងកំពែងនីមួយៗ មានផ្លូវក្រាលថ្មពុះជ្រុងទាំងឡាយ នោះទៅប្រសព្វមុខគ្នានៅទីប្រាសាទភ្នំបានសេចក្ដីថា មានបែងចែកផ្ទៃក្រឡាដីនៅក្នុងបរិវេណប្រាសាទជាបួនភាគស្មើគ្នា។ ជាទូទៅនៅមិនឆ្ងាយប៉ុន្មានពីប្រាសាទ ឬទីក្រុងមានការជីកបារាយណ៍ ជីកត្រពាំងតូច ឬត្រពាំងធំ សំរាប់ផ្ដល់ទឹកទៅឱ្យគូទឹកដែលឋិតនៅជុំវិញប្រាសាទ ឬផ្ដល់



www.elibraryofcambodia.org

ទឹកឱ្យទៅទីក្រុងទាំងនោះ និងឱ្យទៅប្រាសាទដទៃទៀត ដែលឋិតនៅក្នុងបរិវេណទីក្រុងដូចជាអង្គរធំ។ ការរៀបចំក្រុងធ្វើតាមរបៀបនេះ គឺដើម្បីឱ្យប្រជាពលរដ្ឋគ្រប់ៗគ្នា មានទឹកប្រើប្រាស់គ្រប់គ្រាន់សម្រាប់ធ្វើកសិកម្មផង និងមានទឹកសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈផង។ នៅក្នុងកំពែងអង្គរធំ លោក **ជីវ តាក្វាន់** (រាជទូតគោចរមកពីប្រទេសចិន) បានពិនិត្យមើលឃើញថា មានគេហដ្ឋានរបស់អ្នកស្រុកជាច្រើន សង់ឡើងដោយប្រក់ស្លឹក ឬប្រក់ស្បូវ (ព្រោះគេមិនហ៊ានប្រក់ក្បឿងទេ)។ ចំពោះផ្ទះមន្ត្រី នាម៉ឺនៗគេហដ្ឋានសង់ឡើងសុទ្ធតែធំៗ និងមានប្រក់ក្បឿង(នេះក៏ជាការបង្ហាញឱ្យឃើញពីវណ្ណៈសង្គមដែលមាននៅសម័យអង្គរ)។ ផ្ទះទាំងនេះ សង់ខ្ពស់ផុតពីដី ដូចជាផ្ទះខ្មែរសម័យបច្ចុប្បន្ននេះដែរ ហើយតែងនិយមសង់បែរមុខទៅទិសខាងកើតទាំងអស់។ គេមិនបានដឹងពីរបៀបរៀបរយនៃបណ្តុំផ្ទះទាំងអស់នោះទេ តែគេគ្រាន់តែអាចដឹងថា ទំហំផ្ទះទាំងនោះ ត្រូវសង់ទៅតាមលំដាប់ឋានៈយសសក្តិនៃម្ចាស់ផ្ទះ។ ចំពោះប្រាង្គប្រាសាទវិញ លោក **ជីវ តាក្វាន់** ពូសូរគេនិយាយតែពីប្រាសាទមាស ប្រាសាទស្ពាន់។ល។ តែគេអាចដឹងខ្លះ ពីរបៀបរៀបរយនៃប្រាសាទទាំងនោះ ព្រោះមាននៅគង់វង្សរហូតដល់សព្វថ្ងៃនេះ។

ដោយសារស្ថានភាពដីនៅក្រុងអង្គរ ទេរបន្តិចចុះពីជើងឆ្ពោះមកត្បូង គឺខ្ពស់ជាងទិសឥសាន្ត និងទិសនិរតី អ្នករៀបចំក្រុងសម័យអង្គរបានរកឃើញមធ្យោបាយដើម្បីបង្ហូរទឹកក្រខ្វក់ឬទឹកសំអុយ ចេញពីបរិវេណក្រុងតាមប្រឡាយជាច្រើន មកចាក់ចោលក្នុងត្រពាំងមួយហៅថា "**បឹងធំ**" ឋិតនៅជាប់កំពែងខាងត្បូងឈៀងខាងលិច។ គេសង្កេតឃើញថា ក្រៅពីទិដ្ឋភាពដ៏មហិមានៃកំពែង ព្រមដោយ "**គោបុរៈ**" ទាំងប្រាំ និងលម្អរដ៏អស្ចារ្យនៃប្រាសាទសិលាទាំងឡាយនៅសម័យនោះ គេមិនអាចចាត់ទុក **នគរធំ** ថា ជាក្រុងមួយដូចដែលយើងឃើញនោះទេ។ ប៉ុន្តែទោះបីទី



www.elibraryofcambodia.org

ប្រជុំជនជាច្រើន មានសភាពជាទីប្រជុំភូមិយ៉ាងណាក៏ដោយ ក៏ក្រុងអង្គរបានធ្វើឱ្យឈ្លួញបរទេសជំនាន់ **លោក ជីវ តាក្វាន់** និងបេសកសង្ឃព័រទុយហ្គេ អេស្ប៉ាញ៉ុលជាច្រើន នៅជំនាន់ក្រោយៗមកទៀត លាន់មាត់ស្ងើចសរសើរមិនមានដាច់។ ម៉្យាងទៀតអ្នកប្រាជ្ញសម័យបច្ចុប្បន្នជាច្រើន ដូចជាលោក **ព្យែរគូរ៉ូ** (Pierre Gourou) ជនជាតិបារាំង បានកោតសរសើរពីទេពកោសល្យដ៏អស្ចារ្យនៃក្រុងអង្គរ ដែលចេះផ្សាំជំនឿផ្នែកសាសនាជាមួយទ្រឹស្ដីនយោបាយ ជាមួយផលកតិវិទ្យាកសិកម្ម ឱ្យកើតចេញជារបៀបរៀបចំទឹកដីម៉្យាងដ៏ប៉ិនប្រសព្វ ទាំងនេះគឺជាគំនិតសំយោគមួយដែលពុំមានប្រជាជនណាលើលោកនេះអាចធ្វើបានដូច។

ទីប្រជុំជនក្រុងសម័យអង្គរ ក្រៅពីប្រាង្គប្រាសាទដែលជាស្ថាបត្យកម្មធ្វើអំពីសិលានោះ សំណង់ដែលជាលំនៅឋានរបស់ប្រជាជនភាគច្រើន សង់ឡើងនៅលើទីទួលធ្វើអំពីឈើ ឬស្សី ប្រក់ក្បឿង ឬស្លឹក ទៅតាមការបែងចែកវណ្ណៈសង្គមនាសម័យកាលនោះ តែសំណង់ទាំងនេះនៅបច្ចុប្បន្នមិនមាននៅសេសសល់ឡើយ ដោយសារសង្គ្រាម និងការបំផ្លិចបំផ្លាញ ដែលធ្វើឡើងពីសំណាក់ខ្មាំងសត្រូវ។ ផ្ទះសម្បែងត្រូវបានទទួលរងនូវការដុតបំផ្លាញ ក៏ដូចជាត្រូវទទួលរងនូវការបាក់បែកពុកផុយ ដោយសារអាកាសធាតុត្រូពិចមូសុងក្ដៅហើយសើម ដែលធ្វើឱ្យសំណង់ប្រភេទនោះ (ធ្វើអំពីឈើ ឬឫស្សី) ងាយនឹងរងនូវការពុកផុយបាក់បែកណាស់ មិនអាចមានជីវិតឋិតនៅរាប់សតវត្សបានឡើយ តែគេគ្រាន់តែអាចសន្និដ្ឋានថាភូមិករទាំងនោះច្រើនសាងសង់ឡើងលើទីដីទួល។ ដូចនេះអ្វីៗ ដែលមានបន្សល់ទុកឱ្យកូនចៅខ្មែរជំនាន់ក្រោយបានឃើញ និងដឹងឮសព្វថ្ងៃ គឺមានតែសំណង់ជាប្រាង្គប្រាសាទសិលាទេ ដែលនៅមានអាយុលើលោកយើងនេះ។



www.elibraryofcambodia.org

បច្ចុប្បន្នតាមការស្រាវជ្រាវផ្នែកបុរាណវិទ្យា បានបង្ហាញឱ្យកូនខ្មែរជំនាន់ក្រោយដឹងពីទីតាំងទាំងនោះ តាមរយៈកំណាយដែលគេសង្កេតឃើញមានសម្ភារៈមានជាឧបករណ៍ ដែលបុព្វបុរសជំនាន់នោះ បានប្រើប្រាស់ចាន ឆ្នាំង ក្អម... និងសំណល់ដែលសល់ពីការហូបចុកដូចជា ឆ្អឹងសត្វ ឆ្អឹងត្រី... ឆ្អឹងជាសំណល់សាកសពមនុស្សជាដើម ។ នៅព្រះរាជាណាចក្រកម្ពុជាមានស្ថានីយបុរេប្រវត្តិសាស្ត្រ និងស្ថានីយប្រវត្តិសាស្ត្រជាច្រើន ដែលបានបង្ហាញពីភស្តុតាងនៃការរស់នៅរបស់បុព្វ-បុរសខ្មែរសម័យបុព្វកាល តាំងពីរាប់ពាន់ឆ្នាំមុនគ្រិស្តសករាជ ដូចជាស្ថានីយបុរេប្រវត្តិសាស្ត្រនៅល្អាងស្ពានជាដើម ដែលបច្ចុប្បន្នក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកំពុងបន្តធ្វើការសិក្សានិងស្រាវជ្រាវ ។



www.elibraryofcambodia.org

**រូបទី ៧:** រូបលោក ជីវ តាក្វាន់ និងក្រុមការងារ ដែលបានមកដល់រាជធានីអង្គរនៅ ខែសីហា ឆ្នាំ១២៩៦ និងចាកចេញពីអង្គរទៅវិញនៅខែកក្កដា ឆ្នាំ១២៩៧



**ប្រភព:** ដកស្រង់ចេញពីសៀវភៅ Angkor la forêt de pierre, par BRUNO DAGENS, Decouvertes Gallimard, Archeologie, 1989. Imprimerie \Kapp- Lahure- Jombart à Evreux, p. 12 et p.14. តាមកំណាយ ឬតាមការសិក្សាស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យាប៉ុណ្ណោះ ទើបគេអាចសិក្សា និងរកឃើញនូវសំណល់ទាំងឡាយដែលបុព្វបុរសខ្មែរយើង កាលពីសម័យនោះ ធ្លាប់ប្រើប្រាស់។



www.elibraryofcambodia.org

## ៩-មូលហេតុនៃសង្គ្រាមដែលនាំឲ្យការចាកចោលក្រុងអង្គរ

**រូបទី ៨ :** ប្រាសាទអង្គរវត្តបែរមុខទៅទិសខាងកើត



ប្រវត្តិសាស្ត្របានបង្ហាញថា នៅពាក់កណ្ដាលសតវត្សទី១៣ សង្គ្រាមឈ្លានពានពីសំណាក់ពួកសៀម បានបង្កឡើងនូវការដុតបំផ្លាញក្រុងអង្គរ ក៏ដូចជាប្រជា-ជនក្រុងនិងមន្ត្រីមួយចំនួនធំដែលជាកូនចៅប្រជាជន ជាមន្ត្រីមានទេព្យកោសល្យចំណាន១ ដូចជាអ្នកប្រាជ្ញ បណ្ឌិត ដែលបានចារិកទុកនូវក្បួនខ្នាត និងគម្ពីរនានាជាច្រើន ត្រូវបានកងទ័ពសៀមប្រមូលនិងកៀរយកទៅជាមួយ ជាភស្តុតាងមានប្រជាជនខ្មែរជាច្រើនរស់នៅតាមព្រំដែនកម្ពុជាចន្លោះជួរភ្នំដងរែក និងទន្លេណាមមួន "ស្ទឹងព្រៃមូល" ក្នុងខេត្តសុរិន្ទ ខេត្តបុរីរាំ "បុរីរម្យ" និងឃុខាន់ "គោកខណ្ឌ"។ អតីតអាណាចក្រខ្មែរពីសម័យអង្គរ បានបន្សល់ទុកនូវកេរ្ដិ៍តំណែលជាច្រើនក្នុងទឹក



www.elibraryofcambodia.org

ដីថៃភាគខាងកើតសព្វថ្ងៃ ដូចជាផ្លូវថ្នល់ បារាយណ៍ ទីក្រុង ព្រះវិហារនិងប្រាសាទបូរាណចំនួន "១០៥"[៥] ក្រៅពីនេះមានជនជាតិខ្មែរនៅត្រង់រាជធានីបាងកក និងអូរជ្រៅទៀត ដោយមានតំណវង្សត្រកូលខ្មែរ ដែលសៀមបានកៀរយកទៅនៅដើមសតវត្សទី១៩។ ខេត្តមួយចំនួនដែលបច្ចុប្បន្ននៅភាគខាងត្បូង មានឈ្មោះក្លាយមកពីភាសាខ្មែរ គឺមានខេត្តនគររាជក្លាយមកជាខេត្តខូរ៉ាត ខេត្តព្រៃមូលក្លាយមកជាខេត្តណាមមូន ខេត្តប្រាជិនក្លាយពីពាក្យបស្ចឹម...។ ប្រជាជនខ្មែរដែលកំពុងរស់នៅលើទឹកដីប្រទេសសៀមសព្វថ្ងៃ មានភូមិឋានទីតាំង និងនៅរក្សាបានទំនៀមទម្លាប់ប្រពៃណី វប្បធម៌ ភាសា សាសនារហូតមកដល់សព្វថ្ងៃ ទោះបីជាអាជ្ញាធរសៀមហាមឃាត់ពួកគាត់មិនឱ្យរៀនភាសាខ្មែរក៏ដោយ តែពួកគាត់នៅតែរក្សាបាននូវទំនៀមទម្លាប់ប្រពៃណីខ្មែរដដែល។

លោក ជីវ តាក្វាន់ ដែលជាទូតគោចរនិងក្រុមរបស់គាត់មកពីប្រទេសចិន បានមកដល់រាជធានីអង្គរនៅខែសីហា ឆ្នាំ១២៩៦ និងចាកចេញពីដែនដីអាណាចក្រខ្មែរទៅកាន់ប្រទេសចិនវិញនៅខែកក្កដា ឆ្នាំ១២៩៧។ ពួកគាត់បានមកទស្សនាស្រុកខ្មែរនៅសតវត្សទី១៣ ដោយបានកត់ត្រានូវរាល់ទិដ្ឋភាពទាំងឡាយនាសម័យអង្គរដែលពួកគាត់បានឃើញ និងកោតស្ញប់ស្ញែងមិនដាច់ពីមាត់ នូវប្រាង្គប្រាសាទទាំងនោះ និងភាពប្រណិតគ្មានពីរលើលោក ហើយដែលទឹកដីខ្មែរនៅជំនាន់នោះធំទូលាយណាស់ លាតសន្ធឹងគ្របដណ្តប់លើជ្រោយឥណ្ឌូចិនទាំងមូល ដែលមានគោលសិលាចារឹកឆ្ងាយពីរាជធានីអង្គរ ជាទីសំអាងស្រាប់ (ឧទាហរណ៍មានសិលាចារិកសាយហ្វុង ឋិតនៅក្បែរក្រុងវៀងច័ន្ទ ប្រទេសឡាវសព្វថ្ងៃ) និងសំណល់សង្ហារណៈបរិក្ខារសេដ្ឋកិច្ច មានទំនប់ទឹក បណ្តាញជលគតិ បារាយណ៍ ផ្លូវថ្នល់ ។ល។ ដែលគេ

---

[៥] - លោក ម៉ា ជន ភូមិវិទ្យាសេដ្ឋកិច្ច នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៨៨ ទំព័រ ២៤។



www.elibraryofcambodia.org

រកឃើញ ដោយការរុករកតាមរយៈកំណាយ ឬដោយការសង្កេតពីលើយន្តហោះ[១០] ។ ក្រៅពីប្រាសាទនានា គេឃើញមាននៅសេសសល់ជាសំណង់ហេដ្ឋារចនាសម្ព័ន្ធមានផ្លូវថ្នល់ ដែលចេញពីទីក្រុងអង្គរឆ្ពោះទៅប្រទេសសៀម[១១] ដែលពីសម័យនោះទឹកដីនេះជាអាណាចក្ររបស់ខ្មែរ ។

សង្គ្រាមដែលបានកើតឡើងផ្ទួនៗគ្នាបន្ទាប់ពីការឈ្លានពាន ពីសំណាក់ពួកចាម និងជាបន្តមកទៀតជាមួយនឹងពួកសៀម មិនអាចផ្តល់ឱកាសឱ្យអាណាចក្រខ្មែរមានពេលវេលាក្នុងការកសាងប្រទេសឱ្យបានរលូនឡើយ ។ សំណង់ស្ថាបត្យកម្មនានាត្រូវបានបន្ថយល្បឿន ឬបញ្ឈប់ ព្រោះប្រការចាំបាច់ត្រូវកេណ្ឌនិងរើសទ័ពដែលជាកូនចៅប្រជាជន ដើម្បីធ្វើសង្គ្រាមទប់ទល់នឹងការឈ្លានពានពីសត្រូវជិតខាង ។ មូលហេតុមួយទៀត អាចមកពីសត្រូវដឹងពីចំណុចខ្សោយដោយសារផ្ទៃក្នុងគ្នាឯង

---

[១០] - លោក ផាច់ វ៉ាន់ផាត និងលោក កែវ សុភុន ជាសាស្ត្រាចារ្យបរិញ្ញាផ្នែកអក្សរសាស្ត្របារាំង បានធ្វើការសាកល្បងសិក្សាអំពីបុព្វហេតុដែលនាំឱ្យអរិយធម៌អង្គររីកចំរើនដល់កំពូល រួចធ្លាក់ដុនដាបមកវិញ ត្រូវបានបោះពុម្ពផ្សាយលើកទី១ នៅឆ្នាំ១៩៧៣ ។ គឺជាឯកសារមួយដែលបង្ហាញពីភាពរុងរឿង និងពីការធ្លាក់ចុះនៃប្រទេសខ្មែរ ពិសេសគឺទីក្រុងអង្គរក្រោយសតវត្សទី១៣ ។ ដោយការធ្លាក់ចុះរបស់ប្រទេស យើងលែងឃើញមានប្រាសាទសាងសង់ថ្មីទៀតហើយ ។ ចំនាកចោលអង្គរគឺពាក់ព័ន្ធនឹងការលើករាជធានីមកតាំងនៅទី ក្រុងភ្នំពេញ ឬចតុមុខនាសតវត្សទី១៥ ក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ។

[១១] - ព្រោះនៅសម័យអាណាចក្រខ្មែរ ទឹកដីខ្មែរមានផ្ទៃដីលាតសន្ធឹងធំធេង ដូចនេះផ្លូវនានាដែលនៅសេសសល់មានជាតួ ទួលរហូតដល់សព្វថ្ងៃ ដូចជាមានផ្លូវ និងស្ពានបុកចេញពីទីក្រុងអង្គរឆ្ពោះទៅដល់ក្រុងថេប ( ទីក្រុងបាងកកសព្វថ្ងៃដែលក្លាយមកពីឈ្មោះបឹងកក់) និងឆ្ពោះទៅដល់ទីក្រុងព្រៃនគរចេញទៅដល់សមុទ្រ ( ដែលសព្វថ្ងៃឋិតនៅក្នុងទឹកដីវៀតណាម) កាត់តាមខេត្តបាត់ដំបង ស្រុកភ្នំស្រុក( បច្ចុប្បន្នឋិតនៅក្នុងខេត្តបន្ទាយ-មានជ័យ) និងមានស្ពាននៅសេសសល់ស្ពានបុរាណមួយចំនួនដូចជាស្ពានស្រែងនៅចារគោកទាម ស្ពាននៅកំពង់ក្តី ក្នុងខេត្តកំពង់ធំ និងស្ពានតូចៗជាច្រើនទៀត ដែលធ្វើពីថ្មបាយក្រៀមមានទំហំធំដូចផ្លូវថ្នល់សព្វថ្ងៃ និងធ្វើតាមរបៀបសំណង់ផ្គុំរកចំណុចប្រសព្វទម្ងន់ ដោយគ្មានប្រើលោហធាតុមួយសសៃសោះឡើយ នេះជាទេពកោសល្យ និងភាពប៉ិនប្រសព្វ មានគំនិតឆ្នៃប្រឌិតខ្ពស់របស់បុព្វបុរសខ្មែរ ដែលសម្បូរណ៍ដោយអ្នកប្រាជ្ញល្បីៗ ។



www.elibraryofcambodia.org

និងការបែកបាក់ដែលកើតចេញពីការដណ្ដើមរាជ្យក្នុងត្រកូលក្សត្រ ក៏ដូចជាទំនាស់ដែលកើតចេញពីជំនឿសាសនា ( ព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា) បានធ្វើឱ្យអាណាចក្រខ្មែរចុះខ្សោយ និងឈានទៅដល់ការបាត់បង់ទឹកដីដែលធ្លាប់តែថ្កុំថ្កើងរុងរឿង។

កត្តាមួយទៀត ដែលជាមូលហេតុនាំឱ្យអាណាចក្រខ្មែរចាញ់ដៃក្នុងការទប់ទល់ជាមួយសត្រូវ អាចកើតមកពីការនឿយណាយក្នុងការស្ថាបនានូវសំណង់សង្ខារណេះជាបរិក្ខារសម្រាប់បម្រើឱ្យការសាងសង់នូវ សំណង់ស្ថាបត្យកម្មដ៏ធំៗមហិមាទាំងនោះដើម្បីបូជាដល់អាទិទេព។ ដូចនេះ ទោះបីជាប្រជាពលរដ្ឋខ្មែរមានមោទនភាពចំពោះសមិទ្ធផលដ៏អស្ចារ្យ ដែលកើតចេញពីស្នាដៃនិងគំនិតច្នៃប្រឌិតខ្ពស់ប្រកបដោយបញ្ញាញាណនេះក្តី តែក្នុងជំនាន់នោះ វិទ្យាសាស្ត្រផ្នែកវេជ្ជវិទ្យាមិនទាន់មានការរីកចម្រើនឡើយ ដូចនេះភាពហត់នឿយក៏ដូចជាការបាក់កម្លាំងនិងជម្ងឺបៀតបៀនតែងតែយាយី និងមិនអនុគ្រោះដល់ជីវិតមនុស្សលោកឡើយ។ ជាឧទាហរណ៍មានជម្ងឺរាតត្បាតដែលតែងតែកើតឡើង ហើយបានសម្លាប់ប្រជាជនទាំងភូមិៗមាន អាសន្នរោគ ជម្ងឺប៉េស្ត ជម្ងឺអុតធំ...។

ការចាញ់ដៃខ្មាំងសត្រូវឈ្លានពាន បណ្តាលឱ្យដែនដីនៃអាណាចក្រខ្មែរត្រូវបាត់បង់មួយផ្នែកធំ ដូចនេះតាមការយល់ឃើញរបស់អង្គក្សត្រដែលបានសោយរាជ្យបន្តបន្ទាប់ ឃើញយល់ឃើញថាចាំបាច់ត្រូវតែប្តូររាជធានីពីក្រុងអង្គរ មកតាំងទីនៅតំបន់ភាគខាងត្បូងនៃដែនដីទន្លេមេគង្គ ដើម្បីបញ្ចៀសពីការវាយលុករបស់សត្រូវផង និងបញ្ចៀសពីការកាប់សម្លាប់របស់សត្រូវផង។ តែទោះជាមានការប្តូរទីតាំងរាជធានីយ៉ាងណាក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរមួយចំនួនដែលធ្លាប់រស់នៅទីនោះ នៅតែបន្តការរស់នៅក្នុងតំបន់ក្រុងអង្គរខ្លះៗដែរ។



www.elibraryofcambodia.org

www.elibraryofcambodia.org

# ជំពូក២
# ទីក្រុងចតុមុខ (រាជធានីភ្នំពេញ)

## ១-ការរៀបចំទីក្រុងសម័យចតុមុខ

ដោយសារកង្វះឯកសារមូលដ្ឋាន យើងខ្ញុំមានការលំបាកក្នុងការសរសេរលាតត្រដាងនូវសារ៉ាតា និងការលើកឡើងអំពីអំណោះអំណាងនានា និងមូលហេតុចម្បងមួយចំនួនទៀត។ សង្គ្រាមឈ្លានពានបានធ្វើឱ្យអាណាចក្រខ្មែរ ត្រូវរួញមកនៅតូចដូចមានក្នុងផែនទីសព្វថ្ងៃនេះ។ ការរៀបចំរាជធានីនៅសម័យក្រោយអង្គរ ហាក់ដូចជាមិនសូវបានបន្សល់ទុកនូវកេរ្តិ៍មរតកធំធេងដូចសម័យអង្គរឡើយ។

ចាប់ពីសតវត្សទី១៥ ឯកសារខ្លះបានចែងថានៅគ្រិស្តសករាជ១៤៦៣ ខ្លះថានៅឆ្នាំ១៤៣៣ ខ្លះទៀតថា ឆ្នាំ១៤៣៤ ក្នុងរជ្ជកាលព្រះបាទពញាយាត (គ.ស. ១៤០៥ ដល់គ.ស.១៤៦៧) ឯកសារខ្លះទៀតសរសេរថា នៅឆ្នាំ១៣៩៣ មកដល់ឆ្នាំ១៤៦៣ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចលើករាជធានីមកតាំងទីនៅភ្នំពេញ បន្ទាប់ពីការចាកចោលក្រុងអង្គរ ហើយមកតាំងរាជធានីនៅ**ទួលបាសាន** បានមួយឆ្នាំ ឯកសារខ្លះសរសេរថាបាន "៩ឆ្នាំ"។

ដូចនេះចាប់ពីពេលនោះមក ប្រវត្តិសាស្ត្រខ្មែរបានឈានចូលក្នុងសម័យថ្មីមួយទៀត នោះគឺ**សម័យចតុមុខ**។ ដោយសារកាលបរិច្ឆេទ មានខុសៗគ្នាពីឯកសារនានាស្តីពីការមកតាំងទីរាជធានីនៅភ្នំពេញនេះ យើងខ្ញុំមិនអាចសន្និដ្ឋានបានពីកាលបរិច្ឆេទឱ្យបានច្បាស់លាស់ឡើយ ចាំបាច់ត្រូវប្រើពេលវេលាថែមទៀត ដើម្បីធ្វើការសិក្សាបន្ថែម ទើបអាចឈានទៅដល់ការឯកភាពគ្នា។



www.elibraryofcambodia.org

តែបើតាមឯកសារជនជាតិខ្មែរភាគទី១ និពន្ធដោយលោក Paul Brunon និងលោកស៊ិនហេង ម៉េងឈាង បានឱ្យដឹងថា ព្រះបាទពញាយ៉ាតបានលើករាជធានីពីអង្គរមកតាំងនៅទួលបាសាន (ស្រីសន្ធរ ខេត្តកំពង់ចាម) បន្ទាប់មកនៅចតុមុខក្នុងឆ្នាំ១៤៣២។

នៅចន្លោះសម័យក្រោយអង្គរមកដល់សម័យចតុមុខ ព្រះរាជាណាចក្រកម្ពុជានៅតែមានសង្គ្រាមជាហូរហែរ ដែលកម្ពុជាគ្មានឱកាសនឹងកសាងប្រទេសឡើយ ធ្វើឱ្យប្រទេសជិតខាងចូលជ្រៀតជ្រែកឈ្លានពាន និងសង្គ្រាមហែកហួរគ្នាឯង ក្នុងត្រកូលក្សត្រ។ ដូចនេះទោះបីក្នុងរយៈពេលវែង ឬខ្លីយ៉ាងណាក្តី ការអភិវឌ្ឍប្រទេសពិតជាមានការលំបាកលើផ្នែកនគរូបនីយកម្ម ជាពិសេសលើការរៀបចំក្រុងពីព្រោះរាជធានីត្រូវបានប្តូរទីតាំងជាបន្តបន្ទាប់ ពីតំបន់មួយទៅតំបន់មួយ ដើម្បីបញ្ចៀសពីការវាយលុករបស់សត្រូវឈ្លានពាន។

គេអាចដឹងថា ក្រោយពីទីក្រុងចតុមុខបានបង្កើតហើយ តែការតាំងរាជធានីមិនជាប់លាប់ឡើយ លក្ខណៈដែលគួរឱ្យកត់សម្គាល់ គឺមានការកសាងរាជធានីថ្មីដូចជាក្រុងលង្វែក (ក្នុងរជ្ជកាលអង្គចន្ទទី១ ឆ្នាំ១៥២៧ ដល់ឆ្នាំ១៥២៩) និងជាបន្តមកទៀត មានការលើករាជធានីទៅក្រុងឧដុង្គ នៅក្នុងរជ្ជកាលព្រះជ័យជេដ្ឋាទី២ (១៦១៨-១៦២៨)។

ការកសាងរាជធានីភ្នំពេញនៅសតវត្សទី១៥។ ព្រះបាទពញាយ៉ាតគឺជាព្រះរាជាដំបូងគេ ដែលបានមកតាំងរាជធានីនៅទីក្រុងភ្នំពេញនេះ។ ព្រះអង្គបានបញ្ជាឱ្យសម្តេចចៅពញាកែ និងឧញ៉ាហោរាធិបតេយ្យខ្សែវព្រមទាំងមន្ត្រីខ្លះទៀតឱ្យទៅពិនិត្យមើលដីដែលស្ថិតនៅជិតភ្នំដូនពេញ។ លុះមកដល់ពិនិត្យតាមក្បួនសព្វគ្រប់ មន្ត្រីទាំងនោះបានថ្វាយដំណឹងទៅព្រះរាជាវិញថា តំបន់ដែលស្ថិតនៅទិសអគ្នេយ៍ភ្នំ



www.elibraryofcambodia.org

ជូនពេញ មានស្ថានភាពអាចស្ថាបនាជារាជធានីបាន ព្រះអង្គក៏បានបញ្ជាឱ្យគេកេណ្ឌកម្លាំង ដើម្បីកសាងព្រះរាជនិវេសន៍លើដីទួល សម្រាប់ធ្វើកំពែងសង់ប្រាសាទនិងដំណាក់តូចធំក្នុងរយៈពេលដ៏ខ្លីបំផុត។ បន្ទាប់មកព្រះអង្គបានបញ្ជាឱ្យចៅពញាតេជោ ជាចៅហ្វាយស្រុកខេត្តសំរោងទង កេណ្ឌប្រជារាស្ត្រឱ្យលើកដីចាក់បំពេញតំបន់ជុំវិញវត្តភ្នំ និងព្រះរាជវាំង ដែលធ្វើឱ្យតំបន់នេះ មានសណ្ឋានដីរាបស្មើល្អរហូតដល់មាត់ទន្លេ ដែលអ្នកផងហៅថា "កំពង់រាប" តាំងពីពេលនោះមក។ ឯកន្លែងដែលចៅពញាតេជោ ឱ្យរាស្ត្រជីកយកអាចម៍ដីនោះក៏ក្លាយជាបឹងមួយធំជ្រៅទើបឱ្យឈ្មោះថា "បឹងតេជោ" ដែលបច្ចុប្បន្នឋិតនៅត្រង់ផ្សារធំថ្មីសព្វថ្ងៃ។ ព្រះអង្គបានបញ្ជាឱ្យឧកញ៉ាអនុជិតផ្លុង ហៅចៅហ្វាយស្រុកបាទី ឱ្យជីកព្រែកបង្ហូរទឹកចូលក្នុងបារាយណ៍នៅទីនោះ សម្រាប់យកទឹកមកប្រើប្រាស់ ហើយសម័យដែលព្រែកនេះមិនទាន់បានចាក់ដីលុបបំពេញ អ្នកស្រុកបានដាក់ឈ្មោះ និងហៅថាព្រែកឧញ៉ាផ្លុង។ តាមការស្រាវជ្រាវ ព្រែកនេះស្ថិតនៅតាមបណ្តោយសួនច្បារមុខស្ថានីយរាជាយស្ម័យយានរហូតមកដល់មាត់ទន្លេសាប[១២]។ ដើម្បីជាកិច្ចការពារប្រជារាស្ត្រព្រះរាជាបានបញ្ជាឱ្យគេជីកគូរទឹក និងលើកដីជាកំពែងពាំងតាមបណ្តោយព័ទ្ធជុំវិញរាជធានី។ នៅទិសខាងត្បូង គឺព្រែកតាកែវ ឯខាងលិចគឺព្រែកអូរគ ខាងជើងគឺព្រែកពោងពាយ ឬព្រែកចិនដំដែក ពីព្រោះនៅកន្លែងនោះប្រជាពលរដ្ឋភាគច្រើនមានមុខរបររកស៊ីខាងជាងដំដែក។

ក្រៅពីមុខងារការពារទីក្រុង ព្រែកទាំងនោះ នៅមានមុខងារម៉្យាងទៀត គឺផ្តល់ទឹកឱ្យប្រជារាស្ត្រធ្វើស្រែនៅទិសភាគខាងលិច។

---

[១២] - Phnom Penh d'Hier à aujourd'hui ដែលសរសេរដោយលោក Michiel Igout បានបង្ហាញពីរូបថត ពីការជីកព្រែកព័ទ្ធជុំ វិញទីក្រុងនៅឆ្នាំ១៨៩៤-១៩៣១ និងទិដ្ឋភាពនៅទីកន្លែងដែលបានចាក់បំពេញ (រូបថតនៅឆ្នាំ១៩៩៣) ទំព័រ៧៤-៧៥។



www.elibraryofcambodia.org

ក្រោយពីព្រះបាទពញាយ៉ាតសុគតទៅ មានព្រះរាជាបីអង្គទៀតបានបន្តគង់នៅក្រុងភ្នំពេញ គឺព្រះនរាយណ៍រាជា ព្រះស្រីរាជា និងព្រះធម្មរាជា។ នៅសតវត្សទី១៧ មានស្តេចមួយអង្គទៀតបានមកតាំងទីនៅក្នុងរាជធានីភ្នំពេញ បានមួយរយៈពេលខ្លីប៉ុណ្ណោះ ព្រះរាជាអង្គនោះឈ្មោះពញាញ៉ោម។ នៅសតវត្សទី១៩ ព្រះបាទឧទ័យរាជាអង្គច័ន្ទបានលើករាជធានីមកនៅភ្នំពេញវិញ ដោយបានកសាងវាំងថ្មីខាងត្បូងវត្តឧណ្ណាលោមហៅថា "រាជវាំងកំពែងកែវ" ជាទីកន្លែងកសាងរាជវាំងថ្មីនេះដែលស្ថិតនៅរហូតមកដល់សព្វថ្ងៃ។ លុះក្រោយមកព្រះឧទ័យរាជាអង្គច័ន្ទបានប្តូររាជធានីទៅកាន់កោះស្លាកែតវិញ រហូតមកដល់រជ្ជកាលព្រះបាទសម្តេចនរោត្តមឆ្នាំ១៨៦៧។

មកដល់ឆ្នាំ១៩០៤ ទើបមានការប្តូររាជធានីមកនៅភ្នំពេញ ប្រហែលជានៅឆ្នាំ១៨៦៧ និងជាបន្តបន្ទាប់មកការតាំងទីក្រុង ឬរាជធានីមិនមានការផ្លាស់ប្តូរទៀតឡើយ រហូតមកដល់សព្វថ្ងៃនេះ (មើលរូបទី៩ និងទី១០)។

## ១.១-ការពង្រីកទីក្រុងភ្នំពេញ និងល្បឿននគរូបនីយកម្ម

ទីក្រុងភ្នំពេញ ឬទីក្រុងចតុមុខ ចាប់ពីសតវត្សទី១៥ដល់ជិតពាក់កណ្តាលសតវត្សទី១៩ ពុំមានការពង្រីកក្រុងឱ្យធំទូលាយទេ ព្រោះមានវិបត្តិក្នុងប្រទេស និងសង្គ្រាមជាមួយប្រទេសជិតខាង ក៏ដូចជាព្រះរាជាណាចក្រកម្ពុជាត្រូវឋិតក្រោម



www.elibraryofcambodia.org

**រូបទី៩ និងរូបទី១០ :** ប្លង់ព្រែកជីក និងស្ថាននានា យកពីប្លង់ទីក្រុងភ្នំពេញស.វ.ទី១៩

ទស្សនាវដ្ដី L'Illustration ឆ្នាំ១៨៩៤




**ប្រភព:** រូបថតដកស្រង់ចេញពីសៀវភៅរបស់លោក Michel Igout ភ្នំពេញម្សិលមិញ និងបច្ចុប្បន្ន (Phnom Penh Hier et aujourd'hui)



www.elibraryofcambodia.org

អាណាព្យាបាលរបស់បារាំង (ឆ្នាំ១៨៦៣)។ ជាបន្តបន្ទាប់ ទីក្រុងភ្នំពេញបានចាប់ពង្រីកខ្លួន និងរីកធំឡើងចាប់ពីពាក់កណ្តាលសតវត្សទី១៩ ជាពិសេសនៅពេលដែលកម្ពុជាបានទទួលឯករាជ្យពីប្រទេសបារាំងនាឆ្នាំ១៩៥៣ រហូតមកដល់សតវត្សទី២១ គឺបន្ទាប់ពីការតាំងទីក្រុងភ្នំពេញជាប់លាប់។ បើយើងងាកមកក្រោយវិញបន្តិច នៅក្នុងឆ្នាំ១៨៧៦ ទីក្រុងភ្នំពេញបានលាតសន្ធឹងតាមបណ្តោយត្រើយខាងលិចទន្លេសាប និងទន្លេបាសាក់ មានបណ្តោយប្រវែងប្រហែល៣គ.ម.ប៉ុណ្ណោះ និងទទឹងចូលពីមាត់ទន្លេទៅក្នុងជម្រៅដីគោក ប្រវែងយ៉ាងច្រើនពី ៣០០ម៉ែត្រទៅ ៣៥០ម៉ែត្រ ដែលប្រជាជនច្រើននៅប្រមូលផ្តុំគ្នារស់នៅតាមមាត់ទន្លេ។ មកដល់ឆ្នាំ១៨៨៥ មានការចាប់ផ្តើមពង្រីកទីក្រុងទៅទិសខាងលិច តែទិសខាងជើង និងខាងត្បូងពុំសូវមានការប្រែប្រួលទេ។ ដើម្បីអភិវឌ្ឍន៍ក្រុងឱ្យកាន់តែមានសោភ័ណ-ភាព សកម្មភាពពង្រីកក្រុងបានប្រព្រឹត្តទៅជាបណ្តើរៗ ព្រោះស្ថានភាពទីតាំងក្រុងឋិតក្នុងតំបន់ទំនាបទាប និងសំបូរដោយបឹងបួរអូរតូចៗ និងព្រែកជីកព័ទ្ធក្រុង ដូចនេះនៅរដូវវស្សាដីមួយផ្នែកដែលទាបត្រូវលិចទឹក ជួនកាលលិចដោយទឹកតម្លើងផង និងទឹកភ្លៀងផង ដែលចាំបាច់ត្រូវមានការចាក់លុបបំពេញ និងជំនួសដោយសួនឧទ្យាន អគាររដ្ឋបាល និងផ្លូវនានាជាក្រឡាចក្រត្រង្គ ដូចជាសួនច្បារនៅមុខស្ថានីយរាជាយស្ម័យយាន និងការចាក់បំពេញដីតំបន់ខាងមុខសណ្ឋាគាររ៉ូយ៉ាល់ (Hotel Le Royal) តំបន់បឹងកេងកង អូរឫស្សី ចំការមន បឹងទំពុន ។ល។

ការចាក់ដីលុបបំពេញតំបន់ទាបៗនៅឆ្នាំ១៩១០ បានធ្វើឱ្យក្រុងភ្នំពេញមានទិដ្ឋភាពកាន់តែល្អ និងក្លាយជាទីក្រុងមួយពេញលេញ ដោយមានការពង្រីកទីក្រុងទៅទិសខាងលិចកាន់តែរីកធំឡើងៗ ហើយរចនាសម្ព័ន្ធទីក្រុងមានការប្រែប្រួលជាបន្តបន្ទាប់។ ការចាក់ដីលុបតំបន់ទំនាបនៅក្បែរការដ្ឋានសាងសង់សណ្ឋាគាររ៉ូ



www.elibraryofcambodia.org

យ៉ាល់នាឆ្នាំ១៩៣០ អាចឱ្យយើងមើលឃើញពីដំណើរឈានឡើងនៃការអភិវឌ្ឍទីក្រុងភ្នំពេញតាមសម័យកាលបន្តបន្ទាប់។ ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺឈ្មោះមួយចំនួនដែលហៅនៅតាមសង្កាត់នានា រហូតមកដល់សព្វថ្ងៃមានភ្ជាប់ដោយឈ្មោះបឹង អូរ ព្រែក ឬទួល ដែលករណីទាំងនេះអាចជាតឹកតាង បញ្ជាក់ប្រាប់ដល់មនុស្សជំនាន់ក្រោយឱ្យដឹងថា ទីក្រុងភ្នំពេញបានកសាងឡើងលើតំបន់ទំនាបទាបនៃទន្លេចតុមុខ ដែលជាតំបន់ងាយលិចទឹកបំផុត ជាពិសេសនៅរដូវតម្លើង (រដូវវស្សា) ឬពេលមានទឹកជំនន់ទន្លេមេគង្គម្តងៗ ហើយឈ្មោះទាំងនោះតែងតែមានភ្ជាប់ដោយឈ្មោះ បឹង អូរ មានដូចជាបឹងកេងកង បឹងត្របែក បឹងព្រលិត បឹងរាំង បឹងជើងឯក បឹងទំពុន និងបឹងតេជោ (ជាបឹងដែលប្រជាពលរដ្ឋជីកយកអាចម៍ដីទៅចាក់លុបបំពេញ ទីទាបៗនៅជុំវិញវត្តភ្នំ) បឹងមួយចំនួនដែលមាននៅសព្វថ្ងៃ ឋិតក្នុងតំបន់ត្រូវអភិវឌ្ឍន៍ ដូចជាបឹងកក់ និងនៅមានបឹងពោងពាយ ឬអូរឫស្សី ព្រែកចិនដំដែក ព្រែកតាកែវ ព្រែកអូរត និងព្រែកឧញ៉ាផ្លុង (ជាព្រែកដែលជីកដោយប្រជាពលរដ្ឋដើម្បីបង្ហូរទឹកសម្រាប់ធ្វើស្រែ)។

នៅទសវត្សទី៦០ រាជធានីភ្នំពេញមានការអភិវឌ្ឍទៅមុខយ៉ាងលឿន ដែលធ្វើឱ្យមុខមាត់ទីក្រុងមានឈ្មោះបោះសម្លេងថា ជាទីក្រុងមួយតូចតែស្អាតជាងគេនៅក្នុងតំបន់អាស៊ីអគ្នេយ៍។ រហូតមកដល់ឆ្នាំ១៩៦២ ទីក្រុងភ្នំពេញមានផ្ទៃដី ៤៦ គ.ម.២ ដោយមានកូអរដោនេភូមិសាស្ត្រ ស្ថិតនៅលើខ្សែបណ្តោយត្រង់ចំណុចទី ១០៤°៥១ នៃរយៈបណ្តោយខាងកើត និងខ្សែទទឹងត្រង់ចំណុចទី ១១°៣៣ នៃរយៈទទឹងខាងជើង។



www.elibraryofcambodia.org

នៅឆ្នាំ១៩៧៩ ជាពិសេសក្រោយថ្ងៃទី០៧ ខែមករា នៃការរស់ឡើងវិញពីរបបប្រល័យពូជសាសន៍ និងនៅឆ្នាំ១៩៨១ ផ្ទៃក្រឡាទីក្រុងភ្នំពេញ បានកើនឡើងដល់១៨៩គ.ម.[២] ដែលការកើនឡើងនៃផ្ទៃដីទីក្រុងនេះ បានពាក់ព័ន្ធទៅនឹងការកើនឡើងនៃចំនួនប្រជាជនដែលធ្វើចលនាចូលមករស់នៅក្នុងក្រុងភ្នំពេញ។

បើធ្វើការប្រៀបធៀបពីផ្ទៃដីក្រុងភ្នំពេញ នៅចន្លោះសម័យសង្គមរាស្ត្រនិយមឆ្នាំ១៩៦២ (ផ្ទៃដីមាន ៤៦គ.ម.[២]) និងសម័យបច្ចុប្បន្នឆ្នាំ២០១០ (ផ្ទៃដី ៦៧៨,៧៧គ.ម.[២]) នោះបានអះអាងថា ក្នុងរយៈពេល៤៩ឆ្នាំ ទីក្រុងភ្នំពេញមានផ្ទៃដីរីកធំឡើងដល់ទៅជិត១៥ដង។

### ១.២- នគរូបនីយកម្មនៅក្រុងភ្នំពេញ

**រូបទី១១:** ទិដ្ឋភាពការបូមដីចាក់លុបបំពេញ ដើម្បីសាងសង់ សណ្ឋាគារឡឺរ៉ូយ៉ាល់





www.elibraryofcambodia.org

**រូបទី១២:** ព្រែកជីកភ្ជាប់ពីទន្លេសាប



**រូបទី១៣:** ព្រែកជីកដែលត្រូវបានចាក់ដីលុបបំពេញវិញ





www.elibraryofcambodia.org

**រូបទី១៤:** តំបន់នេះបានក្លាយជាសួនឧទ្យានទៅទល់នឹងផ្លូវព្រះមុនីវង្ស ដែលបច្ចុប្បន្នបានអភិវឌ្ឍន៍កាន់តែមានសោភ័ណភាពឡើង



**រូបទី១៥:** ស្ពាននាគចាស់សម្រាប់ឆ្លងទៅវត្តភ្នំបានស្ថាបនានៅសម័យអាណានិគមបារាំង



**ប្រភព:** លោក Michel Igout : Phnom Penh d'Hier a' Aujourd'hui,1993.



www.elibraryofcambodia.org

**រូបទី១៦: ស្ពាននាគថ្មីសង់ជានិមិត្តរូបនៅឆ្នាំ២០០៧**



ប្រភព: ថតដោយកញ្ញា លន់ ពុធារី ឆ្នាំ២០១០



www.elibraryofcambodia.org

## រូបទី១៧ : ប្លង់អភិវឌ្ឍន៍ទីក្រុងភ្នំពេញពីឆ្នាំ១៨៧៦ ដល់ ឆ្នាំ១៩៥៨




**Le développement de Phnom-Penh de 1876 à 1958**

1. 1876. — 2. 1885. — 3. 1910. — 4. 1922. — 5. 1937. — 6. 1942. — 7. 1958.

ប្រភព: ដកស្រង់ចេញពីសៀវភៅ លោក Michel Igout : Phnom Penh décors et stratégies géographiques sur un espace urbain en crise, 25 février 1993.



www.elibraryofcambodia.org

**រូបទី១៨: ប្លង់សុរិយោដីក្រុងភ្នំពេញ មាត្រដ្ឋាន ១/២៥ ០០០ ធ្វើនៅឆ្នាំ១៩២២**




ប្រភព: ដកស្រង់ពីសៀវភៅលោក Michel Igout បោះពុម្ពឆ្នាំ 1993 : Phnom Penh d'Hier à Aujourd'hui, ទំព័រ ៨៤ ។



www.elibraryofcambodia.org

រូបទី១៧និងទី១៨ បង្ហាញពីប្លង់ទីក្រុងភ្នំពេញ ដែលបន្តរីកធំឡើងឆ្ពោះទៅទិសខាងលិច។ ប្លង់ក្រុងបានបង្ហាញពីការប្រើប្រាស់ដី គឺឋិតនៅត្រឹមផ្លូវព្រះមុនីវង្សប៉ុណ្ណោះ ហើយការប្រើប្រាស់ដីនៅខាងលិចផ្លូវព្រះមុនីវង្ស ប្រជាពលរដ្ឋច្រើនធ្វើកសិកម្ម មានដាំស្រូវជាដើម។

យើងអាចមើលឃើញនូវទិដ្ឋភាពផ្សារធំ (ផ្សារថ្មីមើលពីលើយន្តហោះ) (រូបទី១៩) ឋិតក្នុងសង្កាត់ផ្សារថ្មី (បច្ចុប្បន្ន)។ ផ្លូវទាំងឡាយដែលនៅជុំវិញផ្សារមានទម្រង់ជាធរណីមាត្រ។ អ្នករៀបចំក្រុងបានយកផ្សារធំថ្មីជាចំណុចកណ្តាល និងមានផ្លូវប្រសព្វដល់ទៅប្រាំបី។ ផ្លូវទាំងនេះបានកសាងឡើងនៅឆ្នាំ ១៩៤៦។ តាមឯកសារ[១៣] លោក Ernest Hebrard ជាជនជាតិបារាំង និងជាប្រធានផ្នែកខាងរៀបចំក្រុង (Service Urbaniste) ប្រចាំនៅតំបន់ឥណ្ឌូចិន បានបញ្ជាក់ឱ្យដឹងថា **នគរូបនីយកម្ម** បានចាប់ផ្តើមកើតឡើងនៅឆ្នាំ១៩២៥។

តាមរយៈរូបនេះ ក្រុងភ្នំពេញនៅឆ្នាំ១៩៤៦ មានខ្សែក្រវាត់ទីក្រុងនៅតូចនៅឡើយ។

---

[១៣] - Michel Igout " Phnom Penh d'Hier à Aujourd'hui "1993.



www.elibraryofcambodia.org

**រូបទី១៩ :** ទិដ្ឋភាពផ្សារធំ ( ផ្សារថ្មី) ឋិតក្នុងសង្កាត់ផ្សារថ្មី



ក្រោយឆ្នាំ១៩៥៣ ពេលដែលព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យពេញលេញពីសាធារណរដ្ឋបារាំង នោះទីក្រុងភ្នំពេញចាប់ផ្តើមមានកំណើនប្រជាជនដែលអាចបង្ហាញពីចលនាផ្លាស់ទីលំនៅចូលមករស់នៅក្នុងទីក្រុង។ ទោះបីជានៅទសវត្សឆ្នាំទី៦០ រាជធានីភ្នំពេញមានទំហំតូចក៏ដោយ តែការអភិវឌ្ឍបានបោះជំហានទៅមុខយ៉ាងលឿន មុខមាត់ទីក្រុងមានការផ្លាស់ប្តូរ ធ្វើឱ្យទីក្រុងភ្នំពេញមានឈ្មោះបោះសម្លេងក្លាយជា "**ទីក្រុងគុជ**" និងជាប្រទេសដែលមានឈ្មោះថា "**កោះសន្តិភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍**"។

ក្រោយពេលរំដោះពីរបបប៉ុលពត ជាបណ្តើរៗចំនួនប្រជាជនក្រុងភ្នំពេញមានការកើនឡើងជាបន្តបន្ទាប់ ចំនួនប្រជាជនក្រុងភ្នំពេញពីឆ្នាំ១៩៨០ មាន ១១២ ៩៦៥ នាក់ មកដល់ឆ្នាំ១៩៩៨ មាន ៩៩៩៨០៤ នាក់ បើធ្វើការប្រៀបធៀបរវាង



www.elibraryofcambodia.org

ចន្លោះឆ្នាំទាំងពីរ ចំនួនប្រជាជនក្រុងភ្នំពេញបានកើនឡើងដល់ទៅជិត៩ដង។ នោះគឺជាកំណើនមួយ ដែលបានកើនយ៉ាងលឿននៅចន្លោះឆ្នាំទាំងពីរ។ នៅឆ្នាំ២០០៨ ប្រជាជនរាជធានីភ្នំពេញមានចំនួនមួយលានបីសែននាក់ (១៣២៥៦៨១)[១៤] បើរាប់ទាំងអ្នកដែលមករស់នៅមិនបានចុះឈ្មោះក្នុងបញ្ជីពិតប្រាកដផង នោះចំនួនប្រជាជនមានការកើនឡើងលើសពីនេះអាចដល់ទៅ (១.៥លាននាក់)។

នគរូបនីយកម្មមានល្បឿនកាន់តែលឿនឡើង។ ភ្នំពេញមានលទ្ធភាពក្នុងការអភិវឌ្ឍក្រោយពីការរស់រានមានជីវិតឡើងវិញជាលើកទី២។ ភ្នំពេញដែលកើតពីទីក្រុងខ្មោចនោះបានរស់ឡើងវិញ ដោយមានការខិតខំស្តារ និងកសាងឡើងវិញជាបន្តបន្ទាប់ ធ្វើឱ្យទីក្រុងនេះ នៅតែជាទីក្រុងសំខាន់មួយរបស់ប្រទេស មានការទាក់ទាញសម្រាប់ភ្ញៀវទេសចរ និងបានក្លាយជាទីក្រុងដ៏អស្ចារ្យមួយនៅសតវត្សទី២១ ដោយបានជាប់ចំណាត់លេខ១លើពិភពលោកលើប្រធានបទ "**ការរៀបចំស្តារទីក្រុងឡើងវិញ**" នៅឆ្នាំ២០០៥។

ដោយសារល្បឿននៃនគរូបនីយកម្ម ក្រុងភ្នំពេញមានដំណើរឈានឡើង និងអភិវឌ្ឍជានិច្ច (រូបទី ២០)។

---

[១៤] - ជំរឿនប្រជារាស្ត្រ ឆ្នាំ២០០៨។



www.elibraryofcambodia.org

## រូបទី២០: នគរូបនីយកម្មនៅទីក្រុងភ្នំពេញ ទិដ្ឋភាពមើលពីលើយន្តហោះ តំបន់ផ្សារធំថ្មី ដែលមានការអភិវឌ្ឍ ដែលធ្វើឱ្យតំបន់ជាយក្រុងក្លាយជាទីក្រុងថ្មីជាបន្តបន្ទាប់



ប្រភព: នៅឆ្នាំ ២០០៧ Phnom Penh d'hier à Aujourd'hui (SIRPA/ECP Armées-France) ឆ្នាំ១៩៩២ ទំព័រ១៧៧

## រូបទី៦-ការវិវត្តប្រជាជនរាជធានីភ្នំពេញពីឆ្នាំ ១៨៦៥ ដល់ឆ្នាំ ២០០៨ (ន.)

| ឆ្នាំ | ១៨៦៥ | ១៨៧៥ | ១៨៩៧ | ១៩០៨ | ១៩៣៩ | ១៩៤២ |
|---|---|---|---|---|---|---|
| ប្រជ. | ១០០០០ | ៣០០០០ | ៥០០០០ | ៦៥០០០ | ១០៨០០០ | ១១១០០០ |
| ឆ្នាំ | ១៩៤៨ | ១៩៥០ | ១៩៥៨ | ១៩៦២ | ១៩៨០ | ១៩៨៥ |
| ប្រជ. | ១១០ ០០០ | ៣៣៤ ០០០ | ៣៥៥ ០០០ | ៣៩៤ ០០០ | ១១២ ៥៦៥ | ៤២៧ ០០០ |



www.elibraryofcambodia.org

| ឆ្នាំ | ១៩៩០ | ១៩៩៦ | ១៩៩៨ | ២០០៨ |
|---|---|---|---|---|
| ប្រជ. | ៦១៤ ៩៨៤ | ៩០០ ០០០ | ៩៩៩ ៨០៤ | ១ ៣២៥ ៦៨១ |

**ប្រភព:** ទិន្នន័យបានពីសាលារាជធានីភ្នំពេញ និងជំរឿនឆ្នាំ ១៩៩៨

**ក្រាភិចទី១:** ការវិវត្តប្រជាជនរាជធានីភ្នំពេញពីឆ្នាំ១៨៦៥ ដល់ឆ្នាំ២០០០ (នាក់)




ការកើនឡើងនៃចំនួនប្រជាជននិងនគរូបនីយកម្ម បានធ្វើឱ្យភ្នំពេញមានការអភិវឌ្ឍមិនឈប់ឈរ។ សំណង់ស្ថាបត្យកម្មរីកដុះដាល និងពង្រីកខ្លួនឆ្ពោះទៅតំបន់ក្រៅក្រុង។ នៅឆ្នាំ២០១០ ក្រុងភ្នំពេញមានផ្ទៃដីកើនឡើងដល់ទៅ៦៧៨,៧គីឡូ-ម៉ែត្រការ៉េ និងបានស្រូបយកតំបន់ជុំវិញ ដែលឋិតនៅក្នុងខេត្តកណ្ដាល។



www.elibraryofcambodia.org

រូបទី២១:ផែនទីរាជធានីភ្នំពេញឆ្នាំ២០១០



- **Citizen:** 1.325.681 people



www.elibraryofcambodia.org

**រូបទី២២:** ក្រុងភ្នំពេញ និងគំរោងអភិវឌ្ឍន៍ដែលបាន
និងកំពុងដំណើរការបច្ចុប្បន្ន(២០១០)






www.elibraryofcambodia.org

# ជំពូក៣

# ទំនាក់ទំនងរវាងដំណើរនគរូបនីយកម្ម និងចលនាផ្លាស់ទី តាមព្រឹត្តិការណ៍ធំៗនៅកម្ពុជា

## ១-ចលនាផ្លាស់ទីមកទីក្រុងភ្នំពេញឬមកតំបន់ចតុមុខ (សតវត្សទី១៥ មកសតវត្សទី២០)

នៅសម័យអង្គរដ៏រុងរឿង អាណាចក្រខ្មែរមានក្រុងអង្គរជារាជធានី និងមានប្រជាជនប្រមាណជាជាង ១០ លាននាក់ ដូចជាមានបន្សល់ទុកនូវប្រាង្គប្រាសាទជាច្រើនល្បីៗលើលោក។ ដោយឡែកនៅពេលនោះ ទីក្រុងអង្គរមានប្រជាជនរស់នៅប្រមាណជា១លាននាក់។ តែក្នុងរយៈពេលមានសង្គ្រាមឈ្លានពានពីប្រទេសសៀមបានធ្វើឱ្យប្រជាជនទីក្រុងអង្គរ ក៏ដូចជាប្រជាជននៅតំបន់ភាគពាយ័ព្យនិងខាងជើងត្រូវធ្វើចលនាផ្លាស់ទីលំនៅមកភូមិភាគខាងត្បូងប្រទេសកម្ពុជា រហូតមកដល់បច្ចុប្បន្ន។

ក្រោយសម័យអង្គររហូតមកដល់ឆ្នាំ១៨៦៥ ប្រជាជនរាជធានីភ្នំពេញពេលនោះ មិនដឹងមានចំនួនប៉ុន្មានឡើយ ព្រោះគ្មានឯកសារណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនប្រជាជនទេ តែគេអាចសន្និដ្ឋានបានថា រាជធានីភ្នំពេញនៅសម័យកាលនោះ ប្រជាជនពិតជាពុំទាន់មានការប្រមូលផ្តុំជាទ្រង់ទ្រាយធំដុំនៅឡើយ ព្រោះការលើករាជធានីចុះឡើងច្រើនលើកច្រើនសារដែលកើតបានពីការប្តូរទីតាំងរាជវាំងជាញឹកញាប់ ដោយសារសង្គ្រាមឈ្លានពានពីប្រទេសជិតខាង និងការ



www.elibraryofcambodia.org

ច្បាំងដណ្តើមរាជ្យក្នុងត្រកូលក្សត្រខ្លួនឯង  ក៏ដូចជាការជ្រើសរើសទីតាំងធ្វើជារាជធានី មានទួលបាសាន ពោធិសាត់ លង្វែក ល្វាឯម ឧដុង្គ[១៥] បានធ្វើឱ្យប្រជាជនមានការលំបាក  និងនាំមកនូវភាពនឿយហត់ក្នុងការផ្លាស់ទីលំនៅ  ព្រោះមធ្យោបាយដឹកជញ្ជូនគ្មានអ្វីក្រៅពីរទេះគោ រទេះសេះ ដំរី ឬការដឹកជញ្ជូនតាមផ្លូវទឹក មានទូកនោះឡើយ ។ នៅឆ្នាំ១៨៦៥  គឺជាឆ្នាំដែលរាជធានីត្រូវបានផ្លាស់ពីឧដុង្គមកភ្នំពេញវិញ។  បើប្រៀបធៀបនឹងតំបន់ផ្សេងទៀតទូទាំងប្រទេស  និងដោយគិតទាំងចំនួនប្រជាជននៅសម័យកាលនោះផង  យើងអាចសន្និដ្ឋានបានថា  តំបន់វាលរាប  ដែលមានក្រុងភ្នំពេញជារាជធានីមួយផងនោះ  ពិតជាមានប្រជាជនរស់នៅច្រើនជាងគេហើយកត្តានេះទាក់ទងទៅនឹងលក្ខខ័ណ្ឌប្រវត្តិសាស្ត្រ  លក្ខខ័ណ្ឌធម្មជាតិ  សេដ្ឋកិច្ចសង្គម និងសន្តិសុខ ។ នៅឆ្នាំ១៨៦៥ ជាពេលដែលប្រទេសកម្ពុជា ទើបបានចុះសន្ធិ-សញ្ញាឋិតក្រោមអាណាព្យាបាលបារាំង  (១៨៦៣)  ភ្នំពេញមានប្រជាជនរស់នៅមិនលើសពី១០០០០នាក់ឡើយ[១៦] ហើយភាគច្រើនប្រជាជនទាំងនោះ តែងប្រមូលផ្តុំរស់នៅតាមត្រើយខាងលិចនៃដងទន្លេសាប ។ មុនឆ្នាំ១៩៥៣  ពេលដែលប្រទេសកម្ពុជា  ពុំទាន់ទទួលបានឯករាជ្យពីប្រទេសបារាំង  ការកើនឡើងនៃចំនួនប្រជាជនរាជធានីភ្នំពេញ  មានល្បឿនលឿនគួរឱ្យកត់សម្គាល់  គឺក្នុងរយៈពេល១០ឆ្នាំ  ពីឆ្នាំ១៨៦៥ ដល់ឆ្នាំ១៨៧៥  ប្រជាជនក្រុងភ្នំពេញបានកើនឡើង ដល់ទៅ៣ដង ។ ការ

---

[១៥] - សាលាក្រុងភ្នំពេញ (ខែមិនា ១៩៩៨) "ប្រវត្តិរាជធានីភ្នំពេញ" ទំព័រ១១ ។ តែទោះបីជាយ៉ាណាក្តី ក្រៅពីរាជធានីអង្គរ ឬក្រុងអង្គ និងរាជធានីភ្នំពេញ ឬក្រុងភ្នំពេញនេះ ពុំមានរាជធានីណាមួយដែលមានអាយុយូរឡើយ  ព្រោះទីតាំងនៃរាជធានីទាំងនោះមានរយៈពេលខ្លី  និងត្រូវទទួលរងនូវការវាយលុកពីសត្រូវសៀមឈ្លានពាន  មានដូចជាទីក្រុងលង្វែកជាដើម  ហើយទីតាំងទាំងនោះ  មិនមានលក្ខណៈយុទ្ធសាស្ត្រ  សម្រាប់បម្រើឱ្យការអភិវឌ្ឍប្រទេសក៏ដូចជាសេដ្ឋកិច្ច និងកិច្ចការពារប្រទេសផងដែរ ។

[១៦] - Jacques Migozzi, (1973). "Cambodge, faits et problémes de la population ", page24.



www.elibraryofcambodia.org

កើនឡើងនៃចំនួនប្រជាជនទីក្រុងភ្នំពេញ គឺកើតបានពីចលនាបម្លាស់ទីលំនៅចូលច្រើនជាងអត្រាកំណើនធម្មជាតិ និងបានតម្រូវឱ្យរាជធានីត្រូវពង្រីកផ្ទៃដីជាបន្តបន្ទាប់។ នៅចន្លោះឆ្នាំ១៩០៨ ដល់ឆ្នាំ១៩៣៩ ក្នុងរយៈពេល៣១ឆ្នាំ ប្រជាជនកម្ពុជាមានការកើនឡើង២,៤ដង គឺដូចគ្នានឹងល្បឿននៃកំណើនប្រជាជនក្រុងភ្នំពេញឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៩៨ ដែលជាចន្លោះឆ្នាំនៃជំរឿនប្រជារាស្ត្រទាំងពីរលើកមានរយៈពេល៣៦ឆ្នាំ នោះការកើនឡើងនៃប្រជាជនមាន២,៩ដង។ ភ្នំពេញមានទិដ្ឋភាពជាទីក្រុងមួយពេញលេញ និងមានការពង្រីកក្រុងទៅទិសខាងលិចកាន់តែធំឡើងៗ ហេដ្ឋារចនាសម្ព័ន្ធមានការប្រែប្រួល ដោយត្រូវបានស្តារ និងអភិវឌ្ឍន៍ជាបន្តបន្ទាប់។ ទីក្រុងចាប់ពង្រីក និងរីកចម្រើននៅចុងសតវត្សទី១៩រហូតដល់ចុងសតវត្សទី២០។ ពេលនោះបរិវេណទីក្រុងភ្នំពេញនៅមានភូមិខ្លះៗនៅឡើយ (ដូចជាភូមិវៀតណាមនៅខាងកើតបឹងតេជោ ត្រង់ផ្សារថ្មី) ភូមិថ្មីរបស់ប្រជាជននៅប៉ែកខាងលិចទីក្រុង (មហាវិថីព្រះមុនីវង្សសព្វថ្ងៃ) ភូមិអូរឫស្សី ភូមិអណ្តូងប្រេង (ឈ្មោះភូមិនេះបច្ចុប្បន្នហាក់ដូចជាគ្មានអ្នកនឹកដល់ដែលត្រូវហៅ)។ ភាគខាងត្បូងទីក្រុងឋិតនៅដដែលពុំមានការប្រែប្រួលទេ។ ក្រោយពីការកសាងផ្លូវជាតិលេខ១ បានធ្វើឱ្យតំបន់ជាយក្រុងភាគខាងត្បូងទីក្រុងក្លាយទៅជាទីក្រុង។ នៅឆ្នាំ១៩៤២ ការរីកឡើងនៃទីក្រុងពុំមានការប្រែប្រួលទេ ហើយដំណើរនគរូបនីយកម្មបានប្រព្រឹត្តទៅយ៉ាងយឺតៗ លើកលែងតែតំបន់ភាគខាងលិចទីក្រុង ដែលមានប្រជាជនរស់នៅកាន់តែច្រើន ដូចជាភូមិបាក់ទូក (ម្តីវិទ្យាល័យបាក់ទូកបច្ចុប្បន្ន)។ មកដល់ឆ្នាំ១៩៥៨ សន្ទុះនៃការរីកឡើងរបស់ទីក្រុង មានល្បឿនលឿនជាងពេលណាៗទាំងអស់ ហើយលាតសន្ធឹងទៅគ្រប់ទិសទី លើកលែងតែតំបន់ភាគខាងកើតទីក្រុង ដែលឋិតជាប់នឹងទន្លេចតុមុខ។ ដោយឡែកមានការពង្រីកទីក្រុង



www.elibraryofcambodia.org

ថ្មីៗទៀត ដូចជានៅទួលគោក (តំបន់ពាយ័ព្យទីក្រុង) តំបន់ទឹកល្អក់ តំបន់ទួលស្វាយព្រៃ ទួលស្លែង (នៅទិសខាងលិច និងនិរតី)។ នៅតាមសង្កាត់ចាស់ៗ មានការពង្រីកសង្កាត់ឆ្ពោះទៅទិសខាងលិច ដូចជាសង្កាត់ឫស្សីកែវ។ ចន្លោះទសវត្សឆ្នាំទី៥០ និងឆ្នាំ៦០ ទីក្រុងភ្នំពេញបានក្លាយជារាជធានី និងជាទីក្រុងតូចមួយប្រកបដោយសោភ័ណភាពល្អ ជាទីក្រុងមួយដែលមានការកោតសរសើរពីបណ្ដាប្រទេសជិតខាងក្នុងតំបន់។ នៅភាគខាងត្បូងទីក្រុង មានការសាងសង់ជារោងចក្រ និងសិប្បកម្មនានា ដែលធ្វើឱ្យតំបន់នោះ ក្លាយជាសង្កាត់ឧស្សាហកម្មរបស់ក្រុង តែជាតំបន់ឧស្សាហកម្មធុនស្រាល និងសិប្បកម្ម។

## ២-នគរូបនីយកម្មនៅកម្ពុជា និងទីក្រុងភ្នំពេញចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧០ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩

### ២.១- នគរូបនីយកម្មកើតចេញពីចលនាផ្លាស់ទី ចាប់ពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០(ថ្ងៃរដ្ឋប្រហារ)

ថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ដែលជាថ្ងៃរដ្ឋប្រហារទម្លាក់របបរាជានិយមដោយពួកសេរីនិយមដឹកនាំដោយសេនាប្រមុខលន់នល់។ នោះគឺការផ្លាស់ប្ដូររបបនយោបាយ ពីរបបរាជានិយមមកជារបបសាធារណរដ្ឋ ដែលមានឈ្មោះថា សាធារណរដ្ឋខ្មែរ។ កត្តានេះបានបង្កឱ្យព្រះរាជាណាចក្រកម្ពុជាមានសង្គ្រាមស៊ីវិលកើតឡើង ដែលធ្វើឱ្យទីក្រុងភ្នំពេញក៏ដូចជាទីរួមខេត្តក្រុង ឬទីប្រជុំជនទូទាំងប្រទេសមានការជ្រួលច្របល់ និងមានការកើនឡើងនូវចំនួនជនភៀសសឹកដែលជាលទ្ធផលនៃសង្គ្រាមប្រយុទ្ធគ្នា រវាងពួកលន់ណុល (និន្នាការសេរីនិយម) និងមានសម្ព័ន្ធ



www.elibraryofcambodia.org

ភាពជាមួយពួកសហរដ្ឋអាមេរិក និងពួកធីវតី (សាធារណរដ្ឋវៀតណាម ឬវៀតណាមភាគខាងត្បូង)។

ពីមួយថ្ងៃទៅមួយថ្ងៃ នៅគ្រប់សមរភូមិតាមទីរួមខេត្ត ក៏ដូចជានៅទីក្រុងភ្នំពេញ ស្នូរគ្រាប់កាំភ្លើងធំ គ្រាប់ផ្លោងឮនៅជិតបង្កើយ ខ្សែក្រវ៉ាត់ទីក្រុងភ្នំពេញពីមួយថ្ងៃទៅមួយថ្ងៃកាន់តែរួញទៅៗ។ តំបន់សេដ្ឋកិច្ចសំខាន់ៗ ដែលជាជង្ហើមរស់សម្រាប់អ្នកក្រុងភ្នំពេញត្រូវបានកាត់ផ្ដាច់។ អ្នកក្រុងភ្នំពេញរស់ដោយសារជំនួយដឹកមកទម្លាក់តាមយន្តហោះ ដែលដឹកដោយទ័ពលន់នល់ផ្ដល់ដោយសហរដ្ឋអាមេរិក ជាពិសេសគឺអង្ករ។ នៅទូទាំងប្រទេសក្រៅពីទីក្រុងភ្នំពេញ តំបន់ក្បែរៗក្រុងនិងទីរួមខេត្តនានា ត្រូវបានធ្លាក់ក្នុងតំបន់រំដោះ ដូចនេះជង្ហើមសេដ្ឋកិច្ច ដែលជាក្ដីសង្ឃឹមរបស់ទីក្រុងភ្នំពេញមានតិចណាស់។ ចាប់ពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ មកទល់នឹងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលមានរយៈពេល ៥ ឆ្នាំ ប្រជាជនកម្ពុជាត្រូវរស់នៅក្រោមការរត់គេចពីគ្រាប់រំសេវ គ្រាប់កាំភ្លើង គ្រាប់ផ្លោង គ្រាប់បែកណាប៉ាល់ គ្រាប់បែកបេ៥២ ដែលពួកអាមេរិក និងពួកលន់នល់ យកមកទម្លាក់លើប្រជាជនខ្មែរ ដែលជាជនស្លូតត្រង់គ្មានកំហុស ស្លាប់អស់ជាច្រើន និងព្រាត់ប្រាស់បងប្អូនកូនចៅ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការរស់នៅរបស់ប្រជាជនទូទាំងប្រទេស ពិតជាមិនសុខស្រួលឡើយ សង្គ្រាមបានកាត់ផ្ដាច់រវាងតំបន់ក្រុង និងតំបន់ជនបទ ដែលជាប្រភពនៃការផលិតនូវផលិតផលកសិកម្ម ជាពិសេសដំណាំស្បៀងដូចជាស្រូវ ពោត សណ្ដែក ល្ង។ល។

ភាពវឹកវរនេះបានធ្វើឱ្យប្រជាជន ដែលមិនធ្លាប់ស្គាល់សង្គ្រាម មិនធ្លាប់ឮស្នូរគ្រាប់កាំភ្លើងភ័យតក់ស្លុតនាំគ្នាភៀសខ្លួនរត់ចូលក្រុងរកសេចក្ដីសុខ គេចចេញពីតំ



www.elibraryofcambodia.org

បន់ប្រយុទ្ធ គេចពីការស្លាប់ និងបានធ្វើឱ្យរាជធានីភ្នំពេញ ក៏ដូចជាតំបន់ជុំវិញ មានទីរួមខេត្តកណ្តាល (ទីប្រជុំជនតាខ្មៅ) ជាដើម ចំនួនប្រជាជនបានកើនឡើងយ៉ាងលឿនប្រមាណជាពី ២០០០០០០ នាក់ទៅ ៣០០០០០០ នាក់ [១៧]។ តែបើតាមឯកសារបោះពុម្ពផ្សាយរបស់លោក Jacques Migozzi (1973) [១៨] វិញ លោកបានបង្ហាញថា ភ្នំពេញនៅឆ្នាំ១៩៦៨ មានប្រជាជនប្រមាណជា ៦០០០០០ នាក់ប៉ុណ្ណោះ តែចាប់ពីថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧២ ចំនួនប្រជាជនបានកើនឡើងប្រមាណជា ១៩០០០០០ នាក់។ ការកើនឡើងនៃចំនួនប្រជាជននាពេលនោះ គឺជាការកើនឡើងនៃចំនួនប្រជាជន ដែលកើតបានពីការធ្វើចលនាផ្លាស់ទីពីទីជនបទ ចូលមករស់នៅក្នុងទីក្រុង។

អត្រានគរូបនីយកម្មនៅឆ្នាំ១៩៦២ ពេលធ្វើជំរឿនប្រជារាស្ត្រមានតែ ១០ ភាគរយប៉ុណ្ណោះ ល្បឿននគរូបនីយកម្មបានឋិតក្នុងលំដាប់ទាប។ តែល្បឿននគរូបនីយកម្មចាប់ពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៧០ ក៏មិនទាន់មានការវាយតម្លៃឱ្យបានត្រឹមត្រូវដែរ ព្រោះប្រទេសកម្ពុជានៅសម័យកាលនោះ ប្រជាជនភាគច្រើនរស់នៅទីជនបទ ហើយកម្ពុជាជាប្រទេសកសិកម្ម ដែលមានចលនាផ្លាស់ទីលំនៅចូលទីក្រុងគ្មានអ្វីគួរឱ្យកត់សម្គាល់ឡើយ។

ចាប់ពីពេលដែលប្រទេសកម្ពុជាមានរដ្ឋប្រហារ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភ្លក់ភ្លើងសង្គ្រាមស៊ីវិល ពេលនេះហើយដែលដំណើរនគរូបនីយកម្មនៅកម្ពុជាមានការប្រែប្រួល ជាពិសេសនៅដើមឆ្នាំ១៩៧២ នគរូបនីយកម្មមានអត្រាពី ២០ ភាគរយទៅ ២៥ ភាគរយនៃប្រជាជនកម្ពុជាទូទាំងប្រទេស។ ទោះបីជាប្រទេស

---

[១៧] - ការិយាល័យស្ថិតិរាជធានីភ្នំពេញ (ឆ្នាំ២០០០) របាយការណ៍ស្ថានភាពការងារអនុវត្តប្រចាំឆ្នាំរាជធានីភ្នំពេញ។

[១៨] - Jacques Migozzi (1973): Cambodge faits et problémes de population.



www.elibraryofcambodia.org

កម្ពុជា មានទគរូបនីយកម្មកើនឡើងយ៉ាងឆាប់បំផុត និងមានល្បឿនលឿនបែបនេះក៏ដោយ តែបើប្រៀបទៅនឹងនគរូបនីយកម្មនៅសាធារណរដ្ឋវៀតណាម (វៀតណាមភាគខាងត្បូង [១៩] វិញនោះ អត្រានគរូបនីយកម្មនៅប្រទេសកម្ពុជានៅតែទាបជាង ព្រោះនៅវៀតណាមភាគខាងត្បូងមានចលនាតស៊ូរំដោះប្រទេស ដើម្បីរំលំរបបធីវ៉តី កំពុងមានសន្ទុះខ្លាំងក្លា ដែលបណ្តាលឱ្យមានចលនាជនភៀសខ្លួនយ៉ាងច្រើន ចូលមករស់នៅក្នុងទីក្រុងព្រៃនគរ ឬទីក្រុងសាយហ្គន ឬទីក្រុងហូជីមិញ និងទីប្រជុំជននានាយ៉ាងគំហុក។

នៅតាមទីប្រជុំជននៃទីរួមខេត្តធំៗ មានខេត្តបាត់ដំបង ខេត្តកំពង់ចាម ក្រុងព្រះសីហនុ (បច្ចុប្បន្នខេត្តព្រះសីហនុ)... ចលនាជនភៀសខ្លួនប្រមូលផ្តុំរស់នៅយ៉ាងកុះករ។ ចំពោះទីរួមខេត្តកណ្តាលមានក្រុងតាខ្មៅ បានពង្រីកខ្លួនមកភ្ជាប់នឹងទីក្រុងភ្នំពេញ។ នគរូបនីយកម្មមានល្បឿនលឿន ទន្ទឹមនឹងចលនាបម្លាស់ទីពីជនបទចូលមកទីក្រុង និងតំបន់ជុំវិញ ហើយរីករាលដាលដល់តំបន់ជាយក្រុង ក្នុងរយៈពេលដ៏ខ្លី ដោយបានបង្ករនូវបញ្ហាសង្គមយ៉ាងធ្ងន់ធ្ងរដូចជាបញ្ហាសន្តិសុខ បញ្ហាខ្វះជំរកបញ្ហាទឹក បញ្ហាភ្លើង និងបញ្ហាស្បៀង... ព្រោះទីក្រុងមិនអាចបំពេញតាមតម្រូវការបានឡើយ។

តាមលំនៅឋានទីមួយៗ សមាជិកគ្រួសារបានកើនឡើង និងមានជនភៀសសឹកមកស្នាក់នៅតាមដងផ្លូវ បង្កើតបានជាតំបន់អនាធិបតេយ្យទាំងក្នុងក្រុង និងតំបន់ជាយក្រុង។ ទីក្រុងត្រូវបានហ៊ុំព័ទ្ធ ធ្វើឱ្យប្រជាជនរស់នៅលំបាកយ៉ាងក្រៃលែង។

---

[១៩] - តាមរយៈទស្សនាវដ្តីលេខពិសេស "la revue Tiers-Monde" (Le Vietnam entre la guerre et la paix) Tome XI n° 42-43, avril-septembre 1970.



www.elibraryofcambodia.org

តាមរយៈការសិក្សាបានបង្ហាញឱ្យឃើញពីដំណើរនគរូបនីយកម្ម បានផ្សារភ្ជាប់ទៅនឹងស្ថានភាពនយោបាយរបស់ប្រទេស ។ ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខប្រទេស បញ្ហាសង្គមក៏បានកើតឡើងដែរ ដោយរួមជាមួយនឹងបញ្ហាសេដ្ឋកិច្ចគ្រួសារ ក៏ដូចជា បញ្ហាសេដ្ឋកិច្ចជាតិ ដែលមិនអាចស្រោចស្រង់បាន រហូតដល់ថ្ងៃដែលរបបសាធារណរដ្ឋខ្មែរ ត្រូវបានដួលរលំ និងធ្លាក់ទៅក្នុងកណ្តាប់ដៃចលនារំដោះជាតិ ដែលមានទិន្នាការទៅរកលោកខាងកើតគឺរបបកុម្មុយនិស្ត ។ តាមរយៈរូបទី១៩ និង រូបទី២០ យើងអាចមើលឃើញច្បាស់ពីចលនាប្រជាជន ដែលធ្វើដំណើរចាកចេញពីតំបន់ជនបទនៅតាមខេត្តក្រុងទូទាំងប្រទេស ចូលមកក្រុងភ្នំពេញឬចូលមករស់នៅតាមតំបន់ទីប្រជុំជន ដើម្បីភៀសខ្លួនគេចចេញពីតំបន់ប្រយុទ្ធ ដែលកើតចេញពីការវាយប្រហារគ្នា រវាងកងទ័ពលន់នល់គាំទ្រដោយសហរដ្ឋអាមេរិក និងចលនានៃកងទ័ពរំដោះជាតិ ។

ទោះបីជីវភាព នៅទីក្រុងមិនមានលក្ខណៈងាយស្រួលយ៉ាងណាក្តី តែដើម្បីជីវិតគេចឱ្យផុតពីគ្រោះថ្នាក់ ប្រជាជនត្រូវតែចូលមកជ្រកកោននៅក្នុងតំបន់ដែលមានសុវត្ថិភាពនេះសិន ដោយរង់ចាំពេលវេលាណាប្រទេសមានសន្តិភាព ពួកគេនឹងវិលត្រឡប់ទៅរស់នៅភូមិកំណើតវិញ។ ករណីនេះ បានកើតមានចំពោះប្រជាជនគ្រប់រូប។ វត្តអារាមដែលជាទីសក្ការៈ បានក្លាយជាជំរកសម្រាប់ជនភៀសខ្លួន និងជាទីតាំងកងទ័ពលន់នល់ផងដែរ។ ជនភៀសខ្លួនប្រមូលផ្តុំនៅតាមដងផ្លូវ និងតំបន់នានាដូចជាក្នុងវត្តអារាម ក្រោមស្ពាន ជាពិសេសទីណាដែលមានដីទំនេរលើដីរដ្ឋ និងដីឯកជន មានជនភៀសខ្លួនស្នាក់នៅពាសពេញ។ តាមលំនៅឋាននីមួយៗ



www.elibraryofcambodia.org

សមាជិកគ្រួសារបានកើនឡើង ដោយមានការចែករំលែកទីកន្លែងស្នាក់នៅ ព្រោះពួកគេជាសាច់ញាតិសន្តានមកពីខេត្តនានា។

វិស័យអប់រំនិងសិក្សាត្រូវធ្លាក់ចុះ។ សាលារៀនត្រូវបានចែករំលែកវេនគ្នាទៅតាមពេលវេលាជាបីពេល ដើម្បីបំពេញដល់តម្រូវការសិក្សារបស់កូនចៅ ជនភៀសសឹកដែលឋិតក្នុងវ័យសិក្សា ព្រោះនៅទីជនបទដែលជាទីប្រយុទ្ធ សាលារៀនត្រូវបិទទ្វារ។ ចំពោះប្រជាពលរដ្ឋ ដែលមានលទ្ធភាពទោះតិចឬច្រើនក្តី ត្រូវតែបង្ខំចិត្តបញ្ជូនកូនចៅរបស់ពួកគាត់ ឱ្យបានមករៀនសូត្រនៅភ្នំពេញ ឬទីប្រជុំជនខេត្តនានា។ តែចំពោះប្រជាពលរដ្ឋ ដែលគ្មានលទ្ធភាពមករស់នៅទីក្រុងបាន នោះពួកគាត់ត្រូវតែស៊ូទ្រាំរស់នៅទីជនបទ ទោះបីកូនចៅរបស់គាត់កំពុងឋិតនៅក្នុងវ័យសិក្សាក៏ដោយ។

ក្នុងពេលដែលប្រទេសកំពុងឋិតក្នុងសង្គ្រាម សាលាក្រុងគ្មានផែនការដើម្បីអភិវឌ្ឍទីក្រុង ឬរៀបចំក្រុងឡើយ។ សោភ័ណភាពទីក្រុងត្រូវធ្លាក់ចុះ ពិសេសពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន។ ក្បាលម៉ាស៊ីនរដ្ឋដឹកនាំដោយពួកសាធារណរដ្ឋខ្មែរ មិនបានគិតគូរអ្វីក្រៅពីធ្វើយ៉ាងណាដើម្បីទប់ទល់នឹងសង្គ្រាម ដែលមានស្ថានភាពពីមួយថ្ងៃទៅមួយថ្ងៃកាន់តែយ៉ាប់ទៅៗ។ បើពិនិត្យលើផ្នែកចិត្តសាស្ត្រវិញ ប្រជាពលរដ្ឋជិនណាយធុញថប់នឹងសង្គ្រាមស៊ីវិលនេះ ម្នាក់ៗរវល់តែពីបញ្ហាក្រពះ ធ្វើយ៉ាងណាដើម្បីមានជីវិតរស់នៅ និងរង់ចាំថ្ងៃបានវិលត្រឡប់ទៅរស់នៅស្រុកកំណើតវិញ។



www.elibraryofcambodia.org

**រូបទី២៣ និង២៤:** ចលនាជនភៀសខ្លួនចូលមករស់នៅក្នុងទីក្រុងភ្នំពេញ





**ប្រភព:** Jacques Migozzi CAMBODGE faits et problèmes de population

ប្រជាពលរដ្ឋក្នុងទីក្រុងក៏ដូចជាតំបន់ជាយក្រុង ខ្វល់ខ្វាយនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ ឋិតក្នុងស្ថានភាពរីករាលបែបនេះ ទំនិញឡើងថ្លៃ រដ្ឋមិនអាចគ្រប់គ្រងតម្លៃបាន ព្រោះសមរភូមិក្រោយត្រូវកាត់ផ្តាច់ចេញពីសមរភូមិមុខ ដែលសង្រ្គាមនេះ ធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោក លន់ នល់ រង់ចាំតែថ្ងៃបរាជ័យ។



www.elibraryofcambodia.org

ដូចនេះប្រជាជនកម្ពុជាគឺជាអ្នករងគ្រោះពិតប្រាកដ ព្រោះមួយថ្ងៃៗ គ្រាប់បែករបស់សហរដ្ឋអាមេរិក បានទម្លាក់ស្រោចស្រពមកលើតំបន់នានាក្នុងប្រទេសកម្ពុជា និងបានសម្លាប់ប្រជាជនស្លូតត្រង់ ដែលគ្មានកំហុសទាល់តែសោះ បំផ្លាញទាំងធនធានធម្មជាតិមានសត្វរុក្ខជាតិដូចជាចំការកៅស៊ូ ព្រៃឈើ ត្រូវឆេះខ្លោចបំផ្លាញទាំងដំណាំដាំដុះនានា ធ្វើឱ្យវិស័យកសិកម្មធ្លាក់ដល់កម្រិតសូន្យ ។

**ផែនទី ទី ១:** ចលនាផ្លាស់ទីចូលក្រុងភ្នំពេញ និង ទីប្រជុំជនតាមខេត្តក្រុងនានាក្នុងទូទាំងប្រទេស






www.elibraryofcambodia.org

**រូបទី២៥ ទី២៦ :** ទីក្រុងភ្នំពេញពេលមានសង្គ្រាម និងទម្រង់ប្រជាជនក្មេង





**ប្រភព:** Jacques Migozzi CAMBODGE faits et problèmes de Population



www.elibraryofcambodia.org

រូបទី២៥ និង២៦ បង្ហាញពីប្រជាជនដែលកំពុងរស់នៅក្នុងទីក្រុងភ្នំពេញ ពេលសង្គ្រាម ដែលទិដ្ឋភាពនេះ បង្ហាញពីទម្រង់ប្រជាជនក្មេង (ឋិតក្នុងអាយុក្រោមម្ភៃឆ្នាំ) ។ នេះជាបន្ទុកដ៏ធ្ងន់ធ្ងររបស់រដ្ឋាភិបាល និងជាអម្រែក ដែលរដ្ឋត្រូវគិតគូរយកចិត្តទុកដាក់ ។

## ២.២-ការរលំរលាយនគរូបនីយកម្មនៅកម្ពុជាៈទីក្រុង ទីប្រជុំជននានាក្លាយជាទីក្រុងខ្មោច

(ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩) របបសាធារណរដ្ឋខ្មែរ ដែលដឹកនាំដោយលោក លន់ ណុល ត្រូវបានផ្តួលរំលំដោយចលនាកងទ័ពរំដោះជាតិកម្ពុជានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នេះជាជោគជ័យមួយ ដែលប្រជាជនខ្មែរទូទាំងប្រទេសរង់ចាំនិងសង្ឃឹមថាសន្តិភាពបានមកដល់ហើយ ។

តែប៉ុន្មានម៉ោងក្រោយពីការដណ្តើមបានជោគជ័យ របបមួយដែលដឹកនាំដោយពួកប៉ុលពតគឺរបបកម្ពុជាប្រជាធិបតេយ្យ បានប្រែក្លាយប្រទេសកម្ពុជាទាំងមូលទៅជាវាលពិឃាតដ៏គួរឱ្យរន្ធត់ និងមានចលនាបម្លាស់ទីដោយបង្ខិតបង្ខំ ឬដោយចុងកាណុងបានកើតឡើង និងមានការបណ្តេញប្រជាជនឱ្យចាកចេញពីទីក្រុងទៅរស់នៅទីជនបទដាច់ស្រយាល ដែលគ្មានការអភិវឌ្ឍ ។ ដូចនេះភ្នំពេញបានក្លាយជាទីក្រុងខ្មោច គ្មានមនុស្សរស់នៅ និងគ្មានសកម្មភាពសេដ្ឋកិច្ចទាល់តែសោះ (មើលរូប២៧-២៨-២៩) ។



www.elibraryofcambodia.org

ក្រោមការត្រួតត្រារបស់របបប៉ុលពតរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ក្រុងភ្នំពេញមានប្រជាជនរស់នៅប្រមាណជា១០០០ទៅ២០០០នាក់ប៉ុណ្ណោះ [២០] ហើយអ្នកទាំងនោះភាគច្រើនជាពួកអង្គការ និងកងទ័ពរបស់របបប៉ុលពត។ ក្នុងរបបថ្មីនេះទីក្រុងគ្មានទៀតឡើយនៅទូទាំងប្រទេស។

ប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយបិទជិត បានសេចក្ដីថាអ្វី១ជាការរីកចម្រើនលើពិភពលោកត្រូវបានកាត់ផ្ដាច់ គ្មានទំនាក់ទំនងពីខាងក្នុងទៅខាងក្រៅ ក៏ដូចជាពីខាងក្រៅមកខាងក្នុងប្រទេស។ កម្ពុជាក្លាយជាប្រទេសឯកោ ហើយប្រជាជនដែលរស់ក្នុងរបបពួកអាវខ្មៅ គឺរស់គ្មានក្ដីសង្ឃឹមឡើយ ប្រជាជនម្នាក់ៗរស់រង់ចាំតែថ្ងៃស្លាប់ នោះគឺជាការរស់នៅក្នុងគុកឥតជញ្ជាំង។ របបនេះតម្រូវឱ្យប្រជាជនត្រូវរស់នៅធ្វើខ្វាក់ ធ្វើគ ធ្វើថ្លង់ គ្មានសើច គ្មានយំ គ្មានសិទ្ធិសេរីភាព និងមិនត្រូវការអ្នកបញ្ញវន្តឡើយ។ ប្រជាជនត្រូវស្លាប់អស់ ៣៣១៤៧៦៨ នាក់ [២១] បើគិតទូទាំងប្រទេស ដែលក្នុងនោះរួមមានកសិករ ១៩២៧០៦១ នាក់ កម្មករ រដ្ឋការ និង

---

[២០] - Francis Gendreau, (1997), " Démographic de la péninsule indochinoise ", p. 34-37.

[២១] - ទីស្ដីការ ក្រុមប្រឹក្សាទូទាំងប្រទេស រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា ភ្នំពេញ (ឆ្នាំ ១៩៨៣): មានការសម្លាប់ប្រជាជនភ្លាម១ មានបុគ្គលម្នាក់ ឬសម្លាប់ទាំងគ្រួសារ១ ឬដោយចោទថា ជាខ្មាំង ឬជាបនប្រតិកិរិយា លង់ ណាល់ ឬការស្លាប់ដោយប្រយោល ព្រោះសម័យនោះប្រជាជនត្រូវបានបង្ខំឱ្យធ្វើការធ្ងន់ធ្ងរហាលភ្លៀង ហាលខ្យល់ ខ្វះម្ហូបអាហារដាច់ពោះស្លាប់ គ្មានថ្នាំសង្កូវ។ ប្រជាជនសាមញ្ញក៏ដូចជាបញ្ញវ័ន្តត្រូវស្លាប់ដូចគ្នា។ របបនេះមិនត្រូវការអ្នកចេះដឹងឡើយ។ អ្នកដឹកនាំក្នុងរបប ប៉ុល ពត នៅតាមគ្រប់ទីកន្លែងដែលបង្ខំឱ្យប្រជាជនរស់នៅពួកគេបែងចែកវណ្ណៈ មាន **ប្រជាជនចាស់** (ប្រជាជនដែលរស់នៅក្នុងតំបន់រំដោះតាំងពីឆ្នាំ១៩៧០) **ប្រជាជនត្រៀម** (អ្នកដែលរស់នៅក្នុងតំបន់រំដោះតាំងពីឆ្នាំ១៩៧៣) និង**ប្រជាជនថ្មី** (អ្នកដែលរស់នៅក្នុងតំបន់ដែលទើបរំដោះបាននៅឆ្នាំ១៩៧៥)។ ប្រជាជនទាំងនេះរស់ក្នុងរបបប៉ុល ពត ពួកគេចាត់ទុកដូចជាពួកឈ្លើយសឹក ដែលត្រូវបានប៉ុលពតកៀរចេញ និងត្រូវអង្គការនេះប្រមាថមើលងាយ ហើយបង្ខំឱ្យធ្វើការទាំងថ្ងៃទាំងយប់ បាក់កម្លាំង និងអត់ឃ្លានគ្មានអ្វីហូប។ ដូចនេះប្រជាជនទាំងនេះ ដើម្បីមានជីវិតរស់នៅ អ្វី១ក៏ពួកគេអាចទទួលទានបានដែរ ទោះជារបស់នោះគ្មានអនាម័យ ឬដឹងថាពុល ស្លាប់ក៏



www.elibraryofcambodia.org

**រូបទី២៧ :** ទីក្រុងភ្នំពេញក្លាយជាទីក្រុងខ្មោចរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ[២២]



មុខរបរផ្សេងៗ មាន ៣០៥៥១៧នាក់ ព្រះសង្ឃ ២៥១៦៨នាក់ ជនជាតិ ៤៨៨ ៣៥៩នាក់ ស្លាប់ក្នុងព្រៃកប់បាត់ក្នុងរណ្តៅ ៥៦៨៦៦៣នាក់ និងបន្សល់ទុកកុមារកំព្រាប្រមាណជាង ២០០០០០នាក់ អ្នកពិការ និងអ្នកបាក់កម្លាំង ១៤១៨៤៨

ដោយ។ របបនេះគេជ្រើសរើសមនុស្សដែលមានកំហឹងវណ្ណៈ ឬមិនចាំបាច់ចេះដឹងអ្វីឡើយ សំខាន់គឺត្រូវមានជំហរដាច់ខាត ហើយគ្មានការពិចារណា ហ៊ានធ្វើ ហ៊ានកាប់សម្លាប់ ដែលគ្មានការពិចារណា ឱ្យបានត្រឹមត្រូវ ហើយដែលងាយនឹងយកប្រជាជនទៅសម្លាប់ចោល ឬធ្វើបាបរហូតស្លាប់។

២២ - សាលារៀន និងវត្តបានក្លាយជាគុក (បច្ចុប្បន្នមានដូចជាគុកទួលស្លែង) វត្តអារាមក្លាយជាកន្លែងដាក់ជី ឬគុក គ្មានផ្សារ គ្មានប្រាក់ សង្គមកម្ពុជាធ្លាក់ក្នុងភពងងឹត។ ជីវិតប្រជាជនមិនស្មើនឹងសត្វ។ បនប៉ុលពតយកជនល្ងង់ខ្លៅ ឬជនដែលមានគំនុំវណ្ណៈដឹកនាំ ដើម្បីឱ្យពួកគេនោះធ្វើការសងសឹក ដោយវណ្ណៈនៃជនទាំងនេះយកកំហឹងដែលជាគំនុំវណ្ណៈទៅធ្វើការសងសឹក ដោយគ្មានហេតុផល ឬគ្មានការពិចារណា យកមនុស្សទៅប្រហារ កាប់សម្លាប់តាមអំពើចិត្តគ្មានច្បាប់នោះគឺជាច្បាប់ព្រៃ។



www.elibraryofcambodia.org

នាក់។ នេះជាមូលហេតុមួយ ដែលធ្វើឱ្យមានអតុល្យភាព រវាងអត្រាភេទនៅទូ-ទាំងប្រទេស និងមានស្ត្រីមេម៉ាយ ក្មេងកំព្រាជាច្រើននៅប្រទេសកម្ពុជា។

**ក្រាហ្វិកទី១:** ការប្រៀបធៀបរវាងអត្រាភេទតាមបណ្តាឆ្នាំ




រហូតមកដល់សព្វថ្ងៃអតុល្យភាពនៃអត្រាភេទនៅទូទាំងប្រទេស មិនទាន់មានលក្ខណៈសមស្របនៅឡើយ។ តារាងទី៦ និងក្រាហ្វិកទី១បានបង្ហាញឱ្យឃើញថា ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ អត្រាភេទនៅទូទាំងប្រទេសមានអតុល្យភាព។ នៅឆ្នាំ១៩៨០ អតុល្យភាពនេះមានកម្រិតធ្លាក់ខ្លាំងបំផុតគឺ ៨៦,១[២៣] ជាពេលដែលប្រទេសកម្ពុជា ទើបបានរំដោះផុតពីរបបប្រល័យពូជសាសន៍ប៉ុលពត។

[២៣] - អង្កេតប្រជាសាស្ត្រដែលបានធ្វើឡើងនៅទូទាំងប្រទេសកម្ពុជា (នៅចុងឆ្នាំ១៩៨០)។



www.elibraryofcambodia.org

បើពិនិត្យមើលតួលេខជំរឿនប្រជារាស្ត្រឆ្នាំ១៩៦២ វិញ ពេលដែលប្រទេសកម្ពុជាគ្មានសង្គ្រាម អត្រាភេទមានដល់ទៅ៩៩,៩។ អត្រាភេទដែលធ្លាក់ចុះនេះ អាចនឹងកើនឡើងវិញជាបណ្តើរៗ ដែលត្រូវប្រើពេលវេលាយូរ គឺនៅពេលដែលព្រះរាជាណាចក្រកម្ពុជាមានសន្តិភាព។ អត្រាភេទនៅឆ្នាំ២០០៨ កើនឡើងដល់៩៤,៧[២៤] តែនៅរក្សាអតុល្យភាពតិចជាងតួលេខឆ្នាំអង្កេត១៩៨០។ សង្ឃឹមថាទៅអនាគតនៅឆ្នាំ២០៣០ អត្រាភេទនេះ នឹងមានតួលេខកើនឡើងដូចពេលមុនមានសង្គ្រាម។

**តារាងទី៦:** ប្រជាជនកម្ពុជា និងអត្រាភេទតាមប្រភពទិន្នន័យផ្សេងៗ

| ប្រភព | ប្រជាជនកម្ពុជា | | | អត្រាភេទ | កំណត់សម្គាល់ |
|---|---|---|---|---|---|
| | ភេទទាំងពីរ | ប្រុស | ស្រី | | |
| (១) | (២) | (៣) | (៤) | (៥) | (៦) |
| ជំរឿនឆ្នាំ ១៩៦២ | ៥ ៧២៨ ៧៧១ | ២ ៨៦២ ៩៣៩ | ២ ៨៦៥ ៨៣២ | ៩៩.៩ | យោងជំរឿនប្រជារាស្ត្រនៅឆ្នាំ១៩៦២ |
| អង្កេតប្រជារាស្ត្រទូទៅនៅឆ្នាំ១៩៨០ | ៦ ៥ ៨៩ ៩៥៤ | ៣ ០៤៩ ៤៥០ | ៣ ៥៤០ ៥០៤ | ៨៦.១ | យោងលទ្ធផលអង្កេតចុងឆ្នាំ ១៩៨០ |
| អង្កេតសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ ១៩៩៣-១៩៩៤ | ៩ ៨៧០ ០០០ | ៤ ៧១៤ ០០០ | ៥ ១៥៦ ០០០ | ៩១.៤ | យោងអង្កេតនៅខែមេសាឆ្នាំ១៩៩៤ លើមូលដ្ឋានអង្កេតប្រជាជនចំនួន ៥៥៧៨ គ្រួ |
| អង្កេតប្រជារាស្ត្រ ឆ្នាំ ១៩៩៦ | ១០ ៧០២ ៣២៩ | ៥ ១១៩ ៥៣៧ | ៥ ៥៨២ ៧៩២ | ៩១.៧ | យោងអង្កេតនៅខែមិនា ឆ្នាំ១៩៩៦ លើ មូលដ្ឋានអង្កេតប្រជាជនចំនួន ២០០០០ គ្រួ |
| ជំរឿនឆ្នាំ ១៩៩៨ | ១១ ៤៣៧ ៦៥៦ | ៥ ៥១១ ៤០៨ | ៥ ៩២៦ ២៤៨ | ៩៣.០ | យោងជំរឿនប្រជារាស្ត្រនៅឆ្នាំ១៩៩៨ តែមិនរាប់ចំនួនមនុស្ស ដែលរស់នៅក្នុងតំបន់ជម្លោះមួយចំនួនតូច |
| អង្កេតឆ្នាំ២០០៤ នៅចន្លោះជំរឿន | ១២ ៨២៤ ០០០ | ៦ ១៩៧ ០០០ | ៦ ៦២៧ ០០០ | ៩៣.៥ | យោងលទ្ធផលអង្កេតខែមីនាឆ្នាំ២០០៤ នៅ ចន្លោះជំរឿន លើមូលដ្ឋានអង្កេតប្រជាជន ចំនួន៣២០០៤គ្រួ |

[២៤] - វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ លទ្ធផលជំរឿនប្រជារាស្ត្របណ្តោះអាសន្ន ឆ្នាំ២០០៨។



www.elibraryofcambodia.org

| | | | | | |
|---|---|---|---|---|---|
| | | | | | ដោយមិន រាប់ប្រជាជន តាមស្ថានប័ន និងអ្នកគ្មាន លំនៅឋាន |
| ជំរឿនឆ្នាំ ២០០៨ | ១៣ ៣៩៥៦៨២ | ៦ ៥១៦ ០៥៤ | ៦ ៨៧៩ ៦២៨ | ៩៤.៧ | យោងជំរឿនប្រជាសាស្ត្រឆ្នាំ ២០០៨ |

ប្រភព៖ លទ្ធផលជំរឿនប្រជាសាស្ត្រនៅកម្ពុជាឆ្នាំ២០០៨ ដោយវិទ្យាស្ថានជាតិស្ថិតិ ខែសីហា ឆ្នាំ ២០០៩។

របបប៉ុលពត បានបណ្តេញប្រជាជនឱ្យចេញពីទីលំនៅឋាន ដោយលុបបំបាត់រាល់កម្មសិទ្ធិឯកជនទាំងអស់ដែលប្រជាជនមានដូចជាទ្រព្យសម្បត្តិ ផ្ទះសម្បែង ដីធ្លី។ កម្មសិទ្ធិដែលប្រជាជនគ្រប់រូបត្រូវមានគឺកម្មសិទ្ធិមួយបង្វិចតូច មានសម្លៀកបំពាក់មួយសំរបេត ដែលអាចយកជាប់ទៅជាមួយនឹងខ្លួន។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលរំដោះប្រទេសបានភ្លាម ប្រជាពលរដ្ឋចេញមកតាមដងផ្លូវអបអរសាទរនឹងជ័យជំនះនេះ។ តាមដងផ្លូវនានា គេសង្កេតឃើញពួកទាហានលន់ណុលនៃកងទ័ពសាធារណរដ្ឋខ្មែរ ដោះសម្លៀកបំពាក់ទ័ពចេញ ដៃកាន់ទង់ស បានសេចក្តីថា ទាហានទាំងនោះសុំចុះចាញ់ ហើយចេញមកអបអរសាទរនឹងជ័យជំនះជាមួយប្រជាពលរដ្ឋ តែស្ថានភាពនេះបានប្រែប្រួលវិញភ្លាមៗ។ តែប៉ុន្មានម៉ោងក្រោយមក សេចក្តីសប្បាយរីករាយ ក្តីសង្ឃឹម បានប្រែក្លាយជាទុក្ខសោក ដោយសារប្រជាពលរដ្ឋនៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជានៅទីរួមខេត្តនានាទូទាំងប្រទេស ត្រូវបនប៉ុលពតបង្ខំឱ្យចាកចេញពីលំនៅឋានរបស់ខ្លួន និងមានប្រជាពលរដ្ឋខ្លះ ដែលពុំព្រមចាកចេញពីផ្ទះ ត្រូវពួកប៉ុលពតបាញ់រះសម្លាប់នៅនឹងកន្លែងតែម្តង។

តាមដងផ្លូវ និងគ្រប់ផ្លូវចេញពីទីក្រុង ជាពិសេសនៅតំបន់ជាយក្រុងដែលជាទីលានប្រយុទ្ធ គេសង្កេតឃើញមានសាកសពដេកស្លាប់ និងហើមស្អុយពាសពេញ។



www.elibraryofcambodia.org

សាលារៀនទូទាំងប្រទេសត្រូវបិទទ្វារ និងមួយចំនួនបានក្លាយជាគុក (ដូចជាគុកទួលស្លែង...)។ ក្នុងក្រុងភ្នំពេញក៏ដូចជាទីរួមខេត្តនានា មន្ទីរពេទ្យទាំងអស់ត្រូវបិទទ្វារ ទាំងអ្នកជម្ងឺ ទាំងលោកគ្រូពេទ្យ ត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យទាំងអស់ ដែលធ្វើឱ្យមានអ្នកជម្ងឺដេកស្លាប់ក្នុងមន្ទីរពេទ្យ និងនៅតាមដងផ្លូវ គេឮសូរសម្លេងថ្ងូររបស់អ្នកជម្ងឺ សម្លេងថ្ងូររបស់ស្ត្រីដែលឈឺពោះត្រូវសម្រាលបុត្រ រួមនិងសម្លេងទារកយំ ព្រោះមានអ្នកសម្រាលបុត្រតាមដងផ្លូវ។ ទិដ្ឋភាពនេះ គេឃើញមាននៅតាមដងផ្លូវ ដែលជាផ្លូវចេញពីទីក្រុង ពិសេសទីក្រុងភ្នំពេញ[២៥] ដែលជាតំបន់ប្រមូលផ្តុំមនុស្សច្រើនជាងគេរបស់ប្រទេស។ យើងនៅចាំបានរាល់ទិដ្ឋភាពដ៏គួរឱ្យខ្លោចផ្សារទាំងនេះ ដែលបានកើតឡើងចំពោះប្រជាជនកម្ពុជាទាំងអស់ភ្លាមៗ ពេលដែលរបបលន់ណុលត្រូវបានផ្តួលរំលំ និងធ្លាក់ក្នុងរបបប៉ុលពត។ អ្នកដែលវេទនាខ្លាំង និងរងគ្រោះគឺប្រជាជនរស់នៅក្នុងទីក្រុង ទីប្រជុំជន ទីរួមខេត្តនានាដែលត្រូវបណ្តេញចេញ។

តាមដងផ្លូវដែលត្រូវចាកចេញពីទីក្រុង គេឮសូរសម្លេងក្មេងស្រែកយំរកឪពុកម្តាយ និងសម្លេងឪពុកម្តាយស្រែកដង្ហោយហៅរកកូនៗ ព្រោះពួកគេវង្វេង។ ផ្លូវក្នុងក្រុងត្រូវកាត់ផ្តាច់លែងឱ្យឆ្លងកាត់ទៅមក និងមិនដឹងព្រាត់ប្រាស់គ្នាទៅខាងទិសតំបន់ណា។ ម្នាក់ៗមានទឹកមុខសែនស្រពាប់ស្រពោន ស្រងូតស្រងាត់ ពោរពេញដោយភាពតក់ស្លុតមិនអាចនិយាយចេញ។ បនប៉ុល ពតហាមមិនឱ្យទៅមករកគ្នា ចរាចរត្រូវបានបិទ ហាមឃាត់មិនឱ្យឆ្លងកាត់ទៅមករកគ្នាក៏ដូចជាហាមមិនឱ្យទាក់ទងទៅមករកគ្នាបាន។ បន ប៉ុលពត បណ្តេញប្រជាជនឱ្យចេញពីទីក្រុងភ្នំ

---

[២៥] - យើងខ្ញុំជាអ្នកនិពន្ធសៀវភៅនេះ ក៏ត្រូវទទួលរងនូវទុក្ខសោកដូចប្រជាជនទូទាំងប្រទេសដែរ នៅក្នុងរបបព្រៃផ្សៃនេះ។



www.elibraryofcambodia.org

ពេញ ដោយនិយាយបោកបញ្ឆោតប្រជាពលរដ្ឋថា ឱ្យចេញពីទីក្រុងបីថ្ងៃប៉ុណ្ណោះ ព្រោះខ្លាចពួកចក្រពត្តិអាមេរិកទម្លាក់គ្រាប់បែក ដូចនេះចាំបាច់ត្រូវតែជន្លៀសប្រជាជនចេញសិន ដោយមិនបាច់យកអ្វីទៅជាមួយទេ បីថ្ងៃក្រោយប្រជាជននឹងមានសិទ្ធិត្រឡប់ចូលទីក្រុងវិញ។ តែការពិតគឺបនប៉ុលពត បានប្រើឧបាយកលបោកប្រាសប្រជាជនឱ្យចេញពីទីក្រុង បើមិនចេញត្រូវពួកប៉ុលពតបាញ់សម្លាប់ស្រស់ៗតែម្តង ដែលធ្វើឱ្យប្រជាជនភ័យតក់ស្លុតបាត់ស្មារតី ប្រញាប់ប្រញាល់ចាកចេញពីទីក្រុង និងចេញពីលំនៅឋានរបស់ខ្លួន ដោយគ្មានអ្វីយកទៅជាប់នឹងខ្លួន។ អ្នកដែលមានមធ្យោបាយដឹកជញ្ជូនមានរថយន្ត ទោចក្រយានយន្ត និងគ្រឿងលម្អផ្សេងៗ ដែលពួកប៉ុលពតចាត់ទុកជារបស់ចក្រពត្តិឬរបស់ពួកមូលធននិយម តែងនិយមប្រើ ត្រូវតែជម្រុះចោល។ ប្រជាជនត្រូវចាកចេញពីទីក្រុង និងទីរួមខេត្តនានា ឆ្ពោះទៅកាន់ទីជនបទដាច់ស្រយាលដោយមិនដឹងទៅទីណាឱ្យបានច្បាស់លាស់ឡើយ ព្រោះអង្គការប៉ុលពតជាអ្នកកំណត់ទិសឱ្យទៅធ្វើការលត់ដំសតិអារម្មណ៍ ដែលគេអាចហៅថា លាងខួរក្បាល ដែលជាប់កំអែលពួកមូលធននិយមឬពួកចក្រពត្តិនិយម។

ការងារនៅមូលដ្ឋានគឺដូចគ្នាទូទាំងប្រទេស បានសេចក្តីថា ត្រូវបានក្តោបក្តាប់ដោយពួកអង្គការ។ អង្គការប្រៀបប្រដូចទៅនឹងភ្នែកម្នាស់ ប្រជាជនម្នាក់ៗ សុទ្ធតែជាអង្គការ និងមានសិទ្ធិរាយការណ៍ទៅអង្គការ ដើម្បីសម្លាប់ជនទាំងឡាយណា ដែលត្រូវបានគេចោទថា ជាជនក្បត់បដិវត្តន៍។

ក្នុងរបបនេះ បើរស់នៅមិនធ្វើការទេ គឺគ្មានរបបហូបចុកឡើយ ខ្លួនត្រូវទីពឹងខ្លួន ម្នាក់ៗត្រូវតែបញ្ចេញកម្លាំងពលកម្ម សូម្បីមនុស្សចាស់ជរាក៏ដោយ។ ពលកម្មសម្រាប់មនុស្សចាស់មានដូចជាមើលទារក និងកុមារតូចៗ ក្រងស្បូវ ឬក្រងស្លឹក...។ មនុស្សទាំងអស់គ្នា ត្រូវពួកអង្គការបង្ខំឱ្យធ្វើពលកម្មគ្មានពេលសម្រាក



www.elibraryofcambodia.org

បរិភោគមិនឆ្អែត បាក់កម្លាំង បណ្តាលឱ្យប្រជាជនធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់ ដោយគ្មានថ្នាំសង្កូវព្យាបាល គ្មានអាហារហូបគ្រប់គ្រាន់ ដែលគេហៅថា (សម្លាប់ដោយប្រយោល) ។

**រូបថតទី២៨-២៩:** ចលនាផ្លាស់ទីចេញដោយបង្ខំពីទីក្រុងភ្នំពេញ និងទីរួមខេត្តនានាទូទាំងប្រទេស





www.elibraryofcambodia.org



ប្រភព៖ ដកស្រង់ពីនិក្ខេបបទថ្នាក់បណ្ឌិត របស់បណ្ឌិត អ៊ូ វីឌី ការពារនៅឆ្នាំ១៩៩៣
"ទិដ្ឋភាពមួយចំនួនស្តីពីរបាយប្រជាជនកម្ពុជាបច្ចុប្បន្ន"

ប្រជាជនដែលត្រូវពួកប៉ុលពតចោទថាខ្មាំងបដិវត្តន៍ជាកាហ្សេបេ(KGB)[២៦] ឬជាសេអ៊ីអា (CIA)[២៧] ត្រូវតែយកទៅសម្លាប់ទាំងពូជ ដោយវាយសម្លាប់កប់ក្នុងរណ្តៅរួម ដែលហៅថា សម្លាប់ដោយផ្ទាល់ និងមានភស្តុតាងបន្សល់ទុកនៅតាមមូលដ្ឋានតាមរាជធានី ខេត្ត តាមបណ្តាទីក្រុង និងទីជនបទនានាទូទាំងប្រទេស ដូចជានៅគុកទួលស្លែង នៅជើងឯក ខណ្ឌដង្កោ (ក្រុងភ្នំពេញ) ក្នុងរណ្តៅរួម និងតាមទីកន្លែងរាប់សិបទៀតនៅទូទាំងប្រទេស ។

---

[២៦] - ភ្នាក់ងារស៊ើបការណ៍ ដែលមានអង្គការចាត់តាំងនៅប្រទេសរុស្ស៊ី ។

[២៧] - ភ្នាក់ងារស៊ើបការណ៍ ដែលមានអង្គការចាត់តាំងនៅសហរដ្ឋអាមេរិក ។



www.elibraryofcambodia.org

នៅតាមទីកន្លែងដែលបនប៉ុលពតឱ្យប្រជាជនចេញពីទីក្រុង ប្រជាជនទាំងនោះត្រូវបានអង្គការរបស់របប ប៉ុល ពត ឱ្យស្នាក់នៅជាមួយប្រជាជនចាស់ ឬហៅថា ប្រជាជនមូលដ្ឋាន ឬរស់នៅក្នុងខ្ទម ដែលត្រូវបានសង់ដោយខ្លួនឯងនៅកណ្តាលព្រៃ (ដោយត្រូវកាប់គាស់គល់ កាប់រានឆ្ការព្រៃធ្វើភូមិឋាន និងធ្វើការដាំដុះនូវអ្វីៗដែលអង្គការដាក់ទិសឱ្យធ្វើ)។ ការរស់នៅរបស់ប្រជាជនក្នុងសម័យនោះ គឺធ្វើការងាររួម ហូបរួម និងគ្មានសិទ្ធិសេរីភាព គ្មានសិទ្ធិដើរហើរ គ្មានសិទ្ធិនិយាយ និងគ្មានសិទ្ធិតវ៉ារកខុសត្រូវអ្វីទាំងអស់ ទោះបីហេវហត់អត់ឃ្លានលំបាកយ៉ាងណាក្តី ឬឈឺស្លាប់ក្តី ត្រូវតែទ្រាំអត់ ព្រោះបនពុលពតប្រើពាក្យថា ជាការលត់ដំ ជាការឈឺធ្វើពុត ជាការខ្ជិលច្រអូស ដែលបដិវត្តន៍គេមិនត្រូវការទុកមនុស្សបែបនេះឡើយ។ ពួកគេស្អប់អ្នកបញ្ញវន្តណាស់ ពួកគេមិនត្រូវការអ្នកចេះដឹង ឬមានសញ្ញាបត្រឡើយ គេប្រើពាក្យថា អង្គការត្រូវការសញ្ញាឃើញ គឺការធ្វើពលកម្មជាក់ស្តែងមិនត្រូវការស្លាបប៉ាកកា ដោយត្រូវប្រើកម្លាំងបាយមានឧបករណ៍ ចប បង្គី ដងរែក ពូថៅ ដើម្បីកាប់គាស់ រែកដី លើកទំនប់ ជីកប្រឡាយ បង្កបង្កើនផល។

ប្រជាជនគ្រប់ជាតិសាសន៍ គ្រប់ស្រទាប់វណ្ណៈ មានទាំងព្រះសង្ឃ ត្រូវពួកប៉ុល ពតមើលងាយប្រមាថតាមទំនើងចិត្ត និងត្រូវចាប់ផ្សឹកឱ្យធ្វើពលកម្មដូចប្រជារាស្ត្រទូទៅ ដោយបំបាត់សាសនា ប្រពៃណី វប្បធម៌ ទំនៀមទម្លាប់ល្អរបស់ប្រជាជនខ្មែរ កែប្រែប្រពៃណីល្អរបស់ជាតិ ដូចជានៅតាមការដ្ឋានការងារធ្វើក្តៅគគុកតែបែរជាមានការចាប់បង្ខំឱ្យយុវជន យុវនារី ម៉េមាយ ពោះម៉ាយ រៀបការទាំងហ្វូងៗដូចសត្វ ដោយមិនបាច់ស្គាល់មុខគ្នា ហើយចាប់ផ្គូរជាប្តីប្រពន្ធ ចាប់ដៃអង្រួនបែបអឺរ៉ុប ដោយគ្មានមនោសញ្ចេតនាអ្វីសោះឡើយ ដែលនោះគឺជាការប្រមាថ និង



www.elibraryofcambodia.org

មើលងាយដល់វប្បធម៌ ប្រពៃណីដ៏ល្អរបស់ជាតិ ដែលជាមរតករបស់ដូនតាបន្សល់ទុកឱ្យចៅជំនាន់ក្រោយ។ គូរស្រករថ្មីថ្មោងដែលមិនស្គាល់មុខគ្នានេះ ត្រូវពួកប៉ុលពតបញ្ជាឱ្យស្រែកថា "យើងខ្ញុំដឹងគុណអង្គការ ប្តេជ្ញាធ្វើស្រែបង្កបង្កើនផលឱ្យបានបីទៅបួនតោនក្នុងមួយហិកតា"។ ទង្វើទាំងនេះ គឺជាអំពើដ៏សែនល្ងង់ខ្លៅ ឬជារបៀបលេងសើចមួយ ក្នុងពេលដែលពួកប៉ុល ពតមិនឱ្យប្រជាជនបានហូបឆ្អែត និងមានអ្នកស្លាប់ដោយសារការអត់ឃ្លានមានកំរិតច្រើនហួស[២៨]។

នៅក្នុងរបបនេះ ជាទូទៅតាមការសង្កេត ស្ត្រីដែលរៀបការហើយ អាចមានកូនគឺមានចំនួនតិចណាស់ មិនបាន០,២ភាគរយឡើយ (ចំពោះអ្នករស់នៅតាមសហករណ៍)។ តែបើក្រុមមនុស្សរស់នៅក្នុងក្រុមយុវជន តាមកងចល័តវិញ នៅពេលដែលមេកងរបស់អង្គការប៉ុលពត តម្រូវឱ្យរៀបការគឺពួកគេគ្មានកូនទាល់តែសោះ ព្រោះគូរស្រករថ្មីថ្មោងទាំងនេះ ពេលរៀបការហើយ មិនបាននៅរួមរស់ជាមួយគ្នាឡើយ គឺពួកគេត្រូវចាកចេញ ដើម្បីទៅបំពេញភារកិច្ចតាមទិស និងការចាត់តាំងរបស់អង្គការ ហើយអ្នកខ្លះទៀតបានស្លាប់នៅតាមការដ្ឋានតែម្តង ក្នុងសមរភូមិការងារក្តៅគគុក ដោយហូបចុកមិនបានគ្រប់គ្រាន់ ធ្វើការគ្មានពេលសម្រាក និងពេលឈឺគ្មានថ្នាំព្យាបាល។ ចំពោះយុវនារីវិញ ការបរិភោគមិនគ្រប់គ្រាន់ និងរស់នៅគ្មានអនាម័យ ធ្វើការហួសកម្រិត ពួកគេទាំងនោះត្រូវរស់នៅជានារីស្គមស្គាំងរីងរៃ និងគ្មានឈាមរដូវប្រចាំខែឡើយ។ យុវជន និងយុវនារីដោយ

---

[២៨] - ជាអត្ថបទមួយដែលអ្នកនិពន្ធបានសរសេរឡើង ដោយផ្អែកលើស្ថានភាពជាក់ស្តែង ដែលអ្នកនិពន្ធខ្លួនឯងជាប្រជាជនដែលត្រូវពួកប៉ុលពត ជម្លៀសចេញពីទីក្រុងភ្នំពេញ និងជាសាក្សីរស់ក្នុងសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ បានដឹងឮ និងឃើញពីទិដ្ឋភាពទាំងឡាយ ដែលបានកើតឡើងក្នុងរបបប៉ុលពតប្រល័យពូជសាសន៍ឯង។ បើគ្មានកងទ័ពរណសិរ្សរំដោះប្រជាជនទាន់ពេលវេលាទេ នោះប្រជាជននឹងបន្តស្លាប់ច្រើនទៀត ព្រោះប្រជាជនកំពុងរស់ក្នុងស្ថានភាពសម្លាប់ បាក់កម្លាំង និងមានជម្ងឺគ្រប់ៗគ្នា។



www.elibraryofcambodia.org

សារការហូបមិនគ្រប់គ្រាន់ មើលទៅក្បាលជង្គង់ធំជាងក្បាល ហើយដូចជាក្លាយជាកុមារ ឬមនុស្សជរាំរីងរៃ ។

មូលហេតុទាំងអស់ដែលបានអធិប្បាយខាងលើនេះ ជាកត្តាចំបងដែលនាំឱ្យរបបនេះធ្លាក់ក្នុងបរាជ័យ ព្រោះរបបនេះតែងប្រើពាក្យស្លោកថា ***"ទីណាមានការជិះជាន់ទីនោះតែងមានការតស៊ូរើបម្រាស់"*** ដូចនេះរបបប៉ុលពតបានភ្លេចនូវពាក្យស្លោកនេះ ដែលជាហេតុនាំឱ្យមានជាចលនាតស៊ូកើតឡើងពីសំណាក់បងប្អូនខ្មែរស្នេហាជាតិ នោះគឺចលនារណសិរ្សរំដោះជាតិកម្ពុជា ដែលបានប្រសូត្រឡើងនៅ**ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៨** ចលនានេះកើតឡើងនៅភូមិភាគបូព៌ាប៉ែកខាងកើតដងទន្លេមេគង្គនៅក្នុង**ស្រុកស្នួល ខេត្តក្រចេះ** ។



www.elibraryofcambodia.org

**ផែនទីទី២:** ខ្មែរក្រហមជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជនតាមរាជធានី ស្របគ្នានឹងចលនាផ្លាស់ទីឆ្លងព្រំដែន ប្រទេសក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥




ចលនារំដោះជាតិនេះ មានល្បឿនលឿនបីដូចផ្លេកបន្ទោរ ព្រោះមានការគាំទ្រពីប្រជាជនគ្រប់មជ្ឈដ្ឋានទូទាំងប្រទេស និងបានផ្ដួលរំលំរបបប្រល័យពូជសាសន៍ សង្គ្រោះប្រជាជនឱ្យរួចផុតពីការកាប់សម្លាប់នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។ បើគ្មានចលនារំដោះជាតិកម្ពុជាឱ្យបានទាន់ពេលវេលាទេ នោះប្រជាជនខ្មែរនឹងបន្ត



www.elibraryofcambodia.org

រងនូវការស្លាប់ដោយសារការកាប់សម្លាប់ ការស្លាប់ដោយសារការអត់ឃ្លាន និង ការស្លាប់ដោយសារភាពហេវហត់ដែលកើតពីការធ្វើការបាក់កម្លាំង។

កងទ័ពរណសិរ្សរំដោះជាតិកម្ពុជា បានធ្វើចលនារំដោះជាតិពីទិសខាងកើត ឆ្ពោះទៅទិសខាងលិច ដោយដណ្តើមបានជ័យជំនះទាំងស្រុងពីរបបប្រល័យពូជ សាសន៍ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ និងបានប្រកាសជាសាធារណៈឱ្យពិភព លោកដឹងឮ និងដណ្តើមបាននូវសិទ្ធិសេរីភាព និងការរស់រានមានជីវិតជាលើកទី២ មកជូនប្រជាជនវិញ ហើយប្រទេសកម្ពុជាត្រូវបានប្តូរឈ្មោះពីកម្ពុជាប្រជាធិប តេយ្យ មកជា **សាធារណរដ្ឋប្រជាមានិតកម្ពុជា** ដែលដឹកនាំដោយវរជនស្នេហាជាតិ ដែលបាន និងកំពុងដឹកនាំនាវាកម្ពុជាបច្ចុប្បន្ននេះ។

## ២.៣-ចលនាផ្លាស់ទីចូលក្រុងភ្នំពេញ និងទីប្រជុំជននានា ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩

ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនខ្មែរទូទាំងប្រទេសបានរួច ផុតពីការកាប់សម្លាប់របស់បន ប៉ុល ពត នោះគឺជាជីវិតរស់ឡើងវិញលើកទី២ របស់ប្រជាជនខ្មែរយើងដែលនៅសេសសល់ ពីការកាប់សម្លាប់របស់បនប្រល័យពូជ សាសន៍។ ប្រជាជនដែលរួចផុតពីការកាប់សម្លាប់ មានជីវិតរស់នៅមានសេរីភាព ក្នុងការដើរហើរនិយាយស្តី និងមានសេរីភាពក្នុងការវិលត្រឡប់ទៅរស់នៅតាមទី កន្លែងដើម និងស្រុកកំណើតរបស់ខ្លួនវិញ។ ប្រជាជនក្រុងមួយចំនួន ដែលមានជីវិត រស់នៅសល់ពីការកាប់សម្លាប់ បានវិលចូលក្រុងភ្នំពេញវិញជាបណ្តើរៗ។

ដោយឡែកប្រជាជនប្រមាណជា៥០ភាគរយ ដែលចូលមករស់នៅទីក្រុង ភ្នំពេញក្រោយឆ្នាំ១៩៧៩ គឺជាអ្នកដែលធ្លាប់រស់នៅទីជនបទសុទ្ធសាធ ព្រោះនៅ



www.elibraryofcambodia.org

ឆ្នាំ១៩៧៩ ទីក្រុងភ្នំពេញមានប្រជាជនចំនួន១២២៧៧៩នាក់[២៩] គឺតិចជាងប្រជាជនក្រុងភ្នំពេញឆ្នាំ១៩៦២ បីដង ( ៣៩៤000នាក់) ។

ករណីដែលគួរឱ្យកត់សម្គាល់ ពេលរំដោះផុតពីរបបប្រល័យពូជសាសន៍ភ្លាមៗ ជាពិសេសនៅតាមមូលដ្ឋានដែលមានប្រជាជនរស់នៅ និងបានរំដោះរួចផុតពីតំបន់ពួកប៉ុលពតកាន់កាប់ ប្រជាជនមានការអបអរសាទរសប្បាយរីករាយ និងបានប្រញាប់ប្រញាល់ចាកចេញទៅរកស្រុកកំណើត តែពេលនេះក៏ជាពេលដែលមានគ្រោះថ្នាក់បំផុតសម្រាប់ជីវិតប្រជាជនយើងដែរ ព្រោះបនប៉ុលពតនៅតែបន្តតាមកាប់សម្លាប់ប្រជាជនយើងទៀត។ ប្រជាជនដែលចាកចេញផុត ពីតំបន់កាន់កាប់ដោយបន ប៉ុល ពត បានធ្វើចលនាផ្លាស់ទីតាមកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាយ៉ាងលឿនបំផុត ដើម្បីចៀសឱ្យផុតពីការកាប់សម្លាប់ ។

ប្រជាជនបានគាំទ្រយ៉ាងស្មោះស្ម័គ្របំផុត នូវចលនារំដោះជាតិនេះ ហើយប្រជាពលរដ្ឋមួយចំនួនធំបានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពរណសិរ្ស ព្រោះប្រជាពលរដ្ឋខ្មែរចាំមិនភ្លេច និងដឹងគុណថ្ងៃប្រាំពីរ ខែមករា ឆ្នាំ១៩៧៩ ជាដែលថ្ងៃផ្តល់កំណើតទី ២ ដល់ពួកគាត់ ។

ប្រជាជនដែលមានជីវិតនៅរស់ ដើរស្វែងរកបងប្អូនកូនចៅដែលព្រាត់ប្រាសបែកគ្នាមិនដឹងស្លាប់ ឬរស់[៣០] ។ ឯប្រជាជនដែលធ្លាប់រស់នៅទីក្រុងមួយចំនួនធំមិនទាន់ចូលទីក្រុងភ្នំពេញភ្លាមៗទេ ពួកគេរស់នៅទីជនបទ ឬស្រុកកំណើតសិន ទម្រាំ

---

[២៩] - ការិយាល័យស្ថិតិរាជធានីភ្នំពេញ( ឆ្នាំ២000) របាយការណ៍ៈស្ថានភាពការងារ អនុវត្តប្រចាំរាជធានីភ្នំពេញ

[៣០] - រហូតមកដល់សព្វថ្ងៃនេះ ( ឆ្នាំ២០១០) ប្រជាជនខ្មែរយើងនៅតែអំពាវនាវស្វែងរកបងប្អូនកូនចៅនៅឡើយ ដូចជាផ្សព្វផ្សាយរកសាច់ញាតិតាមសារព័ត៌មាន វិទ្យុ ទូរទស្សន៍ ឬតាមអ្នកដែលស្គាល់គ្នា ដើម្បីជួយស្វែងរកឱ្យទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ។



www.elibraryofcambodia.org

រកបងប្អូនឃើញ និងប្រកបមុខរបរកសិកម្មដាំដុះ ព្រោះពួកគេត្រូវការឱ្យក្រពះដែលស្រេកឃ្លានជាយូរមកហើយបានហូបចុកឆ្អែត និងមានកម្លាំងកំហែងសិន ឬពួកគាត់ត្រូវធ្វើអ្វីផ្សេងទៀតតាមលទ្ធភាពនាពេលនោះ ដើម្បីបំប៉នសុខភាពដែលទ្រុឌទ្រោមនោះមកវិញ តែជាទូទៅពួកគាត់ផ្តោតលើការបំពេញក្រពះ ដែលស្រេកឃ្លាន និងតាមរកប្តីប្រពន្ធកូនចៅ និងស្វែងរកសាច់សារលោហិត ដែលមិនទាន់ឃើញនិងជួបគ្នា។ ប្រជាជនមួយចំនួនទៀត នៅមានការខ្លាចរអារច្រើនពុំទាន់ហ៊ានចូលមកទីក្រុងភ្នំពេញវិញភ្លាម។ទេ។

នៅទីក្រុងភ្នំពេញ និងទីប្រជុំជននានា-ប្រជាជនស្វែងរកជម្រកស្នាក់នៅតាមបំណងប្រាថ្នារបស់ខ្លួន និងតាមចំណង់ចំណូលចិត្ត ព្រោះលំនៅឋានទាំងឡាយគ្មានមនុស្សរស់នៅឡើយ ដូចនេះជាបណ្តើ។ផ្ទះសម្បែងទាំងឡាយ ដែលគ្មានមនុស្សស្នាក់នៅត្រូវបានបំពេញដោយមនុស្សមកស្នាក់នៅជាបណ្តើរ។ លើលំនៅដ្ឋាននានាដែលមានពីមុនឆ្នាំ១៩៧០ និងមុនឆ្នាំ១៩៧៥។ ជាបណ្តើរទីក្រុងភ្នំពេញដែលជាទីក្រុងខ្មោច និងទីប្រជុំជននានាទូទាំងប្រទេស បានប្រែក្លាយជាមានស្ថានភាពអ៊ូអរបន្តិចម្តង។ ព្រោះក្រោយថ្ងៃរំដោះរួចផុតពីរបបប្រល័យពូជសាសន៍ កងទ័ពរណសិរ្សរំដោះជាតិកម្ពុជា បានចាប់បង្កើតក្បាលម៉ាស៊ីនដឹកនាំប្រទេសនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តក្រុងនានាឡើងវិញ និងបានអំពាវនាវឱ្យប្រជាជនដែលមានចំណេះដឹង មានបទពិសោធន៍ការងារកន្លងមក ឬមានចំណេះតិចតួចក្តីដោយរៀនផង ធ្វើការងារផង និងចំពោះប្រជាពលរដ្ឋទាំងឡាយ ដែលមានចំណេះដឹង និងនៅមានជីវិតរស់នៅស្នើឱ្យចូលមកបម្រើការងាររដ្ឋវិញ។



www.elibraryofcambodia.org

យោងតាមរូបទី២៥ និងរូបទី២៦ ចលនាផ្លាស់ទីពេលនេះ មានទម្រង់ជាចលនាផ្លាស់ទីលំនៅមានលក្ខណៈជាផែនធំៗ ទៅតាមតំបន់ដែលកងទ័ពរណសិរ្សបានរំដោះរួចផុតពីការគ្រប់គ្រងរបស់ខ្មែរក្រហម ហើយចលនាផ្លាស់ទីនេះ មានទម្រង់ជាផែនធំៗប្រហាក់ប្រហែលគ្នា នឹងពេលដែលបនប៉ុលពតបណ្ដេញប្រជាជនចេញពីទីក្រុង និងទីប្រជុំជនដែរ តែទម្រង់នៃបម្លាស់ទីលើកទីពីរនេះ គឺប្រជាជនធ្វើដោយឯកឯង ចិត្តស្មោះស្ម័គ្រ មានសេរីភាព គ្មានការបង្ខិតបង្ខំ និងមានទឹកមុខរីករាយ។ ប្រជាជនមួយចំនួនបានចូលមករស់នៅទៅតាមទីកន្លែង ដែលពួកគាត់ធ្លាប់រស់នៅ មួយចំនួនពួកគាត់ទៅរស់នៅទីកន្លែងផ្សេង ដែលពួកគាត់គិតថា អាចរស់នៅបាន និងប្រកបរបររកស៊ីបាន និងមួយចំនួនទៀត មិនហ៊ានចូលទៅរស់នៅទីកន្លែងដើមវិញទាំងស្រុងឡើយ ហើយប្រជាជនមួយចំនួនបានផ្លាស់ទីចេញហួសទៅនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម[៣១] ដើម្បីទៅរស់នៅប្រទេសទីបី មានសហរដ្ឋអាមេរិក អឺរ៉ុប អូស្ត្រាលី បារាំង... ដោយពួកគេខ្លាចរអារនឹងរបបខ្មែរក្រហម និងខ្លាចរបបខ្មែរក្រហមវិលមកវិញ ដែលពួកគេអាចប្រឈមមុខនឹងការកាប់សម្លាប់ជាថ្មីម្តងទៀត។ ដូចនេះតាមរយៈផែនទីទី៣ យើងអាចមើលឃើញពីចលនាផ្លាស់ទីចូលមកស្រុកកំណើតវិញ (ពិសេសចលនាផ្លាស់ទីចូលទីក្រុងភ្នំពេញ និងទីរួមខេត្តនានា ព្រោះប្រជាជនទាំងអស់នេះ ត្រូវបនប៉ុលពតដេញចេញពីទីក្រុង និងទីរួមខេត្ត)។ យើងអាចមើលឃើញពីចលនាពីរផ្ទុយគ្នា គឺមានការផ្លាស់ទីចេញទៅក្រៅប្រទេសមួយចំនួន។

---

៣១ - ភាគច្រើននៃប្រជាជនដែលផ្លាស់ទីគឺមានទិសដៅតម្រង់ទៅប្រទេសទីបី ដោយស្នាក់នៅភាគច្រើន តាមជុំរំនៅតាមព្រំដែនកម្ពុជា-ថៃ។



www.elibraryofcambodia.org

នៅតាមព្រំដែនកម្ពុជា-ថៃ និងព្រំដែនកម្ពុជា-វៀតណាមមានជំរុំជនភៀស ខ្លួន ដែលឧបត្ថម្ភដោយអង្គការសហប្រជាជាតិសម្រាប់ជួយដល់ជនភៀសខ្លួន (UNHCR) នៅតាមបណ្តោយព្រំដែន និងមួយចំនួនបានផ្លាស់ទីចេញទៅរស់នៅប្រទេសទីបី និងមួយចំនួនបានធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញ ជាពិសេសនៅឆ្នាំ១៩៩២ ពេលដែលរដ្ឋាភិបាលបានអំពាវនាវឱ្យបងប្អូនខ្មែរយើង ធ្វើមាតុភូមិនិវត្តន៍តាមកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

ជនមាតុភូមិនិវត្តន៍ ដែលបានវិលចូលប្រទេសវិញត្រូវបានទៅរស់នៅតាមការស្ម័គ្រចិត្តនៅតាមបណ្តាខេត្តក្រុងនានាទូទាំងប្រទេស តែតាមការសង្កេតបងប្អូនទាំងនោះមួយចំនួនធំបានវិលត្រឡប់ចូលមករស់នៅក្នុងទីក្រុង និងតាំងទីលំនៅតាមទីប្រជុំជននៃរាជធានី ខេត្ត ក្រុង ហើយមួយចំនួន ដែលវិលមកក្រោយបន្តបន្ទាប់ទៀត បានតាំងទីលំនៅលើដីរដ្ឋ និងមួយចំនួនតាំងទីលើដីឯកជន បង្កើតបានជាតំបន់អនាធិបតេយ្យបង្កនូវការលំបាកដល់សង្គម ក៏ដូចជាការលំបាកដល់ការអភិវឌ្ឍទីក្រុង។

ចំពោះអ្នកជនបទមួយចំនួន ដែលបានចូលមករស់នៅក្នុងទីក្រុងភ្នំពេញក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ពួកគាត់មួយចំនួនបាននាំមកជាមួយនូវប្រពៃណីជនបទមកផង ករណីដូចជាពួកគាត់មិនមានទម្លាប់រស់នៅក្នុងលំនៅឋាន ដែលមានការថែទាំនូវប្រព័ន្ធលូបង្ហូរទឹកកាកសំណល់ ឬបង្គន់អនាម័យជាដើម មួយចំនួនបានបង្កនូវការលំបាកក្នុងការប្រើប្រាស់នូវប្រព័ន្ធបង្ហូរទឹកកាកសំណល់ ប្រព័ន្ធអនាម័យរួមគ្នា និងសិទ្ធិក្នុងការប្រើប្រាស់ ដោយពួកគាត់មានបញ្ហាទំនាស់គ្នាជាមួយអ្នកជិតខាងលើការថែរទាំ ក៏ដូចជាសិទ្ធិលើការប្រើប្រាស់ ពិសេសលំនៅឋានជាអគារ



www.elibraryofcambodia.org

**រូបទី៣០ ទី៣១ :** ចលនាផ្លាស់ទីរបស់ប្រជាជនក្នុងប្រទេសកម្ពុជា

ក្រោយថ្ងៃទី៧ខែមករា ឆ្នាំ១៩៧៩





www.elibraryofcambodia.org

សហកម្មសិទ្ធិ ដែលបានសង់ឡើងនៅមុនឆ្នាំ១៩៧៩ និងមានការរំខានផ្សេងទៀត ដែលកើតឡើងរវាងអ្នកជិតខាងជាមួយគ្នា មានការបង្កជាសម្លេងរំខាន ដោយខ្វះការគោរពសិទ្ធិគ្នាទៅវិញទៅមក ។

ក្រោយថ្ងៃដែលប្រជាជនកម្ពុជា មានជីវិតរស់ឡើងវិញជាលើកទី២ រដ្ឋាភិបាលក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានខិតខំស្តារ និងកសាងប្រទេសឡើងវិញពីគំនរផេះផង់ ដែលរបបប៉ុលពតបន្សល់ទុក ។

ស្ថានភាពក្នុងប្រទេសនៅតែពុំទាន់មានស្ថិរភាពនយោបាយទូទាំងប្រទេសដែរ ។ ទន្ទឹមការខិតខំកសាងប្រទេសឡើងវិញពីភាពខ្ទេចខ្ទាំនេះ ទាំងកម្លាំងទ័ព និងកម្លាំងប្រជាជន រួមគ្នាទប់ស្កាត់នូវការវិលត្រឡប់មកវិញរបបប្រល័យពូជសាសន៍ ដែលមានទីតាំងឋិតនៅតំបន់ពាយ័ព្យប្រទេស ។

ក្នុងគោលបំណងដើម្បីរួបរួមជាតិជាធ្លុងមួយ និងដើម្បីកសាងប្រទេសឆ្ពោះទៅរកការអភិវឌ្ឍ នៅឆ្នាំ១៩៩៨ តាមគម្រិះដ៏ឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវគោលនយោបាយ **ឈ្នះ ឈ្នះ** បានធ្វើឱ្យប្រទេសកម្ពុជាគ្មានតំបន់អប្បគមន៍ទៀតឡើយ ខ្មែរក្រហមបានចូលមករួមរស់ជាមួយរាជរដ្ឋាភិបាល និងបានធ្វើឱ្យប្រទេសកម្ពុជាមានសន្តិភាព និងស្ថិរភាពនយោបាយនៅទូទាំងប្រទេស ។ ប្រជាជនកម្ពុជារស់នៅមានក្តីសង្ឃឹមក្នុងជីវិត និងបង្កលក្ខណៈឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពចូលទៅធ្វើការអភិវឌ្ឍបានទូទាំងប្រទេស ។ នេះជាកត្តាចម្បងមួយ ដែលពីមួយថ្ងៃទៅមួយថ្ងៃ ដំណើរទេសចរណ៍បរិយាកម្មចេះតែមានសន្ទុះកើនឡើងជានិច្ច រួមនឹងការអភិវឌ្ឍ



www.elibraryofcambodia.org

ដែលជាបណ្តើរៗ មានចលនាផ្លាស់ទីរបស់ប្រជាជនពីជនបទ ចូលមករស់នៅក្នុងទីក្រុង និងទីប្រជុំជន។

**ផែនទី ទី៣:** ចលនាផ្លាស់ទីរបស់ប្រជាជនក្នុងប្រទេសកម្ពុជា ក្រោយ ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩




សន្តិភាពបានបង្កនូវលក្ខណៈអំណោយផលដល់ការអភិវឌ្ឍប្រទេសគ្រប់ទិសទីទាំងទីប្រជុំជន និងទីជនបទ។ កំណើនសេដ្ឋកិច្ចមានការកើនឡើង ជីវភាពរស់នៅរបស់ប្រជាជនមានការប្រែប្រួល និងមានវិនិយោគទុនជាតិ និងអន្តរជាតិមក



www.elibraryofcambodia.org

បណ្តាក់ទុនរកស៊ី។ កត្តានេះបានបង្កលក្ខណៈឱ្យប្រជាជនក្រុងមានលទ្ធភាពរកការងារធ្វើបានច្រើន ព្រោះភ្នំពេញជារាជធានី និងជាទីក្រុងធំទី១របស់ព្រះរាជាណាចក្រកម្ពុជា ហើយទីក្រុងភ្នំពេញក៏បានដើរតួសំខាន់ ក្នុងការស្រូបយកកម្លាំងពលកម្មពីទីជនបទមករស់នៅ។


www.elibraryofcambodia.org

www.elibraryofcambodia.org

# ជំពូក៤

# នគរូបនីយកម្ម និងស្ថាបត្យកម្មនៅកម្ពុជាតាមសម័យកាល

## ១-សម័យមុនអង្គរនិងសម័យអង្គរ

តាមសិលាចារិក ក៏ដូចជាឯកសារស្រាវជ្រាវប្រវត្តិសាស្ត្រ បានបង្ហាញឱ្យឃើញពីទេពកោសល្យរបស់កូនខ្មែរ និងបានបន្សល់ទុកនូវស្នាដៃដ៏ច្រើនលើសលុប តាំងពីសម័យមុនអង្គរ និងសម័យអង្គរ ដែលសព្វថ្ងៃគេឃើញមានប្រាសាទមួយចំនួនធំនៅសេសសល់រហូតដល់សព្វថ្ងៃ មានប្រាសាទភ្នំដា ប្រាសាទបាយ័ង នៅខេត្តតាកែវ និងប្រាសាទសម្បូរណ៍ព្រៃគុហ៍ នៅខេត្តកំពង់ធំជាដើម។ អ្វីដែលជាភស្តុតាងបន្សល់ទុកដើម្បីឱ្យបុរាណវិទូអាចធ្វើការស្រាវជ្រាវ និងសម្រាប់យកទៅធ្វើការវិភាគបាន នោះគឺកូនខ្មែរមានទេព្យកោសល្យខ្ពស់ខាងសំណង់ស្ថាបត្យកម្ម និងចម្លាក់ ដោយបានសាងសង់ប្រាសាទធ្វើអំពីឥដ្ឋដុត និងជាពិសេសថ្មភក់ ឬថ្មក្រែ ថ្មបាយក្រៀម ឬថ្មក្រានិត យកមករៀបបន្ទុបត្រួតពីលើគ្នា ស្ថាបនាបានជាប្រាង្គប្រាសាទ និងមានឆ្លាក់ជាក្បាច់លោត ឬក្បាច់ផុស ដោយបង្ហាញជារឿងតាមទេវកថា ឬជារឿងរាវដែលស្តែងចេញ ពីជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរសម័យនោះ ឬជាប្រវត្តិសង្គ្រាមដែលបានកើតឡើងជាមួយប្រទេសចម្ប៉ាជាដើម។ ស្នាដៃចម្លាក់ទាំងនោះ បានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យជាប់ចិត្តជិតអារម្មណ៍ និងគយគន់មិនជិនណាយ ពីភាពរស់រវើកនៃក្បាច់ចម្លាក់ជារឿងរ៉ាវទាំងនោះ។



www.elibraryofcambodia.org

តាមរយៈស្នាដៃដែលកូនខ្មែរបានបន្សល់ទុកនៅសម័យអាណាចក្រខ្មែរ បានបង្ហាញឱ្យឃើញពីធនធានមនុស្សខ្មែរ ប្រកបដោយទេព្យកោសល្យ និងមានគំនិតឆ្នៃប្រឌិតខ្ពស់។ នៅតំបន់ភ្នំគូលែន ឬនៅប្រាសាទព្រះវិហារ បុព្វបុរសយើងបានយកថ្ម ដែលមានទម្ងន់រាប់សិបម៉ឺនតោន មកតម្រៀបបន្តុបលើគ្នាបង្កើតបានជាប្រាសាទភ្នំ ដោយគ្មានប្រើដែកមួយសរសៃរណាឡើយ។ នេះជាគំនិតច្នៃប្រឌិតខ្ពស់ បង្ហាញពីសមត្ថភាព និងគំនិតប្រាជ្ញាផ្នែករូបសាស្ត្រ គណិតសាស្ត្រ ដែលស្ថាបត្យករខ្មែរមានទេព្យកោសល្យក្នុងការរកទីប្រជុំទម្ងន់ ដើម្បីរក្សាលំនឹងនៃតួប្រាង្គប្រាសាទទាំងនោះ ដែលមានទម្រង់សុទ្ធសឹងជាប្រាសាទភ្នំ[៣២] មានកំពូលស្រួច កាន់តែឡើងទៅលើខ្ពស់ នោះកំពូលប្រាសាទកាន់តែស្តួចទៅៗ សំដៅភ្ជាប់ឋានមនុស្សលោក និងឋានសួគ៌នៃព្រះអាទិទេព។

វិស្វករ និងស្ថាបត្យករខ្មែរ បានកសាងប្រាសាទពាសពេញផ្ទៃប្រទេស ដោយសុទ្ធតែប្រើនូវទម្រង់ធរណីមាត្រទាំងអស់ ដែលមានរាងចតុកោណកែង ឬចតុកោណកែងស្មើ។ ប្រាសាទកណ្តាលរបស់អង្គរវត្ត មានកម្ពស់ប្រហែល ៥៥ម៉ែត្រ និងជុំវិញប្រាសាទទាំងអស់ មានពង្រឹងដោយកំពែងការពារធ្វើពីថ្មបាយក្រៀម និងបារាយណ៍ទឹកព័ទ្ធជុំវិញដែលមានប្រវែង ៥,៥គីឡូម៉ែត្រ និងមានប្រព័ន្ធធារាសាស្ត្រសាំញ៉ាំ មានព្រែកជីក អាងស្តុកទឹកសម្រាប់ស្រោចស្រព និងផ្គត់ផ្គង់ទឹកដល់ប្រជា-ជនដែលរស់នៅជុំវិញទីក្រុងអង្គរបុរាណនេះ។ អាងស្តុកទឹកធំជាងគេ មានទំហំ ៨ គីឡូម៉ែត្រ គុណនឹង ២,២គីឡូម៉ែត្រ ដែលមានសមត្ថភាពស្តុកទឹកទុក ប្រហែល

---

[៣២] - គឺជាប្រាសាទភ្នំ ស្ថាបនាឡើងដើម្បីបង្ហាញពីក្រុងអង្គរទី១ យសោធរបុរៈដែលជារាជធានីបានសាងសង់ឡើងដោយព្រះបាទយសោវរ្ម័ននៅរជ្ជកាលឆ្នាំ៨៨៩-៩១០។ ប្រាសាទភ្នំបាខែងនេះមានកម្ពស់ ៦៥ម. ឋិតនៅចម្ងាយ ៤០០ម. ខាងត្បូងក្លោងទ្វារអង្គរធំ។ គេអាចមើលឃើញអង្គរធំ អង្គរវត្ត និងតំបន់ជុំវិញពីចម្ងាយបាន។ ទស្សនីយភាពដែលល្អបំផុតគឺវេលាដែលព្រះសុរិយាជិតអស្តង្គត។



www.elibraryofcambodia.org

៧០លានម៉ែត្រគ្រីគុណ។ តំបន់នេះជារាជធានីមួយ ដែលនៅតែបង្ហាញពីភាពថ្កុំថ្កើងរុងរឿង នៃអាណាចក្រអង្គរកាលពីសតវត្សទី៨ ដល់សតវត្សទី១៣។

នៅតាមអ័ក្សនីមួយៗ មានអមដោយស្រះតូចៗរាងជាការ៉េ។ ជាទូទៅប្រាសាទនានា សាងសង់ឡើងសុទ្ធតែផ្អែកលើលក្ខណៈវិទ្យាសាស្ត្រ បើមិនដូច្នោះទេប្រាសាទទាំងនោះនឹងមិនអាចទ្រាំទ្រនូវទម្ងន់ថ្មដ៏ធ្ងន់រាប់សិបតោន និងមិនអាចឋិតនៅគង់វង្សរាប់សតវត្សបានឡើយ។

ចំពោះការជ្រើសរើសទីតាំងក្នុងការសាងសង់ប្រាសាទ សុទ្ធតែសមប្រកបនឹងសណ្ឋានដីដែលទាក់ទងទៅនឹងភូគព្ភសាស្ត្រ ដោយមិនធ្វើឱ្យស្រុតខូចទម្រង់ប្រាសាទ ឬកំពូលប្រាសាទទ្រេតសោះឡើយ។ មិនតែប៉ុណ្ណោះវិស្វករ និងស្ថាបត្យករខ្មែរ បានប្រើប្រាស់ភាពប៉ិនប្រសប់របស់ខ្លួន ដែលជាទូទៅគេសង្កេតឃើញថា ប្រាសាទនីមួយៗ មានលក្ខណៈស៊ីមេទ្រីគ្នា និងបង្គួតរាងល្អឥតខ្ចោះតាមបែបធរណីមាត្រ រំលេចដោយក្បាច់បង្កប់ និងក្បាច់ផុសរស់រវើក។ ស្ថាបត្យកម្មទាំងនេះ បានបង្ហាញពីភាពរុងរឿងដ៏អស្ចារ្យនៃអាណាចក្រខ្មែរកាលពីសម័យនោះ ដែលកើតបានពីប្រាជ្ញាញាណឆ្នៃប្រឌិតខ្ពស់ល្អឯកគ្មានពីរលើលោក និងកំពុងពញ្ញាក់ស្មារតីដាស់អារម្មណ៍មនុស្សជាតិឱ្យកោតសរសើរស្ញប់ស្ញែង និងស្ងើចសរសើរមិនដាច់មាត់នូវស្នាដៃដ៏អស្ចារ្យនេះ (មើលរូបទី ៣២-៣៣-៣៤-៣៥)[៣៣]។

[៣៣] - ប្រាសាទអង្គរវត្ត និងប្រាសាទព្រះវិហារ ត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោកនៅឆ្នាំ១៩៩២ និងឆ្នាំ២០០៨។ មិនតែប៉ុណ្ណោះ នៅមានរបាំបុរាណនានា និងល្បែងប្រជាប្រិយមួយចំនួនទៀត ក៏បានដាក់បញ្ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោកផងដែរ។



www.elibraryofcambodia.org

**រូបទី៣២៖** ប្រាសាទអង្គរវត្តមើលពីលើ



**រូបទី៣៣៖** ប្រាសាទបន្ទាយស្រីមើលលើមួយជ្រុង





www.elibraryofcambodia.org

រូបទី៣៤: ប្លង់ប្រាសាទអង្គរវត្ត




រូបទី៣៥: ប្លង់ប្រាសាទនាគព័ន្ធ






www.elibraryofcambodia.org

ដោយសារតែសារៈសំខាន់របស់តំបន់ប្រាង្គប្រាសាទទាំងនេះ ទើបរាជរដ្ឋាភិបាលបានកំណត់ផ្នែកខ្លះនៃតំបន់នេះជាតំបន់ទេសភាពអង្គរ ដោយរួមមានប្រាសាទ និងព្រៃព័ទ្ធជុំវិញជាឧទ្យានបុរាណអង្គរនៅក្នុងឆ្នាំ១៩២៥ គឺជាឧទ្យានជាតិទីមួយនៅអាស៊ីអគ្នេយ៍ ។ ការងាររក្សាការពារទីក្រុងអង្គរ បានចាប់ផ្តើមនៅដើមសតវត្សទី១៩ ដោយក្រុមអភិរក្សអង្គរដែលជាស្ថាប័នរបស់រាជរដ្ឋាភិបាល និងមានជំនួយពីសាលាបារាំង (Ecole francaise d'Extrème Orient) ហើយស្ថាប័ននេះបានផ្តោតទៅលើការស្តារឡើងវិញនូវរចនាសម្ព័ន្ធរបរាង និងឯកសារ ។ ការប្រឹងប្រែងនេះត្រូវបានផ្អាកសកម្មភាពនៅដើមទសវត្សឆ្នាំ១៩៧០ បន្ទាប់ពីការផ្ទុះសង្គ្រាម ។ ទោះបីជាព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់នូវវិនាសកម្មពីសត្រូវឈ្លានពាន និងសង្គ្រាមរ៉ាយលុកជាបន្តបន្ទាប់ក៏ដោយ តែទីក្រុងបូរាណនេះ នៅតែឋិតនៅជាតំបន់សំខាន់មួយ ក្នុងចំណោមតំបន់ការពារធម្មជាតិទាំង ២៣ កន្លែងនៅកម្ពុជា ដោយត្រូវបានរាជរដ្ឋាភិបាលធ្វើការអភិរក្សជីវៈចំរុះ និងបូរាណវិទ្យា ។

## ២-សម័យអាណានិគមបារាំង (១៨៦៣-១៩៥៣)

នៅសម័យអាណានិគមបារាំង បួងរាជធានីភ្នំពេញ និងបួងទីក្រុង តាមខេត្តនានាមានរាងជាក្រឡាចត្រង្គ (មើលរូបទី៣៦-៣៧-៣៨-៣៩) ។ គេសង្កេតឃើញមានសំណង់បុរាណត្រូវអភិរក្សមួយចំនួន ដែលនៅសេសសល់រហូតសព្វថ្ងៃ និងមានតម្លៃជាប្រវត្តិសាស្ត្រចាំបាច់ត្រូវរក្សា ។ សំណង់ទាំងនោះច្រើនជាអគាររដ្ឋបាលនានា ឬជាលំនៅឋានរបស់មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជាជនជាតិបារាំង ដែលមកធ្វើការនៅស្រុកខ្មែរ និងច្រើនមានទម្រង់ជាអគារ ឬសំណង់យកតាមលំនាំវប្បធម៌បែបអឺរ៉ុប នៅសម័យក្លាស៊ិក ឬណេអូក្លាស៊ិក (មើលរូបទី៤០-៤១) ដូចជា



www.elibraryofcambodia.org

នៅតាមតំបន់រដ្ឋបាល មានសាលាខេត្ត សាលាក្រុងភ្នំពេញ និងនៅរាជធានីភ្នំពេញ តែសង្កេតឃើញមាននៅតាមតំបន់រដ្ឋបាល និងនៅសង្កាត់វត្តភ្នំ ដែលជាតំបន់លំនៅឋានរបស់មន្ត្រីជាន់ខ្ពស់បារាំង។ លំនៅឋានរបស់ប្រជាជនដែលនៅសេសសល់រហូតមកដល់សព្វថ្ងៃ ច្រើនឋិតនៅជុំវិញទីផ្សារ ជាតំបន់ពាណិជ្ជកម្ម ហើយសំណង់ទាំងនេះ កំពុងទទួលរងនូវការបាត់បង់ជាបណ្តើៗ បើគ្មានវិធានការទប់ស្កាត់អភិរក្សទេនោះ។ ប្រជាជនចេះតែបន្តការកែប្រែតាមបែបសម័យថ្មី ដែលធ្វើឱ្យបាត់បង់នូវទម្រង់ដើម បាត់បង់តម្លៃប្រវត្តិសាស្ត្រ ព្រោះសំណង់ទាំងនោះជាអគារ ដែលមានអាយុចំណាស់ និងជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញពីជីវភាពរស់នៅពីអតីតកាលរបស់សង្គមកម្ពុជា ក្នុងសម័យអាណានិគមនិយមបារាំងអំឡុងឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣។



www.elibraryofcambodia.org

**រូបទី៣៦ : ប្លង់រាជធានីភ្នំពេញទាំងមូល**






www.elibraryofcambodia.org

រូបទី៣៧ : ប្លង់កណ្តាលរាជធានី




រូបទី៣៨: ប្លង់ទីក្រុងបាត់ដំបងចាស់ និងគូរឡើងវិញឆ្នាំ២០០៤





www.elibraryofcambodia.org

## រូបទី៣៩: ប្លង់ទីក្រុងសៀមរាប






www.elibraryofcambodia.org

**រូបទី៤០:** លំនៅឋានដែលជាសំណង់ដ៏ប្រណិតត្រូវអភិរក្ស ថតឆ្នាំ ២០០៤





www.elibraryofcambodia.org

**រូបទី៤១:** ទិដ្ឋភាពនិវេសនដ្ឋានរបស់លោកម្ចាស់ កថាថន ឈុំ ក្នុងឆ្នាំ១៩២៥ សាងសង់ឡើងក្នុងឆ្នាំ១៩០៥ដោយស្ថាបត្យករជនជាតិអ៊ីតាលី និងត្រូវបានជួសជុលដោយរដ្ឋបាលខេត្តបាត់ដំបង និងរក្សាបាននូវលក្ខណៈដើមទាំងស្រុង។



ក្រៅពីសំណង់ដែលបានបង្ហាញ គេសង្កេតឃើញពីសំណង់ស្ថាបត្យកម្ម ធ្វើអំពីឈើជាផ្ទះរោងឡឿង ស្ថិតនៅក្នុងភូមិតាព្រួចគឺជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ខ្មែរ (រូបទី៤០)។ សព្វថ្ងៃសំណង់នេះ នៅគង់វង្សល្អនៅឡើយ និងបានបង្ហាញពីភាពដ៏ប៉ិនប្រសព្វលើការងារឈើ ដែលជាផ្នែកលម្អិតនៃសំណង់ និងត្រូវបានអាជ្ញាធរមូលដ្ឋានថែរក្សាសម្រាប់ទាក់ទាញភ្ញៀវទេសចរ ព្រោះជាសំណង់ដែលមានអាយុចំណាស់ និងជាផ្ទះខ្មែរដែលត្រូវអភិរក្សឋិតនៅក្នុងខេត្តបាត់ដំបង។ បច្ចុប្បន្នសំណង់លំនៅឋានជាគ្រឿងឈើរបស់ប្រជាជនខ្មែរ ដែលមានអាយុចំណាស់បែបនេះ មាន



www.elibraryofcambodia.org

សេសសល់តិចតួចនៅតាមបណ្ដាខេត្តនានាដូចជា ខេត្តបាត់ដំបង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ដែលជាខេត្តសម្បូរណ៍ដោយផ្ទះធំៗធ្វើអំពីគ្រឿងឈើ។ ចំពោះខេត្តបន្ទាយមានជ័យ ក៏មានផ្ទះឈើធំៗដែរតែក្នុងរបប ប៉ុល ពត ផ្ទះឈើដែលមានទំហំធំៗទាំងនោះត្រូវបានបន ប៉ុល ពត រុះរើបំផ្លាញ និងយកមកបំបែកធ្វើជាផ្ទះខ្ទមតូចៗ។

**រូបទី៤០:** លំនៅឋានសង់អំពីឈើដែលត្រូវអភិរក្ស



**៣-សម័យឯករាជ្យឬសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)**

កម្ពុជាទទួលបានឯករាជ្យពេញលេញពីបារាំង នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣។ ក្រោយពេលដែលប្រទេសកម្ពុជាបានទទួលឯករាជ្យ កម្ពុជាមានការរីកចម្រើនឡើងជាពិសេសនៅទសវត្សឆ្នាំទី៦០។ ទន្ទឹមនឹងដំណើរនគរូបនីយកម្មគេសង្កេតឃើញមានសំណង់ស្ថាបត្យកម្មបានកើតឡើង និងរីកដុះដាលនៅតាមរាជ



www.elibraryofcambodia.org

ធានី ទីក្រុង ទីរួមខេត្តនានា។ សំណង់ស្ថាបត្យកម្មទាំងនោះ ភាគច្រើនមានលក្ខណៈមិនស្មុគ្រស្មាញ។ ភូមិគ្រឹះភាគច្រើនបានសង់ឡើងលើដីឡូតិ៍ធំទូលាយ មានរបងព័ទ្ធជុំវិញ តែគេអាចមើលឃើញទីធ្លា និងទេសភាពនៅខាងក្នុងភូមិគ្រឹះទាំងនោះ។

ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តក៏បានបន្តពង្រីក និងមានការចាក់ដីលុបបំពេញបឹង និងតំបន់នានា មានចំការមន បឹងកេងកង... ដើម្បីអភិវឌ្ឍន៍ទីក្រុងភ្នំពេញ ដែលពេលនោះរាជធានី ឬក្រុងភ្នំពេញមានខ្សែក្រវាត់ក្រុងនៅតូច។

វត្តភ្នំគឺជាចំណុចសូន្យគីឡូម៉ែត្រ នៃចម្ងាយពីក្រុងភ្នំពេញទៅបណ្តាខេត្តនានាទូទាំងប្រទេស។ នៅតាមដងមហាវិថីព្រះនរោត្តម ចាប់ពីចំណុចវត្តភ្នំរហូតដល់ផ្លូវបំបែកក្បាលថ្នល់សំណង់ស្ថាបត្យកម្ម បានសាងសង់ឡើងលាយឡំនឹងអគាររដ្ឋបាល។ តំបន់នេះភាគច្រើនជាតំបន់លំនៅឋានរបស់អ្នកមានសម្បត្តិស្តុកស្តម្ភ ឬមន្ត្រីរាជការខ្មែរជាន់ខ្ពស់ និងជាតំបន់ស្ងៀមស្ងាត់ ដូចគ្នានឹងតំបន់ជុំវិញវិមានឯករាជ្យដែរ។ ចំណែកនៅតាមដងមហាវិថីព្រះសីហនុ ចាប់ពីមន្ទីរពេទ្យចិន (បច្ចុប្បន្នជាការដ្ឋានសំណង់ទំនើប៤២ជាន់ ឋិតត្រង់ចំណុចភ្លើងស្តុបវិទ្យាល័យព្រះ-យុគន្ធរ) រហូតទៅទល់នឹងទិសខាងកើត កាត់កែងជាមួយសួនច្បារ ទល់មុខនឹងវត្តព្រះបទុមវត្តី ក៏ជាតំបន់លំនៅឋានដីឡូតិ៍ធំៗដែរ។ តំបន់ទាំងនេះ មានសភាពស្ងប់ស្ងាត់តាំងពីសម័យអាណានិគមនិយមបារាំង។ បច្ចុប្បន្នតំបន់នេះ បានក្លាយទៅជាតំបន់ពាណិជ្ជកម្ម មានអគារលក់ទំនិញធំទំនើបៗ បង្ហួតខ្លួនយ៉ាងទាន់សម័យ និងលម្អដោយភ្លើងចម្រុះពណ៌នាពេលរាត្រី។

ចាប់ពីមហាវិថីព្រះមុនីវង្ស ត្រង់ចំណុចវិទ្យាល័យព្រះយុគន្ធរ ទៅទល់នឹងមហាវិថីព្រះមុនីរ៉េត ផ្សារមុំផ្សារដើមគរគឺជាតំបន់សំណង់ផ្ទះល្វែង លាយឡំនឹងផ្ទះឈើដែលភាគច្រើន បានសាងសង់ឡើងចាប់ពីឆ្នាំ១៩៦០ ទៅដល់ឆ្នាំ១៩៧០។ សំណង់



www.elibraryofcambodia.org

ស្ដាបត្យកម្មជាតិដែលលេចធ្លោគឺពហុកីឡាដ្ឋានជាតិ បានសង់ឡើងសម្រាប់ប្រារព្ធក្នុងពិធីប្រកួតកីឡាហ្គាណើហ្វូលើកទីមួយ នៅព្រះរាជាណាចក្រកម្ពុជានាឆ្នាំ១៩៦៦ ដែលបានធ្វើឱ្យតំបន់នេះមានសំណង់ថ្មីចាប់ផ្ដើមកើតឡើងជាបន្តបន្ទាប់ ជំនួសឱ្យផ្ទះឈើ និងធ្វើឱ្យតំបន់នេះកាន់តែមានសភាពអ៊ូអរឡើង ព្រោះឋិតនៅជិតផ្សារអូឡាំ-ពិច ដែលជាផ្សារលក់ទំនិញបោះដុំច្រើនជាងទំនិញលក់រាយ និងជាទីតាំងចែកចាយទំនិញសម្រាប់នាំចេញទៅតាមខេត្តនានា។ ផ្សារអូឡាំពិចបច្ចុប្បន្នជាសំណង់ ដែលទើបបានសាងសង់ឡើងវិញលើទីតាំងចាស់ និងបានដាក់ឱ្យប្រើប្រាស់ក្នុងអំឡុងឆ្នាំ ១៩៩៤ ធ្វើឱ្យតំបន់ទាំងនេះក្លាយជាតំបន់លំនៅឋានចម្រុះគ្នានឹងតំបន់ពាណិជ្ជកម្មមានសភាពអ៊ូអរណែនណាន់តាន់តាប់ និងចរាចរទៅមកតាមផ្លូវគ្រប់ច្រកល្ហក។

រាជធានីភ្នំពេញនាសម័យមុនឆ្នាំ១៩៧០ តំបន់ពាណិជ្ជកម្មដែលមានសកម្មភាពមមាញឹកខ្លាំង គឺឋិតនៅម្ដុំផ្សារចាស់ បន្ទាប់មកនៅតាមដងមហាវិថីព្រះមុនីវង្សភ្ជាប់ដល់មហាវិថីស្បាលដឹហ្គោល ជាតំបន់ផ្ទះល្វែង និងជាតំបន់ពាណិជ្ជកម្ម មានសកម្មភាពអ៊ូអរ។

ដើម្បីជានិមិត្តរូប និងជាអនុស្សាវរីយ៍នៃការទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ ១៩៥៣ រាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម បានស្ថាបនាវិមានឯករាជ្យ ដើម្បីរំឭកដល់វិញ្ញាណខន្ធរបស់បុព្វការីជន ដែលបានពលីជីវិតដើម្បីជាតិមាតុភូមិ។ នៅត្រង់វិមាននេះ មានសួនច្បារលម្អដោយអាងបាញ់ទឹក និងជាទីដែលមានផ្លូវប្រសព្វគ្នាដល់ទៅប្រាំមួយ។


www.elibraryofcambodia.org

www.elibraryofcambodia.org

## ជំពូក៥

## នគរូបនីយកម្មចុងទសវត្សឆ្នាំទី៨០ នៃសតវត្សទី២០ និង ទសវត្សឆ្នាំទី១០ នៃសតវត្សទី២១

យើងសាកល្បងធ្វើការសិក្សា ពីគរូបនីយកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្រោមទ្រង់ទ្រាយនៃភូមិវិទ្យាទីក្រុង និងដំណើររីកចម្រើននៃរាជធានី ឬទីក្រុងនានា មានក្រុងភ្នំពេញ ឬរាជធានីភ្នំពេញ ក្រុងអង្គរដែលជាក្រុងប្រវត្តិសាស្ត្រ និងខេត្តក្រុងមួយចំនួនទៀតនៅទូទាំងប្រទេស។ យើងអាចមើលឃើញពីលក្ខណៈរូបនៃដំណើរនគរូបនីយកម្មនៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលបានរំលេចឱ្យឃើញនៅក្នុងសៀវភៅប្រវត្តិនគរូបនីយកម្មលើពិភពលោក និងដំណើរប្រព្រឹត្តទៅនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានផ្នែកខ្លះប្រហាក់ប្រហែលគ្នានឹងដំណើរកើតឡើងនៃទីក្រុង និងមានផ្នែកខ្លះទៀត មានលក្ខណៈខុសប្លែកពីបណ្តាប្រទេសនានាលើពិភពលោក ទៅតាមប្រវត្តិសាស្ត្ររបស់ប្រទេសនីមួយៗ។

លក្ខណៈពិសេស ដែលមានចរិតជាក្រិត្យក្រមនៃនគរូបនីយកម្មនៅប្រទេសកម្ពុជាមួយភាគធំបានស្តែងឡើងជាក់ស្តែងក្នុងប្រវត្តិសាស្ត្រ និងគួរឱ្យកត់សម្គាល់គឺមានទីក្រុងសម័យអង្គរ (បច្ចុប្បន្នមានទីតាំងឋិតនៅតំបន់ពាយ័ព្យក្នុងខេត្តសៀមរាប) និងទីក្រុងសម័យចតុមុខ (រាជធានី ឬទីក្រុងភ្នំពេញ)សព្វថ្ងៃ។



www.elibraryofcambodia.org

## ១-ការសិក្សាពីនិយមន័យ ទីប្រជុំជន និងទីជនបទផ្សារភ្ជាប់នឹងបរិបទនៃបណ្ដុំប្រជាជនក្រុង

ពាក្យទីប្រជុំជន គឺផ្ទុយគ្នានឹងពាក្យទីជនបទ ការចាត់ថ្នាក់របស់ពាក្យនេះ ត្រូវបានធ្វើឡើងតាមប្រទេសនីមួយៗលើពិភពលោក។ ដោយឡែកនៅប្រទេសកម្ពុជា ការចាត់ថ្នាក់ពាក្យទីប្រជុំជនមិនសំដៅសម្រាប់បម្រើឱ្យការស្រាវជ្រាវឡើយ គឺជាពាក្យដែលប្រើក្នុងគោលបំណងសម្រាប់ការរៀបចំផែនការតែប៉ុណ្ណោះ។ ក្រសួងផែនការមានភារកិច្ចធ្វើផែនការរដ្ឋ ដោយសំដៅប្រមូលផ្ដុំនូវរាល់ទិន្នន័យទាំងអស់របស់រដ្ឋ ហើយធ្វើការវិភាគពិចារណាសំដៅដាក់ចេញផែនការ និងឈរលើមូលដ្ឋាននៃទិន្នន័យដែលទទួលបានពីជំរឿនតាមបណ្ដាឆ្នាំ និងតាមការអង្កេតប្រជាសាស្ត្រ។

ជំរឿនប្រជារាស្ត្រ គឺជាការរាប់ប្រជាជនទាំងអស់នៅទូទាំងប្រទេស ដែលមានលក្ខណៈបច្ចេកទេស និងគ្រប់ជ្រុងជ្រោយតាមបែបវិទ្យាសាស្ត្រ ដោយត្រូវបានធ្វើឡើងលើកទី១ ក្នុងឆ្នាំ១៩៦២ ហើយបន្ទាប់ពីនោះមក ប្រទេសកម្ពុជាត្រូវខកខានក្នុងការធ្វើជំរឿនប្រជារាស្ត្រអស់រយៈពេលជាងបីទសវត្ស ដោយសារសង្គ្រាមស៊ីវិល។ ព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្ដើមធ្វើជំរឿនប្រជារាស្ត្រលើកទី២ នៅឆ្នាំ១៩៩៨ គឺនៅពេលដែលប្រទេសមានសុខសន្តិភាព និងមានការបង្រួបបង្រួមជាតិ រវាងបងប្អូនខ្មែរក្រហមឱ្យមករួមរស់ក្នុងសង្គមគ្រួសារតែមួយ។ ជាបន្តបន្ទាប់មក ក្នុងរយៈពេលដប់ឆ្នាំម្តង រាជរដ្ឋាភិបាលបានធ្វើជំរឿនប្រជារាស្ត្រលើកទី៣ នៅឆ្នាំ២០០៨។

ជំរឿនប្រជារាស្ត្រនៅឆ្នាំ ១៩៩៨ បានចាត់ថ្នាក់ពាក្យ **ទីប្រជុំជន** ទៅតាមចំណុចដូចខាងក្រោម:



www.elibraryofcambodia.org

-គ្រប់ទីរួមខេត្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាចំណុះឱ្យស្រុក

-រាជធានីភ្នំពេញមានខណ្ឌចំនួនបួននិងស្រុកចំនួនបី

-ព្រះរាជាណាចក្រកម្ពុជាមានក្រុងចំនួនបី គឺក្រុងព្រះសីហនុ ក្រុងកែប និងក្រុងប៉ៃលិន ដោយត្រូវបានចាត់បញ្ចូលក្នុងលំដាប់ជាទីប្រជុំជនទាំងអស់។ ការចាត់ថ្នាក់ឬការឱ្យនិយមន័យពីទីប្រជុំជនដូចបានបង្ហាញខាងលើនេះ គឺបានផ្អែកលើលក្ខណៈរដ្ឋបាល ដែលធ្វើឱ្យលទ្ធផលនៃទិន្នន័យបានពីជំរឿនមិនអាចធ្វើការវិភាគពីទីប្រជុំជនឱ្យបានសមស្របឡើយ។

បើពិនិត្យលើចំណុចទី១ យើងសង្កេតឃើញថា ទីរួមខេត្តនានានៅទូទាំងប្រទេសដែលភាគច្រើនដីធ្លីឋិតនៅជុំវិញទីរួមខេត្តជាដីកសិកម្ម និងមានដង់ស៊ីតេប្រជាជនទាបចំណុះឱ្យស្រុក។ បើពិនិត្យមើលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះវិញ គេអាចសង្កេតឃើញថាពួកគាត់មួយចំនួននៅពឹងផ្អែកលើវិស័យកសិកម្ម ជាពិសេសប្រជាជនដែលរស់នៅតាមតំបន់ឋិតនៅជាយទីរួមខេត្តឬទីប្រជុំជនខេត្ត។

ចំពោះចំណុចទី២វិញ ទីក្រុងភ្នំពេញឬរាជធានីភ្នំពេញទាំងមូល មិនទាន់បានចាត់ទុកប្រជាជនទូទាំងក្រុង ជាអ្នកក្រុងទាំងអស់នៅឡើយទេ ពីព្រោះមានស្រុកបី គឺស្រុកដង្កោ ស្រុកមានជ័យ និងស្រុកឫស្សីកែវ ត្រូវបានហៅថា ស្រុក មានន័យថាប្រជាជនទាំងនោះរស់នៅក្នុងតំបន់ជាយក្រុងនៃទីក្រុងភ្នំពេញ ដែលជីវភាពរស់នៅរបស់ពួកគាត់បង្ហាញឱ្យឃើញពីរបៀបរស់នៅភាគច្រើនគឺជាអ្នកជនបទ។

បើពិនិត្យមើលទៅលើចំណុចទី៣ ព្រះរាជាណាចក្រកម្ពុជាមានក្រុងចំនួន៣ គឺក្រុងព្រះសីហនុ ក្រុងកែបនិងក្រុងប៉ៃលិន ហើយក្រុងទាំងបីនេះ ត្រូវបានចាត់



www.elibraryofcambodia.org

បញ្ចូលក្នុងលំដាប់ជាទីប្រជុំជនទាំងអស់។ តែជាក់ស្តែងនៅឆ្នាំ១៩៩៨ ជាឆ្នាំជំរឿនលើកទី២ តាមការចុះទៅពិនិត្យជាក់ស្តែងលើការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងក្រុងទាំងបីនោះវិញ យើងសង្កេតឃើញថាជីវភាពរស់នៅរបស់ពួកគាត់ក្នុងក្រុងមិនទាន់អាចចាត់ថ្នាក់ថាជាអ្នកក្រុងទាំងអស់បានឡើយ ពីព្រោះជីវភាពរបស់ប្រជាពលរដ្ឋទាំងនោះនូវមានការប្រកបមុខរបរទទួលទានប្រចាំថ្ងៃ ដោយពឹងផ្អែកលើរបរកសិកម្ម ហើយជីវភាពពួកគាត់រស់នៅមានលក្ខណៈជាអ្នកជនបទ។ នៅក្រោមផ្ទះរបស់ពួកគាត់មានឧបករណ៍ផលិតកម្ម និងកម្លាំងអូសទាញសម្រាប់បម្រើឱ្យវិស័យកសិកម្មមានដូចជា នង្គ័ល រនាស់ គោ ក្របី សំណាញ់ ទូកនេសាទ។ល។ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់ជាយក្រុងមាន ខណ្ឌព្រៃនប់ ខណ្ឌស្ទឹងហាវ ក្នុងក្រុងព្រះសីហនុ និងខណ្ឌសាលាក្រៅក្នុងក្រុងប៉ៃលិន។

យើងអាចធ្វើការកត់សម្គាល់នូវភាពខុសគ្នាពីរគឺក្រុងព្រះសីហនុ មានខណ្ឌមិត្តភាពដែលអាចវាយតម្លៃថាជាទីប្រជុំជន ចំណែកខណ្ឌព្រៃនប់ និងខណ្ឌស្ទឹងហាវប្រជាជនរស់នៅមានកម្រិតជីវភាពជាអ្នកជនបទនៅឡើយ។ ឯក្រុងប៉ៃលិនវិញ មានខណ្ឌបី តែក្នុងចំណោមខណ្ឌទាំងបីនោះ មានតែខណ្ឌប៉ៃលិនមួយប៉ុណ្ណោះ ដែលអាចចាត់ថ្នាក់ជាទីប្រជុំជនបាន ចំណែកខណ្ឌ ២ ទៀត ប្រជាជននូវមានកម្រិតជីវភាពរស់នៅជាអ្នកជនបទ។ ចំពោះក្រុងកែប ក៏មានលក្ខណៈមិនខុសគ្នានឹងក្រុងព្រះ-សីហនុ និងក្រុងប៉ៃលិនដែរ។

អាស្រ័យហេតុនេះទើបក្រសួងផែនការបានធ្វើការពិចារណាឡើងវិញ ដោយកំណត់យកការធ្វើចំណាត់ទីប្រជុំជនក្នុងកិរិតរដ្ឋបាលនៅថ្នាក់ឃុំ ដែលអាចទទួលបានលទ្ធផលប្រសើរជាងមុន សម្រាប់ការរៀបចំផែនការ។ ក្រសួងផែនការចង់កំណត់និយមន័យនេះដល់ថ្នាក់ភូមិតែមិនអាចធ្វើទៅកើត ព្រោះភូមិមួយចំនួននៅ



www.elibraryofcambodia.org

មិនទាន់កំណត់ឱ្យបានច្បាស់លាស់លើព្រំប្រទល់រដ្ឋបាលនៅឡើយ ដែលអាចមានភូមិខ្លះនឹងត្រូវបំបែកជាពីរភូមិឬត្រូវរួមបញ្ចូលគ្នា អាស្រ័យលើស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ។

នៅខែវិច្ឆិកា ឆ្នាំ២០០៤ ក្រសួងផែនការ បានចាត់ថ្នាក់និយមន័យទីប្រជុំជនឡើងវិញ ដោយផ្អែកលើការសិក្សាជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ និងដោយពិនិត្យគ្រប់ទិដ្ឋភាពដែលបានចុះទៅសិក្សាជាក់ស្តែងនៅមូលដ្ឋានផងនោះ លទ្ធផលនៃការសិក្សាមួយដែលមានលក្ខណៈសមស្រប អាចទទួលយកបាន គឺនិយមន័យពីប្រជាជនទីប្រជុំជនត្រូវបានសម្រេចឡើងក្នុងកិរិតរដ្ឋបាលឃុំមាន៖

១-សរុបប្រជារាស្ត្រនៅក្នុងឃុំទាំងមូលលើសពី២០០០នាក់។

២-ដង់ស៊ីតេប្រជាជនយ៉ាងតិច២០០នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

៣-ចំនួនបុរសធ្វើការងារក្នុងវិស័យកសិកម្មតិចជាង៥០ភាគរយ។

ជំរឿនឆ្នាំ១៩៩៨ បានយកតាមនិយមន័យចាស់មានប្រជារាស្ត្រទីប្រជុំជន ១៥,៧ភាគរយ បើសម្រួលយកតាមនិយមន័យកែសម្រួល (ឆ្នាំ២០០៤[៣៤] កម្ពុជាមានប្រជារាស្ត្រទីប្រជុំជនចំនួន២,០៣លាន នាក់ស្មើនឹង១៧,៦ភាគរយនៃប្រជារាស្ត្រសរុប។ ផ្អែកលើនិយមន័យកែតម្រូវនេះ ត្រូវបានក្រសួងផែនការយកមកប្រើ

---

[៣៤] - ក្រសួងផែនការបានចាប់ផ្តើមធ្វើការកែសម្រួលនិយមន័យឡើងវិញ ព្រោះនិយមន័យដែលបានធ្វើឡើងនៅឆ្នាំ ១៩៩៨ មិនទាន់មានលក្ខណៈច្បាស់លាស់ និងមិនគ្នាស៊ីគ្នារវាងទីក្រុងភ្នំពេញ (ស្រុកដង្កោ ស្រុកមានជ័យ ស្រុកឫស្សីកែវ) និងខណ្ឌពីរនៅក្រុងព្រះសីហនុ ក្រុងប៉ៃលិន និង ក្រុងកែប។ ហេតុនេះ ចាំបាច់ត្រូវធ្វើការកែសម្រួលនិយមន័យឡើងវិញ។ ជំរឿនប្រជារាស្ត្រនៅឆ្នាំ២០០៨ មាននិយមន័យទីប្រជុំជន ដែលមានលក្ខណៈសមស្របអាចទទួលយកបាន។



www.elibraryofcambodia.org

ក្នុងជំរឿនឆ្នាំ២០០៨ ដែលមានប្រជាភាស្ត្រទីប្រជុំជនចំនួន២,៦១លាននាក់ ស្មើនឹង ១៩,១ភាគរយនៃប្រជាភាស្ត្រសរុបចំនួន១៣,៤លាននាក់។ ដូច្នេះក្នុងរយៈពេល១០ ឆ្នាំ នៃចន្លោះពេលធ្វើជំរឿនរវាងឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ ចំនួនប្រជាជនទីប្រជុំជន បានកើនឡើងដល់ទៅ១,៩០ភាគរយ ជាពិសេសមានការកើនឡើង នូវប្រជាជន ក្នុងទីក្រុងភ្នំពេញមានចំនួន២៩១៨៦៨នាក់។ការកើនឡើងនៃចំនួនប្រជាជនទីក្រុង ភ្នំពេញនេះ បានបង្ហាញឱ្យឃើញពីដំណើររីកធំធាត់នៃនគរូបនីយកម្មនាពេល បច្ចុប្បន្ន ជាពិសេសពេលដែលព្រះរាជាណាចក្រកម្ពុជាមានសុខសន្តិភាពពេញលេញ មានស្ថិរភាពនយោបាយ និងមានកំណើនសេដ្ឋកិច្ចឈានឡើង រហូតដល់ពីរខ្ទង់ នៅ ចន្លោះឆ្នាំ២០០៤ ទៅឆ្នាំ២០០៧។

ចលនាបម្លាស់ទីប្រជាជនចូលក្រុងភ្នំពេញ ចេះតែបន្តកើនឡើងដែលអាចឱ្យ យើងមើលឃើញពីការរីកធំធាត់ឡើងផ្នែកសំណង់លំនៅឋានផ្ទះល្វែង និងលំនៅ ឋានមានលក្ខណៈភូមិគ្រឹះ បានផុសឡើងយ៉ាងលឿនដើម្បីបំពេញតម្រូវការរបស់ មនុស្សដែលចូលមករស់នៅក្នុងក្រុង ក៏ដូចជាអ្នកដែលបានកើតឡើងក្រោយសម័យ ប្រទេសបានរំដោះផុតពីរបបកាប់សម្លាប់ ហើយជំនាន់នៃមនុស្សទាំងនោះបានចូល មកដល់ដំណាក់កាលអាយុធំពេញវ័យ ត្រូវមានគូរស្រករ ត្រូវបែកចេញពីគ្រួសារធំ មករស់នៅក្នុងគ្រួសារទំហំមធ្យមឬគ្រួសារតូច។

នៅខែកញ្ញា ឆ្នាំ២០១១ ក្រសួងផែនការបានធ្វើសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការសិក្សារៀបចំតំបន់ទីប្រជុំជនឡើងវិញ ដើម្បីឈានទៅកំណត់លក្ខណៈ វិនិច្ឆ័យទីប្រជុំជន ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ។ តាមការ ពិភាក្សាបានរកឃើញនូវលក្ខណៈវិនិច្ឆ័យចំនួនពីរគឺ:



www.elibraryofcambodia.org

### ១.១-ការកំណត់លក្ខណៈវិនិច្ឆ័យទីប្រជុំជនឡើងវិញ៖

- ដោយតំបន់ទីប្រជុំជន យកត្រឹមកម្រិតឃុំ

- ក្នុងនិយមន័យចាស់ឆ្នាំ២០០៨ ការកំណត់ទីប្រជុំជនគឺផ្អែកលើលក្ខណៈវិនិច្ឆ័យបីដូចបានរៀបរាប់ខាងលើ តែក្រោយជំរឿនឆ្នាំ ២០០៨ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានធ្វើការសិក្សាឡើងវិញ នូវលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ទីប្រជុំជន និងកំណត់ចំនួនទីប្រជុំជនឡើងវិញ ដោយបានរកឃើញថា លក្ខណៈវិនិច្ឆ័យទី១ និងលក្ខណៈវិនិច្ឆ័យទី២ ត្រូវរក្សាទុកដដែល ដោយឡែកលក្ខណៈវិនិច្ឆ័យទី៣ ត្រូវកែមកជា **ចំនួនបុរស និងស្ត្រីធ្វើការងារក្នុងវិស័យកសិកម្មតិចជាង ៥០ភាគរយ ។**

### ១.២-ការកំណត់ចំនួនទីប្រជុំជននៅទូទាំងប្រទេស៖

- ចំនួនឃុំជាទីប្រជុំជននៅទូទាំងប្រទេសមានចំនួន១ ៤១៧

- សុំឱ្យតំណាងក្រសួងពាក់ព័ន្ធដែលចូលរួម ជាពិសេសតំណាងមន្ទីរពាក់ព័ន្ធរាជធានី ខេត្តជួយពិនិត្យឡើងវិញ និងជួយផ្តល់យោបល់កែសម្រួល ក្នុងករណីមានការសរសេរលេខកូដខុសឬកំហុសដទៃទៀត ។

សិក្ខាសាលាពិគ្រោះយោបល់នេះ មានជាសំណួរលើកឡើងមួយចំនួនពីក្រសួងពាក់ព័ន្ធ ដូចជាក្រសួងគមនាគមន៍ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់៖

-ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ចរាចរ ក្នុងការកំណត់ល្បឿននៅទីប្រជុំជន

-ពាក់ព័ន្ធនឹងការយកពន្ធពោលគឺតម្លៃពន្ធក្នុងទីប្រជុំជន និងទីជនបទមានលក្ខណៈខុសគ្នាដូចម្តេច



www.elibraryofcambodia.org

-គោលបំណងក្នុងការកំណត់ទីប្រជុំជនមានអ្វីខ្លះ ឬការកំណត់ទីប្រជុំជនដើម្បីគោលដៅ ដោយតម្រូវឱ្យគ្រប់ក្រសួងស្ថាប័នទាំងអស់សម្រាប់រៀបចំផែនការតាមវិស័យដូចជាសម្រាប់ការកំណត់ទំហំដីចំណីផ្លូវថ្នល់ ផ្លូវដែក និងការកំណត់ល្បឿនចរាចរ... សម្រាប់ជាមូលដ្ឋានគោលដៅពន្ធដារ សម្រាប់តំបន់ទីប្រជុំជនក្នុងការកំណត់សេវាសុរិយោដី ការធ្វើផែនការប្រើប្រាស់ដីធ្លី តំបន់សាងសង់មានលំនៅឋាន សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាពឬប៉ុស្តិ៍សុខភាព...។ បន្ថែមពីលើការងារនេះ តាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៅព្រះរាជាណាចក្រកម្ពុជា បានតម្រូវឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រៀបចំជាអនុក្រឹត្យ ស្តីពីនគរូបនីយកម្មរាជធានី ទីក្រុង និងទីប្រជុំជន ដែលក្នុងន័យនេះ តើទីប្រជុំជន ដែលលើកឡើងខាងលើ គឺជាមុខសញ្ញាសម្រាប់ការអនុវត្តអនុក្រឹត្យនេះឬយ៉ាងណា ? នេះជាសំណួរដែលក្រសួងផែនការ ក៏ដូចជាអង្គសិក្ខាសាលាត្រូវធ្វើការពិចារណា។

## ២-ចំណាត់ថ្នាក់ទីក្រុងនិងមុខងារ

ទោះបីជានៅសម័យមុនអង្គរ និងសម័យអង្គរ[៣៩] ក្រុងអង្គរមានសកម្មភាពជាទីប្រជុំជនក៏ពិតមែន តែនគរូបនីយកម្មនេះ ស្តែងឡើងបែបជាទីប្រមូលផ្តុំសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេស ដែលមានលក្ខណៈជាទីប្រជុំជនភូមិ។ នគរូបនីយកម្មនៅកម្ពុជាដែលមានលក្ខណៈពេញលេញ អាចចាប់ផ្តើមឡើងបន្តិចម្តងៗនៅក្រោយឆ្នាំ១៩៥៤ ដោយមធ្យោបាយសម្ភារៈមិនទាន់គ្រប់គ្រាន់ ប៉ុន្តែយុគសម័យសិប្បកម្មបានផ្តាច់ចេញពីឧស្សាហកម្មដែលជាការរំដោះចេញដំបូងនៃដំណើរនគរូបនីយកម្ម។

[៣៩] -ពាក្យអង្គរគឺមានន័យថាក្រុង (Wikipedia)។



www.elibraryofcambodia.org

ការផ្តាច់ចេញទីក្រុងពីជនបទ គឺជាលទ្ធផលនៃដំណើរវិវត្តន៍ជំហានថ្មីមួយ នៃការបែងចែកកម្លាំងពលកម្ម ។

នៅពេលដែលព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យពីបារាំង ទីក្រុងនៅកម្ពុជា មានប្រជាជនក្រុងតែ១០ភាគរយនៃប្រជាជនទូទាំងប្រទេសប៉ុណ្ណោះ ។ នេះជាភស្តុតាងមួយ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីភាពទន់ខ្សោយនៃផលិតកម្មឧស្សាហកម្ម ។ ក្រោយឆ្នាំ១៩៥៤ ការរីកចម្រើននៃកម្លាំងផលិតកម្ម បាននាំមកនូវនគរូបនីយកម្មលូតលាស់យ៉ាងឆាប់រហ័ស ។ ទាក់ទងទៅនឹងដំណើរឧស្សាហូបនីយកម្ម ធ្វើឱ្យដំណើរនគរូបនីយកម្មត្រូវបានជំរុញខ្លាំងដែលសព្វថ្ងៃនេះ ទីក្រុងកាន់តែមានអត្ថន័យធំធេង និងមានតួនាទីសំខាន់ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ។

**រូបទី៤២ :** រាជវាំងនៅក្រុងភ្នំពេញឆ្នាំ១៨៨៥





www.elibraryofcambodia.org

រូបទី៤៣ៈរាជវាំងនៅឆ្នាំ១៩៣១ និងហ្វូងដំរីរបស់រាជវាំង



រូបទី៤៤ៈរាជវាំងនៅឆ្នាំ១៩៩៣



តាមរូបទី៤២-៤៣-៤៤ បង្ហាញពីវាំងស្ដេចនៅតាមបណ្ដាឆ្នាំមានលក្ខណៈនិងបង្ហាញពីខុសគ្នាដំណើរឈានឡើងនគរូបនីយកម្ម និងបង្ហាញឱ្យឃើញពីទំហំទីក្រុងផងដែរ ។



www.elibraryofcambodia.org

យោងលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ត្រង់មាត្រា៤ និងមាត្រា៥ ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញត្រូវចែកជាខណ្ឌ ហើយខណ្ឌត្រូវបែងចែកជាសង្កាត់។ ចំពោះទីក្រុងភ្នំពេញត្រូវបានប្តូរមកជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ឯក្រុងព្រះសីហនុ ក្រុងកែប និងក្រុងប៉ៃលិនត្រូវប្តូរមកជាខេត្ត និងមានការប្រែប្រួលលើព្រំដែនរដ្ឋបាលខ្លះ ដោយត្រូវកាត់បញ្ចូលនូវស្រុកមួយចំនួន។ ដោយឡែកយោងតាមច្បាប់នេះ ខេត្តត្រូវបែងចែកជាក្រុងនិងស្រុក ហើយក្រុងត្រូវចែកជាសង្កាត់ ឯស្រុកត្រូវចែកជាឃុំនិងសង្កាត់។ បើផ្អែកលើពាក្យថា **ក្រុង ខណ្ឌ និង សង្កាត់** នោះអ្នកដែលកំពុងរស់នៅតាមទីតាំងទាំងនោះ អាចចាត់ថ្នាក់ថា ជាអ្នកក្រុង ឬអ្នកទីប្រជុំជន ហើយដែលអាចធ្វើឱ្យចំនួនអ្នកក្រុងនឹងកើនឡើង។ តាមទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្នុងជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ ព្រះរាជាណាចក្រកម្ពុជាមានចំនួនអ្នកក្រុងដល់ទៅ១៩,១ភាគរយ បើតាមការចាត់ថ្នាក់របស់ច្បាប់ថ្មីនេះ នោះចំនួនអ្នកក្រុងនៅព្រះរាជាណាចក្រកម្ពុជាតាមជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ នឹងមានប្រជាជនក្រុងកើនឡើង។ ដូចនេះចំនួនអ្នកក្រុងអាចប្រែប្រួល អាស្រ័យលើការឱ្យនិយមន័យ ទៅតាមករណីរបស់ប្រទេសនីមួយៗ។

ប្រជាជនកម្ពុជាតែងចងចាំជានិច្ច នូវរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានផ្តួលរំលំដោយកងទ័ពរណសិរ្សរំដោះជាតិកម្ពុជា នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃផ្តល់កំណើតទី២ឱ្យដល់ប្រជាជនកម្ពុជាទូទាំងប្រទេស។ របបនេះបានបន្សល់ទុកនូវការឈឺចាប់ដល់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ និងបន្សល់នូវស្លាក



www.elibraryofcambodia.org

ស្ពានជាកម្ទេចចផេះផង់ ដែលរដ្ឋាភិបាលក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិ បានស្រោចស្រង់ស្តារ និងកសាងឡើងវិញ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបដីធ្លីត្រូវបានផ្លាស់ប្តូរទាំងស្រុង។ កម្ពុជាសម័យនោះ មិនមានច្បាប់ស្តីពីទ្រព្យសម្បត្តិទេ ហើយឯកសារនានាក៏ត្រូវបានបំផ្លាញចោល ដែរ។ កម្មសិទ្ធិឯកជនលើដីធ្លីត្រូវបានហាមឃាត់។ អចលនវត្ថុរួមជាមួយផលិតផល ដែលជាទ្រព្យសម្បត្តិទូទៅសំខាន់ៗផ្សេងៗទៀត គឺជាទ្រព្យសម្បត្តិរបស់សមូហភាព[៣៦]។ នេះជាបញ្ហាប្រឈមមួយ ដែលប្រជាជនលើសកលលោកមិនមានវាសនា ដូចប្រជាជនកម្ពុជាឡើយ។

ផ្អែកលើតួនាទីសំខាន់នៃទីក្រុងនៅព្រះរាជាណាចក្រកម្ពុជា យើងអាចធ្វើចំណាត់ថ្នាក់ប្រភេទទីក្រុងនៅប្រទេសយើងដូចតទៅ:

១-ក្រុងភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ជាតំបន់ប៉ូលសេដ្ឋកិច្ចទី១ សំខាន់បំផុតក្នុងប្រទេស ជាក្រុងក្បាលម៉ាស៊ីនដឹកនាំប្រទេសទាំងនយោបាយ និង រដ្ឋបាល...។

២-ក្រុងសៀមរាបជាទីក្រុងបូរាណ និងមានតួនាទីជាទីក្រុងប៉ូលសេដ្ឋកិច្ចទី២ បន្ទាប់ពីក្រុងភ្នំពេញ និងបម្រើឱ្យវិស័យទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ។

៣-ក្រុងព្រះសីហនុជាទីក្រុងប៉ូលសេដ្ឋកិច្ចទី៣ ជាក្រុងតំបន់កំពង់ផែសមុទ្រ ដែលមានតួនាទីលេចធ្លោជាងគេ ក្នុងចំណោមក្រុងបីទៀត (ក្រុងកោះកុង ក្រុងកែប ក្រុងកំពត) បម្រើឱ្យវិស័យឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិ (អេកូទេសចរណ៍)។

---

[៣៦] - មាត្រា ២ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។



www.elibraryofcambodia.org

៤-ក្រុងផ្សេងទៀតនៅតាមបណ្តាខេត្ត ពីមុនមានតួនាទីជាទីរួមខេត្តក្នុងចំណោមខេត្តទាំង ២៣ ដែលបច្ចុប្បន្នទីរួមខេត្តទាំងនេះកំពុងអភិវឌ្ឍ និងប្រែក្លាយជាទីក្រុង។

៥-ក្រុងដែលទើបបង្កើតថ្មី៣ (ក្រុងសួង ក្រុងបាវិត ក្រុងប៉ោយប៉ែត) ជារួមក្រុងទាំងនេះ ពីមុនមានចំណាត់ថ្នាក់ត្រឹមជាទីរួមស្រុកប៉ុណ្ណោះ តែបច្ចុប្បន្នរាជរដ្ឋាភិបាលបានបង្កើតឡើង ដោយផ្អែកលើតួនាទីរបស់ក្រុងដែលប្រជាជនទាំងពីរភេទមានការងារធ្វើផ្តោតសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្ម។ ក្រុងប៉ោយប៉ែត និងក្រុងបាវិត ជាក្រុងដែលជាច្រកទ្វារអន្តរជាតិរវាងប្រទេសថៃ និងប្រទេសវៀតណាម។

ក្រៅពីនេះនៅមានទីប្រជុំជនផ្សេងៗទៀត ដែលមានកម្រិតឋិតនៅតាមស្រុក ឃុំ សង្កាត់។

## ៣-គោលនយោបាយ និងក្របខណ្ឌគតិយុត្តមួយចំនួននៅកម្ពុជា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នៅពេលដែលសង្គមជាតិកាន់តែមានការវិវត្តស្មុគ្រស្មាញ ពេលនោះសង្គមពិតជាត្រូវការវិធានថ្មីកាន់តែច្រើនទៀត។ ចាប់ពីឆ្នាំ១៩៨៩ កម្ពុជាបានធ្វើដំណើរមកដល់ផ្លូវមួយ ដែលជារបត់នៃការឈានឡើងមួយទៀតជាពិសេសលើកំណែទម្រង់សេដ្ឋកិច្ច។ ដំណើរនៃការឈានឡើងដោយប្រុងប្រយ័ត្ននេះ បានធ្វើឱ្យកម្ពុជាប្តូរពីសាធារណរដ្ឋប្រជាមានិតកម្ពុជា មកជារដ្ឋកម្ពុជា (ឆ្នាំ១៩៧៩-ឆ្នាំ១៩៨៩)។ ប៉ុន្តែក្នុងឆ្នាំ១៩៨៩ មានការកែទម្រង់មុនការអនុម័តច្បាប់រដ្ឋធម្មនុញ្ញថ្មីបន្តិច តាមរយៈការអនុម័តអនុក្រឹត្យលេខ២៥អនក្រ.បក.ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ ស្តីពី


www.elibraryofcambodia.org

ការផ្តល់សិទ្ធិកម្មសិទ្ធិលើផ្ទះសម្បែងជូនប្រជាជន[៣៧] ។ ក្រោយមកទៀត តាមរយៈការអនុម័តសេចក្តីណែនាំលេខ០៣សណន.ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ស្តីពីការអនុវត្តគោលនយោបាយប្រើប្រាស់ និងគ្រប់គ្រងដីធ្លីបានទទួលស្គាល់សិទ្ធិ កម្មសិទ្ធិលើលំនៅឋាន។ សេចក្តីណែនាំលេខ០៣ នៅមាត្រា១០ បានបញ្ជាក់អះអាងជាគោលការណ៍ថាភោគៈ ត្រូវតែពាក់ព័ន្ធជាសំខាន់ទៅនឹងការប្រើប្រាស់ដី ចំពោះដីស្រែ និងដីកសិកម្ម។ ឯដីភោគៈ រដ្ឋបានកំណត់ត្រឹមតែ ៥ ហិចតាប៉ុណ្ណោះ។ សេចក្តីណែនាំនេះ ចែងអំពីភោគៈ ដែលបានផ្តល់ជូនប្រជាជនក្នុងទម្រង់ជាដីសម្បទាន។

នៅសម័យរដ្ឋកម្ពុជាពី(ឆ្នាំ១៩៨៩ដល់ឆ្នាំ១៩៩៣) នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ភូមិបាលថ្មី (ច្បាប់ភូមិបាលឆ្នាំ១៩៩២[៣៨])។ ច្បាប់នេះបានបញ្ជាក់ថា មានតែដីលំនៅឋានមួយគត់ដែលអាចជាកម្មវត្ថុនៃកម្មសិទ្ធិឯកជន និងថា ដីនៅក្នុងតំបន់ទីក្រុងនឹងត្រូវបញ្ញត្តិតាមច្បាប់ដោយឡែក។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រា៦ បានចែងថា ទីក្រុងភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។

នៅឆ្នាំ១៩៩៨ ក្រោមពាក្យស្លោក "**គ្មានអ្នកឈ្នះ គ្មានអ្នកចាញ់ ប្រជាជនកម្ពុជាជាអ្នកឈ្នះទាំងអស់គ្នា**" នោះគឺនយោបាយ **ឈ្នះ ឈ្នះ** ដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជា មាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវគោលនយោបាយនេះ និងធ្វើឱ្យប្រទេសមានសុខសន្តិភាព ស្ថិរភាពនយោបាយ

[៣៧] - មាត្រា១ នៃអនុក្រឹត្យនេះ ចែងអំពីប្រភេទនៃកម្មសិទ្ធិសមូហភាពលើដីលំនៅឋាន និងមាត្រា២ នៃអនុក្រឹត្យបានធ្វើការកែប្រែយ៉ាងច្រើន ដោយចែងថាប័ណ្ណកម្មសិទ្ធិលើផ្ទះសម្បែង អាចចេញជូនបុគ្គលម្នាក់ៗ ហើយប័ណ្ណលើផ្ទះសម្បែងនេះ អាចធ្វើការផ្ទេរតាមរយៈមរតកសាសន៍ ឬការលក់។

[៣៨] - សម័យរដ្ឋកម្ពុជាពីឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៣។



www.elibraryofcambodia.org

ដែលជាកាលានុវត្តភាពមួយ ផ្តល់ឱ្យប្រជាជនកម្ពុជាចាប់ផ្តើមផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យដីធ្លី ដើម្បីធ្វើការដាំដុះបង្កបង្កើនផលជំរុញខឿនសេដ្ឋកិច្ចជាតិ។

នៅពេលដែលសង្គមជាតិកាន់តែមានការអភិវឌ្ឍ នោះសង្គមពិតជាត្រូវការនូវវិធានថ្មីកាន់តែច្រើនដើម្បីអនុវត្ត។ រាជរដ្ឋាភិបាលកម្ពុជានៅអាណត្តិទី២នៃរដ្ឋសភាជាតិ បានបង្កើតច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមព្រះរាជក្រមលេខនស/រកម/០៦៩៩/០៩ អនុម័តថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ ដែលច្បាប់នេះរួមមាន៦មាត្រា។ យោងតាមមាត្រា១ និងមាត្រា២ នៃច្បាប់នេះ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតឡើងដោយមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា៣នៃច្បាប់នេះ ក្រសួងត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់។ រដ្ឋមន្ត្រីដែលបានដឹកនាំក្រសួងនេះមុនគេបង្អស់ គឺ **ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុន លឹម**។ ឯមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាមន្ត្រីដែលភាគច្រើនមកពីស្ថាប័នចំរុះ ហើយមន្ត្រីមួយចំនួនធំ គឺជាមន្ត្រីដែលចេញពីក្រសួងកសិកម្ម មានឈ្មោះថា នាយកដ្ឋានសុរិយោដី (នាយកដ្ឋាននេះក្រោយមកឋិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី និងមន្ត្រីមួយចំនួនទៀត មកពីក្រសួងគមនាគមន៍ និងដឹកជញ្ជូន ដែលភាគច្រើនគឺជាវិស្វករមកពីអគ្គនាយកដ្ឋានសំណង់ ព្រោះថា មុននឹងឋិតនៅក្រោមក្រសួងគមនាគមន៍ និងដឹកជញ្ជូន រាជរដ្ឋាភិបាលបានបង្កើតអគ្គនាយកដ្ឋានសំណង់ ដែលឋិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី។ ឯនាយកដ្ឋានភូមិសាស្ត្រ ក៏មកពីទីស្តីការគណៈរដ្ឋមន្ត្រីដែរ។



www.elibraryofcambodia.org

តាមអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ បានចែងអំពីការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់[៣៩] ។ អនុក្រឹត្យនេះមាន១៤ជំពូក និង៣៦មាត្រា ក្នុងជំពូកទី៦ នៃអនុក្រឹត្យនេះ ក្រសួងមានអគ្គនាយកដ្ឋានបួន តែអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មាននាយកដ្ឋានបីគឺៈ នាយកដ្ឋានស្រាវជ្រាវ និងបទប្បញ្ញត្តិ នាយកដ្ឋានរៀបចំដែនដី និងនាយកដ្ឋាននគរូបនីយកម្ម[៤០] ។ ក្រៅពីនេះ ក្រសួងនៅមាន

---

[៣៩] - អនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រួមមាន១៤ ជំពូក និង ៣៦ មាត្រា។ ត្រង់មាត្រា៣ ក្នុងបេសកកម្មការងារនគរូបនីយកម្ម និងសំណង់ ក្រសួងនេះត្រូវធ្វើការស្រាវជ្រាវ និងវិភាគសំរាប់អនាគត និងចងក្រងស្ថិតិទាំងឡាយទាក់ទងនឹងការងារនគរូបនីយកម្ម និងសំណង់ ដោយលើកសំណើរនិងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋានចាំបាច់ទាំងឡាយ ក្នុងការអនុវត្តនយោបាយនគរូបនីយកម្ម និងសំណង់។ លើកសំណើនយោបាយផែនការសកម្មភាព និងវិធានការសម្រាប់ការដោះស្រាយសំណង់អនាធិបតេយ្យ និងការសាងសង់លំនៅឋាន ដោយរក្សា ទេសភាព រមណីយដ្ឋាននៅក្នុងទីក្រុង និងទីប្រជុំជន ជនបទ និងការពារបរិស្ថាន។ កំណត់វិធានទាំងឡាយ និងរៀបចំបទបញ្ជាទាក់ទងនឹងការកាន់កាប់ដីធ្លី នគរូបនីយកម្ម សំណង់ អសុរាមិករណ៍ ការកំណត់ដីបំរុងចេញលិខិតអនុញ្ញាត និងការយល់ព្រមទាំងឡាយទាក់ទងនឹងនគរូបនីយកម្ម និងសំណង់។ល។

[៤០] - នាយកដ្ឋាននគរូបនីយកម្មមានភារកិច្ចដូចតទៅ:

- លើកសំណើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋានស្តីពីនគរូបនីយកម្ម
- អនុវត្តនយោបាយ នគរូបនីយកម្ម ដើម្បីអភិវឌ្ឍទីក្រុង តំបន់ជុំវិញក្រុង ទីប្រជុំជន ជនបទ និងតំបនផ្សេងទៀត ដែលជះឥទ្ធិពលលើទីក្រុង ដើម្បីលើកស្ទួយសណ្តាប់ធ្នាប់សង្គម សោភ័ណភាព សុវត្ថិភាព និងសុខុមាលភាព
- សិក្សារៀបចំប្លង់មេ និងប្លង់លំអិត ដោយបែងចែកទីក្រុង និងតំបន់ជុំវិញទីក្រុង ជាតំបន់សម្រាប់ទីតាំងមជ្ឈមណ្ឌលពាណិជ្ជកម្ម សិប្បកម្ម រដ្ឋបាល ទីតាំងសម្រាប់សកម្មភាពអប់រំ លំនៅដ្ឋាន ដីបំរុងសាលារៀន ទីលានកីឡា ចំណើសងខាងផ្លូវសាធារណៈ ទីលំហែកាយ មន្ទីរពេទ្យ ទីសក្ការៈបូជា វត្តអារាម សួនច្បារសាធារណៈជាដើម
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំគម្រោងបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ប្រព័ន្ធធ្វើដំណើរសាធារណៈ បណ្តាញលូទឹកស្អុយ បណ្តាញទឹកស្អាត អគ្គិសនី ទូរគមនាគមន៍ និងបណ្តាផ្សេងទៀតសម្រាប់តម្រូវការក្នុងទីក្រុង
- រៀបចំកែលម្អគុណភាពទីក្រុង និងតំបន់ថ្មីក្នុងទីក្រុង



www.elibraryofcambodia.org

ច្បាប់ និងអនុក្រឹត្យមួយចំនួនសម្រាប់ជួយសម្រួលដល់ការអនុវត្ត ដែលច្បាប់និងអនុក្រឹត្យទាំងនោះបានអនុម័ត និងដាក់ឱ្យអនុវត្តតាំងពីមុនមានការបង្កើតក្រសួងម្លេះ ក្នុងនោះមានច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ (បានអនុម័តនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤ និងក្របខណ្ឌគតិយុត្តមួយចំនួនទៀត ដូចជាអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់[៤១] អនុក្រឹត្យលេខ៨៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់។ បច្ចុប្បន្នច្បាប់ និងព្រះរាជក្រឹត្យ អនុក្រឹត្យមួយចំនួន ដែលបានអនុម័តមុនពេលបង្កើតក្រសួងកំពុងធ្វើវិសោធនកម្ម ឬធ្វើថ្មីតែម្តង ក្នុងករណីដែលមានការកែតម្រូវច្រើនពេក ព្រោះក្របខណ្ឌគតិយុត្តទាំងនេះ មានការលំបាកក្នុងការអនុវត្តទៅតាមសភាពការណ៍ថ្មីៗតាមស្ថានភាពជាក់ស្តែង។

យោងតាមបេសកកម្ម និងភារកិច្ច ដែលមានចែងក្នុងអនុក្រឹត្យលេខ៦២ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចធ្ងន់ធ្ងរ ដែលត្រូវរែក

---

- រៀបចំគម្រោងបង្កើតទីក្រុងថ្មី និងតំបន់អភិវឌ្ឍន៍សាហគមន៍ថ្មី
- តាមដាន កត់ត្រា វិភាគទិន្នន័យ សេដ្ឋកិច្ច សង្គម សមត្ថភាពផ្គត់ផ្គង់ ដឹកជញ្ជូន ស្ថិតិជំរឿន ដង់ស៊ីតេប្រជាជន និងកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលទៅលើការអភិវឌ្ឍទីក្រុង
- ពិនិត្យ និងផ្តល់លិខិតអនុញ្ញាតសាងសង់
- ត្រួតពិនិត្យ និងមានវិធានការសម្រាប់អនុវត្តនយោបាយនគរូបនីយកម្មឱ្យមានប្រសិទ្ធភាព។

[41] - អនុក្រឹត្យនេះ ត្រូវបានបង្កើតឡើងដោយយោងតាមព្រះរាជក្រមលេខ ០៤ នស. ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ១៩៩៤ និងតាមសំណើររបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។ អនុក្រឹត្យនេះមានគោលបំណង ដើម្បីធានាសុខុមាលភាពនៃសំណង់ និងសុវត្ថិភាពសាធារណៈ ព្រមទាំងការពារដីធ្លីសាធារណៈចាំបាច់ សម្រាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ។ បទប្បញ្ញត្តិទូទៅនៃសំណង់ មានកំណត់អំពីសិទ្ធិនិងអំពីករណីយកិច្ច ប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និងសំណង់ឯកជន។



www.elibraryofcambodia.org

ពុន ព្រោះនៅពេលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនទាន់បានបង្កើត មានបញ្ហាមួយចំនួនបានកើតមានរួចជាស្រេចទៅហើយ ដូចជាប្រជាពលរដ្ឋតាំងទីលំនៅមុនមានការធ្វើផែនការប្រើប្រាស់ដីធ្លី បានសេចក្តីថា បញ្ហាដីធ្លីបានកើត និងកំពុងកើតរួចទៅហើយ ដែលការងារនេះ ជាបញ្ហាចំបងមួយនៅពេលដែលរាជរដ្ឋាភិបាលធ្វើការអភិវឌ្ឍ ស្តារមុខមាត់រាជធានី ទីក្រុងឱ្យមានសោភ័ណភាព ដើម្បីប្រែក្លាយពីតំបន់ទីក្រុងដែលមានបរិស្ថានកខ្វក់ ពេលនោះទំនាស់បានកើតឡើង ធ្វើឱ្យការអនុវត្តត្រូវប្រឈម និងជាកង្វល់មួយដែលរដ្ឋត្រូវដោះស្រាយដោយយកច្បាប់មកអនុវត្ត ឬដោះស្រាយ ដោយប្រើគោលនយោបាយដោះស្រាយជូនប្រជាពលរដ្ឋទាំងនោះ តាមសារាចរលេខ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរដ្ឋ ដែលត្រូវបានទន្រ្ទានកាន់កាប់ដោយខុសច្បាប់តាមរាជធានីទីក្រុង និងទីប្រជុំជន ឬអនុវត្តតាមសម្បទានដីសង្គមកិច្ច ឬអនុវត្តតាមសារាចរលេខ ០២ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុស ច្បាប់សម្រាប់អ្នករស់នៅទីជនបទ។

ប្រជាពលរដ្ឋបានមកតាំងទីលំនៅលើដីទំនេររបស់រដ្ឋ តាមទីប្រជុំជនទីក្រុងនានា ដែលភាគច្រើនកើតឡើងក្រោយឆ្នាំ១៩៩៣ និងបានបង្កើតនូវបញ្ហាទំនាស់ជាច្រើន ជាពិសេសពេលដែលទីផ្សារដីធ្លីកើតមាន។ ទន្ទឹមនេះដែរ ក៏មានជនឱកាសនិយម ឆ្លៀតបង្ក និងបន្តកាន់កាប់ដីរដ្ឋដោយបំពានល្មើសច្បាប់ និងនាំមកនូវការលំបាកដល់រាជរដ្ឋាភិបាលក្នុងការដោះស្រាយ។

យោងតាមព្រះក្រឹត្យលេខនស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ តាមសំណើនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ស្របតាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៩ និងព្រះរាជក្រឹត្យលេខ សន/រកត/១១០០/២១៣ ចុះ



www.elibraryofcambodia.org

ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីការបញ្ចូលសមាសភាពឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋត្រង់មាត្រា ១ ត្រូវបានបញ្ចូលសមាសភាពចំនួនពីរថ្មីទៀត ជាសមាជិកនៃឧត្តមក្រុមប្រឹក្សា កំណែទម្រង់រដ្ឋ គឺ : ១-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច និង ២-ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងអនុក្រឹត្យលេខ៨៨អនក្រ.បកចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី។ មាត្រា ៤ នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានដឹកនាំដោយប្រធានមួយរូប ជារដ្ឋមន្ត្រីនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដោយមានអគ្គលេខាធិការដ្ឋានជាជំនួយការ មានភារកិច្ចជួយដល់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងជួយសម្របសម្រួលនូវរាល់ការងារពាក់ព័ន្ធនឹងវិស័យដីធ្លី ដែលមន្ត្រីទាំងនោះភាគច្រើនលើសលុបជាមន្ត្រីមុខងារសាធារណៈមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមការងារមកពីក្រសួងស្ថាប័នពាក់ព័ន្ធនឹងវិស័យដីធ្លី ទៅតាមប្រធានបទនីមួយៗ និងជាសមាជិកចំពោះកិច្ច។

ដើម្បីសម្រួលនូវរាល់ការងារទាក់ទងទៅនឹងវិស័យដីធ្លី ក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានបន្ទុកធ្វើគោលនយោបាយ និងបទដ្ឋានគតិយុត្តមួយចំនួន ក្នុងន័យនេះរាជរដ្ឋាភិបាលបានបង្កើតអគ្គលេខាធិការដ្ឋាន ដែលមានទីតាំងឋិតនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ តាមអនុក្រឹត្យលេខ៩៦អនក្រ.បក. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០[៤២] ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីជួយសម្របសម្រួលនូវ

[៤២] - អនុក្រឹត្យនេះមានបីជំពូក និង ១៧ មាត្រា។ ដើម្បីឱ្យអគ្គលេខាធិការដ្ឋានអាចបំពេញបាន នូវភារកិច្ចរបស់ខ្លួនឱ្យបានគ្រប់ជ្រុងជ្រោយ អនុក្រឹត្យលេខ ៨៣ អនក្រ.បក. ត្រូវបានអនុម័តថ្មី នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១០។


www.elibraryofcambodia.org

រាល់ការងារទាំងឡាយទាក់ទងនឹងវិស័យដីធ្លីនេះ។ ក្រុមប្រឹក្សាគោនយោបាយដីធ្លីបានធ្វើការប្រជុំលើកទី១ របស់ខ្លួននៅចុងខែមិនា ឆ្នាំ២០០១ ដោយបានពិនិត្យ និងព្រមព្រៀងជាឯកច្ឆន្ទ លើសេចក្តីព្រាងប្រកាសគោលនយោបាយដីធ្លី ដែលក្រោយមកគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០១ បានសម្រេចលើសេចក្តីប្រកាស ដែលជាសេចក្តីប្រកាសគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាល មានខ្លឹមសារសង្ខេបប្រមាណ២ទំព័រ គ្របដណ្តប់លើអនុវិស័យធំៗបីគឺៈ រដ្ឋបាលដីធ្លី ការរៀបចំដែនដី និងការបែងចែកដីធ្លី។ ដោយវិស័យដីធ្លីកាន់តែមមាញឹក អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបានធ្វើការកែសម្រួលរចនាសម្ព័ន្ធឡើងវិញ តាម អនុក្រឹត្យលេខ ៨៣ អនក្រ.បក. ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០ ដោយមានការបែងចែកភារកិច្ចទៅតាមផ្នែកនីមួយៗឱ្យបានច្បាស់លាស់ និងរៀបចំឡើងវិញនូវអង្គការលេខគ្រប់គ្រង ដើម្បីតម្រូវទៅតាមបន្ទុក និងភារកិច្ចតាមផ្នែកនីមួយៗ។

បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ១៩៩២ មានច្បាប់ភូមិបាលថ្មីមួយទៀត ដែលត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តចាប់ពី ខែសីហា ឆ្នាំ២០០១។ រាជរដ្ឋាភិបាលបានសម្រេចលើឯកសារបឋមនៃក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី (Green paper on Land Policy) នៅខែកញ្ញា ឆ្នាំ២០០២ ដែលឯកសារនេះ ជាឯកសារមួយមានលក្ខណៈស៊ីជម្រៅ លើកឡើងនូវបញ្ហាដែលកំពុងកើតមាន និងបង្ហាញផ្លូវក្នុងការគ្រប់គ្រង និងការអភិវឌ្ឍពាក់ព័ន្ធទៅនឹងវិសយ័ដីធ្លី ដើម្បីធានានូវនិរន្តរភាព ធនធានធម្មជាតិ និងបរិស្ថាន និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។



www.elibraryofcambodia.org

គិតមកដល់ពេលនេះ រាជរដ្ឋាភិបាលក៏ដូចជាក្រសួងនានា បាននិងកំពុងអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី និងមានការវិវឌ្ឍយ៉ាងច្រើនក្នុងការគ្រប់គ្រងវិស័យដីធ្លី ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍរបស់សង្គម។ បើពិនិត្យឡើងវិញនូវការអនុវត្តអនុសាសន៍ទាំងឡាយ ដែលមានចែងក្នុងឯកសារក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី ក្នុងបរិបទនៃការអភិវឌ្ឍសង្គមនាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រុមប្រឹក្សាគោលនយោបាយដីធ្លី បាននិងកំពុងសិក្សាវិភាគ ដើម្បីឱ្យការសិក្សាលើវិស័យដីធ្លី កាន់តែមានលក្ខណៈស៊ីជម្រៅទៅតាមសេដ្ឋកិច្ចទីផ្សារដី ដែលនឹងមានបញ្ហាថ្មីៗទៀតត្រូវបំពេញបន្ថែម។ ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងនេះ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ដោយកំណត់បញ្ហាថ្មីៗ ដែលបាននិងកំពុងកើតមាន ដើម្បីលើកទិសដៅត្រូវអនុវត្តបន្ត។ ប៉ុន្តែការរៀបចំឯកសារ ត្រូវការប្រើពេលវេលា ដូចនេះក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានស្នើឱ្យមានការរៀបចំជា **"សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយដីធ្លី"** ដែលសេចក្តីថ្លែងការណ៍នេះ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលលេខ ២៧ សជណ.អក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩។ ឯកសារសង្ខេបនេះ ជាផែនទីឬជាត្រីវិស័យ បង្ហាញផ្លូវលើវិស័យដីធ្លី និងសម្រាប់អភិវឌ្ឍឱ្យទៅជាគោលនយោបាយដីធ្លីទូលំទូលាយ ឬហៅថា **សៀវភៅសដីធ្លី** [៤៣] (White paper on Land Pol-

[៤៣] - សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី ត្រូវបានអនុម័តឱ្យប្រើប្រាស់ដោយប្រមុខរាជរដ្ឋាភិបាលលេខ: ២៧ សជណ.អក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩) ។ សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយដីធ្លីទូលំទូលាយនេះ គឺមានសារសំខាន់ណាស់ ជាផែនទីចង្អុលផ្លូវ មានចក្ខុវិស័យដោយផ្តោតការយកចិត្តទុកដាក់លើការគ្រប់គ្រងរៀបចំ ប្រើប្រាស់ និងបែងចែកដី ប្រកបដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅជាតិ នៃការកាត់បន្ថយភាពក្រីក្រ ធានា



www.elibraryofcambodia.org

icy)។ រាជរដ្ឋាភិបាលដែលមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានខិតខំធ្វើឱ្យសម្រេចបាននូវផ្លែផ្កាជាច្រើន មានអនុក្រឹត្យលេខ ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ សារាចរលេខ ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន ព្រមទាំងបាន និងកំពុងរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តជាច្រើនទៀតពាក់ព័ន្ធនឹងវិស័យដីធ្លី ក៏ដូចជាសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីលំនៅឋាន សេចក្តីព្រាងគោលនយោបាយស្តីពីការវាយតម្លៃថ្លៃដី និងគោលនយោបាយផ្សេងទៀត ដែលនឹងត្រូវព្រាងឡើងជាបន្តបន្ទាប់ (មើលឧបសម្ព័ន្ធ១)។

## ៤-នគរូបនីយកម្មទសវត្សឆ្នាំទី៨០ ចល់ទសវត្សទី៩០ នៃសតវត្សទី២០

ស្ថិតក្នុងស្ថានភាពមួយ ដែលប្រទេសទើបបានរំដោះផុតពីរបបប្រល័យពូជសាសន៍ ក្រោយថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា មានភារកិច្ចដ៏សែនធ្ងន់ធ្ងរ ដោយត្រូវធ្វើការដោះស្រាយបញ្ហាគ្រប់មុខ និងរំដោះប្រជាជនឱ្យរួចផុតពីការស្លាប់ដោយការខ្វះអាហារបរិភោគ។ ទោះបីឋិតក្នុងករណីលំបាកបែបណាក៏ដោយ រដ្ឋាភិបាលក្រោមទង់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដាច់ខាតមិនបានបណ្តោយឱ្យប្រជាជនខ្មែរស្លាប់ដោយសារការអត់ឃ្លានឡើយ។

---

សន្តិសុខស្បៀង ការពារបរិស្ថាន និង[illegible]ធនធានធម្មជាតិ គិច្ចការពារជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារ"។



www.elibraryofcambodia.org

ហេតុដូចនេះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមាននិន្នាការសេដ្ឋកិច្ចផែនការកម្ម បានបង្កើតជាក្រុមសាមគ្គីដែលមានអត្ថន័យ និងមានសារៈសំខាន់ធំធេងណាស់ បានសេចក្តីថាប្រជាពលរដ្ឋរស់នៅតាមមូលដ្ឋាន ភូមិ ឃុំនានាដែលមានឧបករណ៍ផលិតកម្មដូចជា គោ ក្របី សេះ រទេះ រនាស់ នង្គ័ល រទេះ និងពូជស្រូវក៏ដូចជារុក្ខជាតិហូបផ្លែសព្វសារពើមួយចំនួន ត្រូវចែះចែករំលែក និងដាក់បញ្ចូលក្នុងក្រុមសាមគ្គី ដើម្បីផ្តល់ឱកាសឱ្យដល់ប្រជាជនដែលត្រូវបន ប៉ុល ពត បណ្តេញឱ្យចាកចេញពីផ្ទះសម្បែងនៅឆ្នាំ១៩៧៥ ហើយកំពុងធ្វើចលនាផ្លាស់ទីវិលត្រឡប់ចូលមកភូមិកំណើត ឬទីកន្លែងដែលពួកគេចង់ទៅរស់នៅ ទោះបីជាគ្រួសារទាំងនោះចូលមករស់នៅមិនមែនជាស្រុកកំណើតរបស់ខ្លួនក៏ដោយ និងគ្មានអ្វីក៏ដោយ ឱ្យតែស្ម័គ្រចិត្តមករស់នៅក្នុងសហគមន៍ជាមួយគ្នា នោះសហគមន៍ត្រូវតែមានភារកិច្ចចែករំលែកភោគផលទាំងឡាយ ឱ្យដល់គ្រួសារចំណូលថ្មី ដោយពួកគេចេះជួយគ្នាទៅវិញទៅមក ដូចជាបម្រើឱ្យដល់ការដាំដុះ (ពួកគាត់អាចជួយភ្ជួររាស់ បោចស្ទូង ថែទាំអ្វីៗដែលជាសមិទ្ធផលឋិតក្នុងក្រុមសាមគ្គី) និងចែកដីឱ្យធ្វើការដាំដុះតាមគ្រួសារនីមួយៗ។ របៀបរបបចែកគ្នារស់បែបនេះ ជាវិធីមួយល្អបំផុតដែលកម្រមាននៅលើពិភពលោក។ ពេលនោះបើរដ្ឋាភិបាល គ្មានវិធានការបង្កើតជាក្រុមសាមគ្គីទេ នោះប្រជាជនខ្លះអាចស្លាប់ដោយសារការអត់ឃ្លាន ព្រោះក្នុងអំឡុងឆ្នាំ១៩៧៩ ប្រទេសកម្ពុជាមិនទាន់មានការចាយវាយក្រដាសប្រាក់នៅឡើយ ទោះបីជារូបិយវត្ថុនោះបានបោះពុម្ពហើយក៏ដោយ តែការចរាចរប្រាក់រៀលឡើងវិញ គឺមាននៅថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៨០។ ដូច្នេះចាប់ពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់ខែមិនា ឆ្នាំ១៩៨០ ប្រជាជនកម្ពុជាឋិតក្នុងដំណាក់កាលមួយដែលមនុស្សជំនាន់ក្រោយមិនបានដឹង ឬកើតមិនទាន់ហេតុការណ៍នេះឡើយ។



www.elibraryofcambodia.org

ក្នុងពេលនោះ ប្រជាជនកម្ពុជា ហាក់ដូចជាកំពុងរិតនៅក្នុងសង្គមបុព្វកាលមួយ ដែលប្រជាពលរដ្ឋម្នាក់ៗ ចេះដោះដូររបស់របរសព្វមុខ និងប្រើប្រាស់ស្រូវ ឬអង្ករ និងមាស ពេជ្រ ដោយប្រៀបវត្ថុទាំងនេះប្រដូចទៅនឹងរូបិយវត្ថុ ហើយដោះដូរពីវត្ថុមួយទៅវត្ថុមួយទៀត គិតជាតម្លៃតាមការចរចាត្រូវរ៉ូវគ្នា រវាងអ្នកលក់និងអ្នកទិញ។ ការដោះដូរ ឬការចាយវាយទិញម្ហូបអាហារ និងវត្ថុសព្វសារពើ មានដូចជាអង្ករ ១ កំប៉ុងទឹកដោះគោ ស្មើនឹងនំអន្សមចេក១ មាស ១ ជី ស្មើនឹងស្ករត្នោត ១ គីឡូក្រាម សំពត់សារុងពុម្ព១ ស្មើនឹងមាស ៣ ហ៊ុន ត្រី១ គីឡូក្រាម ស្មើនឹងអង្ករ ១ គីឡូក្រាម ឬស្រូវ ១ គីឡូក្រាមកន្លះ។ សកម្មភាពបែបនេះ ធ្លាប់បានកើតមានយ៉ាងសម្ងាត់បំផុត រវាងប្រជាជនថ្មី និងប្រជាជនចាស់ ដែលបានរស់នៅតាមមូលដ្ឋានក្នុងរបបប្រល័យពូជសាសន៍ មានដូចជា អង្ករ ស្ករត្នោត ត្រីសាច់... ដូរជាមួយនឹងគ្រឿងអលង្ការ មានមាស ពេជ្រ នាឡិកាដៃ ឬសម្លៀកបំពាក់... នេះជាទម្លាប់ដែលពួកគេធ្លាប់បានធ្វើដោយលួចលាក់ និងបានកើតមានរួចជាស្រេចមកហើយ នៅក្នុងរបបប៉ុលពតតាមរយៈប្រជាជនថ្មី ដែលមានរបស់របរដូចជា សំពត់អាវ មាស ពេជ្រ ទៅដូរយកអង្ករ ត្រី សាច់ ស្ករ ពីប្រជាជនចាស់ភាគច្រើនដែលពួកគាត់មាន។ នៅពេលដែលរបបប៉ុលពតត្រូវបានផ្តួលរំលំភ្លាម សកម្មភាពបែបនេះបានកើតមានគ្រប់ទីកន្លែង ក្នុងតំបន់ដែលកងទ័ពរណសិរ្សរំដោះជាតិកម្ពុជារំដោះបាន។ ជាបណ្តើៗ ប្រជាជនបាននាំគ្នាមកប្រមូលផ្តុំរស់នៅតាមទីក្រុង និងទីប្រជុំជននានាតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌវិញ ហើយនេះក៏ជាកត្តាមួយដែលធ្វើឱ្យទីក្រុងខ្មោច ឬទីប្រជុំជនដែលធ្លាប់តែស្ងាត់ស្ងៀម គ្មានមនុស្សរស់នៅនោះ ចេះតែមានការរីកចម្រើនធំធាត់ឡើងៗ និងផ្តល់ឱកាសឱ្យមានការប្រមូលផ្តុំមនុស្សកាន់តែច្រើនឡើង។



www.elibraryofcambodia.org

ទន្ទឹមនឹងការបង្កើតតំបន់រដ្ឋបាលនិងវិស័យផ្សេងៗ រដ្ឋាភិបាលបានយកចិត្តទុកដាក់ ទំនុកបម្រុងដល់ប្រជាជនទៅតាមលទ្ធភាពដែលអាចធ្វើបាន និងបង្កលក្ខណៈឱ្យមានការប្រមូលផ្តុំមនុស្ស ដោយរដ្ឋបានចលនាគៀងគរអំពាវនាវដល់ប្រជាពលរដ្ឋ ដែលមានចំណេះដឹង ទោះតិចក្តី ឬច្រើនក្តីឱ្យចូលរួមបម្រើជាតិ ដើម្បីឈានទៅបង្កើតឡើងវិញនូវស្ថាប័ននានា មានផ្នែកដែលចាំបាច់ៗសិន មានដូចជាឃោសនាអប់រំ សុខាភិបាល (មន្ទីរពេទ្យ) អប់រំ (សាលារៀន[៤៤]) កសិកម្ម ពាណិជ្ជកម្ម... តាមគោលនយោបាយអ្នកចេះច្រើនបង្រៀនអ្នកចេះតិច និងរៀនផងធ្វើការផង ព្រោះជាតិត្រូវការចាំបាច់ ដើម្បីប្រមូលផ្តុំអ្នកមានចំណេះដឹង ដែលនៅសេសសល់ពីការកាប់សម្លាប់ក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ហើយនេះក៏ជាមូលហេតុនៃការកកើតមានឡើងវិញនូវទីប្រជុំជន និងទីក្រុងនានា មានដូចជារាជធានីភ្នំពេញ និងទីរួមខេត្ត ក្រុងទូទាំងប្រទេស។

ចំពោះក្រុមសាមគ្គីដែលបានដំណើរការអស់រយៈពេល១០ឆ្នាំ ត្រូវបានប្តូរជាបណ្តើរៗមកជារបបឯកជនវិញ ព្រោះរដ្ឋាភិបាលបានដឹកនាំប្រទេសក្នុងមាគ៌ាមួយ

---

[៤៤] - មន្ទីរពេទ្យ សាលារៀននៅឆ្នាំ ១៩៧៩ មានសភាពទ្រុឌទ្រោម ព្រោះរបបប៉ុលពតបានបិទមន្ទីរពេទ្យ សាលារៀន និងច្រើនយកទីទាំងនេះធ្វើជាកន្លែងដាក់ជី ឬធ្វើជាគុក ដូចជាវត្តអារាមក៏មានលក្ខណៈដូចគ្នាដែរ។ គ្រូបង្រៀនសិស្សស្ម័គ្រចិត្ត ហើយសិស្សដែលចូលរៀនថ្នាក់ដំបូង មិនមានការគិតអាយុទេ ឱ្យតែស្ម័គ្រចិត្តចូលរៀនគឺរៀនបានទាំងអស់ ម្ល៉ោះហើយសិស្សមានអាយុមិនដូចគ្នា ជាពិសេសច្រើនជាមនុស្សវ័យជំទង់ដែលមិនបានរៀនសូត្រ ព្រោះប្រទេសឋិតក្នុងសង្គ្រាម។ គ្រូបង្រៀនសិស្សក្រោមដើមឈើ ពេលខ្លះត្រូវយកទ្រុងគោធ្វើជាកន្លែងបង្រៀន អាស្រ័យតាមទីកន្លែងជាក់ស្តែងនីមួយៗ។ អ្នកធ្វើការមានរបបបើកឱ្យរាល់ខែ តែមិនមែនជាប្រាក់ខែទេ គឺជារបបអង្ករសាលី (៦៤) ពោតដែលបានពីជំនួយ (ក្នុងមួយខែម្នាក់អាចមានរបបដូចជាពោត ឬអង្ករស្រូវសាលី ១៨ គីឡូក្រាមក្នុងម្នាក់ បើមានកូន ឬឪពុកម្តាយរស់ក្នុងបន្ទុកអាចមានរបបបន្ថែមទៀត) ជួនកាលអាចមានជាអង្ករដែរ។ នៅពេលដែលរដ្ឋបង្កើតឱ្យមានជាក្រដាសប្រាក់ចាយវាយ ជាទូទៅការចាយអង្ករត្រូវឈប់ដំណើការឯកឯង តែមាសនៅតែមានចាយខ្លះៗ ដោយកន្លែង និងបន្តិចម្តងៗ ការដោះដូរដែលអាចប្រដូចទៅនឹងសម័យបុព្វកាលត្រូវបានប្រជាជនងាកមកចាយក្រដាសប្រាក់ជំនួសវិញ។



www.elibraryofcambodia.org

ត្រឹមត្រូវ ដោយប្រមើលឃើញពីប្រការដែលប្រជាជនមានជំហររឹងប៉ឹង និងអាចរស់ជាឯកជនបាន។ ដូចនេះចាប់ពីឆ្នាំ ១៩៨៩ មកដល់ឆ្នាំ ១៩៩៣ កម្ពុជាបានដើរមកដល់ដំណាក់កាលមួយទៀត ដែលមានការឈានឡើងដោយបានផ្លាស់ប្តូរជាបណ្តើរៗ ពីរបបសេដ្ឋកិច្ចផែនការទៅជារបបសេដ្ឋកិច្ចទីផ្សារ ដែលជាសេដ្ឋកិច្ចមានការប្រកួតប្រជែង។ រោងចក្រ សិប្បកម្មមួយចំនួនដែលដឹកនាំដោយរដ្ឋ ត្រូវបានធ្វើស្វ័យាភិបាលសេដ្ឋកិច្ច និងជាបណ្តើរៗមានដំណើរឆ្ពោះទៅឯកជនភាវូបនីយកម្ម។ នេះគឺជារបថផ្លូវមួយថ្មីទៀត ដែល **សាធារណរដ្ឋប្រជាមានិតុកម្ពុជា** ត្រូវបានប្តូរឈ្មោះទៅជា **រដ្ឋកម្ពុជា**។

ដំណើរឈានឡើងជានិច្ច ឬបានសេចក្តីថា កម្ពុជាកំពុងដើរលើមាគ៌ាមួយដ៏ត្រឹមត្រូវក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រដ្ឋាភិបាល បានធ្វើដំណើរឈានឡើងជាជំហានៗ និងប្រកបដោយការប្រុងប្រយ័ត្នខ្ពស់។ សេដ្ឋកិច្ចទីផ្សារបានធ្វើឱ្យប្រជាពលរដ្ឋមានសកម្មភាពសកម្ម និងមានល្បឿនលឿន ដោយមានអ្នកក្នុងស្រុកបញ្ចេញទុនរកស៊ី និងក៏ជាកត្តាជំរុញធ្វើឱ្យទីផ្សារដីធ្លីមានការប្រែប្រួល និងមានការកើនឡើងនូវតម្លៃដីធ្លី តម្លៃផ្ទះសម្បែង ដែលជំរុញឱ្យដំណើរនគរូបនីយកម្មប្រព្រឹត្តទៅយ៉ាងសកម្ម ពិសេសទីក្រុងភ្នំពេញដែលជារដ្ឋធានី និងទីក្រុងធំៗមួយចំនួន ដូចជា ក្រុងព្រះសីហនុ ក្រុងសៀមរាប ក្រុងបាត់ដំបង។ ដោយឡែករាជធានីភ្នំពេញបានពង្រីកខ្លួនយ៉ាងលឿនទៅគ្រប់ទិសទី គួបផ្សំនឹងអត្រាកើត (អត្រាជាតិប្រមាណ) ខ្ពស់ក្រោយសម័យសង្គ្រាមស៊ីវិល។

នៅឆ្នាំ១៩៩៣ រដ្ឋកម្ពុជាបានឈានចូលមកដល់ដំណាក់កាលមួយថ្មីទៀត នោះគឺការបង្រួបបង្រួមជាតិ។ តាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ **កម្ពុជាគឺជាព្រះរាជាណាចក្រកម្ពុជាទី២** (ព្រះរាជាណាចក្រកម្ពុជាទី១ គឺនៅមុនឆ្នាំ១៩៧០)។ ក្នុងសម័យ



www.elibraryofcambodia.org

កាលនេះ ព្រះរាជាណាចក្រកម្ពុជាពុំទាន់មានសន្តិភាពពេញលេញនៅឡើយទេ បាន សេចក្តីថា កម្ពុជានៅមានតំបន់អប្បគមន៍ ដែលត្រួតត្រាដោយពួកខ្មែរក្រហម ជាពិសេស តំបន់ពាយ័ព្យដែលឋិតនៅតាមព្រំដែនកម្ពុជា-ថៃ។ នៅឆ្នាំ១៩៩៨ ក្រោមការដឹកនាំដ៏ឈ្លាសវៃនៃប្រមុខរាជរដ្ឋាភិបាល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានដាក់ចេញនូវគោលនយោបាយ **ឈ្នះ ឈ្នះ** បានធ្វើឱ្យកងទ័ពខ្មែរក្រហម ចូលមករួមរស់កសាងប្រទេស ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលតែមួយ ដែលធ្វើឱ្យប្រទេសកម្ពុជាមានសុខសន្តិភាពទូទាំងប្រទេស មានស្ថិរភាពនយោបាយ សេដ្ឋកិច្ចកើនឡើង គោរពសិទ្ធិមនុស្ស និងបានចូលជាសមាជិកអាស៊ាន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ មុខមាត់ប្រជាជនកម្ពុជាដែលធ្លាប់តែក្រៀមស្រពោន បានក្លាយមកជាមានស្នាមញញឹមឡើងវិញ[៤៥] សេដ្ឋកិច្ចគ្រួសារកើនឡើង ប្រជាជនរស់នៅក្នុងក្តីសង្ឃឹម សម្រាប់អនាគតកូនចៅរបស់ពួកគេជំនាន់ក្រោយ។

## ៥-ទីក្រុងនិងបញ្ហាលំនៅឋាន ទសវត្សឆ្នាំទី១០នៃសតវត្សទី២១

នៅដើមទសវត្សឆ្នាំទី១០ នៃសតវត្សទី២១ ទីក្រុងភ្នំពេញជាទីក្រុងមួយឈរជួរទី៣១៤ ក្នុងចំណោមទីក្រុងជាង៤០០នៃទីក្រុងនានានៅលើពិភពលោក ដែលក្នុងនោះទីក្រុងភ្នំពេញមានប្រជាជនកំពុងរស់នៅលើសពី១លាននាក់ (ទីក្រុងភ្នំពេញមានចំនួនប្រជាជន ១.៣លាននាក់)[៤៦] ។

[៤៥] - ជនបរទេសតែងនិយាយ និងលើកឡើងពីស្នាមញញឹមនៃអង្គរ ដែលជាស្នាមញញឹមនៃប្រជាជនខ្មែរ (Sourire cambodgienne)។

[៤៦] - ទីក្រុងភ្នំពេញមានប្រជាជន ១.៣ លាននាក់ តាមជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ ប៉ុន្តែបើតាមជំរឿនឆ្នាំ១៩៩៨ ភ្នំពេញមានប្រជាជនលើសពីមួយលាននាក់រួចស្រេចទៅហើយ ថ្វីត្បិតតែទិន្នន័យជំរឿនឆ្នាំ១៩៩៨បានបង្ហាញថាមានប្រជាជនជាង ៩.៩ សែននាក់ក៏ដោយ។



www.elibraryofcambodia.org

បច្ចុប្បន្ននៅលើពិភពលោកយើងនេះ មានទីក្រុងជាង៤០០ដែលមានប្រជាជនលើសពី១លាននាក់ ហើយជិតពាក់កណ្ដាលនៃចំនួនប្រជាជនទូទាំងពិភពលោកកំពុងរស់នៅក្នុងទីក្រុង។ បើយើងធ្វើការឆ្លុះបញ្ចាំងទៅសតវត្សទី១៨ ក្នុងឆ្នាំ១៨០០វិញនោះ មាន៩៧ភាគរយនៃប្រជាជនលើពិភពលោករស់នៅតាមទីជនបទ។ តាមការដកស្រង់ក្នុងសៀវភៅពានរង្វាន់ពិភពលោក ភាពជាអ្នកដឹកនាំ ឆ្នាំ២០០៥ បានធ្វើការសន្និដ្ឋានថា "នៅឆ្នាំ២០៣០ ប្រជាជនលើពិភពលោកដែលរស់នៅក្នុងទីក្រុងស្រូបយកដល់ទៅជាង៦០ភាគរយ ហើយកំណើននេះច្រើនកើត មាននៅបណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចតួចប៉ុណ្ណោះ។ ផ្ទុយទៅវិញ នៅសហព័ន្ធអឺរ៉ុបមានប្រជាជន៨០ភាគរយ បាននិងកំពុងរស់នៅក្នុងទីក្រុងរួចទៅហើយ[៤៧]"។

ដោយសារប្រទេសកម្ពុជាមានស្ថិរភាពនយោបាយ ក៏ដូចជាសុវត្ថិភាពសង្គម ទីក្រុងភ្នំពេញចេះតែរីកធំធាត់ទៅ និងមានការអភិវឌ្ឍគ្រប់វិស័យធ្វើឱ្យទីក្រុងរីកលូតលាស់ទៅគ្រប់ទិសទីយ៉ាងឆាប់រហ័ស។ ជាបន្តបន្ទាប់រហូតមកដល់ឆ្នាំ២០០៥ ផ្ទៃដីទីក្រុងបានកើនឡើងដល់ទៅ៣៧៥គ.ម $^{២}$ [៤៨] និងមានប្រជាជនរស់នៅដល់ទៅ

---

47 - ទិន្នន័យបានបង្ហាញពីទំនោរនៃអ្នកក្រុង តែទន្ទឹមនេះលើពិភពលោក ជាពិសេសបណ្ដាប្រទេសអភិវឌ្ឍន៍កំពុងតែផ្ដោតការរស់នៅតំបន់ជាយក្រុង និងជនបទវិញ ដែលដំណើរនេះកំពុងដើរផ្ទុយគ្នានឹងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងឬអភិវឌ្ឍន៍តិចតួច ដែលឧស្សាហកម្មកំពុងតែធ្វើឱ្យទីក្រុងមួយ ឬពីរក្នុងប្រទេសកាន់តែរីកធំទៅៗ ដូចជាប្រទេសវៀតណាម(ទីក្រុងហាណូយ និងទីក្រុងហូជីមិញ) ប្រទេសថៃ (ទីក្រុងបាងកក ទីក្រុងឈៀងម៉ៃ)និងប្រទេសកម្ពុជាមាន(ទីក្រុងភ្នំពេញនិងទីក្រុងសៀមរាប) ជាដើម។

៤៨ - នេះជាតួលេខដែលបានពីឯកសារសាលាក្រុងភ្នំពេញស្ដីពី "ពានរង្វាន់ពិភពលោកឆ្នាំ២០០៥" តែបើតាមតួលេខដែលប្រើប្រាស់ដោយវិទ្យាស្ថានជាតិស្ថិតិពេលជំរឿនប្រជារាស្ត្រ ១៣ មីនា ឆ្នាំ២០០៨ ការប្រើប្រាស់ទិន្នន័យបានបង្ហាញថាភ្នំពេញមានផ្ទៃដីត្រឹម ២៩០ គ.ម. $^{២}$ ប៉ុណ្ណោះ។



www.elibraryofcambodia.org

១៣២៩៦៨១នាក់[៤៩] ។ ភ្នំពេញបន្តពង្រីកខ្លួនធំឡើងៗ អាស្រ័យដោយនគរូបនីយ-កម្មមានសន្ទុះលឿនគួរឱ្យចាប់អារម្មណ៍ ។ ទីក្រុងភ្នំពេញពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែមានការទាក់ទាញ មានមុខរបរកាន់តែសម្បូរសម្បាញឡើង និងមានចំណាកជនបទនៃប្រជាជនគ្រប់ប្រភេទចូលមកទីក្រុង ដើម្បីរកការងារធ្វើជាកម្មករ ក្នុងរោងចក្រកាត់ដេរនិងធ្វើការផ្នែកសេវាកម្មផ្សេងៗទៀត ឬដើម្បីបន្តការសិក្សា ។

ដំណើរនគរូបនីយកម្មបានកើតឡើងដោយឯកឯង ទន្ទឹមនឹងទីក្រុងនានាមិនទាន់បានធ្វើផែនការប្រើប្រាស់ដីធ្លី ។ ក្រោយកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រដ្ឋាភិបាលកម្ពុជាបានបង្កលក្ខណៈឱ្យប្រជាជនខ្មែរដែលកំពុងរស់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ធ្វើមាតុភូមិនិវត្តន៍ចូលមករស់នៅក្នុងទឹកដីកម្ពុជា ដែលភាគច្រើនក្រោយមកពួកគាត់បានវិលមករស់នៅក្នុងទីក្រុង និងទីប្រជុំជនវិញ ។ ចលនានេះ បានដើរទន្ទឹមគ្នានឹងលំហូរប្រជាជនចេញពីទីជនបទចូលមករស់នៅក្នុងទីក្រុងនានា ជាពិសេសក្រុងភ្នំពេញ និងបានបង្កើតឱ្យមានការតាំងទីលំនៅលើដីរដ្ឋ មានដូចជាលើសួនច្បារសាធារណៈ លំហសាធារណៈ ដីឯកជនរបស់រដ្ឋ ដីរបស់បុគ្គល ដីវត្តអារាម លើប្រឡាយទឹក... និងនៅលើទីតាំង ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព ដូចជាលើប្រព័ន្ធលូបង្ហូរទឹកកាកសំណល់ និងលើទីតាំងដែលងាយរងគ្រោះថ្នាក់ ដូចជាលើដីចំណីផ្លូវថ្នល់ ផ្លូវរថភ្លើង លើទំនប់ទឹក ការពារទឹកជំនន់ លើច្រាំងទន្លេ ស្ទឹង ព្រែក លើដីបូលទែវ៉ាស... (មើលរូបទី៤៥) ។

[៤៨] - ជាទីក្រុងដែលមានប្រជាជនបិតក្នុងចំណាត់ថ្នាក់ទី ៣១ ក្នុងចំណោមទីក្រុងនានាលើពិភពលោក មានអត្រាកំណើនប្រជាជនប្រចាំឆ្នាំ ៣,២% គឺប្រមាណជា ៤០០០០ នាក់ ដែលរស់នៅក្នុង ១ ឆ្នាំ (វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ ១៩៩៨) ឬប្រមាណជា ១០០០០ គ្រួសារក្នុង ១ ឆ្នាំចូលមករស់នៅក្នុងទីក្រុងភ្នំពេញ ។



www.elibraryofcambodia.org

បើពិនិត្យមើលលើដង់ស៊ីតេប្រជាជនទីក្រុងភ្នំពេញ នៅឆ្នាំ១៩៩៨ មាន ៣៤៤៨ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។ នៅឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជន នៅលើទីតាំងដដែលនេះបានកើនឡើងមានដល់ទៅ៤៥៧១ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ដែលអាចបង្ហាញឱ្យដឹងថា ក្នុងរយៈពេល១០ឆ្នាំនៃចន្លោះជំរឿនប្រជារាស្ត្រ ពីឆ្នាំ ១៩៩៨ មកទល់នឹងឆ្នាំ២០០៨ ដង់ស៊ីតេប្រជាជនក្រុងភ្នំពេញ បានកើនឡើងដល់ទៅ១១២៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ព្រោះក្រុងភ្នំពេញជារាជធានី ជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ជាទីតាំងក្បាលម៉ាស៊ីនដឹកនាំប្រទេស ជាតំបន់ស្នូលរដ្ឋបាល និងជាតំបន់ស្រូបយកកម្លាំងពលកម្មមកធ្វើការកាន់តែច្រើន និងជាតំបន់ទាក់ទាញស្រូបយកគ្រប់វិស័យ និងមានមុខរបរកាន់តែស្មុគស្មាញដូចជា ទីក្រុងធំៗនៅបណ្តាប្រទេសអភិវឌ្ឍន៍ និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀតលើពិភពលោក។

ទីក្រុងភ្នំពេញក្នុងមួយឆ្នាំ មានអត្រាកំណើនប្រជាជន៣.២ភាគរយ ដូចនេះក្នុងមួយឆ្នាំទីក្រុងភ្នំពេញ មានចំនួនប្រជាជនប្រមាណជា៤០០០០នាក់ ដែលត្រូវកើនឡើង ឬប្រមាណជា១០០០០គ្រួសារក្នុងមួយឆ្នាំ[៥០] ហើយបើពិនិត្យមើលទៅលើផលិតផលជាតិសរុបសម្រាប់ប្រជាជនកម្ពុជាម្នាក់ៗវិញ គឺទទួលបាន៨៣០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ (GNP US$ 830 per capita and per year) ដែលទាបជាងផលិតផលជាតិសរុបរបស់ប្រជាជនប្រទេសសិង្ហបុរី និងប្រជាជនប្រទេសថៃ។

តាមការគណនាបានឱ្យដឹងថា នៅឆ្នាំ២០៣០ ព្រះរាជាណាចក្រកម្ពុជានឹងមានចំនួនប្រជាជនកើនឡើង គួបផ្សំនឹងតម្រូវការលំនៅឋានបន្ថែមទៀត ដើម្បី

---

[៥០] - ទិន្នន័យវិទ្យាស្ថានជាតិស្ថិតិឆ្នាំ ១៩៩៨។



www.elibraryofcambodia.org

បម្រើឱ្យមនុស្សជំនាន់ក្រោយដែលជាគូស្រកររៀបអាពាហ៍ពិពាហ៍រួច ក៏ពួកគេត្រូវការលំនៅឋានស្នាក់នៅចាំបាច់ផងដែរ។ ប្រការនេះហើយដែលរាជរដ្ឋាភិបាលកំពុងគិតគូរយកចិត្តទុកដាក់ បើពុំដូច្នោះទេ អាចនឹងមានប្រជាជនចំណាកជនបទចូលមកតាំងទីលំនៅបណ្តោះអាសន្ន ចាប់ដីតាំងទីលំនៅតាមទីតាំងដីរដ្ឋ ដីឯកជន និងបង្កើតបានជាតំបន់អនាធិបតេយ្យបន្ថែមទៀត ប្រសិនបើមិនមានវិធានការទប់ស្កាត់ ឬកង្វះខាតក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី។

នៅតាមទីក្រុងនានា មានដូចជា ក្រុងភ្នំពេញ ក្រុងសៀមរាប និងក្រុងផ្សេងទៀត... បញ្ហាកាន់កាប់ដីរដ្ឋកើតមាន និងបានបង្កើតជាបញ្ហាលំបាក ដែលរាជរដ្ឋាភិបាលបាន និងកំពុងធ្វើការដោះស្រាយ ជាពិសេសរាជធានីភ្នំពេញ ក្នុងតំបន់ដែលត្រូវធ្វើការអភិវឌ្ឍ។ ព្រោះនៅពេលដែលប្រទេស មានស្ថេរភាពនយោបាយ ភ្នំពេញបានក្លាយជាចំណុចស្រូបទាក់ទាញយកជនចំណាកជនបទចូលមករស់នៅ និងក៏ដូចជា ទីក្រុងនានាទៀតដែរ ដើម្បីស្វែងរកការងារធ្វើ និងជនចំណូលស្រុកដែលបានមកពីការធ្វើមាតុភូមិនិវត្តន៍។

ដើម្បីទប់ស្កាត់ការមកតាំងទីលំនៅខុសច្បាប់បន្តទៀត ក្នុងទីក្រុង និងទីប្រជុំជន រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ ០៣ សរចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលបានទន្ទ្រាន កាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន។ សារាចរនេះ មានអត្ថន័យ ដើម្បីទប់ស្កាត់កុំឱ្យមានការតាំងទីបែបនេះជាថ្មីទៀតនៅក្នុងរាជធានី ទីក្រុងនានា និងទីប្រជុំជន ក្នុងន័យរក្សាបាននូវសោភ័ណភាពនិងបរិស្ថានក្រុង។ តែទន្ទឹមនេះ រាជរដ្ឋាភិបាល មានការយកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋទាំងនោះ



www.elibraryofcambodia.org

ដោយផ្តល់ ឱកាសដល់ពួកគាត់ឱ្យធ្វើការតាំងទីលំនៅនៅកន្លែងថ្មីឬអភិវឌ្ឍន៍លំនៅឋាននៅនឹងកន្លែងឬផ្តល់ជាគោលយោបាយទៅតាមករណីជាក់ស្តែងនីមួយៗ។

ឋិតក្នុងស្ថានភាពមួយនៃកំណើនប្រជាសាស្ត្រ រាជរដ្ឋាភិបាលកម្ពុជាមានកង្វល់ពីបញ្ហាលំនៅឋាន ដោយត្រូវធ្វើយ៉ាងណាដើម្បីឱ្យប្រជាពលរដ្ឋទូទាំងប្រទេសមានលំនៅឋានសមរម្យ។ នៅឆ្នាំ២០០៣ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ដូចជាក្រុមប្រឹក្សាគោលនយោបាយដីធ្លី បានផ្តួចផ្តើមគំនិត និងតម្រូវឱ្យមានការសិក្សាមួយ ក្នុងគោលស្វែងយល់ពីបញ្ហាលំនៅឋាននៅកម្ពុជា។ ការសិក្សានេះ មានការគាំទ្រពីអង្គការសហការប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UNHABITAT)។



www.elibraryofcambodia.org

## រូបទី៤៥: ការតាំងទីលំនៅរបស់ប្រជាជនលើដីរដ្ឋ ក្នុងតំបន់ងាយរងគ្រោះថ្នាក់

ទីកន្លែងដែលអ្នកក្រីក្រកំពុងរស់នៅ (ការធ្វើអង្កេត ឆ្នាំ២០០៩)

The place where the poor are living (Survey in 2009)



១. តាមផ្លូវរទេះភ្លើង: Along the railways 1,34% (5% in 2003)



២. តាមច្រាំងទន្លេ: Along the riverbank 2.21% (25.6% in 2003)



៣. តាមផ្លូវថ្មើរជើង: Along the sidewalk 1.16% (4.6% in 2003)



៤. តាមប្រឡាយលូទឹក: Along the drainage : 0,89% (35.7% in 2003)

និងបានធ្វើការអង្កេតនៅតាមទីតាំងបីគឺរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តកោះកុង។ លទ្ធផលនៃការសិក្សានេះ បានជារបាយការណ៍មួយដែលជាមូលដ្ឋានសម្រាប់ផ្តល់ឱ្យក្រុមការងារក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី បន្តយកទៅធ្វើការសិក្សាស៊ីជម្រៅបន្ថែមទៀត ដើម្បីជាមូលដ្ឋានបានរៀបចំជាសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីលំនៅឋាននៅឆ្នាំ២០១០ និងដោយមានការប្រជុំពិភាក្សា ពិគ្រោះយោបល់យ៉ាងទូលំទូលាយជាបន្តបន្ទាប់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិ-



www.elibraryofcambodia.org

វឌ្ឍន៍ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងត្រៀមដាក់ឆ្លងក្រុមប្រឹក្សាគោលនយោបាយដីធ្លី មុននឹងដាក់ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីអនុម័ត។

គោលនយោបាយជាតិស្ដីពីលំនៅឋាននេះ បានផ្ដោតការសិក្សាលើលំនៅឋានជាលក្ខណៈទូទៅ ទាំងទីប្រជុំជន និងទីជនបទ ដោយយកចិត្តទុកដាក់លើប្រជាពលរដ្ឋដែលមានចំណូលថវិកាទាបនិងមធ្យម។ យោងតាមច្បាប់អន្តរជាតិ ស្ដីពីសិទ្ធិមនុស្ស បានចែងតម្រូវនូវកត្តាផ្សំចំនួន ៧ ដែលជាមូលដ្ឋាននៃលំនៅឋានសមរម្យសម្រាប់មនុស្សគ្រប់រូប ក្នុងនោះមាន : ១-សុវត្ថិភាពនៃការកាន់កាប់ ២-ភាពអាចស្នាក់នៅបានសមរម្យ ៣-ស្ថិតនៅទីតាំងសមស្រប ៤-មានសេវាផ្គត់ផ្គង់ចាំបាច់ជាមូលដ្ឋាន ដូចជាសេវាកម្មសុខភាព អប់រំ និងហេដ្ឋារចនាសម្ព័ន្ធនានា ៥-តម្លៃសមរម្យអាចមានលទ្ធភាពទិញបាន ៦-អាចទទួលបានសេវាផ្គត់ផ្គង់ខាងលំនៅឋាននិង ៧-ឆ្លើយតបនឹងវប្បធម៌។

តាមរបកគំហើញជារួម ផ្អែកលើទិន្នន័យជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ លោកថកស្ដែនហ្វ្រីឌ្រីកហៃតខម (Thorsten Friedrich Heitkam) ទីប្រឹក្សាជនជាតិអាល្លឺម៉ង់ លោកបានធ្វើការប៉ាន់ស្មានថា នៅឆ្នាំ២០០៨ តាមជំរឿនប្រជារាស្ត្រប្រជាជនកម្ពុជាមានចំនួន ១៣.៣លាននាក់ និងមានគ្រួសារចំនួន ២.៨លានគ្រួរហើយតម្រូវការលំនៅឋានមានចំនួន ២.៨លាន។ លោកបានគណនាថា ប្រមាណជា២០ឆ្នាំទៅអនាគត ក្នុងឆ្នាំ២០៣០ ប្រជាជនកម្ពុជានឹងកើនឡើនដល់ទៅ ១៨លាននាក់ ហើយចំនួនគ្រួសារនឹងកើនឡើងដល់ទៅ ៤.១លានគ្រួរ។ ទន្ទឹមគ្នានឹងនេះដែរតម្រូវការលំនៅឋាននឹងមានចំនួនដល់ទៅ ៤.១លាន នេះបើគិតត្រឹមតែក្នុងមួយគ្រួរ មានចំនួនមនុស្សជាមធ្យមពី ៤.៧នាក់ទៅ ៤.៥នាក់ប៉ុណ្ណោះ (តារាងទី៧)។



www.elibraryofcambodia.org

**តារាងទី៧:** តម្រូវការលំនៅឋានពីឆ្នាំ ២០០៨ ទៅ ឆ្នាំ ២០៣០

| ឆ្នាំ | ចំនួនប្រជាជន(ន.) | ទំហំគ្រួសារ | ចំនួនគ្រួសារ(ន.) | តម្រូវការលំនៅឋាន |
|---|---|---|---|---|
| ២០០៨ | ១៣ ៣៨៨ ៩១០ | ៤.៧ | ២ ៨៣២ ៦៩១ | ២ ៨៣២ ៦៩១ |
| ២០៣០ | ១៨ ៤៨២ ០៥១ | ៤.៥ | ៤ ១០៧ ១២២ | ៤ ១០៧ ១២២ |

**ប្រភព:** ទិន្នន័យជំរឿនប្រជារាស្ត្រ ឆ្នាំ២០០៨

ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០៣០ កម្ពុជានឹងមានតម្រូវការលំនៅឋានប្រមាណ ជាចំនួនជាង **១.២ លាន** លំនៅឋាន (៤ ១០៧ ១ ២២ លំនៅឋាន - ២ ៨៣២៦៩១ លំនៅឋាន = **១.២ លាន លំនៅឋាន**) ហើយកំណើនលំនៅឋាននេះនឹងកើនឡើងភាគច្រើននៅតាមទីប្រជុំជន។ នៅពេលដែលតម្រូវការលំនៅឋានកើនឡើង នោះតម្រូវការដីសម្រាប់បម្រើឱ្យការសាងសង់ក៏នឹងកើនឡើងដែរ។ ការគណនារបស់លោក ថកស្តែន ហ្វ្រីឌ្រីក ហែតខម គឺលោកបានយកតាមគំនិតនិងវប្បធម៌ ដែលប្រជាពលរដ្ឋនៅអឺរ៉ុប ឬបណ្តាប្រទេសលោកខាងលិចកំពុងអនុវត្ត ព្រោះគូស្រករមុននឹងរៀបអាពាហ៍ពិពាហ៍ អនាគតគូស្រករថ្មីថ្មោងនេះ ត្រូវតែសន្សំប្រាក់ ដើម្បីទិញផ្ទះសម្រាប់ខ្លួនស្នាក់នៅពេលដែលពួកគេរៀបការរួច តែករណីនេះ នៅប្រទេសកម្ពុជាមានលក្ខណៈប្លែកពីបណ្តាប្រទេសនៅអឺរ៉ុប ព្រោះសម័យកាលបុរាណ ព្រះរាជាណាចក្រកម្ពុជាមានវប្បធម៌មួយ ដែលអនុវត្តនូវរបបមាតាធិបតេយ្យ គឺយកស្ត្រីជាធំ ឯការដឹកនាំប្រទេសត្រូវបានដឹកនាំដោយព្រះនាងសោមា ដែលភាសាចិនហៅថា ព្រះនាងលីវយី[៩១]។ កូនកម្លោះដែលបានរៀប

[៩១] - យើងអាចពិនិត្យមើលលើផ្នែកអាជ្ញាធរដែនដី មន្ត្រីកាន់ការងារសុទ្ធតែប្រើឈ្មោះ មេ នៅពីមុខ ដូចជាមេកន្ទ្រាញ មេស្រុក មេឃុំ មេភូមិ មេគយ មេកង។ល។ កូនស្រីដែលបានរៀបការរួច មានអាទិភាពយកកូនប្រុសមកនៅខាងស្រី និងរួមរស់ជាមួយមាតាបិតារបស់ខាងកូនស្រី ដោយអាចរស់នៅមួយជីវិត ឬអាចបែក



www.elibraryofcambodia.org

អាពាហ៍ពិពាហ៍រួច ភាគច្រើនត្រូវមករស់នៅគេហដ្ឋានខាងកូនស្រី រហូតដល់មានកូនចៅច្រើន ហើយទំនោរចិត្តបែបនេះ នៅមានរហូតដល់សព្វថ្ងៃ។

## ៦-នគរូបនីយកម្ម និងប្រវត្តិនៃទីតាំងរាជធានី ទីក្រុង និងទីប្រជុំជន

នគរូបនីយកម្មតែងតែវិវត្តទៅជាប់ជាមួយនឹងស្ថាបត្យកម្ម ហើយល្បឿននៃនគរូបនីយកម្មនិងស្ថាបត្យកម្មនេះ ក៏តែងតែបត់បែនតាមសម័យកាលជាប្រវត្តិសាស្ត្រដែរ។ ពេលខ្លះនគរូបនីយកម្មបានកើតឡើងដោយឯកឯង ខ្វះការគ្រប់គ្រងច្បាស់លាស់។ នគរូបនីយកម្មដែលកើតឡើងរបៀបនេះ នាំមកនូវភាពអនាធិបតេយ្យ ដែលគេតែងសង្កេតឃើញមាននៅបណ្ដាប្រទេសក្រីក្រ និងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងភាគច្រើនមិនទាន់មានផែនការប្រើប្រាស់ដីធ្លី ហើយរដ្ឋដើរមិនទាន់សភាពការណ៍របស់ប្រជាជន ករណីដូចជានៅប្រទេសកម្ពុជាក្រោយសម័យសង្គ្រាម។

ចាប់តាំងពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ នគរូបនីយកម្មបានកើតឡើងដោយឯកឯង អាស្រ័យដោយចលនាបម្លាស់ទីចូលក្រុងគួបផ្សំនឹងកត្តាសេដ្ឋកិច្ច និងសង្គមកិច្ចដែលទើបមានជីវិតរស់ឡើងវិញ។ ចលនាបម្លាស់ទីចូលក្រុងនេះ កើតមានជាបន្តបន្ទាប់ស្របពេលដែលប្រជាពលរដ្ឋមួយចំនួន ដែលធ្លាប់តែរស់នៅតំបន់ជនបទមិនទាន់មានការយល់ដឹងពីច្បាប់ទម្លាប់ក្នុងការរស់នៅទីក្រុង និងទីប្រជុំជន និងនៅមានការខ្វះចន្លោះក្នុងការអនុវត្តច្បាប់។

ចេញ តាមការយល់ឃើញរបស់គ្រួសារនីមួយៗ តែគ្មានការបង្ខិតបង្ខំឡើយហើយវប្បធម៌នេះ មានរហូតមកដល់សព្វថ្ងៃនៅក្នុងសង្គមកម្ពុជាមានន័យថា ការតណោនាពីតម្រូវការលំនៅឋានពិតប្រាកដនៅកម្ពុជា អាចតិចជាងពីការ គិតរបស់លោកថក ស្ដែនប្រ៊ី ត្រ៊ីកហែតខម។



www.elibraryofcambodia.org

ដោយប្រទេសកម្ពុជាជាប្រទេសដែលទើបរួចផុតពីសង្គ្រាមផង និងរបបប្រល័យពូជសាសន៍ផង ជាកត្តាមួយដែលធ្វើឱ្យព្រឹត្តិការណ៍ទាំងឡាយក្នុងសង្គមតែងកើតឡើងមុនមានច្បាប់ ។ ករណីខ្លះកើតឡើងមកពីប្រជាជនដែលធ្លាប់រស់នៅជនបទ មិនបានយល់ដឹងពីច្បាប់ ដែលធ្វើឱ្យការអនុវត្តរបស់ពួកគាត់ ប្រព្រឹត្តទៅផ្ទុយពីច្បាប់ ដែលបានចែង និងការអនុវត្តរបស់ពួកគាត់តែងតែមានការខុសឆ្គង ។ តែទន្ទឹមនេះ ក៏មានជនមួយក្តាប់តូច ដែលដឹងពីច្បាប់ហើយតែនៅធ្វើបំពាន ដោយតាំងទីលំនៅ និងសាងសង់គ្មានការអនុញ្ញាត ឬធ្វើទៅតាមចិត្តដែលចង់បាន ។ បើពិនិត្យមើលលើប្លង់ស្ថាបត្យកម្មវិញ ប្រជាពលរដ្ឋនៅមានការខ្វះខាតក្នុងការគោរពច្បាប់លើប្លង់អនុញ្ញាតការសាងសង់ ក៏ដូចជាផ្លូវតម្រង់ ដែលបានបង្ហាញពីការមិនឯកភាពគ្នា ដោយមានសំណង់ខ្លះលយចេញ ខ្លះលយចូល ធ្វើឱ្យបាត់បង់សោភ័ណភាព និងក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញពីការអនុវត្តច្បាប់នៅមានកំរិត ជាពិសេសនៅពេលដែលព្រះរាជាណាចក្រកម្ពុជាមិនទាន់មានការឯកភាពជាតិនៅឡើយ ។

ក្រោយពីការរស់ឡើងវិញជាលើកទី២ នេះ ប្រទេសកម្ពុជាកំពុងឋិតក្នុងសម័យកាលមួយនៃអន្តរកាលប្រជាសាស្ត្រ ដោយមានបន្ទុះប្រជាសាស្ត្រដែលកើតបានពីការកើតឡើងនៃមនុស្សជំនាន់ក្រោយ នោះគឺជាពេលដែលប្រជាជនកម្ពុជាមានសិទ្ធិសេរីភាពក្នុងការរស់នៅ ក្នុងការរកទទួលទាន មានម្ហូបអាហារបរិភោគគ្រប់គ្រាន់ ។ ដូចនេះក្រុមគ្រួសារ និងគូរស្រករដែលព្រាត់ប្រាស់គ្នា ត្រូវបានរស់នៅជួបជុំគ្នាវិញ ហើយក៏ជាច្បាប់ធម្មជាតិដែរ ប្រជាជនបានធ្វើការបន្តពូជពង្សវង្សត្រកូល ដែលត្រូវបានរបប ប៉ុល ពតកាប់សម្លាប់ និងជំនាន់មនុស្សថ្មីត្រូវកើតឡើងដែលជាការរួមចំណែកជាកម្លាំងពលកម្មឱ្យដល់ប្រទេស និងជាតម្រូវការចាំបាច់



www.elibraryofcambodia.org

សម្រាប់បម្រើឱ្យវិស័យកសិកម្ម និងតម្រូវការសង្គមនៃជំនាន់មនុស្សទើបកើតក្រោយឆ្នាំ១៩៧៩។

តាមជំរឿនប្រជាសាស្ត្រឆ្នាំ១៩៩៨ ពីរាមីតអាយុរបស់ប្រជាជនកម្ពុជា មានបាតរីកធំទូលាយ និងស្រួចទាំងពីរឡើងទៅលើស្តួចរៀវ ដែលបង្ហាញឱ្យឃើញថាទម្រង់អាយុប្រជាជនកម្ពុជាមានទម្រង់ប្រជាជន "**ក្មេង**" (young population) ដែលបច្ចុប្បន្នវ័យនៃជំនាន់មនុស្សថ្មីនេះ កំពុងឋិតក្នុងនៃវ័យពលកម្ម ជាវ័យត្រូវចូលរួមចំណែកឱ្យដល់ការបង្កបង្កើនផលសម្រាប់កំណើនសេដ្ឋកិច្ចជាតិ។

ដោយឡែកនៅទីក្រុងភ្នំពេញ និងនៅតាមទីប្រជុំជននៃទីរួមខេត្តធំៗ មានចលនាប្រជាជនបានធ្វើចលនាបម្លាស់ទីចូលមកតាំងនៅជាបន្តបន្ទាប់ ជាពិសេសនៅតាមតំបន់ជាយក្រុង បង្កើតជាតំបន់រស់នៅគ្មានសណ្តាប់ធ្នាប់។ បច្ចុប្បន្ននៅតាមបុកខ្លះ តាមសង្កាត់ក្នុងខណ្ឌមួយចំនួន គេសង្កេតឃើញនូវមានផ្ទះខ្លះសង់បិទផ្លូវឬសង់លើដីចំណីផ្លូវ ដែលធ្វើឱ្យផ្លូវមានសភាពតូចចង្អៀតឬសង់ពង្រីកបន្ថែមលើសំណង់ចាស់ដោយគ្មានច្បាប់អនុញ្ញាត និងបានប្រើប្រាស់ដីគ្មានសណ្តាប់ធ្នាប់ ឬសង់ឡើងដោយខ្លួនឯង ស្មុគស្មាញ ចង្អៀត គ្មានជួរតម្រង់ ធ្វើឱ្យផ្លូវគ្មានចិញ្ចើម វៀចក្រងិកក្រងក់ និងតូចចង្អៀត ពេលមានអាសន្ន ឬគ្រោះអគ្គិភ័យកើតឡើង មិនអាចផ្តល់លទ្ធភាពឱ្យរថយន្តពន្លត់អគ្គិភ័យចូលប្រតិបត្តិការបានឡើយ។

នៅអាណត្តិទី២នៃរដ្ឋសភាជាតិ រាជរដ្ឋាភិបាលបានបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្រោយពីការបង្កើតក្រសួងក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងបានខិតខំបង្កើតច្បាប់ និងក្របខណ្ឌគតិយុត្តជាច្រើន ដើម្បីទុកឱ្យប្រជាពលរដ្ឋអនុវត្តច្បាប់។ ដូចនេះរាល់សំណង់នានាដែលនឹងត្រូវសង់ ត្រូវតែ



www.elibraryofcambodia.org

គោរពទៅតាមបទដ្ឋានដែលច្បាប់បានដាក់ចុះ[៥២]។ ទន្ទឹមនេះសំណង់ដែលខុសច្បាប់ត្រូវមានការកែលម្អឡើងវិញ ដើម្បីឱ្យសក្តិសមទៅនឹងនិយមន័យនៃទីក្រុង និងដើម្បីប្រែក្លាយមុខមាត់ទីក្រុងឱ្យមានសោភ័ណភាព និងសុខុមាលភាព។ ប្រព្រឹត្តិការណ៍ទាំងនេះ គេសង្កេតឃើញច្រើនកើតមានឡើងនៅចន្លោះឆ្នាំ១៩៩២ ទៅឆ្នាំ១៩៩៧។

រាជរដ្ឋាភិបាលបានធ្វើការបណ្តុះបណ្តាលធនធានមនុស្សជាប្រចាំ និងមានការផ្សព្វផ្សាយនូវសមិទ្ធិផលដែលសម្រេចបាន តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ក្នុងន័យដើម្បីឱ្យមន្ត្រីរាជការរបស់ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក៏ដូចជាប្រជាពលរដ្ឋបានយល់ដឹងនិងចេះគោរពច្បាប់របស់ប្រទេសលើវិស័យដីធ្លី។

ជាទូទៅនៅកម្ពុជា បើពិនិត្យមើលពីទីតាំងរាជធានីភ្នំពេញ និងទីតាំងក្រុងស្ទួលនានានៅតាមខេត្តទាំងម្ភៃបីវិញ គឺ ៩៩ភាគរយមានទីតាំងឋិតនៅជាប់នឹងផ្លូវទឹក។ រាជធានីភ្នំពេញ ឋិតនៅចំផ្លូវបំបែកនៃទន្លេមេគង្គ ដែលទីប្រសព្វនៃទន្លេចតុមុខ មើលរូបទី២១ ផែនទីរាជធានីភ្នំពេញឆ្នាំ២០១០។

ទីក្រុងសៀមរាប មានដងស្ទឹងសៀមរាបហូរកាត់ ចាក់ទៅបឹងទន្លេសាប។ ដោយក្រុងនេះ មានស្ទឹងសៀមរាបហូរកាត់ បានធ្វើឱ្យទេសភាពក្រុងមានសោភ័ណភាពល្អប្លែក សម្រាប់ទាក់ទាញភ្ញៀវទេសចរ និងបង្កើតបានបរិយាកាសគួរគយគន់ក្រោយពេលដែលអ្នកទេសចរចូលមកក្រុងវិញ បន្ទាប់ពីការទស្សនាប្រាសាទទាំងឡាយនាពេលថ្ងៃ។

[៥២] - មើលឧបសម្ព័ន្ធ ១ ។



www.elibraryofcambodia.org

ក្រុងសេរីសោភ័ណឋិតក្នុងខេត្តបន្ទាយមានជ័យ មានទីតាំងអំណោយផលល្អ គឺមិនត្រឹមតែឋិតជិតច្រកព្រំដែនប៉ុណ្ណោះទេ ថែមទាំងមានកូនភ្នំ ស្ទឹងសេរីសោភ័ណ ហូរកាត់ និងមានព្រៃក ប្រឡាយ ដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ច សម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងមូលដ្ឋាន។

ផ្អែកលើសក្តានុពល និងកាលានុវត្តភាព កំណើនប្រជាជន និងការងារធ្វើក្នុងក្រុង មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត និងក្រុង បានរៀបចំប្លង់គោលប្រើប្រាស់ដីក្រុង ដោយរៀបចំឡើងសម្រាប់រយៈពេល ១៥ ឆ្នាំ គឺពីឆ្នាំ២០១០ ទៅឆ្នាំ២០២៥ (មើលរូបទី៤៦-៤៧-៤៨)។ តាមការប្រមើលមើលទៅអនាគតក្នុងរយៈពេល២៥ឆ្នាំប្រជាជននៅក្នុងក្រុងនេះ នឹងកាន់តែមានជីវភាពធូរធារឡើង និងប្រកបដោយសុខមាលភាព អាស្រ័យដោយសារក្រុងពីរនៃខេត្តនេះ (ក្រុងមួយទៀតនោះគឺក្រុងប៉ោយប៉ែត) មានទីតាំងជាប់នឹងព្រំដែន ដែលជាច្រកសេដ្ឋកិច្ចដ៏សំខាន់ ភ្ជាប់ពីប្រទេសថៃមកប្រទេសកម្ពុជាតាមផ្លូវជាតិលេខ៥ និងមានផ្លូវដែកឆ្លងតំបន់កាត់តាមក្រុងប៉ោយប៉ែត ដែលបាននិងកំពុងធ្វើការជួសជុលឡើងវិញ។

រាជរដ្ឋាភិបាលមានទិសដៅជាយុទ្ធសាស្ត្រ អភិវឌ្ឍន៍តំបន់ព្រំដែនទាំងអស់ ដែលជាតំបន់មានជម្លោះ ប្រែក្លាយឱ្យទៅជាតំបន់សេដ្ឋកិច្ចនិងមានការអភិវឌ្ឍ។ ទន្ទឹមនេះផ្លូវជាតិលេខ៥ ក៏ជាទីប្រសព្វមកផ្លូវជាតិលេខ៦ ឆ្ពោះមកក្រុងសៀមរាប ដែលជាទីក្រុងបូរាណនិងទីក្រុងប្រវត្តិសាស្ត្រ។



www.elibraryofcambodia.org

## រូបទី៤៦ :ការរៀបចំផែនការប្រើប្រាស់ដីនិងការអភិវឌ្ឍ ក្រុងសេរីសោភ័ណសម្រាប់ឆ្នាំ២០២៥



## រូបទី៤៧ : ប្លង់អភិវឌ្ឍក្រុងសេរីសោភ័ណនៅអនាគត





www.elibraryofcambodia.org

**រូបទី៤៨:** ទំនាក់ទំនងរវាងតំបន់ក្នុងក្រុងនិងតំបន់ជុំវិញ



ទេសភាពដងស្ទឹងសង្កែក៏មិនខុសពីទេសភាពស្ទឹងសៀមរាបដែរ បានធ្វើឱ្យក្រុងបាត់ដំបងឋិតក្នុងទិដ្ឋភាពស្រទន់នៃរាត្រីកាល ក្រោមជំនោរខ្យល់ត្រជាក់បក់មករំភើយៗ។ ភាគច្រើនមានភ្ញៀវទេសចរអន្តរជាតិ អង្គុយសម្រាកលំហែកាយនៅតាមភោជនីយដ្ឋានឋិតនៅតាមដងស្ទឹង ដែលបានសាងសង់ឡើងតាំងពីសម័យបារាំង ហើយសំណង់ស្ថាបត្យកម្មទាំងនេះ នូវរក្សាបានទម្រង់ដើមខ្លះៗរហូតដល់សព្វថ្ងៃ។

ទេសភាពទាំងនេះក៏មិនខុសពីដងស្ទឹងពោធិសាត់ដែលហូរកាត់ក្រុងពោធិសាត់ និងដងស្ទឹងសែនដែលហូរកាត់ក្រុងកំពង់ធំឡើយ។ ខេត្តទាំងពីនេះ ឋិតនៅជិតគ្នាបង្កើយ ត្រើយម្ខាងម្នាក់នៃបឹងទន្លេសាប។ បើគេជិះកាណូតឆ្លងកាត់បឹងទន្លេសាបត្រង់កន្លែងខណ្ឌចែករវាងបឹងធំ និងបឹងតូច មានទីតាំងនៅផាត់សណ្ដាយ (ខេត្ត



www.elibraryofcambodia.org

កំពង់ធំ) ឆ្លងទៅស្រុកក្រគរ (ខេត្តពោធិសាត់) នោះ គេប្រើពេលវេលាប្រមាណជាកន្លះម៉ោងប៉ុណ្ណោះ នៅរដូវសម្រក។

ក្រុងកំពង់ឆ្នាំងមានទីតាំងភូមិសាស្ត្រ ឋិតនៅតាមដងផ្លូវជាតិលេខ៥ ចម្ងាយ ៩១គ.ម. ពីក្រុងភ្នំពេញ។ ជាខេត្តមានប្រវត្តិផ្នែកសិប្បកម្មស្មូនក្អមឆ្នាំងតាំងពីសម័យបូរាណ។ទីប្រជុំជនក្រុងនៃខេត្តឋិតនៅជាប់នឹងបឹងទន្លេសាប ភ្ញៀវទេសចរអាចឈរសម្លឹងមើលទៅត្រើយម្ខាង ឃើញទេសភាពខៀវស្រងាត់ រំលេចដោយប្រជុំភ្នំតូចៗ ដែលមើលទៅឃើញភ្នំទាំងនេះហាក់ជាប់គ្នា បង្កើតបានជាប្រជុំភ្នំមានរូបសណ្ឋានដូចនាងកង្រីពេលនាងរត់តាមរកស្វាមីរិទ្ធិសែន ហើយបានស្លាប់នៅត្រង់ផ្លូវទឹកនេះ(ក្នុងរឿងរិទ្ធិសែននិងនាងកង្រី)។ ក្រៅពីទីនេះ នៅមានទីតាំងជាច្រើនទៀត ដែលមានឈ្មោះជាប់ពាក់ព័ន្ធនឹងរឿងរិទ្ធិសែននិងនាងកង្រី។

**រូបទី៤៩:** ផែនទីប្រើប្រាស់ដីក្រុងកំពង់ឆ្នាំង





www.elibraryofcambodia.org

ក្រុងកំពង់ឆ្នាំងមានកូនភ្នំតូចៗជាច្រើនទៀត ដែលជារមណីយដ្ឋានបម្រើឱ្យវិស័យទេសចរណ៍មានដូចជា ភ្នំសន្ទួច ភ្នំទ្រពាត... ជាភ្នំមានទម្រង់សិលាក្រែពុកផុយ អំណោយផលដល់ការដុះលូតលាស់រុក្ខជាតិស្រស់បំព្រង និងមានទេសភាពប្លែកៗ (មើលរូបទី៤៩)។ លើផ្នែកនគរូបនីយកម្ម ទីក្រុងនេះហាក់ដូចជាពុំទាន់មានការទាក់ទាញប៉ុន្មានឡើយ ដោយសារក្រុងនេះជាផ្លូវឆ្លងកាត់ទៅខេត្តនានា។

ថ្វីត្បិតតែព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានផ្ទៃដីតូចក៏ពិតមែន តែកម្ពុជាមានភ័ព្វសំណាង ដោយនៅភាគនិរតីនៃប្រទេស មានខេត្តចំនួនបួនឋិតនៅជាប់នឹងសមុទ្រគឺ ខេត្តកែប ខេត្តកំពត ខេត្តកោះកុង និងខេត្តព្រះសីហនុ ។

**រូបទី៥០:** ទីតាំងក្រុងព្រះសីហនុក្រុងកោះកុង ក្រុងកំពត និងក្រុងកែប




Source: JICA Study Team

**Figure 5.6.2 Image of Logistic Axis in the Study Area**



www.elibraryofcambodia.org

### រូបទី៩១: ទីតាំងក្រុងកោះកុង




Source: JICA Study Team

**Figure 4.2.3 Distribution of Urban Poor Areas in Koh Kong Provinc**

### រូបទី៩២: ទីតាំងក្រុងព្រះសីហនុ និងខណ្ឌព្រៃនុប-ខណ្ឌស្ទឹងហាវ




Source: JICA Study Team

**Figure 4.2.4 Profile of Each Urban Poor Area in City of Sihanouk**



www.elibraryofcambodia.org

ខេត្តព្រះសីហនុជាតំបន់ប៉ូលសេដ្ឋកិច្ចមួយក្នុងតំបន់។ តាមរយៈរូបទី ៥០-៥១-៥២ បង្ហាញឱ្យឃើញពីទីតាំងក្រុងទាំងបួន ដែលសុទ្ធតែមានទីតាំងភូមិសាស្ត្រ ឋិតនៅជាប់នឹងឆ្នេរសមុទ្រទាំងអស់)[៥៣]។ ឆ្នេរសមុទ្រកម្ពុជាដែលឋិតនៅក្នុងខេត្តទាំងបួន មានបណ្តោយ ៤៤០ គីឡូម៉ែត្រ ត្រូវបានដាក់បញ្ចូលជាសមាជិកនៃក្លិប ដែលមានឆ្នេរស្អាតលើសគេលើពិភពលោកនៅឆ្នាំ២០១១។ ក្រុងទាំងបួនសុទ្ធជាក្រុងដែលមានភាពទាក់ទាញលើវិស័យអេកូទេសចរណ៍ ឬទេសចរណ៍ធម្មជាតិ។ មិនតែប៉ុណ្ណោះក្រុងព្រះសីហនុ គឺជាក្រុងកំពង់ផែអន្តរជាតិ មានសារៈសំខាន់លើផ្នែកសេដ្ឋកិច្ចជាតិ និងតំបន់នេះជាតំបន់ឧស្សាហកម្មនៅអនាគត។

ក្រុងកំពង់ចាម ក្រុងក្រចេះ និងក្រុងស្ទឹងត្រែងជាក្រុងដែលឋិតនៅជាប់ដងទន្លេមេគង្គផ្នែកខាងលើ។ នេះជាសញ្ញាមួយ បង្ហាញពីភាពឈ្លាសវៃរបស់បុព្វបុរសខ្មែរដែលមានភាពប៉ិនប្រសព្វក្នុងការជ្រើសរើសទីតាំងភូមិសាស្ត្រ ដើម្បីកំណត់តំណាងទីតាំងរដ្ឋបាល នៃក្រុងនានាតាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ន ដែលទីតាំងទាំងអស់នោះ បានផ្សារភ្ជាប់ទៅនឹងបរិស្ថានធម្មជាតិ សេដ្ឋកិច្ច សង្គមកិច្ច ប្រវត្តិសាស្ត្រ និងជាបណ្តុំគមនាគមន៍ដឹកជញ្ជូនរវាងផ្លូវគោកនិងផ្លូវទឹក បានយ៉ាងងាយស្រួល។

នគរូបនីយកម្មនៅតំបន់ឥសាន្ត មិនមានល្បឿនលឿនដូចតំបន់វាលទំនាបទន្លេមេគង្គឡើយ។ សម័យបច្ចុប្បន្ន នៅពេលដែលព្រះរាជាណាចក្រកម្ពុជាមានសន្តិភាពទូទាំងប្រទេស រាជរដ្ឋាភិបាលបានអភិវឌ្ឍន៍តំបន់នេះ មានការបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម និងបានធ្វើឱ្យទីក្រុងក្នុងតំបន់នេះ ក៏ដូចជាខេត្ត

---

[៥៣] - ឯកសារ Final Report Book I : "National integration Development Strategy for coastal area, November 2010" MLMUPC and Japan International Cooperation Agency (JICA)



www.elibraryofcambodia.org

ក្នុងតំបន់ទាំងមូលមានការផ្លាស់ប្ដូរមុខមាត់គួរឱ្យកត់សម្គាល់ និងធ្វើឱ្យប្រទេសលែងមានតំបន់ដាច់ស្រយាល ។

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានអនុញ្ញាតឱ្យខ្សែបណ្ដោយខេត្តក្រុងទាំងនេះអភិវឌ្ឍន៍ក្រុង ដោយអនុវត្តតាមគម្រោងប្លង់ក្រុងទាំងនេះ មានប្លង់ក្រុងរតនគិរី ក្រុងមណ្ឌលគិរី ក្រុងប៉ៃលិន ដើម្បីចៀសវាងការប្រើប្រាស់ដីក្រុងដោយគ្មានផែនការច្បាស់លាស់ ។

ទោះបីជាមានក្រុងទើបបង្កើតថ្មីៗនៅឆ្នាំ២០០៩ ក៏ដោយ តែក្រុងទាំងនោះមានដើមកំណើតពីទីរួមខេត្តរបស់ខេត្តក្រុងពីសម័យមុនដែរ លើកលែងក្រុងបាវិតក្រុងប៉ោយប៉ែត និងក្រុងសួងចេញ ។ ឈរលើមូលដ្ឋាននៃប្លង់ទីក្រុងចាស់ អ្នករៀបចំក្រុងបច្ចុប្បន្នបាន និងកំពុងធ្វើប្លង់ពង្រីកទីក្រុងទៅតំបន់ជាយក្រុង អាស្រ័យដោយកំណើនប្រជាជនចេះតែកើនឡើងឥតឈប់ឈរ ដែលបាននិងកំពុងដើរទន្ទឹមគ្នានឹងដំណើរនគរូបនីយកម្ម ដោយបានធ្វើឱ្យប្លង់រាជធានីឬក្រុងភ្នំពេញ ក៏ដូចជាប្លង់ទីក្រុងមួយចំនួន មានក្រុងសៀមរាប ក្រុងព្រះសីហនុ ក្រុងបាត់ដំបង ក្រុងកំពង់ចាម...ជាដើម ត្រូវតែពង្រីកផ្ទៃដីក្រុង ដើម្បីឱ្យស្របទៅតាមការអភិវឌ្ឍ និងតម្រូវការតាមស្ថានភាពជាក់ស្ដែងនៃក្រុងនីមួយៗ ។

ប្លង់កណ្ដាលក្រុងនានាច្រើនបានគូរនៅសម័យអាណានិគមបារាំង និងសម័យសង្គមរាស្ត្រនិយម តែគ្រាន់ជាប្លង់ទីរួមខេត្តដ៏តូចប៉ុណ្ណោះ ។ បច្ចុប្បន្នទាក់ទងទៅនឹងកំណើនប្រជារាស្ត្រក្នុងរយៈពេលជិតកន្លះសតវត្ស (១៩៦២-២០០៨[៥៤]) កំណើនប្រជាជនកម្ពុជាមានល្បឿនលឿន បានធ្វើឱ្យចំនួនប្រជាជនកើនឡើងទ្វេដង ។ ដូចនេះ ទំហំឬផ្ទៃទីក្រុង ត្រូវមានការពង្រីកបន្ថែមជាបន្តបន្ទាប់ ។

---

[៥៤] - ឆ្នាំ ១៩៦២ ជំរឿនប្រជារាស្ត្រលើកទី ១ និងឆ្នាំ ២០០៨ ជំរឿនប្រជារាស្ត្រលើកទី ៣ (រយៈពេល៤៦ឆ្នាំ) ។



www.elibraryofcambodia.org

បច្ចុប្បន្នបើពិនិត្យមើលទៅលើសំណង់ស្ថាបត្យកម្មវិញឃើញថា នៅក្រុងភ្នំពេញ ហាក់មានការប្រែប្រួលនៅតាមទីកន្លែងមួយចំនួន ដោយតំបន់លំនៅឋានជាភូមិគ្រឹះធំៗខ្លះ ដែលពីមុនប្រើប្រាស់ជាលំនៅឋាន បានក្លាយជាតំបន់ពាក់កណ្តាលលំនៅឋាននិងពាណិជ្ជកម្ម និងមានខ្លះបានប្រែក្លាយជាសណ្ឋាគារ ឬជាភោជនីយដ្ឋាន ដូចជានៅតាមមហាវិថីព្រះនរោត្តម មហាវិថីព្រះសីហនុ មហាវិថីព្រះមុនីវ៉ង្ស ជាពិសេសគេសង្កេតឃើញមាននៅខណ្ឌទួលគក ដែលជាតំបន់ភូមិគ្រឹះស្ងប់ស្ងាត់ បច្ចុប្បន្នបានក្លាយជាអ៊ូអរនិងមានការអភិវឌ្ឍប្លែកៗ។ ចំពោះលំនៅឋានចាស់ៗខ្លះ ដែលជាសំណង់ទ្រុឌទ្រោមត្រូវបានរុះរើ និងក្លាយជាសំណង់ថ្មីរឹងមាំ ជាអគារពាណិជ្ជកម្ម និងធ្វើឱ្យតំបន់ទាំងនេះក្លាយជាតំបន់ដែលមានតម្លៃដីឡើងខ្ពស់។

ដីធ្លីពីមុនដែលនៅទំនេរ ជាតំបន់ដីទុកចោលមានស្មៅដុះមិនទាន់ប្រើការ បច្ចុប្បន្នមានសំណង់ថ្មីៗកើតឡើង មានទាំងភូមិគ្រឹះឬផ្ទះល្វែងទាំងប្លុកៗ ដុះឡើងដូចផ្សិត និងបុរីនានាបានកើតឡើង ធ្វើឱ្យទីក្រុងភ្នំពេញរីកយ៉ាងលឿនទៅគ្រប់ទិសទី ជាពិសេសនៅតំបន់ជាយក្រុងបានរីកយ៉ាងលឿន។ ដីឡូត៍ធំៗដែលនៅទំនេរ មិនទាន់សាងសង់ឬមានស្មៅដុះ បានក្លាយជាអគារធំៗ និងកន្លែងទីតាំងខ្លះក្លាយជាលក់រថយន្តដែលបានប្រើរួច និងរថយន្តថ្មីនាំចូលគ្រប់ប្រភេទ មានរថយន្តទេសចរណ៍ និងរថយន្តដឹកទំនិញតូចធំ។

អ្នកក្រុងភ្នំពេញបច្ចុប្បន្ន កំពុងជួបប្រទះនឹងបញ្ហាខ្វះចំណតរថយន្ត ដែលពីមួយថ្ងៃទៅមួយថ្ងៃចំនួនរថយន្តកាន់តែកើនច្រើនឡើងៗ ដូចនេះទីកន្លែងចតរថយន្តកាន់តែមានការលំបាក។ អាជ្ញាធរក្រុងបាន និងកំពុងរៀបចំចំណតរថយន្តដែលត្រូវបង់ថវិកាតាមម៉ោង និងធ្វើយ៉ាងណារៀបចំសណ្តាប់ធ្នាប់ក្រុងឱ្យមានរបៀបរៀបរយក្នុងការប្រើប្រាស់ផ្លូវថ្នល់។



www.elibraryofcambodia.org

មូលហេតុនៃចំនួនរថយន្តកើនឡើង គឺដោយសារប្រជាជនមានលទ្ធភាព ឬមានសេដ្ឋកិច្ចគ្រួសារល្អ អាចឱ្យពួកគេមានលទ្ធភាពទិញរថយន្តបាន សម្រាប់ប្រើប្រាស់ជាមធ្យោបាយក្នុងគ្រួសារ ក៏ដូចជាការដឹកជញ្ជូនផ្សេងៗ មានការដើរកំសាន្តពេលចុងសប្តាហ៍។ល។ ពីមួយឆ្នាំទៅមួយឆ្នាំ គេសង្កេតឃើញចំនួនរថយន្តគ្រប់ប្រភេទទំនើបៗកើនឡើង។ តាមដងផ្លូវនានាពីមួយថ្ងៃទៅមួយថ្ងៃ បញ្ហាកកស្ទះចរាចរបានកើតឡើងជាញឹកញាប់ ពិសេសនៅពេលព្រឹកម៉ោងចេញពីលំនៅឋានទៅធ្វើការ និងពេលល្ងាចម៉ោងវិលត្រឡប់ចូលលំនៅឋានវិញ។ ដង់ស៊ីតេមនុស្សដែលប្រើប្រាស់ផ្លូវថ្នល់បានកើនឡើង ទន្ទឹមនឹងចំណូលប្រជាជនមករស់នៅក្នុងទីក្រុងភ្នំពេញ។ គេសង្កេតឃើញថ្នាក់ដឹកនាំសាលារាជធានីភ្នំពេញមានញឹកក្នុងការពង្រីកផ្លូវជាបន្តបន្ទាប់ និងមានការបំពាក់ដោយកំរាលឥដ្ឋលើចំណើផ្លូវ និងរក្សាបាននូវតំបន់បៃតងតាមដងផ្លូវ ដើម្បីធានាបានសោភ័ណភាពនិងបរិស្ថានទីក្រុង។

ទន្ទឹមនឹងបញ្ហាចរាចរ ដែលពីមួយថ្ងៃទៅមួយថ្ងៃកាន់តែមានការកកស្ទះនៅតាមផ្លូវមួយចំនួនសាលាក្រុងភ្នំពេញ បានបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដើម្បីបញ្ចៀសការកកស្ទះ ដោយបានសាងសង់ស្ពាននៅតាមច្រកផ្លូវចេញទៅក្រៅក្រុងមានស្ពានព្រែកក្តាម ស្ពានភ្លោះព្រះមុនីវង្ស និងស្ពានអាកាសទី១នៅក្បាលថ្នល់។ សាលារាជធានីមានគម្រោងសង់ស្ពានមួយចំនួនទៀត ស្របនឹងស្ពានជ្រោយចង្វា និងស្ពាននៅតាខ្មៅ ឆ្លងកាត់ទន្លេបាសាក់ឆ្ពោះទៅត្រើយម្ខាង មុំវត្តចំពុះក្អែក។ ស្ពានអាកាសទី២ ចាប់ផ្តើមបើកការដ្ឋាននៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ដែលនឹងត្រូវប្រើពេលវេលា ១៣ខែ ដោយចំណាយទឹកប្រាក់អស់ប្រមាណជា ៨,៧លានដុល្លារស.រ.អ.។ ស្ពានអាកាសទី២នេះ ឋិតនៅត្រង់ចំណុចភ្លើងស្តុបព្រះកុសុមៈ (មើលរូបទី៥៣) ប្រសព្វនឹងមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីកម្ពុជាក្រោម



www.elibraryofcambodia.org

ដែលមានប្រវែង ៣៤៥ម៉ែត្រ និងទទឹង ១៥,២ម៉ែត្រ និងកម្ពស់ ៥,៥០ម៉ែត្រ។ ប្រមុខរាជរដ្ឋាភិបាលបានបញ្ជាឱ្យសាលារាជធានីភ្នំពេញ លើកគំរោងសាងសង់ស្ពានអាកាសទី៣ ទៀត ឋិតនៅស្របនឹងស្ពានស្ទឹងមានជ័យដើម្បីបញ្ចៀសការកកស្ទះនៅត្រង់ចំណុចប្រសព្វមហាវិថីព្រះមុនីរ៉េត និងផ្លូវលេខ២៧២។

បើយើងត្រឡប់មើលទៅមុនឆ្នាំ១៩៩០ វិញ ក្រុងភ្នំពេញជាទីស្ងប់ស្ងាត់នៅពេលថ្ងៃ បើពេលយប់គឺងងឹតដោយសារភ្លើងអគ្គិសនី មិនអាចបម្រើការបានគ្រប់គ្រាន់។ តែបច្ចុប្បន្នរាជធានីភ្នំពេញនាពេលរាត្រីជាទីក្រុងមួយ ដែលប្រកបដោយភ្លើងពណ៌ចម្រុះ មានមនុស្សម្នាទៅមកកកកុញ។ ផ្សារទំនើបកើតឡើងហូរហែរមានភ្ញៀវជាតិ បរទេស ចេញចូល ទិញ និងបរិភោគ ដែលជាកត្តាមួយបង្ហាញឱ្យឃើញពីសង្គមកម្ពុជាមានការអភិវឌ្ឍឈានឡើងយ៉ាងលឿនជាបន្តបន្ទាប់ ពីមួយឆ្នាំទៅមួយឆ្នាំគួរឱ្យមានមោទនភាព។ នៅពេលថ្ងៃសកម្មភាពសេដ្ឋកិច្ច ចរាចរខ្វាត់ខ្វែង ទៅ និងមកយ៉ាងមមាញឹក។ ភ្នំពេញមានផ្លូវកាត់ខ្វាត់ខ្វែងជាក្រឡាចក្រត្រង្គ តែនៅពេលល្បឿននគរូបនីយកម្មនៅមានកម្រិត មនុស្សម្នាច្រើនធ្វើចរាចរតាមមហាវិថីធំៗតែប៉ុណ្ណោះ ផ្ទុយពីបច្ចុប្បន្នសកម្មភាព ផ្លូវទាំងឡាយក្លាយជាអ៊ូអរ និងជាញឹកញាប់មានការកកស្ទះបានកើតឡើង។



www.elibraryofcambodia.org

**រូបទី៥៣:** គម្រោងសាងសង់ស្ពានអាកាសទី ២



**ប្រភព:** ដកស្រង់ចេញពីគេហទំព័រដើមអំពិលថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០

តម្លៃដីធ្លីបានកើនឡើងខ្ពស់ហួសពីការស្មាន ជាពិសេសតំបន់កណ្តាលក្រុង (តម្លៃដី ១ម.$^2$ អាចឡើងដល់ទៅលើសពី១ពាន់ដុល្លារសហរដ្ឋអាមេរិក)។ បច្ចុប្បន្នទីផ្សារដីហាក់ស្ថិតក្នុងស្ថានភាពស្ងប់វិញ នៅពេលមានវិបត្តិអចលនទ្រព្យលើពិភពលោក ដែលវិបត្តិនេះក៏មានឥទ្ធិពលខ្លះមកដល់កម្ពុជាផងដែរ។

ដោយសារប្រទេសកម្ពុជាមានសង្គ្រាម ការខកខានមិនបានធ្វើជំរឿនជាបញ្ហាចំបងមួយ ធ្វើឱ្យប្រទេសយើងខ្វះទិន្នន័យជាក់ស្តែង និងមិនអាចមានទិន្នន័យច្បាស់លាស់ ដើម្បីធ្វើការព្យាករណ៍ ក៏ដូចជាមានការលំបាកក្នុងការធ្វើផែនការឱ្យបានជាក់លាក់ ដើម្បីអភិវឌ្ឍន៍ប្រទេសបានឡើយ។ នៅឆ្នាំ១៩៩៨ ជាឆ្នាំដែលកម្ពុជាមានសន្តិភាព ស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើជំរឿនប្រជា-



www.elibraryofcambodia.org

រាស្ត្រឡើងវិញ ក្នុងអំឡុងពេលដែលប្រទេសកម្ពុជាខកខានមិនបានធ្វើជំរឿនសោះ តាំងពីឆ្នាំ១៩៦២ បើគណនាទៅគឺមានរយៈពេល៣៦ឆ្នាំ។ ដូចនេះនៅឆ្នាំ១៩៩៨ ជាឱកាសដ៏ល្អមួយដែលប្រទេសកម្ពុជាគ្មានតំបន់អប្បគមន៍ ហើយអ្នកធ្វើជំរឿន អាចមានលទ្ធភាពចូលទៅធ្វើសម្ភាសន៍ដល់ទីកន្លែង ដែលប្រជាជនរស់នៅក្នុងតំបន់ខ្មែរក្រហម។

រយៈពេលដប់ឆ្នាំចាប់ពីជំរឿនប្រជារាស្ត្រលើកទី១ឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៨ រាជរដ្ឋាភិបាលបានបន្តធ្វើជំរឿនប្រជារាស្ត្រទៀត ដែលធ្វើឱ្យកម្ពុជាមានទិន្នន័យគ្រប់គ្រាន់សម្រាប់បម្រើឱ្យការវិភាគ ក៏ដូចជាការស្រាវជ្រាវ ក្នុងការធ្វើផែនការគ្រប់វិស័យ ដើម្បីឈានទៅអភិវឌ្ឍន៍ប្រទេស។ ការអភិវឌ្ឍប្រទេសបានប្រព្រឹត្តទៅដោយមានសន្ទុះឈានឡើងជាបន្តបន្ទាប់ ថ្វីត្បិតតែនៅចុងទសវត្សទី៩០ មានបណ្តាប្រទេស ក្នុងតំបន់អាស៊ីអគ្នេយ៍មួយចំនួនជាប្រទេសសមាជិកអាស៊ាន ហើយដែលសេដ្ឋកិច្ចវិទូបានចាត់ទុកថា ជាប្រទេសកូនខ្លានោះ កំពុងតែទទួលរងនូវវិបត្តិសេដ្ឋកិច្ចនេះ ក្នុងនោះមាន (ប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសភីលីពីន និងប្រទេសឥណ្ឌូនេស៊ីជាដើម)។ ចំណែកប្រទេសកម្ពុជាវិញ ដូចជាមិនទទួលរងនូវឥទ្ធិពលនេះឡើយ ដែលធ្វើឱ្យដំណើរការអភិវឌ្ឍរបស់ប្រទេសកម្ពុជា បានឈានឡើងទៅមុខតាមជំហាន នៃកម្លាំងសេដ្ឋកិច្ចដែលប្រទេសយើងមាន។

លទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះ បានធ្វើឱ្យអភិបាលរាជធានីភ្នំពេញសម្រេចចិត្តយកប្រធានបទនៃការអភិវឌ្ឍទីក្រុង ទៅចុះឈ្មោះចូលនៅដើមខែសីហា ឆ្នាំ២០០៥ [៥៥] ដោយធ្វើការជ្រើសរើសយកគម្រោង ២ នៅក្នុងការរៀបចំ

[៥៥] - ដឹកនាំដោយឯកឧត្តម កែប ជុតិមា អភិបាលរាជធានី និងគណៈប្រតិភូរួមមានឯកឧត្តមម៉ាន់ឈឿន អភិបាលរងរាជធានី លោកឆាយរិទ្ធីសែន ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី លោក ប៉េង



www.elibraryofcambodia.org

ស្ដារទីក្រុងឡើងវិញ ដែលគម្រោងទាំងពីរនេះឋិតនៅក្នុងគម្រោងផែនការយុទ្ធសាស្ត្រនគរូបនីយកម្មរាជធានីភ្នំពេញឆ្នាំ២០២០។

គម្រោងទាំងនោះរួមមាន:

-គម្រោង FSP ជំនួយដល់ការគ្រប់គ្រងការងារក្នុងវិស័យគ្រប់គ្រង និងការអភិវឌ្ឍន៍ទីក្រុង (FSP Project: Assistance in the field of management and urban development)

-រាជធានីភ្នំពេញ: ការគ្រប់គ្រងទីក្រុង ការបង្កើតនិងធ្វើឱ្យប្រសើរនូវគោលនយោបាយ (Phnom Penh: Urban Management, Development and Rehabilitation Policies)។

ក្នុងចំណោមទីក្រុង៤០០ ដែលបានចុះឈ្មោះចូលប្រកួតប្រជែងទីក្រុងភ្នំពេញត្រូវបានជាប់ឈ្មោះក្នុងបញ្ជីខ្លី នៃការជ្រើសរើសប្រកួតក្នុងចំណោមទីក្រុងចំនួន ២០។ ទីក្រុងទាំងម្ភៃមានទីក្រុងអេតឌីសអាបាបា (Addis Ababa) ទីក្រុងអានតាណារីវ៉ូ (Antanarivo) ទីក្រុងបាសេឡូណា (Barcelona) ទីក្រុងកាលហ្គារី (Cal-

---

ហុង សុជាតិខេមរ៉ូ អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម លោកលោក តាណាវុឌ្ឍ ប្រធានការិយាល័យអន្តរជាតិ និងលោក Eric Huybrechts ទីប្រឹក្សាអភិបាលរាជធានីភ្នំពេញ។ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ ការប្រកួតប្រជែងនេះ ទីក្រុងភ្នំពេញត្រូវបានប្រកាស និងជាប់ចំណាត់ថ្នាក់លេខ១ លើប្រធានបទការរៀបចំស្ដារទីក្រុងឡើងវិញ ដោយបានទទួលពានរង្វាន់ជ័យលាភី Star Trophy។ ការប្រកួតប្រជែងមានគណៈមេប្រយោគធ្វើការចោទសួរអស់រយៈពេល ១៥ នាទី ស្ដីពីការងារអនុវត្តប្លង់គោលឆ្នាំ២០២០ លើផែនការគ្រប់គ្រងប្រជាពលរដ្ឋ ការអនុវត្តរូបមន្ត ៥០% បូក ៥០% និងមីក្រូឥណទាន ដែលពាក់ព័ន្ធនឹងផែនការផ្ទះសម្បែង និងបង្កើតមុខរបរដល់ប្រជាពលរដ្ឋ។ កិច្ចការនេះគឺជាមោទនភាពមួយ និងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ព្រោះក្រោយពីទីក្រុងភ្នំពេញបានរស់ឡើងវិញ ជាមួយនឹងកំណើតទី ២ របស់ប្រជាពលរដ្ឋទូទាំងប្រទេស ហើយបានបង្ហាញខ្លួនលើឆាកអន្តរជាតិ ក្នុងការស្ដារនិងអភិវឌ្ឍន៍ទីក្រុងនេះឱ្យមានសោភ័ណភាព។



www.elibraryofcambodia.org

gary) ទីក្រុងឆាងសា (Changsha) ទីក្រុងក្លេវឡេន (Cleveland) ទីក្រុងកូឡាំបឹស (Columbus) ទីក្រុងដាម៉ាសហ្គូស (Damascus) ទីក្រុងដូសសែលដុប (Düsseldorf) ទីក្រុងជូប៊ែល (Jubail) ទីក្រុងកាហ្សាន (Kazan) ទីក្រុងឡាហ្គូស (Lagos) ទីក្រុងលីសបោន (Lisbon) ទីក្រុងលីវើភូល (Liverpool) ទីក្រុងម៉ាទ្រីត (Madrid) ទីក្រុងមីលវ៉ូគី (Milwaukee) ទីក្រុងភ្នំពេញ (Phnom Penh) ទីក្រុងផតអេលីហ្សាបេត (Elizabeth) ទីក្រុងរីយ៉ាដ (Riyadh) និងទីក្រុងសាល់ឡេក (Salt Lake)។

ទីក្រុងទាំង ២០ ត្រូវធ្វើការប្រកួតប្រជែងដណ្តើមពានរង្វាន់ ទៅតាមផ្នែកនីមួយៗដោយចែកចេញជា ៩ ផ្នែក ដែលមានបេក្ខភាពបែងចែកតាមផ្នែកនីមួយៗ:

១-ស្ថាបត្យកម្មនិងវិស្វកម្មសំណង់ : ទីក្រុងកូឡាំបឹស ទីក្រុងដាម៉ាសហ្គូស ទីក្រុងផតអេលីហ្សាបេត។

២-សេដ្ឋកិច្ចនិងការងារ : ទីក្រុងដូសសែលដុប ទីក្រុងជូប៊ែល ទីក្រុងម៉ាទ្រីត។

៣-ការអប់រំនិងការអភិវឌ្ឍយុវជន : ទីក្រុងឡាហ្គូស ទីក្រុងលីវើភូល។

៤-បរិស្ថាន : ទីក្រុងកាលហ្គារី ទីក្រុងសាល់ឡេក ទីក្រុងផតអេលីហ្សាបេត។

៥-សុខាភិបាល : ទីក្រុងក្លេវឡេន ទីក្រុងឡាហ្គូស ទីក្រុងរីយ៉ាដ។

៦-ការរៀបចំលំនៅឋាន : ទីក្រុងកាហ្សាន ទីក្រុងមីលវ៉ូគី។

៧-វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា : ទីក្រុងឆាងសា ទីក្រុងឡាហ្គូស ទីក្រុងលីវើភូល។

៨-ការរៀបចំទីក្រុង : ទីក្រុងអេតឌីសអាបាបា ទីក្រុងបាសេឡូណា ទីក្រុងផតអេលីហ្សាបេត។



www.elibraryofcambodia.org

៩-ការរៀបចំទីក្រុងឡើងវិញ : ទីក្រុងអានតាណាណារីវ៉ូ ទីក្រុងលីសបោន ទីក្រុងភ្នំពេញ ។

ការប្រកាសលទ្ធផលនៃការប្រកួតប្រជែង បានប្រារព្ធធ្វើនៅវិមានតុលាការយុត្តិធម៌នាទីក្រុងឡុងដ្រ៍ ដែលជាវិមានបេតិកភ័ណ្ឌដ៏ប្រណិតរបស់ចក្រភពអង់គ្លេស ។ ទីក្រុងភ្នំពេញត្រូវបានប្រកាសជាផ្លូវការ ដោយជាប់ចំណាត់ថ្នាក់លេខ១លើប្រធានបទ "**ការរៀបចំស្តារទីក្រុងឡើងវិញ**" ។

សមិទ្ធិផលនេះគឺកើតចេញបានពីស្ថិរភាពនយោបាយ ការនាំមកនូវចលនាផ្លាស់ទីចូលរបស់ប្រជាជនមករស់នៅក្នុងរាជធានីភ្នំពេញកើតមានជាហូរហែរ ដោយចលនានេះ ដើរទន្ទឹមនឹងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាឱកាសមួយប្រទេសកម្ពុជាបានចូលជាសមាជិកអាស៊ានទី១០នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ : សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ ដែលភាសាអង់គ្លេសសរសេរថា (Association of South-East Asian Nations ) និងកម្ពុជាបានធ្វើសមាហរណកម្មចូលទៅក្នុងពិភពលោក ។



www.elibraryofcambodia.org

**រូបទី៥៤:** ការអភិវឌ្ឍលំនៅឋាន នៅទីក្រុងភ្នំពេញបច្ចុប្បន្ននិងអនាគត



នៅដើមឆ្នាំ២០០៩ ក្រសួងមហាផ្ទៃបានបង្ហាញពីការប្រែប្រួលចំនួនក្រុងស្រុក ខណ្ឌ នៃរាជធានី និងខេត្តទូទាំងប្រទេស ដែលក្នុងនោះទីក្រុងភ្នំពេញ ពីមុនមាន ៧ ខណ្ឌ បច្ចុប្បន្នត្រូវបានបង្កើតបន្ថែម ១ ខណ្ឌទៀត ត្រូវជា ៨ ខណ្ឌ ដោយបង្កើតខណ្ឌសែនសុខ ដែលបានបំបែកចេញពីខណ្ឌឫស្សីកែវ។ បច្ចុប្បន្ននៅទូទាំងប្រទេសកម្ពុជាមានក្រុងចំនួន២៧ រួមទាំងរាជធានី ឬក្រុងភ្នំពេញ បានសេចក្តីថា ក្នុងមួយខេត្តមានក្រុងចំនួន១ លើកលែងតែខេត្តកំពង់ចាម ខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យ ក្នុងមួយខេត្ត១មានក្រុងចំនួន២។ ខេត្តកំពង់ចាម មានស្រុកសួង ត្រូវ



www.elibraryofcambodia.org

បង្កើតទៅជាក្រុងស្ទួងដែលជាក្រុងមានប្រជាជនរស់នៅកុះករ បម្រើការងារក្នុងវិស័យសេវាកម្ម ជាពិសេសក្រុងថ្មីនេះ មានប្រជាជនភាគច្រើនជាកម្មករធ្វើការក្នុងចំការកៅស៊ូ ទទួលប្រាក់បំណាច់តាមម៉ោងពេលធ្វើការងារ ។ ចំពោះខេត្តស្វាយរៀង និងខេត្តបន្ទាយមានជ័យវិញ មានក្រុងពីរដែលទើបបានបង្កើតថ្មីគឺ ក្រុងបាវិត ( ឋិតនៅភាគអគ្នេយ៍) ជាប់ព្រំដែនកម្ពុជា-វៀតណាម និងក្រុងប៉ោយប៉ែត( ឋិតនៅភាគពាយ័ព្យ) ជាប់ព្រំដែនកម្ពុជា-ថៃ។ ក្រុងថ្មីទាំងពីរនេះជាតំបន់ដែលមានប្រជា-ពលរដ្ឋ ប្រកបការងារភាគច្រើនក្នុងវិស័យឧស្សាហកម្ម និងសេវាកម្ម។ បើផ្អែកលើតារាងទី៨នោះ ចំនួនអ្នកក្រុងនឹងកើនឡើងថែមទៀត និងធ្វើឱ្យចំនួនអ្នកក្រុងកើនឡើងលើសពីទិន្នន័យជំរឿនឆ្នាំ២០០៨ ដែលទទួលបានពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។ ករណីនេះ បានធ្វើឱ្យក្រសួងផែនការ និងក្រសួងមហាផ្ទៃ ទទួលបាននូវភារកិច្ចថ្មីបន្ថែមទៀត ដោយត្រូវធ្វើការកែតម្រូវទិន្នន័យឡើងវិញ ដូចជាការកំណត់នូវព្រំប្រទល់រដ្ឋបាល ចំពោះក្រុងថ្មី និងផ្តល់នូវនិយមន័យពីទីក្រុង ក៏ដូចជាធ្វើការកំណត់នូវចំនួនអ្នកក្រុងឡើងវិញ និងរៀបចំអភិវឌ្ឍន៍តំបន់ដែលបានបញ្ចូលជាក្រុងទាំងនោះ តើត្រូវរៀបចំផែនការរបៀបណា ដើម្បីគ្រប់គ្រងក្រុងទាំងនោះឱ្យក្លាយជាទីក្រុង និងត្រូវបំពាក់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម ដើម្បីកែប្រែជីវភាពរស់នៅរបស់ប្រជាជន ពីជីវភាពអ្នកជនបទទៅជាជីវភាពបែបអ្នកក្រុងជាបណ្តើរៗ ។

ការពង្រីកក្រុងនៅតំបន់ជុំវិញ បានបង្កលក្ខណៈឱ្យក្រុងភ្នំពេញមានផ្ទៃដីជាលំហរទំនេរ ដើម្បីផ្តល់លទ្ធភាពងាយស្រួលឱ្យដល់វិនិយោគិនជាតិ និងអន្តរជាតិមានឱកាសក្នុងការវិនិយោគក៏ដូចជាអភិវឌ្ឍន៍ ព្រោះលំហជុំវិញក្រុងមានដីទំនេរ



www.elibraryofcambodia.org

ដែលជាកាលានុវត្តភាពមួយសម្រាប់អ្នកក្រុងភ្នំពេញនាពេលអនាគត ហើយប្រជាជនទាំងនោះ នឹងបានទទួលនូវផ្លែផ្កាពីក្រុងភ្នំពេញវិញជាប្រាកដ។

**រូបទី៩៥៖**ផែនទីរាជធានីភ្នំពេញឆ្នាំ២០១០






www.elibraryofcambodia.org

## តារាងទី៨: តារាងប្រៀបធៀបការប្រែប្រួលចំនួនក្រុង ស្រុក ខណ្ឌ នៃរាជធានី និងខេត្ត ទូទាំងប្រទេស

| ល.រ . | រាជធានី / ខេត្ត | ចំនួនពីមុន | | | | ចំនួនក្រោយការកែសម្រួល | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្រុក | ខណ្ឌ | ឃុំ | សង្កាត់ | ក្រុង | ស្រុក | ខណ្ឌ | ឃុំ | សង្កាត់ | |
| ១ | ភ្នំពេញ | - | ៧ | - | ៧៦ | - | - | ៨ | - | ៧៦ | (១) |
| ២ | កំពង់ចាម | ១៦ | - | ១៧៣ | - | ២ | ១៤ | - | ១៦៧ | ៦ | (២) |
| ៣ | កណ្ដាល | ១១ | - | ១៤៧ | - | ១ | ១០ | - | ១៤១ | ៦ | |
| ៤ | តាកែវ | ១០ | - | ១០០ | - | ១ | ៩ | - | ៩៧ | ៣ | |
| ៥ | ព្រៃវែង | ១២ | - | ១១៦ | - | ១ | ១២ | - | ១១៣ | ៣ | (៣) |
| ៦ | ស្វាយរៀង | ៧ | - | ៨០ | - | ២ | ៦ | - | ៦៨ | ១២ | (៤) |
| ៧ | ព្រះសីហនុ | - | ៣ | - | ២២ | ១ | ៣ | - | ២១ | ៥ | |
| ៨ | កោះកុង | ៨ | - | ៣៣ | - | ១ | ៦ | - | ២៦ | ៣ | |
| ៩ | កែប | - | ២ | - | ៥ | ១ | ១ | - | ៣ | ២ | |
| ១០ | កំពត | ៨ | - | ៩២ | - | ១ | ៧ | - | ៨៧ | ៥ | |
| ១១ | កំពង់ធំ | ៨ | - | ៨១ | - | ១ | ៧ | - | ៧៣ | ៨ | |
| ១២ | សៀមរាប | ១២ | - | ១០០ | - | ១ | ១១ | - | ៨៧ | ១៣ | |
| ១៣ | បាត់ដំបង | ១៣ | - | ៩៦ | - | ១ | ១៣ | - | ៨៦ | ១០ | (៥) |
| ១៤ | ពោធិ៍សាត់ | ៦ | - | ៤៩ | - | ១ | ៥ | - | ៤២ | ៧ | |
| ១៥ | កំពង់ឆ្នាំង | ៨ | - | ៦៩ | - | ១ | ៧ | - | ៦៥ | ៤ | |
| ១៦ | ប.ម.ជ័យ | ៨ | - | ៦៤ | - | ២ | ៧ | - | ៥៥ | ៩ | (៦) |
| ១៧ | កំពង់ស្ពឺ | ៨ | - | ៨៧ | - | ១ | ៧ | - | ៨២ | ៥ | |
| ១៨ | ព្រះវិហារ | ៧ | - | ៤៩ | - | ១ | ៧ | - | ៤៧ | ២ | (៧) |
| ១៩ | ក្រចេះ | ៥ | - | ៤៦ | - | ១ | ៥ | - | ៤១ | ៥ | (៨) |
| ២០ | ស្ទឹងត្រែង | ៥ | - | ៣៤ | - | ១ | ៤ | - | ៣០ | ៤ | |
| ២១ | មណ្ឌលគិរី | ៥ | - | ២១ | - | ១ | ៤ | - | ១៧ | ៤ | |
| ២២ | ខេត្តរតនគិរី | ៩ | - | ៤៩ | - | ១ | ៨ | - | ៤៦ | ៣ | |



www.elibraryofcambodia.org

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ២៣ | ឧត្តរមានជ័យ | ៥ | - | ២៤ | - | ១ | ៤ | - | ១៩ | ៥ | |
| ២៤ | ប៉ៃលិន | ២ | - | - | ៨ | ១ | ១ | - | ៤ | ៤ | |
| | សរុប | ១៧៣ | ១២ | ១៥១០ | ១១១ | ២៦ | ១៥៩ | ៨ | ១៤១៧ | ២០៤ | |

ប្រភព៖ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

(១) រាជធានីភ្នំពេញបន្ថែម០១ខណ្ឌ ខណ្ឌសែនសុខ បំបែកពីខណ្ឌឫស្សីកែវ

(២) ខេត្តកំពង់ចាមបង្កើតក្រុងសួងថ្មី

(៣) បង្កើតក្រុងព្រៃវែងបំបែកចេញពីស្រុកកំពង់លាវ

(៤) ខេត្តស្វាយរៀងបង្កើតក្រុងបាវិតថ្មី

(៥) ខេត្តបាត់ដំបងបង្កើតស្រុករុក្ខគិរីថ្មី( កាត់ឃុំ២ពីស្រុកមោងឫស្សី និងភូមិ២ពីស្រុកវាលវែង ខេត្តពោធិ៍សាត់)

(៦) ខេត្តបន្ទាយមានជ័យបង្កើតក្រុងប៉ោយប៉ែតថ្មី

(៧) បង្កើតក្រុងព្រះវិហារបំបែកចេញពីត្បែងមានជ័យ

(៨) បង្កើតក្រុងក្រចេះបំបែកចេញពីស្រុកក្រចេះ ដោយប្តូរឈ្មោះមកជាស្រុកចិត្របុរី ។

ទន្ទឹមនឹងបញ្ហាបម្លាស់ទីរបស់ប្រជាជនចូលក្រុង រាជរដ្ឋាភិបាលបានចាត់វិធានការ ដើម្បីទប់ស្កាត់ចលនាផ្លាស់ទីចូលក្រុងដោយមានគោលនយោបាយធ្វើការពង្រាយរោងចក្រនៅតាមបណ្តាខេត្តនានាជុំវិញទីក្រុងភ្នំពេញ។ តែជាការធម្មតាចរិតរបស់ទីក្រុងបានទាក់ទាញមនុស្សម្នាឱ្យមកស្នាក់នៅ ដោយសារវិស័យសេវាកម្ម ឧស្សាហកម្ម និងការអភិវឌ្ឍនានា ដែលសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាជនក្រុង ។

មូលហេតុនេះ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល សាលារាជធានីភ្នំពេញដែលមានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីជាសេនាធិការមានគម្រោងផែនការនគរូបនីយកម្ម ដោយបានកំណត់តំបន់អភិវឌ្ឍន៍ជុំវិញក្រុងនិងធ្វើការពង្រីកក្រុងមានកាំរហូតដល់ ៣០គ.ម. (មើលរូបទី៥៥) ក្នុងគោលបំណងបញ្ចៀសនូវការប្រមូលផ្តុំមនុស្សចូលមករស់នៅក្នុងតំបន់ស្នូល នៃទីក្រុងភ្នំពេញ។



www.elibraryofcambodia.org

សាលារាជធានីភ្នំពេញ ចាប់ផ្តើមមានគម្រោងអភិវឌ្ឍន៍ ដែលមានវិនិយោគទុនជាតិ និងអន្តរជាតិ ចូលមកបណ្តាក់ទុនរកស៊ី និងបង្កើតបានជាទីក្រុងរណបចំនួនប្រាំមួយ និងជាបន្តបន្ទាប់ទៀតនោះគឺ:

- គំរោងអភិវឌ្ឍន៍ជ្រោយចង្វា
- គំរោងអភិវឌ្ឍន៍កោះពេជ្រ
- គំរោងអភិវឌ្ឍន៍បឹងស្នោ
- គំរោងអភិវឌ្ឍន៍បឹងកក់
- គំរោងអភិវឌ្ឍន៍បឹងពោងពាយ និង
- គំរោងអភិវឌ្ឍន៍ស៊ីពុត្រា (CIPUTRA)

**រូបទី៥៦:** គំរោងអភិវឌ្ឍន៍ក្រុងរណប




ប្រភព: សៀវភៅគោលដៅសហស្សវត្សរ៍ របស់រាជធានីភ្នំពេញ ឆ្នាំ ២០០៩ របស់សាលាក្រុងភ្នំពេញ



www.elibraryofcambodia.org

រូបទី៥៦ បានបង្ហាញពីការអភិវឌ្ឍ ដែលកំពុងមានដំណើរការទៅមុខ នៅក្នុងគម្រោងអភិវឌ្ឍន៍ទីក្រុងរណបទាំងប្រាំមួយ។ បើទោះបីជាពិភពលោកទាំងមូលកំពុង ជួបប្រទះនូវវិបត្តិអចលទ្រព្យ ដែលធ្វើឱ្យសេដ្ឋកិច្ចទទួលរងនូវវិបត្តិធ្ងន់ធ្ងរក៏ដោយ តែនៅរាជធានីភ្នំពេញ នៅតាមការដ្ឋានមួយចំនួន ដំណើរការសាងសង់នៅមានសកម្មភាពនៅឡើយ ជាពិសេសវិនិយោគទុនជាតិ ដែលកំពុងសាងសង់សំណង់ទាបជាង១០ជាន់។ តែនៅតាមការដ្ឋានខ្លះ ដែលមានវិនិយោគទុនជាជនបរទេសនៅបន្តការសាងសង់ តែក្នុងដំណើរយឺតៗ ឬជួនកាលសង់បានពាក់កណ្ដាល ក៏ត្រូវផ្អាកដោយអន្លើ មូលហេតុមកពីខ្វះទុនដែលកប់នៅធនាគារឯបរទេស។

ឥទ្ធិពលនៃវិបត្តិសេដ្ឋកិច្ច មិនថាកើតមាននៅប្រទេសផ្សេងៗលើសកលលោកឡើយ សូម្បីតែប្រទេសកម្ពុជាបច្ចុប្បន្ន មានវិស័យបីកំពុងធ្លាក់ចុះគឺ វិស័យសំណង់ វិស័យទេសចរណ៍ និងវិស័យកាត់ដេរ ដែលធ្វើឱ្យពលករទាំងនោះក្លាយជាជនគ្មានការងារធ្វើ ព្រោះមានរោងចក្រកាត់ដេរមួយចំនួនត្រូវកាត់បន្ថយនូវលំនាំចេញ និងរោងចក្រខ្លះត្រូវបិទទ្វារមិនថានៅបរទេសឬនៅកម្ពុជាឡើយ ដោយសារចប់កិច្ចសន្យាក្នុងការទទួលនាំចេញផលិតផលសម្រេចទាំងនោះ មានសម្លៀកបំពាក់ខោអាវ មួក ស្បែកជើង កាបូប។ល។ ទៅប្រទេសក្រៅដូចជា សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ចិនប្រជាមានិត... ហើយកិច្ចការទាំងនោះ បានជះឥទ្ធិពលទៅវិញទៅមកក្នុងសកលលោក។ តែនៅឆ្នាំ២០១០ វិបត្តនេះ ហាក់ដូចជាធូរស្រាលមកវិញ ចំពោះប្រទេសកម្ពុជាយើង (មើលក្រាហ្វិកទី២)។



www.elibraryofcambodia.org

**ក្រាហ្វិកទី២ :** អត្រាកំណើននៃសរុបផលិតផលសង្គម ពីឆ្នាំ ២០០៤-២០១៣




តាមទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នាសិក្ខាសាលាស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ នៅសណ្ឋាគារសាន់វ៉េ ព្រះរាជាណាចក្រកម្ពុជារវាងចន្លោះឆ្នាំ២០០០ ទៅឆ្នាំ២០០៣ មានកំណើនសេដ្ឋកិច្ចបានកើនឡើងខ្ពស់ ប្រមាណជា៨ភាគរយ និងរវាងឆ្នាំ២០០៤ ទៅឆ្នាំ២០០៧ កំណើននេះបានកើនឡើង រហូតដល់ពីរខ្ទង់គឺ ១០ភាគរយ ដែលក្នុងនោះ រួមមានវិស័យសំណង់មានបរិមាណកើនឡើងខ្ពស់ មានការនាំចេញសម្លៀកបំពាក់ទៅបណ្តាប្រទេសអភិវឌ្ឍន៍ និងវិស័យទេសចរណ៍ មានការកើនឡើងគួរឱ្យកត់សម្គាល់។ កំណើនសេដ្ឋកិច្ច ដែលមានលេខពីរខ្ទង់នេះ បានធ្វើឱ្យពិភពលោកមានការភ្ញាក់ផ្អើល និងជាមោទនភាពមួយ ដែលប្រទេសកម្ពុជាបង្ហាញពីបៀបដឹកនាំដ៏ត្រឹមត្រូវ និងគោល-នយោបាយត្បៀងគរដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាល។ ជាបណ្តើរៗទីក្រុងភ្នំពេញដែលជារាជធានីមានតួនាទីកាន់តែសំខាន់ឡើងនិងបានបង្កលក្ខណៈឱ្យទីក្រុងភ្នំពេញក៏ដូចជាទីក្រុងធំៗខ្លះក្នុងប្រទេសចាប់ពង្រីកខ្លួនធំឡើងៗ។



www.elibraryofcambodia.org

## ក្រាហ្វិកទី៣ និងទី៤: ការប្រៀបធៀបរវាងវិស័យសំណង់និងចំណូលជាថវិកា

សរុបក្រាហ្វិកផ្ទៃក្រឡាសំណង់ទាំងពីរថ្នាក់ ពីឆ្នាំ២០០០ ដល់រយៈពេល១១ខែដើមឆ្នាំ២០១០




សរុបក្រាហ្វិកតម្លៃគម្រោងទាំងពីរថ្នាក់គិតជាដុល្លារអាមេរិកពីឆ្នាំ២០០០ ដល់រយៈពេល១១ខែដើមឆ្នាំ២០១០




**ប្រភព:** ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

“ទស្សនាវដ្តីប្រចាំឆ្នាំ២០០៩-២០១០”



www.elibraryofcambodia.org

បច្ចុប្បន្នចលនានគរូបនីយកម្មនៅកម្ពុជា មានអត្រាកំណើន ២,៥៥ភាគរយក្នុងមួយឆ្នាំ។ កំណើននេះនឹងបង្កឱ្យមានជាបញ្ហាលំបាកមួយចំនួន ដូចជានាំមកនូវការអភិវឌ្ឍគ្មានតុល្យភាព រវាងទីក្រុងនិងជនបទ រវាងទីក្រុងធំ និងទីក្រុងតូច បញ្ហាបរិស្ថាន បញ្ហាទឹក ភ្លើង និងអនាម័យ បញ្ហាសុវត្ថិភាព បញ្ហាសណ្ដាប់ធ្នាប់សង្គម និងបញ្ហាកកស្ទះក្នុងទីក្រុង ។ល។

តាមរបាយការណ៍របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងលទ្ធផលជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ បង្ហាញឱ្យឃើញថា ប្រជាជនដែលកំពុងរស់នៅក្នុងទីក្រុងស្រូបយកអត្រា ១៩.១ភាគរយ។ ក្នុងន័យនេះហើយ សាលារាជធានីភ្នំពេញ ដែលមានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី ជាខ្សែបណ្ដោយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាសេនាធិការ ឱ្យសាលាក្រុងភ្នំពេញបានខិតខំធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់ពីការពង្រីកទីក្រុងភ្នំពេញដោយបានធ្វើការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្ដាល មានការកាត់យកឃុំចំនួន២០ នៃខេត្តកណ្ដាលមកបញ្ចូលក្នុងរាជធានីភ្នំពេញ តាមព្រះរាជក្រឹត្យលេខ: នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ និងធ្វើឱ្យផ្ទៃដីរាជធានីភ្នំពេញកាន់តែរីកធំទៅៗ ដែលមានផ្ទៃដីកើនឡើងដល់ទៅ ៦៧៨,៧គ.ម.$^{២}$ (មើលតារាងទី៩)។ ហើយនៅជំហានទី២ ភ្នំពេញអាចស្រូបយកប្រាំពីរឃុំទៀតក្នុង ស្រុកល្វាឯម និងស្រុកខ្សាច់កណ្ដាល ដែលធ្វើឱ្យខ្សែក្រវ៉ាត់ក្រុង ត្រូវខិតកាន់តែពង្រីកខ្លួនបានឆ្ងាយបន្តិចម្ដងពីតំបន់ស្នូល ។

បច្ចុប្បន្នដើម្បីឈានទៅដឹកនាំវិស័យរដ្ឋបាលក៏ដូចជាការងារអភិវឌ្ឍន៍ផ្សេងៗទៀត សាលារាជធានីភ្នំពេញ បានខិតខំរៀបចំអង្គការលេខថ្នាក់រាជធានី និងថ្នាក់មូលដ្ឋាន ដើម្បីឱ្យមានភាពរលូនក្នុងការដឹកនាំ។



www.elibraryofcambodia.org

## តារាងទី៩: ស្ថានភាពឃុំទាំង២០ត្រូវកាត់ផ្ទេរទៅនៅក្រោមសាលារាជធានីភ្នំពេញ

| ស្រុក | ឃុំ | ផ្ទៃដី (ហ.ត.) | ភូមិ | លក្ខណៈប្រជាសាស្ត្រ | | | អាយុ ១៨ឆ្នាំឡើង | ស្រី |
|---|---|---|---|---|---|---|---|---|
| | | | | គ្រួសារ | ប្រជា.សរុប | ស្រី | | |
| កណ្ដាលស្ទឹង | ឃុំគងនយ | ៣៩៦ | ៤ | ៤២១ | ១ ៧៩៧ | ៩៣០ | ១ ២១១ | ៦៤៩ |
| | ឃុំទៀន | ៥៨០ | ៦ | ៥៧៣ | ២ ៣៥១ | ១ ២៤៩ | ១ ៥៥០ | ៨៤៤ |
| | ឃុំរលួស | ៥៥០ | ៣ | ៦០៦ | ២ ៥៧០ | ១ ៣៧២ | ១ ៧២៥ | ៩៥០ |
| | ឃុំស្ពានថ្ម | ៧១៧. ១០ | ៨ | ៦៩៨ | ២ ៩០០ | ១ ៥២៤ | ១ ៨៥០ | ១ ០៧៨ |
| | ឃុំព្រែកកំពឹស | ៩១៥. ៥០ | ៦ | ១ ៨៣៨ | ៧ ៧៥០ | ៤ ០០៣ | ៥ ០២២ | ២ ៦៤៩ |
| | **សរុបទី ១** | **៣១១៨. ៦០** | **២៧** | **៤ ១៣៦** | **១៧ ៣៦៨** | **៩ ០៧៨** | **១១ ៣៥៨** | **៦ ១៧០** |
| ពញាឮ | ឃុំព្រែកព្នៅ | ៤៧៤. ៩៦ | ៥ | ១ ៩៧២ | ៨ ៦០២ | ៤ ៤៥០ | ៥ ៧៤១ | ៣ ១១៤ |
| | ឃុំសំរោង | ១ ៦៩១. ៤៤ | ៤ | ១ ៣៦៩ | ៥ ៨៥៦ | ២ ៩៩៣ | ៣ ៧៦២ | ១ ៩៥៨ |
| | ឃុំពញាពន់ | ១៣០៣. ៤២ | ៨ | ១ ២៦៣ | ៦ ២៣៥ | ៣ ២៧៦ | ៣ ៩៩៧ | ២ ១៦៩ |
| | **សរុបទី ២** | **៣ ៤៦៩. ៨២** | **១៧** | **៤ ៦០៤** | **២០ ៦៩៣** | **១០ ៦៧៩** | **១៣ ៥០០** | **៧ ២៤១** |
| កៀនស្វាយ | ឃុំវាលស្បូវ | ៩៦០ | ៤ | ១ ៦២៨ | ៧ ៦៨៨ | ៣ ៩១៦ | ៥ ១៤៦ | ២ ៧១៧ |
| | ឃុំព្រែកឯង | ២ ០០០ | ៦ | ២ ៩៨៤ | ១៣ ៧០៨ | ៧ ០១៦ | ៩ ៥៤៦ | ៥ ០១៤ |
| | ឃុំក្បាលកោះ | ១ ៤៨៥ | ៣ | ៣ ៧១០ | ១៦ ៨៨០ | ៨ ៦៤៨ | ១២ ២៣០ | ៦ ៣៥៥ |
| | ឃុំព្រែកថ្មី | ១ ៨៦៣ | ៣ | ៣ ៣១៦ | ១៦ ៣៣០ | ៨ ១៧២ | ១១ ៩៧៥ | ៥ ៩៥៥ |
| | **សរុបទី ៣** | **៦ ៣០៨** | **១៦** | **១១ ៦៣៨** | **៥៤ ៦០៦** | **២៧ ៧៥២** | **៣៨ ៩៩៧** | **២០ ០៨១** |
| អង្គស្នួល | ឃុំពន្សាំង | ៣ ៦៨០ | ២៤ | ១ ៩៩៨ | ៩ ១៨១ | ៤ ៦៨៤ | ៥ ៤៧៦ | ២ ៨៦៣ |
| | ឃុំស្នោ | ១ ៣៨០ | ១៨ | ៩៤១ | ៤ ៩៦២ | ២ ៦០២ | ៣ ០០៤ | ១ ៦១២ |
| | ឃុំឪឡោក | ១ ៣៣៨ | ១៤ | ៧៦១ | ៣ ៨៥៥ | ២ ០២៧ | ២ ៥០៥ | ១ ៤១១ |
| | ឃុំបឹងធំ | ១ ៥៥០ | ១៦ | ១ ៥៥៦ | ៧ ២១៥ | ៣ ៥២៦ | ៤ ៦២២ | ២ ៤៨១ |
| | ឃុំកំបូល | ១ ៧០២ | ១៨ | ១ ៥៧៤ | ៧ ៧១០ | ៣ ៩២៣ | ៤ ៩៩៥ | ២ ៥០៥ |
| | ឃុំកន្ទោក | ៩២២ | ១៣ | ១ ៧៣៤ | ៨ ២៣៨ | ៤ ២៥១ | ៥ ៣៦៨ | ២ ៨៧០ |
| | **សរុបទី ៤** | **១០ ៦១២** | **១០៣** | **៨ ៥៦៥** | **៤១ ១៦១** | **២០ ៦១៣** | **២៥ ៩៣៨** | **១៣ ៧៤២** |
| មុខកំពូល | ឃុំបាក់ខែង | ៣ ២៦៨ | ៣ | ១ ៩១៥ | ៦ ៩៣២ | ៣ ៣១៤ | ៤ ០៨៨ | ២ ០៩០ |
| | ឃុំកោះដាច់ | ២ ២៤៨. ៧០ | ៥ | ២ ៩៨៥ | ១២ ៦០៤ | ៦ ៩៣០ | ៨ ២៦៥ | ៤ ៣៩៤ |
| | **សរុបទី ៥** | **៥ ៥១៦. ៧០** | **៨** | **៤ ៩០៤** | **១៩ ១៣៦** | **៩ ៨៤៤** | **១២ ៣៥៣** | **៦ ៤៤៤** |
| | **សរុបរួម** | **២៥០២៥.១២** | **១៧១** | **៣៣ ៤៥១** | **១៥២ ៩៦៤** | **៧៧ ៩៦៦** | **១០ ១២៨៦** | **៥៣ ៧១៨** |

**ប្រភព:** តួលេខបានពីក្រសួងមហាផ្ទៃ សាលាខេត្តកណ្ដាល លេខ ០៤៨ របក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០ និង តាមព្រះរាជក្រឹត្យ នស/រកត/០៥១០/៧៦៣ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០១០។



www.elibraryofcambodia.org

ស្ថិតក្នុងស្ថានភាពវិបត្តិសេដ្ឋកិច្ច ដើម្បីឈានទៅស្តារឡើងវិញនូវកំណើនសេដ្ឋកិច្ចពីរខ្ទង់ (១៣.៣ភាគរយ ឆ្នាំ២០០៥) ហើយបានធ្លាក់ចុះមកនៅ (០.១ ភាគរយ នៅឆ្នាំ២០០៩) និងដោយផ្អែកលើទីតាំងភូមិសាស្ត្ររបស់ប្រទេស ដែលឋិតក្នុងតំបន់ត្រូពិចមូសុងក្តៅហើយសើម កម្ពុជាមានអាទិភាពច្រើនលើវិស័យកសិកម្ម រួមមានប្រជាជនប្រកបរបរកសិកម្មប្រមាណជា ៨០ភាគរយ និងដោយសារកម្ពុជាមានផ្ទៃដីនៅសេសសល់ច្រើនសម្រាប់ធ្វើកសិកម្ម ដូចនេះប្រទេសកម្ពុជាអាចក្លាយជាទីតាំងជង្រុកស្រូវដ៏ធំមួយ និងក្លាយជាប្រទេសនាំចេញអង្ករ ទៅលក់នៅលើទីផ្សារក្នុងសកលលោក[៩៦] ។

ក្នុងសភាពការណ៍នេះ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីជំហរ មួយក្នុងកិច្ចប្រជុំផ្សព្វផ្សាយឯកសារគោលនយោបាយ ស្តីពីការជម្រុញផលិតផលស្រូវ និងការនាំចេញអង្ករ ដោយមានការចូលរួមពីមន្ត្រីរាជរដ្ឋាភិបាល និងមន្ត្រីឯកជនជាច្រើនរូបទៀត។ គោលនយោបាយដែលបានដាក់ចេញនេះ មានមហិច្ឆិតាចង់ឱ្យកម្ពុជាក្លាយជាជង្រុកស្រូវ និងជាប្រទេសនាំចេញអង្ករសំខាន់មួយនៅលើទីផ្សារពិភពលោក។ ឈរលើមូលដ្ឋាននៃទិសដៅជាយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ២០១៥ ជាឆ្នាំគោលដើម្បីៈ

ទី១- ជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង ៤លានតោន ក្នុងនោះបរិមាណអង្ករសម្រាប់នាំចេញ ត្រូវសម្រេចឱ្យបានយ៉ាងតិច ១លានតោន។

ទី២- ធ្វើឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។

---

[៩៦] - ប្រភពបានមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (WWW.mef.gov.kh)



www.elibraryofcambodia.org

ឈរលើមាគ៌ានេះរាជរដ្ឋាភិបាលនឹងអនុវត្ត ដោយផ្តួចផ្តើមគំនិត និងគោរព ប្រតិបត្តិគោលការណ៍សំខាន់ៗមួយចំនួនដូចខាងក្រោមៈ

ទី១-ប្រកាន់យកគោលការណ៍ទីផ្សារ ដោយរក្សាការប្រកួតប្រជែងក្នុងគោល ដៅជំរុញការនាំចេញ ឱ្យមានប្រសិទ្ធភាពខ្ពស់ផង ធានាផលប្រយោជន៍របស់កសិករ តាមរយៈការបង្កើនប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្ររបស់ពួកគាត់ផង និងរក្សាបានសន្តិសុខស្បៀង ដោយប្រើប្រាស់នូវយន្តការសុវត្ថិភាពសង្គមមួយរឹង មាំផង។

ទី២-លើកទឹកចិត្ត និងគាំទ្រការចូលរួមពីសំណាក់កសិករ និងសហគមន៍ កសិករ ដោយការពារផលប្រយោជន៍របស់ពួកគាត់ តាមរយៈការបង្កើតឡើងនូវ បរិស្ថានអំណោយផល និងភាពងាយស្រួលសម្រាប់ការបង្កើនផលិតកម្ម និងការផ្គត់ ផ្គង់ស្រូវអង្ករ ប្រកបដោយគុណភាពក៏ដូចជាការលើកស្ទួយអំណាចចរចាថ្លៃ។

ទី៣-ជំរុញកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងដៃគូ អភិវឌ្ឍន៍ សង្គមស៊ីវិល ព្រមទាំងវិស័យឯកជន ដូចជាផលិតករស្រូវ អាជីវករ ម៉ាស៊ីនកិនស្រូវ ពាណិជ្ជករ និងអ្នកដឹកជញ្ជូន ក្នុងការអនុវត្តគោលនយោបាយជំរុញ ផលិតកម្មស្រូវ និងការនាំចេញអង្ករ។

ទី៤-លើកកម្ពស់ប្រសិទ្ធភាព ក្នុងការសម្របសម្រួលរវាងក្រសួងស្ថាប័ននានា របស់រាជរដ្ឋាភិបាលដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃ ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ពាក់ព័ន្ធនឹងការជំរុញផលិតកម្មស្រូវ និងការ នាំចេញអង្ករ ។

ទី៥-ជំរុញការបង្កើនសមត្ថភាពនាំចេញអង្ករពីកម្ពុជាដោយខ្លួនឯង ដោយ លើកទឹកចិត្តដល់ក្រុមហ៊ុនទាំងអស់ ឱ្យបើកស្នាក់ការប្រមូលទិញ និងការធ្វើស្រូវ


www.elibraryofcambodia.org

នៅក្នុងប្រទេស រួចធ្វើការនាំចេញអង្ករជាផ្លូវការ ឈរលើគោលការណ៍ប្រកួតប្រជែងដោយសុច្ចរិត យុត្តិធម៌ និងស្មោះត្រង់ ទន្ទឹមនឹងការគោរពបាននូវកាតព្វកិច្ចពន្ធដារ និងកាតព្វកិច្ចផ្សេងទៀតរបស់កម្ពុជាជាធរមាន ។

ហេតុអ្វីបានជារាជរដ្ឋាភិបាល ចាត់ទុកការជំរុញលើកស្ទួយវិស័យកសិកម្ម ជាឧបករណ៍គោលនយោបាយសេដ្ឋកិច្ចដ៏សំខាន់មួយ សម្រាប់ដោះស្រាយបញ្ហាប៉ះពាល់ផលអាក្រក់នៃវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលនេះ ?

ជាការពិត បើយើងពិនិត្យមើលរចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន យើងអាចកត់សម្គាល់ឃើញនូវចំណុចសំខាន់១មួយចំនួនដូចតទៅ:

ទី១- វិស័យកសិកម្មមានចំណែករហូតទៅដល់ជាង៣០ ភាគរយនៃផលិតផលក្នុងស្រុកសរុប ក្នុងនោះអនុវិស័យដំណាំ ដែលមានស្រូវជាដំណាំសំខាន់ជាងគេបានរួមចំណែករហូតដល់ទៅជិត២០ភាគរយនៃផលិតផលក្នុងស្រុកសរុប ។

ទី២-តាមលទ្ធផលនៃជំរឿនប្រជាជនឆ្នាំ ២០០៨ ប្រជាជនកម្ពុជាប្រមាណ ៨០ ភាគរយរស់នៅតាមទីជនបទ។ ជាមួយគ្នានេះ វិស័យកសិកម្មបានស្រូបយកកម្លាំងពលកម្មប្រមាណជា៧២ភាគរយនៃកម្លាំងពលកម្មសរុបនៅក្នុងប្រទេស។

ទី៣-ប្រពៃណីនៃចំណងទាក់ទងសង្គមសេដ្ឋកិច្ច ផ្ទៃក្នុងគ្រួសារនីមួយ១ រវាងអ្នករស់នៅទីជនបទនិងអ្នករស់នៅទីក្រុងឬទីប្រជុំជន នៅមានសភាពស្អិតល្មួត និងបំពេញឱ្យគ្នាទៅវិញទៅមកខ្លាំងក្លានៅឡើយ។

តែបើយើងធ្វើការពិនិត្យជារួមនៅប្រទេសកម្ពុជាវិញ វិបត្តិនេះមិនធ្ងន់ធ្ងរដូចបណ្តាប្រទេសនានាឡើយ ដោយសារប្រជាជនខ្មែរ មានទម្លាប់ប្រើប្រាស់ទុនរបស់



www.elibraryofcambodia.org

ខ្លួនក្នុងស្រុក។ ធនាគារមួយចំនួនប្រើទុនក្នុងស្រុក ដូចនេះផលប៉ះពាល់ខុសគ្នាពីបណ្តាប្រទេសអភិវឌ្ឍន៍នានា។ ចំពោះការអភិវឌ្ឍឋានិយកម្មស្បែកផ្សេងៗចំនួនត្រូវបានបិទទ្វារក៏ដោយ តែកម្មករដែលមកពីទីជនបទទាំងនេះពួកគាត់ជាកូនចៅកសិករ ពេលគេវិលត្រឡប់ទៅលំនៅឋានវិញ ពួកគេទៅធ្វើស្រែចម្ការ ព្រោះគ្រួសារគេមានដីសម្រាប់ធ្វើស្រែចម្ការ។

តាមប្រសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលនៅឆ្នាំ ២០១០ បានលើកឡើងថា : **"នឹងធ្វើឱ្យទីក្រុងភ្នំពេញដែលជាទីក្រុងគុជនៅអាស៊ីអគ្នេយ៍ មានអគារទំនើបនៅក្នុងតំបន់អភិវឌ្ឍន៍កោះពេជ្រដែលសំណង់ស្ថាបត្យកម្មនេះ មានកំពស់ដល់ទៅ ៥៥៥ ម៉ែត្រ"** នោះគឺជាអគារឈរជួរទី៣ បន្ទាប់ពីសំណង់ស្ថាបត្យកម្មនៅសហរដ្ឋអាមេរិក (KVLY-Tvmart ដែលមានកម្ពស់ ៦២៦ម៉ែត្រ) និងអគារខ្ពស់កប់ពពកនៅទីក្រុងឌុយបាយនៃប្រទេសអារ៉ាប់រួម (៨១៨ម៉ែត្រ)។ អគារដ៏ទំនើបនៅកោះពេជ្រនេះ នឹងរិតតែធ្វើឱ្យមានការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិបន្ថែមទៀត ព្រោះទស្សនិកជនអាចឈរគយគន់ពីទីខ្ពស់បំផុតនោះ ដោយអាចគន់មើលឃើញទេសភាពនានា និងទស្សនីយភាពបឹងទន្លេសាបបានផងដែរ។

ដំណាក់កាលនេះ ការអភិវឌ្ឍទីក្រុងក៏ដូចជាការរៀបចំក្រុងនៅព្រះរាជាណាចក្រកម្ពុជា តម្លៃដីនៅរាជធានីពិសេសនៅតាមផ្លូវសំខាន់ៗកាន់តែថ្លៃទៅ ឯការប្រើប្រាស់ដីត្រូវតែប្រើប្រាស់តម្រូវទៅតាមតម្លៃដី ដើម្បីឱ្យការប្រើប្រាស់សមតុល្យទៅនឹងតម្រូវការចាំបាច់តាមពេលវេលា ដែលធ្វើឱ្យការសាងសង់សំណង់នានាក្នុងទីក្រុង ច្រើនតែធ្វើឡើងតាមខ្សែឈរ (Vertical) ដែលការតម្លើងជាន់កាន់តែខ្ពស់ទៅផ្ទុយពីសម័យដែលដីនៅក្នុងទីក្រុងនៅមានតម្លៃថោក ហើយពេលវេលានោះការប្រើប្រាស់ដីសម្រាប់បម្រើឱ្យការសាងសង់សំណង់នានា ច្រើនធ្វើឡើងតាមខ្សែ



www.elibraryofcambodia.org

ផ្ដេក (Horizontal)។ ការប្រើប្រាស់ផ្ទៃដីធំទូលាយ សំណង់ស្ថាបត្យកម្មមានលក្ខណៈទាបៗ ដូចជាផ្ទះសម្បែងរបស់ប្រជាជន ឬអគារនានា (មើលរូបទី៥៤-៥៧)។

នយោបាយអភិវឌ្ឍន៍ទីក្រុងនាសម័យកាលនេះ ទោះនៅតាមរាជធានី ទីក្រុងនានាតាមបណ្ដាខេត្ត អ្នករៀបចំរាជធានី ក្រុង គិតគូរធ្វើយ៉ាងណារក្សាឱ្យបាននូវអត្តសញ្ញាណជាតិ បរិស្ថានស្រស់ស្អាត មានតំបន់បៃតង តំបន់លំហែកាយ និងធ្វើយ៉ាងណា ដើម្បីឱ្យការរស់នៅក៏ដូចជាការប្រកបមុខរបរ មានផាសុខភាពសម្រាប់ជីវិតរស់នៅ គ្មានការចុញទ្រាន់ ដោយធ្វើឱ្យអារម្មណ៍ល្អប្រសើរ និងស័ក្តិសមជាព្រះរាជាណាចក្រកម្ពុជាអច្ឆរិយៈ (The Kingdom of Wonder)។

**រូបទី៥៧:** សំណង់ស្ថាបត្យកម្មដែលមានលក្ខណៈតាមខ្សែឈរ





www.elibraryofcambodia.org

**តារាងទី១០** : ចំនួនប្រជាជនគិតតាមទីកន្លែងរស់នៅជនបទ និងទីក្រុង ១៩៩៨-២០៣០

| ឆ្នាំ | ចំនួនប្រជាជនសរុប | ចំនួនប្រជាជននៅជនបទ | | ចំនួនប្រជាជននៅទីក្រុង | |
|---|---|---|---|---|---|
| ១៩៩៨ | ១១.៤៣៧.៦៥៦ | ៩.៣៨២.៥៨២ | ៨៤.៣ % | ២.០៥៥.០៧៤ | ១៥.៧ % |
| ២០០៨ | ១៣.៣៩៥.៦៨២ | ១០.៧៨១.៦៥៥ | ៨០.៥ % | ២.៦១៤.០២៧ | ១៩.៥ % |
| ២០១០ | ១៤.៣០២.៧៧៩ | ១១.៣៧៥.៩៦៩ | ៧៩.៥ % | ២.៩២៦.៨១០ | ២០.៥ % |
| ២០១៥ | ១៥.៤០៥.១៥៧ | ១១.៨៦៤.៥៨២ | ៧៧.០ % | ៣.៥៤០.៥៧៥ | ២៣.០ % |
| ២០២០ | ១៦.៥០៥.១៥៦ | ១២.៣១២.១៣៨ | ៧៤.៦ % | ៤.១៩៣.០១៨ | ២៥.៤ % |
| ២០២៥ | ១៧.៥១៩.២៧២ | ១២.៦៩៦.២២៩ | ៧២.៥ % | ៤.៨២៣.០៤៣ | ២៧.៥ % |
| ២០៣០ | ១៨.៣៩០.៦៨៣ | ១២.៩៧០.៣៨២ | ៧០.៥ % | ៥.៤២០.៣០១ | ២៩.៥ % |

ប្រភព : ជំរឿនប្រជារាស្ត្រ ឆ្នាំ ២០០៨ ក្រសួងផែនការ

**រូបទី៥៨:** មហាជននៅតាមរាជធានី ទីក្រុង ទីប្រជុំជន
ចូលរួមហាត់ប្រាណដើម្បីសុខភាពនៅតាមសួនឧទ្យាននានា



**រូបទី៤៥:** ភ្នំពេញទីក្រុងបៃតង



www.elibraryofcambodia.org

**រូបទី៥៩:** ទីក្រុងភ្នំពេញ និងសួនឧទ្យានបៃតង



លើពិភពលោកគេតែងនិយាយពីសកលភាវូបនីយកម្ម ដោយឡែកប្រទេសកម្ពុជាក៏មិនខុសអ្វីពីបណ្ដាប្រទេសទាំងនោះឡើយ។ ក្នុងរយៈពេល១៣ឆ្នាំ ដែលព្រះរាជាណាចក្រកម្ពុជាបានសន្តិភាពទូទាំងប្រទេស ពី (ឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១១) កម្ពុជាកំពុងរើបម្រាស់ខ្លួនពីនឹមនៃភាពក្រីក្រ ដែលរាជរដ្ឋាភិបាលបាន និងកំពុងខិតខំធ្វើឱ្យអត្រានៃភាពក្រីក្រថយចុះជាបណ្ដើរៗ ពីមួយឆ្នាំទៅមួយឆ្នាំ។ នៅឆ្នាំ២០០៩ តាមការគណនាតួលេខចំណោលធ្វើឡើងនៅក្នុងឆ្នាំ២០១០ អត្រានៃភាពក្រីក្របានចុះមកត្រឹម ២៧.៤ភាគរយ ហើយអត្រានៃភាពក្រីក្រនេះ នៅឆ្នាំ២០០៧ មានដល់ ៣០ភាគរយ។ ក្នុងឆ្នាំ២០១០ កំណើនសេដ្ឋកិច្ច បានកើនឡើងវិញប្រមាណជា ៥ភាគរយ គឺទល់នឹង ៣ភាគរយ ក្នុងការគ្រោងទុកនៅដើមឆ្នាំ២០១០ នេះ[៥៧]។

---

[៥៧] - ប្រសាសន៍ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តាមការគណនាដោយប្រុងប្រយ័ត្នបំផុត កំណើនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១១ នឹងកើនឡើងដល់ទៅ ៧ភាគរយ។



www.elibraryofcambodia.org

# សេចក្ដីសន្និដ្ឋាន

ទៅអនាគតល្បឿននគរូបនីយកម្មនៅព្រះរាជាណាចក្រកម្ពុជា នឹងឋិតក្នុងកម្រិតណា។ តើរាជធានីភ្នំពេញនិងក្រុងនានានឹងវិវត្តក្នុងកម្រិតណាទៀត។ ព្រោះរាជធានី ទីក្រុង ទីប្រជុំជន និងនគរូបនីយកម្ម តែងមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមកយ៉ាងស្អិតរមួត។

ក្នុងស្ថានភាពដែលព្រះរាជាណាចក្រកម្ពុជាមានសន្តិភាព និងស្ថិរភាពនយោបាយដូចបច្ចុប្បន្ននេះ នោះល្បឿននៃនគរូបនីយកម្មកាន់តែមានកម្រិតខ្ពស់ ហើយប្រទេសកម្ពុជាក៏មិនទាន់ឆ្លងដល់ដំណាក់កាលមួយនៃនគរូបនីយកម្មទុំជោរ ដូចជានៅបណ្ដាប្រទេសអភិវឌ្ឍន៍នានាលើពិភពលោកឡើយ។ បច្ចុប្បន្នចរន្តផ្លាស់ទីដើម្បីស្វែង រកការងារនៅរាជធានីភ្នំពេញ និងទីក្រុងនានាមានកម្រិតខ្ពស់ ដែលចលនានេះ កើតមានដោយសារចំណាកជនបទចូលមករស់នៅក្នុងទីក្រុង។

នគរូបនីយកម្មនៅព្រះរាជាណាចក្រកម្ពុជានាអនាគត នឹងមានទំនោរទៅរកការទុំជោរ ដែលត្រូវប្រើរយៈពេលមួយដើម្បីក្លាយទៅជាប្រទេសអភិវឌ្ឍន៍ និងប្រជាជនមានទម្រង់ជាប្រជាជនចាស់។ ពេលនោះទិដ្ឋភាពនៅតំបន់ជនបទនឹងផ្លាស់ប្ដូរមុខមាត់បន្តិចម្ដងៗ ព្រោះទីជនបទត្រូវបានអភិវឌ្ឍន៍ឡើង មានប្រព័ន្ធទឹកស្អាតប្រើ មានប្រព័ន្ធអគ្គិសនីប្រើ មានបង្គន់អនាម័យ ដែលនាំឱ្យប្រជាជនទូទាំងប្រទេសមានសុខភាពល្អ ថែរក្សាអនាម័យ បរិស្ថានរស់នៅស្អាត ដែលនាំឱ្យមានជីវភាពធូរធារ ទោះបីជាមុខរបររបស់ពួកគាត់ឋិតនៅក្នុងវិស័យកសិកម្មក៏ដោយ។ គម្លាតរវាងអ្នកក្រុង និងអ្នកជនបទមើលទៅមិនខុសគ្នាឆ្ងាយប៉ុន្មាន ព្រោះជីវភាពប្រជាជននៅជនបទមានការប្រែប្រួល ដោយទិដ្ឋភាពទីក្រុងនិងជនបទមិនខុសគ្នាឆ្ងាយ។



www.elibraryofcambodia.org

កម្លាំងប្រជាជនទាំងពីរភេទធ្វើការក្នុងវិស័យកសិកម្មថយចុះទាប តែផ្ទៃដីបង្កបង្កើនផលកើនឡើងហើយទទួលបានទិន្នផលខ្ពស់។ ឧបករណ៍កសិកម្មដែលពីមុនប្រើប្រាស់ដោយកម្លាំងសត្វអូសទាញមាន គោ ក្របី រទេះ នង្គ័ល បានប្រែក្លាយមកប្រើជាគ្រឿងយន្ត។ នយោបាយទឹកផុសផុល និងមានប្រព័ន្ធធារាសាស្ត្រខ្វាត់ខ្វែងបានពង្រីកនៅទីជនបទ ដើម្បីបង្កើនរដូវដាំដុះតាមបែបប្រពលវប្បកម្ម។

ព្រះរាជាណាចក្រកម្ពុជានឹងប្រែក្លាយពីប្រទេសកសិកម្មទៅជាប្រទេសកសិឧស្សាហកម្ម ឬឧស្សាហកម្មរួមទាំងទេសចរណ៍ផងដែរ។ ល្បឿននៃចលនាប្រជាជនផ្លាស់ទីចូលមករស់នៅក្នុងទីក្រុងថយចុះ តែអាចមានចលនាផ្លាស់ទីប្រចាំថ្ងៃ ឬប្រចាំសប្តាហ៍កើនឡើង ដើម្បីទៅធ្វើការក្នុងក្រុង និងពេលល្ងាចឬចុងសប្តាហ៍ត្រឡប់ចូលផ្ទះវិញ។ ផលិតផលសរុបសង្គមប្រចាំឆ្នាំនៅតែបន្តកើនឡើង ដែលធ្វើឱ្យប្រទេសជាតិមានកំណើនសេដ្ឋកិច្ចខ្ពស់និងបន្តស្ថិរភាពនៃកំណើន ដែលនាំឱ្យសរុបផលិតផលជាតិប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗកើនឡើង និងភាពក្រីក្រកាន់តែថយចុះខ្លាំងទៅ។

ទន្ទឹមនេះអន្តរកាលប្រជាសាស្ត្រនៅកម្ពុជាអាចឆ្លងផុតលឿន ដោយប្រជាជនមានការយល់ដឹង ចេះគិតគូរពីសុខភាពផ្ទាល់ខ្លួនក៏ដូចជាសុខភាពគ្រួសារ គូស្រករចេះធ្វើផែនការគ្រួសារ ចេះគិតពីសេដ្ឋកិច្ចក្នុងគ្រួសារ ប្រជាជនម្នាក់ៗស្គាល់ពីតម្លៃជីវិត ចេះគិតពីសុខភាពជាធំ អនុវត្តច្បាប់បានល្អ សីលធម៌រស់នៅល្អ សង្គមមានសណ្តាប់ធ្នាប់ និងវិស័យអប់រំត្រូវបានពង្រឹង និងអនក្ខរកម្មត្រូវបានលុបបំបាត់។

តាមការព្យាករណ៍ពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយយោងតាមជំរឿនប្រជារាស្ត្រឆ្នាំ២០០៨ (តារាងទី១០) បានសន្និដ្ឋានថា នៅឆ្នាំ២០៣០ ប្រជាជនទីក្រុងនៅព្រះរាជាណាចក្រកម្ពុជា នឹងកើនឡើងដល់ទៅ ២៩,៥ភាគរយ



www.elibraryofcambodia.org

ដែលកំណើននេះ នឹងកើតមានភាគច្រើននៅតាមបណ្តាទីក្រុងថ្មីៗ មួយចំនួនក្នុងប្រទេស ព្រោះហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្តនិងសង្គម ត្រូវបានពង្រីកដល់ទីជនបទ ដែលធ្វើឱ្យមុខមាត់ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជនត្រូវប្រែប្រួលនិងអាស្រ័យទៅតាមនិយមន័យដែលបានដាក់ចេញផងដែរ។ ទន្ទឹមនេះ ប្រជាជនទីក្រុងក៏អាចកើនឡើងថែមទៀត លើសពីការប៉ាន់ស្មានរបស់ក្រសួងផែនការ នៅឆ្នាំ២០៣០ ព្រោះនៅឆ្នាំ២០១០នេះ រាជរដ្ឋាភិបាលបានកាត់យកឃុំចំនួន ២០ មកបញ្ចូលក្នុងក្រុងភ្នំពេញ និងមានការកាត់បញ្ចូលជាបន្តបន្ទាប់ទៀត ដូចនេះតាមការប៉ាន់របស់អ្នកនិពន្ធយល់ឃើញថាប្រជាជនក្រុងនៅឆ្នាំ២០៣០អាចនឹងកើនឡើងដល់ពី ៣៥ ទៅ ៤០ភាគរយ។

សមិទ្ធិផលដែលប្រជាជនខ្មែរទាំងអស់គ្នាទទួលបាននៅថ្ងៃនេះ និងទៅអនាគត គឺកើតបានពីឆន្ទៈនៃប្រមុខអ្នកដឹកនាំដ៏ឈ្លាសវៃ មានការដឹកនាំត្រឹមត្រូវប្រកប ដោយឧត្តមគតិជាតិខ្ពស់ មានកម្លាំងសាមគ្គី យកអស់កម្លាំងកាយចិត្ត ខិតខំតស៊ូតវ ប្រមូលផ្តុំអស់បញ្ញាជនជាតិ និងប្រជាជនគ្រប់ស្រទាប់ទូទាំងប្រទេស រួបរួមកសាងជាតិទាំងអស់គ្នាពីគំនរផេះផង់ក្រោយសម័យបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ។



www.elibraryofcambodia.org

# ឯកសារយោង

១-កម្ពុជា អត្ថបទ: នាក់ សារ៉ាត រូបថត : កាន សុណា លេខ ៩០ មករា ២០១០ "**រាជធានីភ្នំពេញ ប្រារព្ធខួប ៥៧៥ ឆ្នាំ** "ផ្សាយចេញដោយអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា បោះពុម្ពដោយ រោងពុម្ពក្រសួងព័ត៌មាន លេខ ៦២ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ទំព័រ២២-២៦

២-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ :**អភិរក្សអគារបេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្រ្ត** ឆ្នាំ ២០០៤

៣-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ :**ទស្សនាវដ្តីប្រចាំឆ្នាំ ២០០៩-២០១០**

៤-ក្រសួងផែនការ វិទ្យាស្ថានជាតិស្ថិតិ : "**ជំរឿនទូទៅនូវប្រជារាស្រ្តរបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨**"

៥-ធាច់ វ៉ាន់ធាត និងកែវ សុភុន : **អាទិទេពក្រុងអង្គរ** បោះពុម្ពឡើងវិញឆ្នាំ ១៩៨៩

៦-ទស្សនាវដ្តីសម័យនិយម : **អគារខ្ពស់បំផុតលើពិភពលោក** ឆ្នាំទី២ លេខ ១៤ បោះពុម្ព ប្រចាំខែ កុម្ភៈ ២០០៩ ទំព័រ៥៦-៥៧

៧-ទីស្តីការក្រុមប្រឹក្សាទូទាំងប្រទេស រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា : **ឧក្រិដ្ឋកម្មរបស់បនវាតទីអនុត្តរភាពនិយមចិនប៉េកាំង និងបរិវារប៉ុលពត អៀងសារី ខៀវសំផន** ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៨

៨-ទីស្តីការគណៈរដ្ឋមន្ត្រី "**ស្ថានភាពនគរូបនីយកម្មនៅកម្ពុជា**"



www.elibraryofcambodia.org

៩- រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ : "**បទប្បញ្ញត្តិច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ**" ឆ្នាំ២០០៩

១០-រាជរដ្ឋាភិបាល យុទ្ធសាស្ត្រត្រីកោណ

១១-រាជរដ្ឋាភិបាល យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១

១២-រាជរដ្ឋាភិបាល យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២

១៣-រាជរដ្ឋាភិបាល ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ឯកសារបឋមស្តីពី : **ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី** បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០២

១៤-រាជរដ្ឋាភិបាលកម្ពុជា : **សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល ស្តីពីគោលនយោបាយដីធ្លី**បោះផ្សាយ ដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លីខែកក្កដា ឆ្នាំ២០០៩

១៥-វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ: **ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា** ឆ្នាំ២០០៨

១៦-សាលារាជធានីភ្នំពេញ សាលាក្រុងប៉ារីស ក្រុមរោងជាងនគរូបនីយកម្មក្រុងប៉ារីស "**ភ្នំពេញកំណើននិងការផ្លាស់ប្តូរ**" ឧបត្ថម្ភដោយក្រសួងការបរទេស និងកិច្ចការអឺរ៉ុបនៃសាធារណរដ្ឋបារាំង"

**១៧-សាលារាជធានីភ្នំពេញ** : គោលដៅអភិវឌ្ឍន៍សហវត្សរបស់រាជធានីភ្នំពេញ ២០០៩ ( Phnom Penh Millennium Development Goals )



www.elibraryofcambodia.org

១៨-អ៊ូ រ៉ែឌី "**ការវិវត្តចំនួនប្រជាជនរាជធានីភ្នំពេញ ក្នុងដំណើរឆ្លងកាត់ជាប្រវត្តិសាស្ត្រ (១៨៦៥-២០០០)**" អត្ថបទបង្ហាញក្នុងសមាជស្រាវជ្រាវសង្គមវប្បធម៌ អំពីកម្ពុជាលើកទី៣

១៩-អាំងជូលាន , អេរិកប្រេណូរិត្យ , អាស្លីថមសុន (អាជ្ញាធរអប្សរា): **អង្គរ អតីត-បច្ចុប្បន្ន-អនាគត** ១៩៩៨

20 -Anuchat Poungsomlee and Helen Ross, **Impacts of Modernisation and Urbanization in Bangkok: an integration Ecological and Biosocial Study**, A joint research project between Institute for population and Social Research Mahodol University, Thailand and Centre for Resource and Environmental Studies, Australian National University, Australia, August, 1992.

21-Arsenio M. Balisacan, Poverty, **Urbanization and Development Policy**.

22-Asian Population Studies series N$^0$ 122, **Urbanization and Socio-Economic Development in Asia and The Pacific**, New York, 1988.

23-Asian Population Studies series N$^0$ 111, **Migration and Urbanization in Asia and The Pacific: Interrelationships with Socio-economic Develop ment and Evolving Policy Issues,** New York, 1992.

24-Bruno Daens, " Angkor la forêt de Pierre " Gallimard 1989, Imprimerie Kapp-Lahure-Jombart à Evreaux.

25-Cambodia Economy Magazine, 2010.

26-Collection Recherches Asiatiques, dirigée par Alain Forest, Péninsule Indochinoise Etudes Urbaines, **Travaux du Centre d'Histoire et Civilisa tions de la Péninsule Indochinoise,** Publiés par P.B. LAFONT, Editions l'Harmattan, 5-7 rue de l'Ecole Polytechnique 75005 PARIU.

27-Daniel Robinson and Tony Wheeler, "**Cambodia a travel survival kit** "Printed by Colorcraft Ktd, Hong Kong ,Photography by Daniel Robinson (Dr.) Tony Wheeler(TW), Published September 1992.

***28-Department of International Economic and Social Affaits, United Nations,*** *Populaion Studies, Prospects of World Urbanization,* ***New York, 1988.***

***29-Department of Environmental Science, Compiled by Lay Chanthy, AIT Technical Adviser: Prof. A.T.M.Narul Amin,*** *Urban Environment ,* ***1995.***

30-Encyclopedia **Britannica** 2005, 2007

31-Encyclopedia **Encarta** 2009.



www.elibraryofcambodia.org

32 -East –West Management Institute, Inc.: " **ច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សានិងស្រាវជ្រាវ** "គាំទ្រដោយគម្រោងអនុវត្តច្បាប់ភូមិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB TA 3577-CAM.ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០០៣

32-Fernand Lemaitre-Marcel Lemaitre-Bruno L'Hoste, **Angkor regards croisés**, 1993

33-Jacqueline Desbarats, "**Prolific Survivors: Population Change in Cambodia 1975-1993** ", Arizona, 1995.

34-Jacques Migozzi, **CAMBODGE faits et problèmes de population,**Editions du centre national de la recherche scientifique, Paris 1973.

35-John Wolforth and Roger Leigh, **Urban Prospects,** Revised Edition. Reprinted 1984.

36-J. Pelletier, Ch. Delfante, **Villes et Urbanisme dans le monde**, Masson ,Paris Milan Barcelone, 1993.

37-NDN Books, " ANGKOR " Printed in Japan

38-Minstère des affaires étrangères de la République Populaire du Kampuchea, "**Crimes des dirigeants chinois contre Le Kampuchea** ", Avril 1984.

39-Michel Igout, "**Phnom-Penh d'Hier à Aujourd'hui** ", White Lotus 1993. Municipalité de Phnom Penh, Mairie de Paris, Atelier parisien d'urbanisme " **PHNOM PENH Croissance et transformation** " avec le soutien du ministère des Affaires étrangères et des européennes de la République française.

40-Ministry of Land Management, Urban Planning and Construction and Japan International Cooperation Agency(JICA): The Study on National Integrated Strategy of Coastal Area and Master Plan of Sihanouk-ville for sustainable development, Final Report : Book 1, National Integrated Development Strategy for Coastal Area, November 2010.

41-Ou Vuddy, " **Quelques Aspects de la répartition de la population Cambodgienne actuelle** " Thèse doctorat en 28 avril 1993.

42-Peter Haggett, "**Geograpiy : A Global Synthesis** ", Printice Hall, 2001, pp.233-244.

43-Pelletier J. Delfante Ch, **Villes et Urbanisme dans le monde**, Masson,Parie, 1985.

44-Pierre Loti, **Un pèlerin d'Angkor**, Kailash Editions 1996.

45-Space and Environment: KRIHS Gazette, **Building Safe Cities with Integrated Mechnisms to Cope With Climate Change-Induced Natural Disasters**. Published September 2010, Vol. 40.

***46-UNHABITAT***, State of The World's CITIES 2010/2011 Bridging The Urban Divide. ***Earthscan publishing for a sustainable future.***



www.elibraryofcambodia.org

47-United Nations, **World Urbanization Prospects**, New York, 1991.
48-Nurul Amin, **Urban Environment**, compiled by Lay Chanthy.
49-UNESCO Regional office for Education in Asia and the Pacific, Apia, Migration and Urbanization in the Pacific, 1985.
50-Véronique Petit, "**Migrations et société dogon** ", L'Harmattan 1998.
51-World Bank : " **Equity and Development** " world development Overwiew 2006



www.elibraryofcambodia.org

## ឧបសម្ព័ន្ធ១

### គោលនយោបាយ និងក្របខណ្ឌគតិយុត្តដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាគោលនយោបាយដីធ្លីសម្រេចបានតាមបណ្តាឆ្នាំ

១-សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី២០០១

២-ក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយដីធ្លី ២០០២

៣-គោលនយោបាយស្តីពីសម្បទានដីសង្គមកិច្ច ២០០៣

៤-គោលនយោបាយស្តីពីការគ្រប់គ្រងដីរដ្ឋ២០០៤

៥-គោនយោបាយស្តីពីសម្បទានដីសេដ្ឋកិច្ច២០០៥

៦-គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ ជនជាតិដើមភាគតិច២០០៩

៧- សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពីគោលនយោបាយដីធ្លី២០០៩

៨- គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៅព្រះរាជាណាចក្រកម្ពុជា

៩- គោលនយោបាយជាតិស្តីពីលំនៅឋាន២០១២

១០- គោលនយោបាយស្តីពីការវាតតម្លៃថ្លៃដី២០១២

១១-គោលនយោបាយស្តីពីប្រព័ន្ធព័ត៌មានដីធ្លី២០១៣

**ឆ្នាំ ២០០១**

១២-ច្បាប់ភូមិបាលនស/រកម/០៨០១/១៤/៣០ សីហា

១៣-សេចក្តីជូនដំណឹងស្តីពីការបញ្ចប់ការចូលកាន់កាប់កោតៈលើអចលនវត្ថុលេខ៤៣សជណ

២០០១

១៤-សេចក្តីសម្រេចស្តីពីការកំណត់ដីភូមិ ដែលកំពុងធ្វើអាជីវកម្ម ក្នុងដែនព្រៃសម្បទាន លេខ

៤៣៨សសរ/កសក ខែតុលា



www.elibraryofcambodia.org

១៥-សេចក្តីប្រកាសស្តីពីការផ្អាកសកម្មភាពអាជីវកម្មព្រៃគុបសម្រាប់ក្រុមហ៊ុនព្រៃសម្បទាន
ប្រកាស ៥៧២១កសក/១៣ធ្នូ

**ឆ្នាំ ២០០២**

១៦-ប្រកាសអន្តរក្រសួងស្តីពីការកំណត់ចំណូលសេវាសុរិយោដីលេខ៣៧៧សហវ/២៣ឧសភា

១៧-អនុក្រឹត្យស្តីពីការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
លេខ៤៦អនក្រ/បក/៣១ឧសភា

១៨-អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
លេខ៤៧អនក្រ/បក/៣១ ឧសភា

១៩-អនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ លេខ៤៨អនក្រ/បក/៣១ឧសភា

២០-លិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនីតិវិធី និងការគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ
និងចំណូល ពុំមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមន្ទីររៀបចំដែនដី
នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង លេខ៣៣៤០ សហវ/១១កក្កដា

២១-លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការកែលម្អ និងនីតិវិធីនៃការ
គ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋ និងចំណូល ពុំមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិ
រដ្ឋ នៅមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង លេខ៣៣៤០
សហវ/១១កក្កដា/៥៨៤ដនស/ផសហ ២៤កក្កដា

២២-សារាចរណែនាំអនុវត្ត នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
(ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ) លេខ០០១ដនស/សជ១៩សីហា

២៣-ប្រកាសស្តីពីគោលការណ៍ណែនាំ និងនីតិវិធីនៃគណៈកម្មការសុរិយោដី១១២ដនស/ប្រក ២១
សីហា

២៤-ច្បាប់ ស្តីពីព្រៃឈើនស/រកម/០៨០២/០១៦ ៣១សីហា



www.elibraryofcambodia.org

### ឆ្នាំ២០០៣

២៤-អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច លេខ១៩អនក្រ/បក/១៩មីនា

២៥-ប្រកាសស្តីពីការបំពេញបន្ថែមការណែនាំអនុវត្តប្រមូលពន្ធប្រថាប់ត្រា លេខ៦០៦សហវ/ពដ/២៧សីហា

២៦-ប្រកាសអន្តរក្រសួងស្តីពីការកំណត់របស់តុលាការ និងគណៈកម្មការសុរិយោដី លេខ០២ប្រកន/០៣/២៦វិច្ឆិកា

### ឆ្នាំ២០០៤

២៧-សេចក្តីណែនាំស្តីពីការប្រើប្រាស់ផ្លូវផ្ទាល់ លេខ០១៥ផថ/ ២០ មករា

២៨-លិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញនិងហិរញ្ញវត្ថុ ស្តីពីករណីសុំអនុញ្ញាតជាវសេវា ចុះបញ្ជីដីធ្លីមាន លក្ខណៈជាប្រព័ន្ធសម្រាប់គម្រោង LMAP នៃក្រសួងរៀបដ.ន.ស. លេខ០៥៥ សហវ/ទរ / ១២មករា

២៩- សារាចរណែនាំអនុវត្ត នីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ លេខ០១ជនស/សជ១៩មីនា

៣០-សេចក្តីណែនាំស្តីពីការចុះបញ្ជីបន្ត លេខ០២ជនស/សជ/២៨ឧសភា

៣១-លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការទទួលពាក្យស្នើសុំកាន់កាប់ដីធ្លី លេខ៦២១ជនស/សជ/១៦មិថុនា

៣២-បទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ លេខ០១បប/០៩មិថុនា

៣៣-សេចក្តីណែនាំអនុវត្តបទបញ្ជាស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការកាប់រាន ការដុត ការហ៊ុមព័ទ្ធ កាន់កាប់ដីព្រៃឈើលេខ ៦២៣ជនស/ដស/១៦មិថុនា

៣៤-ប្រកាសស្តីពីវិធានការជម្រុញ និងប្រមូលបំណុល ចំណូលថ្លៃឈ្នួលរោងចក្រ អចលនវត្ថុរបស់រដ្ឋ លេខ៣១៩ សហវ/ប្រក/២៣កញ្ញា

៣៥-ប្រកាសស្តីពីបែបបទនៃការដោះដូរអចលនទ្រព្យរបស់រដ្ឋ នៅតាមបណ្តាក្រសួង ក្រុង លេខ



www.elibraryofcambodia.org

៣៨៦ សហវ/ ទរ/២០ តុលា

៣៦-ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលប្រកាសអន្តរក្រសួងលេខ ៣៧៧ខែឧសភា ឆ្នាំ២០០២ ស្តីពីការកំណត់ចំណូលពីសោហ៊ុយសេវាសុរិយោដី ប្រក/២៨តុលា

**ឆ្នាំ២០០៥**

៣៧-លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីរបាយការណ៍ស្តីពីការប្រមូលពន្ធអចលនវត្ថុ លេខ២២៥ សជណ/ ០៩កុម្ភៈ

៣៨-លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ស្តីពីលិខិតសញ្ញាផ្ទេរសិទ្ធិ លេខ១៧៩ ដនស/សជ/ ១០កុម្ភៈ

៣៩-បទបញ្ជាស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ លេខ០២បប

៤០- សារាចរណែនាំស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគអនុវត្តបទបញ្ជាលេខ ០២បបចុះថ្ងៃទី១៣ មិថុនា ឆ្នាំ២០០៥

៤១-សារាចរណែនាំស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់គម្រោងវិនិយោគអនុវត្តបទបញ្ជាលេខ ០៥រណន/០១ កក្កដា

៤២-លិខិតរបស់ក្រសួងរៀបចំដែនដី នគរូបនិយកម្ម និងសំណង់ស្តីពីការផ្តល់ព័ត៌មានដីធ្លីពាក់ព័ន្ធនឹងដីព្រៃ លេខ១០២៩ដនស/សជ/១៣កក្កដា

៤៣-ប្រកាសអន្តរក្រសួងស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ លើដីធ្លី លេខ២១៥ប្រក/ ដនស/មផ/០៩កញ្ញា

៤៤-សេចក្តីណែនាំស្តីពីនីតិវិធីសវនាការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិតសជ/២៣កញ្ញា

៤៥-សារាចរណែនាំស្តីពីការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិលេខ០១ដនស/ អគតជ/ សរណោហ /២១កញ្ញា

៤៦-អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ១១៨អនក្រ/បក/០៧ តុលា

៤៧-អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច លេខ១៤៦អនក្រ/បក/២៧ធ្នូ



www.elibraryofcambodia.org

## ២០០៧

៤៨-សេចក្តីណែនាំអនុវត្តសារាចររាជរដ្ឋាភិបាលលេខ០២សរ ស្តីពីការកាន់កាប់ដីរដ្ឋក្រោមដែនសមត្ថកិច្ចរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ២៩៤៣កសក/០៥មិថុនា

៤៩-សេចក្តីជូនដំណើងស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ លេខ០១០សហវ/ប្រក/ពដ/០៦មិថុនា

៥០-សារាចរណែនាំស្តីពីចំណាត់ការ និងនីតិវិធីនៃការដោះស្រាយរឿងក្តីដែលពាក់ព័ន្ធនឹងទំនាស់លេខ ០១កឃ/សរណន/០៧/០៣កក្កដា

៥១-ប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុសម្រាប់អ្នកសុំដីសម្បទានសង្គមកិច្ចលេខសអឃ/០៣កក្កដា

៥២-ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីស្តីពីការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ លេខដនស/មផ/២៥កក្កដា

៥៣-បង្កើតគណៈកម្មការកំណត់ផ្ទៃទីតាំងបឹងបូរក្នុងព្រះរាជាណាចក្រកម្ពុជា លេខ១០១អនក្រ/បក/១៥សីហា

៥៤-អនុក្រឹត្យស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែងឬសិទ្ធិសេដ្ឋកិច្ច លេខ១១៤ / អនក្រ/បក/២៩សីហា

៥៥-អនុក្រឹត្យស្តីពីការធ្វើសម្បទានរាជាយស្ម័យានកម្ពុជា លេខ ១២៤/អនក្រ/បក/១២កញ្ញា

៥៦-សេចក្តីណែនាំស្តីពីវិធីកែតម្រូវឯកសារផ្លូវការនិងDigital(សម្រាប់នីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ)លេខ២៧៣/អសដក/៣០តុលា

៥៧-សារាចរណែនាំស្តីពីការអនុវត្តផែនការបែងចែកសម្បាដីសង្គមកិច្ច លេខ០៦ សរណណ/៨វិច្ឆិកា

## ២០០៨

៥៨-អនុក្រឹត្យស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋ សម្រាប់ការដាំដើមឈើ លេខ ២៦អនក្រ/បក/២៥មីនា



www.elibraryofcambodia.org

៥៩-អនុក្រឹត្យស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច លេខ១៣១អនក្រ/បក/ ១៥កញ្ញា

៦០-ព្រះរាជក្រឹត្យស្ដីពីវិសោធនកម្មមាត្រា១នៃព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៥៧ ២៦ កុម្ភៈ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីលេខនស/រកត/០៩តុលា

**២០០៩**

៦១-អនុក្រឹត្យស្ដីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច លេខ៨៣អនក្រ/បក/០៩មិថុនា

៦២-សេចក្ដីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្ដីពីគោលនយោបាយដីធ្លីលេខ ២៧សជណ/អក០១ កក្កដា

៦៣-អនុក្រឹត្យស្ដីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិលេខ១២៦អនក្រ/បក/១២ សីហា

**២០១០**

៦៤- សារាចររាជរដ្ឋាភិបាលស្ដីពីការដោះស្រាយសំណង់បណ្ដោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ដោយ ខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន លេខៈ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា

៦៥- អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីលេខ : ៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា

៦៦- សេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើប្រាស់គំរូឱ្យបសម្ព័ន្ធ ដើម្បីអនុវត្តសារាចរស្ដីពីការដោះស្រាយ សំណង់បណ្ដោះអាសន្នលើដីរដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ តាមរាជធានី ទីក្រុង និងទីប្រជុំជនលេខៈ ៤៩ សសរ-អកគជ ចុះថ្ងៃទី ២៧ ខែកញ្ញា

៦៧- ច្បាប់ស្ដីពីការផ្ដល់កម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស លេខ : នស/រកម/០៥១០/០៣០ ចុះថ្ងៃទី ២៤ ខែ ឧសភា

៦៨- អនុក្រឹត្យស្ដីពីការកំណត់ចំនួនសមាមាត្រ និង របៀបគិតគូរចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេស នៅក្នុងអគារសហកម្មសិទ្ធិ លេខៈ ៨២ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា



www.elibraryofcambodia.org

៦៩- សារាចរណែនាំ ស្តីពីការអនុវត្តនីតិវិធីនៃការធ្វើសេចក្តីសម្រេច លើសំណុំរឿងវិវាទដីធ្លីរបស់ គណៈកម្មការសុរិយោដី ថ្នាក់រាជធានី ខេត្ត ក្នុងយន្តការគណៈកម្មការសុរិយោដី លេខៈ០១ជនស/សរណនចុះថ្ងៃទី២១ខែមករា

៧០- សារាចរណែនាំអនុវត្តស្តីពីការសិក្សាទីតាំងធ្វើអត្តសញ្ញាណកម្ម កសាងផែនទី និងចំណាត់ថ្នាក់ ដីសម្រាប់ធ្វើសម្បទាន សង្គមកិច្ច លេខៈ ០៤ ជនស/អគសសជ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ

៧១- សេចក្តីណែនាំស្តីពីការចុះបញ្ជីដី ដែលឋិតនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម កម្ពុជា -ឡាវ និងកម្ពុជា-ថៃ លេខៈ ០៦ ជនស/ជស/សណ ចុះថ្ងៃទី ១១ ខែ ឧសភា

៧២- សេចក្តីណែនាំស្តីពីការផ្តល់សេវាសាធារណៈផ្នែកសំណង់នៅក្រុងតាខ្មៅ ខេត្តកណ្តាល ក្រុង ស្ទឹងសែន ខេត្តកំពង់ធំ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមាន ជ័យ ក្រុងក្រចេះ ខេត្តក្រចេះ ក្រុងសួង ខេត្តកំពង់ចាម និងស្រុកពាមរក៍ ខេត្តព្រៃវែង លេខ : ០៨ សណន ចុះថ្ងៃទី០៨ ខែ មិថុនា

៧៣-សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារច្រកចេញ-ចូលតែមួយរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លេខៈ ៥១ សសរ/ប្ក ចុះថ្ងៃទី ២៧ ខែ តុលា

៧៤- សេចក្តីណែនាំ ស្តីពីការផ្តល់ច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់រដ្ឋបាលឃុំ-សង្កាត់ លេខៈ១៤ជនស /អរសជ

..............

**២០១១**



www.elibraryofcambodia.org

## ឧបសម្ព័ន្ធ២

### ១-ប្លង់លំនៅឋានដែលត្រូវអភិរក្សនៅសម័យដើម ច្រើនឋិតនៅជុំវិញផ្សារ[៥៨] ឬតាមមាត់ស្ទឹងសង្កែក្រុងបាត់ដំបង

ទីក្រុងបាត់ដំបងជាទីក្រុងមួយ ដែលបានបន្សល់ទុកនូវសំណង់បេតិកភ័ណ្ឌជាច្រើន ជាមួយនឹងស្ថាបត្យកម្មប្រវត្តិសាស្ត្រដ៏សម្បូរណ៍បែប រចនាបទ និងរបៀបរៀបចំបានបង្ហាញនូវដំណាក់កាលផ្សេងៗគ្នានៃប្រវត្តិសាស្ត្រទីក្រុង។

តំបន់អភិរក្សឋិតនៅចន្លោះផ្លូវលេខ១ និងផ្លូវលេខ៣ត្រូវបានផ្តល់នូវលក្ខណៈពិសេសដោយក្រុមសំណង់បេតិកភ័ណ្ឌ ដែលមានលក្ខណៈដូចៗគ្នាចំនួនប្រហែល ៨០០ អគារ បានសាងសង់នាសម័យអាណានិគមបារាំង និងមួយចំនួនត្រូវបានសាងសង់សម័យសង្គមរាស្ត្រនិយម។ ក្រៅពីតំបន់នេះ នៅមានសំណង់បេតិកភ័ណ្ឌប្រណិតៗមួយចំនួនទៀត ដូចជាសកលវិទ្យាល័យចាស់ជាស្ថាបត្យកម្មខ្មែរសម័យទំនើប ភូមិគ្រឹះយកតាមរចនាបថបារាំងឋិតនៅតាមដងស្ទឹងសង្កែ និងផ្ទះខ្មែរចាស់ៗដែលធ្វើអំពីឈើ ឋិតនៅតាមភូមិ។ ទន្ទឹមនេះនូវមានបេតិកភ័ណ្ឌល្អប្រណិតដែលជាស្ថាបត្យកម្មខ្មែរ កើតបានពីគំនិតឆ្នៃប្រឌិតរស់រវើក នៅសេសសល់មកដល់សព្វថ្ងៃ កំពុងបង្ហាញនៅតាមវត្តអារាមសំខាន់ៗ និងជាការរួមចំណែកលើកកម្ពស់ឱ្យទីក្រុងបាត់ដំបងកាន់តែមានសោភ័ណភាពស្រស់ត្រកាល និងធ្វើឱ្យទីក្រុងមាន

---

58 - រូបភាព និងខ្លឹមសារអត្ថបទបានពីប្រតិទិនឆ្នាំ២០១០ "បាត់ដំបងអតីតកាល និងបច្ចុប្បន្នកាល"។ ឧបត្ថម្ភដោយសាលា**ក្រុងបាត់ដំបង** DED Cooperation Kingdom of Cambodia and Federal Republic of Germany ។



www.elibraryofcambodia.org

លក្ខណៈពិសេសប្លែកពីគេ ជាកត្តាទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យចាប់អារម្មណ៍ និងយល់ដឹងពីភាពចំណាស់នៃវប្បធម៌ និងអារ្យធម៌ខ្មែរ ។





រូបភាពពុះ (អ-អ)

រៀបចំដោយមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តបាត់ដំបង សហការជាមួយ គំរោង LMAP និង អង្គការ GTZ



www.elibraryofcambodia.org



២-ប្រភេទក្បាច់ដែលប្រជាជនប្រើប្រាស់សម្រាប់លំនៅឋានសម័យដើម
និងបច្ចុប្បន្ន



www.elibraryofcambodia.org







បង្កាន់ដៃជើងទៀន



[illegible]



[illegible]



[illegible]



[illegible]



[illegible]



www.elibraryofcambodia.org

៣-សំណង់សាសនាជាផ្នែកសំខាន់ នៃបេតិកភ័ណ្ឌវប្បធម៌របស់ទីក្រុងខ្មែរ

ក្បាច់លម្អិតនៃស្ថាបត្យកម្មដ៏ស្រស់ស្អាតរបស់វត្តពិភិទ្ធារាម វត្តសង្កែចាស់







ស្ថាបត្យកម្មដ៏ស្រស់ស្អាតរបស់វត្តដីរីស



www.elibraryofcambodia.org

## ៤-ទីតាំងក្រុង និង ទីប្រជុំជននៃខេត្តទាំងបួននៅតំបន់សមុទ្រ




Source: JICA Study Team

**Figure 4.3.14 Present Transportation Route in the Study Area**



www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ញៅ យុនសំរ៉ង ខ្ញៅ យ៉ាតណៃ ខ្ញៅសុខផល ខ្ញៅ វិសាល ខ្ញៅ រ៉ាមុន
ខ្ញៅ ភារាដា ខ្ញៅ ចំរើន ខ្ញៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ញៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សៀង ស៊ីវ៉ាន់

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ញៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org